# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ភាគ ២

## ១. អង្កេតតាមដានជំងឺសត្វនៅតាមមូលដ្ឋាន

## ២. ការចិញ្ចឹមមាន់

## ៣. ការពិនិត្យ និងការព្យាបាលជំងឺគោក្របី

## ៤. ការណែនាំអំពីការប្រើប្រាស់វ៉ាក់សាំង សំរាប់ភ្នាក់ងារសុខភាពសត្វភូមិ

កុម្ភៈ ២០១០

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ

# អារម្ភកថា

ស្ថិតក្នុងស្ថានភាពដែលប្រទេសយើងទទួលបានស្ថិរភាព សន្តិភាពនិងអភិវឌ្ឍន៍ក្រោមការដឹកនាំរបស់សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី បានបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិលើគ្រប់វិស័យ ដែលក្នុងនោះវិស័យកសិកម្មដើរតួយ៉ាងសំខាន់ និងជាអទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណជំហានទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីជំរុញលើកកំពស់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ឆ្លើយតបទៅនឹងគោលដៅនេះក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវគោលនយោបាយ និងកម្មវិធីច្បាស់លាស់ក្នុងការ ធានាស្បៀងអាហារគ្រប់គ្រាន់ និងមានសុវត្ថិភាពដល់ប្រជាពលរដ្ឋគ្រប់រូប ការកាត់បន្ថយភាពក្រីក្រ បង្កើនប្រាក់ចំណូលគ្រួសារ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ នៅឆ្នាំ ២០០៨ វិស័យកសិកម្មបានចូលរួមចំណែក ៣៤ភាគរយ នៃផលិតផលក្នុងស្រុកសរុប។ តាមរបាយការណ៍របស់ធនាគារពិភពលោក បានឱ្យដឹងថាប្រសិនបើវិស័យកសិកម្មកើនឡើង ៤ភាគ-រយក្នុងមួយឆ្នាំ នោះអត្រាភាពក្រីក្រនឹងអាចធ្លាក់ចុះ ៣៤ ភាគរយ មកនៅត្រឹមតែ ២១ ភាគរយនៅឆ្នាំ ២០១៥។ អត្រាភាពក្រីក្របានធ្លាក់ចុះពី ៤៧ ភាគរយ នៅឆ្នាំ ១៩៩៣ មកនៅត្រឹមតែ ៣៥ ភាគរយ នៅឆ្នាំ២០០៤ និងថ្មីៗនេះ អត្រានេះបានបន្តធ្លាក់ចុះមកនៅត្រឹមតែ ៣០ ភាគរយ ប៉ុណ្ណោះនៅឆ្នាំ ២០០៧ នេះ។ លើសពីនេះ នៅពេលដែលមានវិបត្តិហិរញ្ញវត្ថុពិភពលោកចាប់តាំងពីឆ្នាំ ២០០៨ មក វិស័យសំខាន់ៗរបស់សេដ្ឋកិច្ចកម្ពុជា បានធ្លាក់ចុះដូចជា វិស័យសំណង់ ឧស្សាហកម្មកាត់ដេរ និងទេសចរណ៍ ធ្វើឱ្យវិស័យកសិកម្មបាន និងកំពុងដើរតួនាទី យ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិទាំងមូលដែលក្នុងនោះផ្នែកចិញ្ចឹមសត្វ បានរួមចំណែក ១៥.៨ភាគរយ នៃផលិតផលក្នុងស្រុកសរុប ដោយផ្តល់ជាកំលាំងអូសទាញសន្តិសុខស្បៀង និងប្រាក់-ចំណូលប្រចាំគ្រួសារ ជាពិសេសដល់ប្រជាកសិករនៅជនបទ។

បច្ចុប្បន្នមានប្រជាជនយើងប្រមាណ៨០ភាគរយ ប្រកបរបរកសិកម្ម ហើយដីស្រែប្រមាណជាង ៧០ ភាគរយ នៅតែត្រូវបានភ្ជួររាស់ដោយគោ ក្របី។ ជាទូទៅ ប្រជាជនយើងចិញ្ចឹមគោ ក្របី ជ្រូក មាន់ ទា ជាលក្ខណៈគ្រួសារ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងគ្រួសារ និងបង្កើតប្រាក់ចំណូល។ គោក្របីជាទ្រព្យសម្បត្តិ និងជាមរតកសម្រាប់ចែកកូនចៅ ប្រើប្រាស់ជាកំលាំងអូសទាញ ភ្ជួររាស់ និងសម្រាប់លក់ដោះដូរនៅពេលត្រូវការថវិកាចាំបាច់។ ផលិតកម្មលក្ខណៈគ្រួសារបែបនេះ ជាផលិតកម្មផ្គត់ផ្គង់ខ្លួនឯង ដែលខ្វះការថែទាំ ផ្តល់ចំណីហើយជាទូទៅសត្វមានអត្រាស្លាប់ និងឈឺនៅមានកំរិតខ្ពស់ រួមជាមួយកត្តាផ្សេងទៀតដូចជា គ្មានការជ្រើស

រើសពូជ ការបង្កាត់ពូជត្រឹមត្រូវ និងជាពិសេសពុំបានគិតគូរអំពីប្រសិទ្ធភាពសេដ្ឋកិច្ច។ កត្តាទាំងនេះធ្វើឱ្យប៉ះពាល់លើជីវភាពជនបទយ៉ាងធ្ងន់ធ្ងរ និងសេដ្ឋកិច្ចជាតិ និយាយជារួមផលិតភាព និងប្រាក់ចំណូលទទួលបានពីការចិញ្ចឹមសត្វនៅទាបដែលពាក់ព័ន្ធទៅនឹងកង្វះដើមទុន បច្ចេកទេស និង ប្រព័ន្ធទីផ្សារ ពុំមានប្រសិទ្ធភាព។

ឆ្លើយតបទៅនឹងស្ថានភាពខាងលើនៅឆ្នាំ ២000 ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សហការជាមួយសហគមន៍អឺរ៉ុបបានធ្វើការសិក្សាលើចំណុចខ្លាំង និងចំនុចខ្សោយនៃ ការងារផលិតកម្ម និង បសុព្យា-បាល ដើម្បីធ្វើអន្តរាគមន៍ និងលើកផែនការយុទ្ធសាស្ត្រនៅកម្ពុជា។ ឆ្លងតាមការសិក្សានេះ យើងបានរកឃើញនូវចំណុចមួយចំនួនដែលត្រូវអន្តរាគមន៍ដូចជា បង្កើនសមត្ថភាពមន្ត្រី នាយកដ្ឋាន និងការិយាល័យផលិតកម្ម និងបសុព្យាបាល តាមរយៈការធ្វើសមាហរណកម្មកម្មវិធីបណ្តុះបណ្តាលក្នុងតំបន់ បង្កើនសេវាសុខភាពសត្វនៅជនបទ ការទប់ស្កាត់ជំងឺ ការកែលំអពូជ និងចំណីសត្វ ការនាំសត្វចេញ-ចូលតាមច្រកព្រំដែន និងអនាម័យសាច់សត្វ និង ទីផ្សារ។

ក្នុងគោលបំណងដើម្បីជំរុញវិស័យចិញ្ចឹមសត្វឱ្យប្រសើរឡើង គម្រោងចិញ្ចឹមសត្វក៏បានទទួលការគាំទ្រហិរញ្ញប្បទានពីសហគមន៍អឺរ៉ុបក្នុងភាពជាដៃគូអភិវឌ្ឍន៍ជាមួយរដ្ឋាភិបាលកម្ពុជា។ ដោយមានការផ្តួច-ផ្តើមគម្រោង បានចូលរួមជំរុញការអនុវត្តន៍គោលនយោបាយ និងកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានទឹកប្រាក់សរុបប្រមាណ ជាង៥លានអឺរ៉ូ មានរយៈពេល៥ឆ្នាំ ហើយបានចាប់ផ្តើមពីខែមេសា ឆ្នាំ២00៥ រហូតដល់ ខែមីនា ឆ្នាំ២0១0 នៅក្នុងខេត្តគោលដៅចំនួន ៤ គឺខេត្តតាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង និង ពោធិ៍សាត់។ គោលបំណងសំខាន់បំផុតរបស់គម្រោង គឺបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករតាមរយៈការកែលំអការចិញ្ចឹមសត្វ។ ដើម្បី សម្រេចបាននូវគោលបំណងនេះ គម្រោងអន្តរាគមន៍សកម្មភាពសំខាន់ៗចំនួន ៣ គឺ ១-ការកែលំអសេវាកម្មសុខភាពសត្វ ២-ការកសាងសមត្ថភាពបច្ចេកទេសមូលដ្ឋាននៅជនបទ និង ៣-លើកស្ទួយទីផ្សារសត្វនិងសមធម៌នៃប្រាក់ចំណូល។ គម្រោងចិញ្ចឹមសត្វបានធ្វើសកម្មភាពជាច្រើន និងទទួល លទ្ធផលជាផ្លែផ្កាទៅតាមគោលដៅគួរឱ្យកត់សម្គាល់ ដែលក្នុងនោះសកម្មភាពសំខាន់ៗរួមមានៈ ការបណ្តុះបណ្តាលរំលឹកភ្នាក់ងារសុខភាពសត្វភូមិ ការបង្កាត់សិប្បនិម្មិតគោនិង ជ្រូក ការកែលំអពូជមាន់ ការថែរក្សា កូនជ្រូក ការចាក់វ៉ាក់សាំង កម្មវិធីដំណាំចំណីសត្វ ការធ្វើបង្ហាញអំពីបច្ចេកទេស ចិញ្ចឹមសត្វ ការចងក្រង ក្រុមកសិករ និងការផ្សព្វផ្សាយជាខ្សែវីដេអូនូវបច្ចេកទេសចិញ្ចឹមសត្វជូនដល់កសិករនៅខេត្តគោល ដៅទាំង៤ នៃគម្រោង។

ភ្នាក់ងារសុខភាពសត្វភូមិជាភ្នាក់ងារឯកជន ជាអ្នកដែលនៅជិតបំផុតជាមួយកសិករ ដឹងអំពីសុខទុក្ខពីកសិករ ដើរតួនាទីជាអ្នកផ្សព្វផ្សាយកសិកម្មភូមិ និងជាពិសេសផ្តល់នូវសេវាកម្មផលិតកម្ម និងបសុពេទ្យជាប្រចាំដល់កសិករដើម្បីជួយកែលំអការចិញ្ចឹមសត្វ និងលើកកម្ពស់ជីវភាពរបស់ពួកគាត់។ ឆ្លើយតបទៅនឹងតួនាទីដ៏សំខាន់នេះ គម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប បានបណ្តុះបណ្តាលរំលឹកភ្នាក់ងារសុខភាពសត្វភូមិបានចំនួនប្រមាណ១១៥០នាក់ នៅបណ្តាខេត្តគោលដៅលើម៉ូឌុលចំនួន១៩ទាក់ទងទៅនឹង បច្ចេក-ទេសចិញ្ចឹមសត្វ និងទីផ្សារសត្វ។ ម៉ូឌុលនីមួយៗបានរៀបចំឡើងដោយឆ្លើយតបនៅនឹងស្ថានភាពសុខភាពនិងការចិញ្ចឹមសត្វនៅជនបទ និងបានចូលរួមផ្តល់ជាគំនិត និងការកែលំអពីផ្នែកពាក់ព័ន្ធនានាក្នុងនោះមានមន្ត្រី សម្របសម្រួលគម្រោងមកពីនាយកដ្ឋាន និងការិយាល័យផលិតកម្ម និងបសុពេទ្យ ខេត្តគោលដៅក្រុម ការងារបច្ចេកទេសគម្រោង និងនាយកគម្រោង។ ឯកសារម៉ូឌុលនេះ បានយកទៅបង្រៀនដោយគ្រូបង្គោលនៃគម្រោង បន្ទាប់មកបានធ្វើការកែលំអឱ្យមានភាពសុក្រិតបន្ថែមទៀត បន្ទាប់ពីបានបង្រៀននិងអនុវត្ត ផ្ទាល់ដោយភ្នាក់ងារសុខភាពសត្វភូមិ។ ទន្ទឹមនឹងនេះដែរ គម្រោងបានរៀបចំនូវសៀវភៅបច្ចេទេសខ្នាតតូច នេះឡើងដើម្បីផលប្រយោជន៍បន្ថែមទៀត សម្រាប់ភ្នាក់ងារសុខភាពសត្វភូមិដែលទទួលការបណ្តុះបណ្តាលរំលឹកហើយ។

ដើម្បីឆ្លើយតបនឹងតម្រូវការមិនចេះឈប់ឈរក្នុងការពង្រឹងសមត្ថភាព បង្កើនការយល់ដឹង ក៏ដូចជាចែករំលែកបទពិសោធន៍ និងជាផលប្រយោជន៍យូរអង្វែងសម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ កសិករ ភ្នាក់ងារផ្តល់សេវាកម្មបសុពេទ្យផ្សេងៗទៀត ហើយនិងជាឯកសារសិក្សាផ្សព្វផ្សាយបច្ចេកទេសមូលដ្ឋាន ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ សហការជាមួយគម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប និងបណ្តាផ្នែកពាក់ព័ន្ធផ្សេងទៀត ធ្វើការចងក្រងសៀវភៅខ្នាតតូចនេះ ក្នុងគោលបំណងរួមចំណែកលើកកម្ពស់ជីវភាពប្រជាកសិករសុវត្ថិភាពស្បៀង និងកាត់បន្ថយភាពក្រីក្រស្របទៅតាមកម្មវិធី និងគោលនយោបាយរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១០

រ ដ្ឋ ម ន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# អង្កេតតាមដានជំងឺសត្វ
# នៅតាមមូលដ្ឋាន


ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ


**១. សេចក្តីផ្តើម** ... ៣

១-១- អ្វីទៅដែលហៅថាការអង្កេតតាមដានជំងឺ? ... ៣

១-២- គោលបំណងនៃការអង្កេតតាមដានជំងឺ ... ៣

១-៣- ការផ្ទុះជំងឺ និងការឆ្លងរាតត្បាត ... ៤

១-៤- ជំងឺឆ្លងដែន ... ៥

១-៥- ឥទ្ធិពលរបស់ជំងឺឆ្លងរាតត្បាត ... ៥

១-៦- ជំងឺដែលត្រូវធ្វើការអង្កេតតាមដាន ... ៦

១-៧- ជំងឺស្ថិតក្រោមការអង្កេតតាមដាននៅកម្ពុជា ... ៧

១-៨- ជំងឺស្ថិតក្នុងការតាមដានពិសេសនៅប្រទេសកម្ពុជា ... ៨

**២. ការអនុវត្តន៍លើការអង្កេតតាមដានជំងឺរបស់ភ្នាក់ងារសុខភាពសត្វភូមិ** ... ៨

២-១- មូលដ្ឋានគ្រឹះនៃការអង្កេតជំងឺ ... ៨

២-២- ការអង្កេតតាមដានជំងឺ ... ១០

២-៣- ការស្លាប់ដោយមិនដឹងមូលហេតុ ... ១២

២-៤- តួនាទីរបស់ភ្នាក់ងារសុខភាពភូមិក្នុងការតាមដានជំងឺ ... ១៣

២-៥- ការចាត់វិធានការណ៍ជាបន្ទាន់ ... ១៤

**៣. ប្រព័ន្ធព័ត៌មាន** ... ២៤

៣-១- អ្វីទៅជាប្រពន្ធ័ព័តិមាន? ... ២៤

៣-២- ហេតុអ្វីបានជាគេត្រូវការប្រព័ន្ធព័តិមាន? ... ២៥

៣-៣- ព័តិមាននៅថ្នាក់ភូមិ ... ២៦

៣-៤- ព័តិមាននៅថ្នាក់ស្រុក ... ២៧

៣-៥- ព័ត៌មាននៅថ្នាក់ខេត្ត ..... ២៨
៣-៦- ព័ត៌មាននៅថ្នាក់ជាតិ ..... ២៨
៣-៧- ប្រពន្ធ័ព័ត៌មាននៅថ្នាក់អន្តរជាតិ ..... ៣១
៣-៨- ប្រពន្ធ័ព័ត៌មាន( ផ្លូវកាត់) ..... ៣២

**៤_ ការអង្កេតតាមដាន + ប្រព័ន្ធព័ត៌មាន = ការទទួលខុសត្រូវ** ..... ៣៤
៤-១- មូលដ្ឋានគ្រឹះ ..... ៣៤
៤-២- អ្នកណាជាអ្នកចាត់វិធានការណ៍? ..... ៣៤
៤-៣- តើមានសកម្មភាពអ្វីខ្លះ? ..... ៣៥

**៥_បញ្ហាដែលធ្លាក់ចារសុខភាពសត្វតូមិប្រឈមមុខក្នុងពេលអនុវត្តការ អង្កេតតាម ដាន/រាយការណ៍** ..... ៤១
៥-១- ខ្វះការរាយការណ៍ ..... ៤១
៥-២- ការអង្កេតតាមដាន/របាយការណ៍ដែលប្រសើរ ..... ៤៥

**៦_ការរំលឹកពីជម្ងឺមួយចំនួន ដែលត្រូវប្រកាសជូនដំណឹង** ..... ៤៨
៦-១- ជំងឺផ្តាសាយបក្សី ..... ៤៨
៦-២- ជំងឺអុតក្តាម ..... ៥០
៦-៣- ជំងឺសារទឹក ..... ៥៣
៣-៤- ជំងឺប៉េស្តជ្រូក ..... ៥៤
៣-៥- ជំងឺញ៉ូវកាស ឬដង្កោ ..... ៥៦

# អង្កេតតាមដានជំងឺសត្វនៅតាមមូលដ្ឋាន

## ១. សេចក្ដីផ្ដើម

### ១.១. អ្វីទៅដែលហៅថាការអង្កេតតាមដានជំងឺ?

ការអង្កេតតាមដានជំងឺគឺជា :

- ការតាមដាននូវ ការផ្ទុះ និងការរាតត្បាតនៃជំងឺសត្វ មានន័យថាជាការកំណត់បញ្ជាក់ពីប្រភេទជំងឺ និង ការទទួលបាននូវភាពច្បាស់លាស់ស្ដីពីដំណើរការរាតត្បាតជំងឺនៅថ្នាក់ស្រុក ខេត្ត ឬ ប្រទេស
- ព្រមទាំងរាយការណ៍ពីករណីជំងឺសត្វ ដូចជាការជូនដំណឹងដល់អ្នកដែលពាក់ព័ន្ធក្នុងវិស័យផលិតកម្ម និង បសុព្យាបាល ។

*ការធ្វើរោគវិនិច្ឆ័យជំងឺរាតត្បាតបានត្រឹមត្រូវ និង ការជូនដំណឹងដល់ពេទ្យសត្វស្រុក គឺត្រូវចាប់ផ្ដើមចេញពីការអង្កេតតាមដានច្បាស់លាស់ពីថ្នាក់មូលដ្ឋាន*



### ១.២. គោលបំណងនៃការអង្កេតតាមដានជំងឺ

ការអង្កេតតាមដានជំងឺមានគោលបំណងសំខាន់គឺ :

- ធ្វើឱ្យគេដឹងទាន់ពេលវេលាពីសភាពជំងឺឆ្លងរាតត្បាត ( ការផ្ទុះឡើងនូវជំងឺ)
- តាមរយៈកិច្ចការនេះអាចឱ្យគេបញ្ឈប់ និង កម្ចាត់ជំងឺបានមុនពេលវាធ្វើការរាតត្បាតបន្ត
- ការរាតត្បាតរបស់ជំងឺអាចត្រូវបានគេបញ្ឈប់តាមរយៈ ការដុត ឬកប់សាកសពសត្វ សម្លាប់សត្វឈឺ បង្ខាំង ការចាក់ថ្នាំការពារ ឬការព្យាបាលត្រឹមត្រូវ ។

*ការចាក់វ៉ាក់សាំងជំងឺអុតក្តាមនៅភូមិ ដែលនៅជិតតំបន់ផ្ទុះជំងឺ អាចឱ្យគេបញ្ឈប់បាននូវការរាតត្បាត របស់ជំងឺ*



## ១.៣. ការផ្ទុះជំងឺ និងការឆ្លងរាតត្បាត

### ១.៣.១. ការផ្ទុះជំងឺឆ្លង

ការផ្ទុះជំងឺគឺជាកត្តាដែលធ្វើឱ្យសត្វឈឺ ឬស្លាប់កើនឡើងភ្លាមៗ ។

### ១.៣.២. ការឆ្លងរាតត្បាត

ការឆ្លងរាតត្បាតគឺជាការផ្ទុះឡើងនូវជំងឺឆ្លងរាតត្បាត ដែល:

- រាតត្បាតយ៉ាងឆាប់រហ័សលើសត្វជាច្រើននៅក្នុងកសិដ្ឋាន ឬភូមិ ហើយសត្វចាប់ផ្តើមឈឺក្នុងរយៈពេល ខ្លី (១-២ ថ្ងៃ)
- រាតត្បាតយ៉ាងទូលំទូលាយ ដោយជំងឺចាប់ផ្តើមរាតត្បាត យ៉ាងរហ័សពីភូមិមួយទៅភូមិមួយ ពីខេត្តមួយទៅខេត្តមួយ ឬ ពីប្រទេសមួយទៅប្រទេសមួយ ។



*ការប៉ះពាល់ផ្ទាល់រវាងសត្វជាច្រើន តាមរយៈការធ្វើដំណើរគឺជាកត្តាជួយសម្រួលដល់ការសាយភាយនូវមេរោគជំងឺឆ្លងរាតត្បាត*

## ១.៤. ជំងឺឆ្លងដែន

- ជំងឺសត្វឆ្លងដែន (TADs = Trans-boundary Animal Diseases): គឺជាប្រភេទ ជំងឺឆ្លងរាតត្បាតសាហាវខ្លាំង ដែលងាយរាតត្បាតទៅកាន់ប្រទេសផ្សេងទៀត ហើយមានសកម្មភាពរាតត្បាតខ្ពស់
- ជំងឺទាំងនេះបង្កគ្រោះថ្នាក់ខ្លាំងលើសេដ្ឋកិច្ច-សង្គម និង សុខភាពសាធារណៈ
- ការគ្រប់គ្រងលើជំងឺទាំងនេះតម្រូវឱ្យមានការសហប្រតិបត្តិការគ្នារវាងប្រទេស ជាច្រើន។




*ផែនទីបង្ហាញពីការរាតត្បាតជំងឺផ្តាសាយបក្សីពីប្រទេសមួយទៅប្រទេសមួយទៀត ដែលធ្វើឱ្យមានការខូចខាតធ្ងន់ធ្ងរ បញ្ហានេះគឺជាជំងឺសត្វឆ្លងដែន (TAD)*

## ១.៥. ឥទ្ធិពលរបស់ជំងឺឆ្លងរាតត្បាត

នៅពេលមានជំងឺឆ្លងការរាតត្បាតផ្ទុះឡើងនឹងធ្វើឱ្យ:

- ចំនួនហ្វូងសត្វថយចុះយ៉ាងខ្លាំង ដែលជាហេតុធ្វើឱ្យបន្ថយទាំងបរិមាណ និងគុណភាពចំណីអាហារសម្រាប់មនុស្ស
- មានឥទ្ធិពលទៅលើកម្លាំងអូសទាញ (ដូចជាភ្ជួរ រាស់)
- ផលិតកម្មសត្វមានកម្រិត ព្រោះដោយសារកសិករនឿយណាយនឹងការខាតបង់លុយកាក់ដោយសារសត្វឈឺ និងស្លាប់ ដែលជាហេតុធ្វើឱ្យពួកគាត់មិនបង្កើនសកម្មភាព ផលិតកម្មសត្វ

- ពាណិជកម្មសត្វមានការថយចុះ ឬ បញ្ឈប់ ពីព្រោះប្រទេសនីមួយៗត្រូវការចាត់ វិធានការការពារជំងឺឆ្លង ដូចនេះគេមិនអាចនាំចេញនូវផលិតផលមានដើមកំណើតពីសត្វ ឬសត្វរស់បានឡើយ ។



*ហេតុអ្វីបានជាការវិនិយោគ ចិញ្ចឹមមាន់ដោយមានរបង បិទជិត នៅតែ អាចជួយបង្កើន ចំនួនមាន់ដដែល បើទោះជា កន្លែងចិញ្ចឹមប្រឈមនឹងបញ្ហា ជំងឺឆ្លងក៏ដោយ?*

## ១.៦. ជំងឺដែលត្រូវធ្វើការអង្កេតតាមដាន

ជំងឺដែលត្រូវធ្វើការអង្កេតតាមដាន រួមមាន:

- ជំងឺដែលអាចចម្លងនៅក្នុងតំបន់
- ជំងឺបង្កឥទ្ធិពលធ្ងន់ធ្ងរទៅលើ សេដ្ឋកិច្ច គ្រួសាររបស់កសិករ
- ជំងឺដែលមានឥទ្ធិពលធ្វើឱ្យបាត់បង់ផលិតកម្មធ្ងន់ធ្ងរ
- ជំងឺបង្កគ្រោះថ្នាក់ទៅលើ សុខភាពសាធារណៈ (ជំងឺឆ្លងពីសត្វទៅមនុស្ស)
- ជំងឺដែលមានឥទ្ធិពលខ្លាំងទៅលើពាណិជ្ជកម្មសត្វ និង ផលិតផលមានដើមកំណើតពី សត្វជាអន្តរជាតិ ។



*ប្រសិនបើជ្រូកមានរោគសញ្ញាជំងឺប៉េស្ត តើវាមានតម្លៃយ៉ាងដូចម្តេចដែរ?*

## ១.៧. ជំងឺស្ថិតក្រោមការអង្កេតតាមដាននៅកម្ពុជា

អង្គការសុខភាពសត្វពិភពលោក (អូអ៊ីអ៊ី: OIE) គឺជាអង្គការអន្តរជាតិដែលចេញ សេចក្តីប្រកាសជាផ្លូវការណ៍នូវជំងឺឆ្លងមួយចំនួន ហើយនៅក្នុងនោះនៅប្រទេសកម្ពុជាយើង ជំងឺ ដែលត្រូវប្រកាសរួមមាន:

- ជំងឺផ្តាសាយបក្សី (HPAI ជំងឺផ្តាសាយបក្សីដែលមានឥទ្ធិពលបង្កជំងឺខ្លាំង)
- ជំងឺអុតក្តាម (FMD)
- ជំងឺប៉េស្តជ្រូក (CSF)
- ជំងឺដង្កោ (NcD)
- ជំងឺសារទឹក (HS)
- ជំងឺបូសខ្យល់ (Blackleg)

*អង្គការសុខភាពសត្វពិភពលោក (OIE) សម្របសម្រួលលើយុទ្ធនាការប្រឆាំងនឹងជំងឺអុតក្តាមនៅ ប្រទេសកម្ពុជា ឡាវ ម៉ាឡេស៊ី ភូមា ហ្វីលីពីន ថៃ និង វៀតណាម ក្រោមឈ្មោះ (SEAFMD)*

### ១.៨. ជំងឺស្ថិតក្នុងការតាមដានពិសេសនៅប្រទេសកម្ពុជា

ក្នុងនោះមានជំងឺ ២ ដែលត្រូវរាយការណ៍ជាបន្ទាន់:

- ជំងឺផ្តាសាយបក្សីដែលមានឥទ្ធិពលបង្កជំងឺខ្លាំង (HPAI) ព្រោះជំងឺនេះឆ្លងទៅមនុស្ស និង មានគ្រោះថ្នាក់ខ្លាំង
- ជំងឺអុតក្តាម : ជំងឺនេះឆ្លងរាតត្បាតខ្លាំង ហើយអាចចម្លងបានលឿនក្នុងចំណោមគោ និង ជ្រូក ដែលធ្វើឱ្យបាត់បង់សេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ។

សម្រាប់ជំងឺអុតក្តាម ប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិកំណត់ជំងឺបានច្បាស់លាស់ ហើយរាយការណ៍បានឆាប់ នោះធ្វើឱ្យគេអាចមានលទ្ធភាពចាក់វ៉ាក់សាំងការពារដល់សត្វ ដែល នៅភូមិជិតខាងបានភ្លាមៗ ហើយគោទាំងនោះអាចត្រូវបានគេការពារ ។



ជំងឺផ្តាសាយបក្សី



ជំងឺអុតក្តាម

## ២. ការអនុវត្តន៍លើការអង្កេតតាមដានជំងឺរបស់ភ្នាក់ងារសុខភាពសត្វភូមិ

### ២.១. មូលដ្ឋានគ្រឹះនៃការអង្កេតជំងឺ

ការអង្កេតឃើញដំបូង

- គន្លឹះសំខាន់ក្នុងការគ្រប់គ្រងលើការផ្ទុះជំងឺប្រកបដោយជោគជ័យគឺ ការអង្កេតឃើញដំបូង/លឿន

- ប្រសិនបើដំណាក់កាលផ្ទុះជំងឺត្រូវបានគេអង្កេតឃើញលឿន នោះគេអាចមានលទ្ធភាពបញ្ឈប់ជំងឺបានមុនពេលវាបង្កគ្រោះថ្នាក់ខ្លាំងក្លា ។



*នណាជាអ្នកអង្កេតឃើញជំងឺនៅតាមមូលដ្ឋានដំបូងបំផុត? ចំលើយគឺភ្នាក់ងារសុខភាពសត្វភូមិ !*



*ភ្នាក់ងារសុខភាពសត្វភូមិគឺជាអ្នករស់នៅក្នុងមូលដ្ឋាន ហើយជាអ្នកមានចំណេះដឹងលើការត្រួតពិនិត្យ សត្វ និង កំណត់អត្តសញ្ញាណជំងឺ ដូចនេះគេគឺជាមនុស្សសំខាន់ម្នាក់ក្នុងការអង្កេតឃើញដំបូង*

ការអង្កេតឃើញដំបូង គឺជាកិច្ចការដ៏ល្អ! តែវាកាន់តែប្រសើរថែមទៀត ប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិ អាចជូនដំណឹងដល់អ្នកភូមិផ្សេងទៀតឱ្យចាត់វិធានការការពារសត្វរបស់ពួកគេ ព្រោះ :

- ភ្នាក់ងារសុខភាពសត្វភូមិអាចជូនដំណឹងដល់អ្នកក្នុងភូមិបានងាយស្រួល
- តែភូមិ ឃុំ... ដែលនៅជិតខាងក៏ត្រូវតែដឹងពីគ្រោះថ្នាក់នេះដែរ
- មនុស្សសំខាន់ដែលអាចជូនដំណឹងដល់ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ និង ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត គឺពេទ្យសត្វស្រុក
- *ការអង្កេតឃើញដំបូងរបស់ភ្នាក់ងារសុខភាពសត្វភូមិ រួមជាមួយនឹងការរាយការណ៍ជាបន្ទាន់ទៅកាន់ពេទ្យសត្វស្រុក គឺជាដំណើរការអង្កេតតាមដានជំងឺដ៏ មានប្រសិទ្ធភាពបំផុត ។*




*ការិយាល័យពេទ្យសត្វស្រុក ជាកន្លែងដ៏សំខាន់ ក្នុងការអង្កេត តាមដានជំងឺនៅតាមភូមិ*

## ២.២. ការអង្កេតតាមដានជំងឺ

វិធីសាស្ត្រសំខាន់ៗ ក្នុងការអង្កេតលើសត្វឈឺរួមមាន:

- ពិនិត្យលើសត្វទាំងមូល ដើម្បី :
    - កំណត់រោគសញ្ញា
    - ធ្វើរោគវិនិច្ឆ័យប្រៀបធៀប ព្រោះគេមិនអាចប្រាកដ ១០០% ទេ តែវាអាចជា ប្រភេទជំងឺដែលគេសង្ស័យខ្លាំងបំផុត។
- សូមការជួយគាំទ្រពីពេទ្យសត្វស្រុក
    - ស្នើសុំឱ្យពេទ្យសត្វស្រុកជួយកំណត់បញ្ជាក់ពីការធ្វើរោគវិនិច្ឆ័យ
    - ពេទ្យសត្វស្រុកអាចបញ្ជូនសំណាកទៅកាន់ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល (NaVRI) តាមរយៈការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត។



*ការត្រួតពិនិត្យលើខ្លួនសត្វទាំងមូលគឺ ជាកិច្ចការចាំបាច់បំផុតក្នុងការរកមើលនូវ សញ្ញាផ្សេងៗ*

*រោគសញ្ញាជំងឺខ្លះអាចបង្ហាញច្បាស់លាស់ តែវានៅតែមិនគ្រប់គ្រាន់សម្រាប់ធ្វើរោគ វិនិច្ឆ័យជំងឺ !*



ហូរទឹកមាត់មានពពុះ និងការមិន
ចង់ស៊ីចំណីជាសញ្ញានៃជំងឺរលាក ក្រពះ?
អុតក្ដាម? មានវត្ថុផ្សេង នៅក្នុងមាត់?
ឬដោយសារការលិត នូវសារធាតុផ្សេង
ទៀតដែលធ្វើឱ្យ ដាច់រលាត់មាត់?



ពេលបើកមាត់សត្វ ហើយគេធ្វើការត្រួតពិនិត្យ
ដោយប្រុងប្រយ័ត្ន។
ឥឡូវនេះគេច្បាស់ណាស់ ថា ជាជំងឺអុតក្ដាម



ដើម្បីឱ្យកាន់តែច្បាស់លាស់ ពេទ្យសត្វស្រុក
ត្រូវតែយកសំណាក វិភាគ



*ហើយមន្ទីរពិសោធន៍ជាអ្នកធ្វើ ការវិភាគ*

## ២.៣. ការស្លាប់ដោយមិនដឹងមូលហេតុ

ការស្លាប់ដោយមិនដឹងមូលហេតុ ឬ មានការសង្ស័យគឺមានន័យថាអត្រាស្លាប់មាន សភាពស្រួ-ចស្រាវ ដែលជាហេតុធ្វើឱ្យយើងមិនអាចមើលឃើញរោគសញ្ញាច្បាស់លាស់ ព្រោះ សត្វស្លាប់មុនរោគសញ្ញាលេចចេញ ដូចនេះ ៖

- ដើម្បីចៀសវាងកុំឱ្យមានការសាយភាយជំងឺ គេមិនត្រូវធ្វើការវះកាត់សាកសពសត្វ ឡើយ ព្រោះផ្ទាំងសាច់មានពេញទៅដោយមេរោគ
- ពិតណាស់ថាការស្លាប់ភ្លាមៗដោយគ្មានហេតុផលច្បាស់លាស់ គឺគេចាំបាច់ត្រូវតែមានការសង្ស័យ ហើយទាមទារឱ្យមានការវិភាគនៅមន្ទីរពិសោធន៍
- ដើម្បីវាយតម្លៃឱ្យបានប្រសើរលើបញ្ហានេះ ភ្នាក់ងារសុខភាពសត្វភូមិត្រូវធ្វើការអង្កេតភ្លាមៗ ។



*មាន់ទាំងនេះងាប់ភ្លាមៗដោយសារ សត្វចង្រៃខាំ! ដូចនេះគេមិនអាចសង្ស័យថាជាជំងឺផ្តាសាយបក្សីទេ!*



*មាន់ងាប់ដោយសារធ្លាក់ពីដើមឈើ នៅពេលយប់។ កសិករទិញមាន់ជល់ នេះពីប្រទេសវៀតណាម ៣ ថ្ងៃមកហើយ តើវាជាជំងឺផ្តាសាយបក្សី ឬជាជំងឺដង្កោ ?*



*គោនៅក្រោមដើមឈើទទួលរង នូវខ្យល់ព្យុះ និងរន្ទះ ហើយងាប់ ដោយមានស្នាមឆ្នូតឆេះ នៅលើ ជើង តើវាងាប់ដោយរន្ទះបាញ់ ឬ ជំងឺឈាមខ្មៅ?*

## ២.៤. តួនាទីរបស់ភ្នាក់ងារសុខភាពភូមិក្នុងការតាមដានជំងឺ

ភ្នាក់ងារសុខភាពភូមិគឺជាមនុស្សដ៏សំខាន់ក្នុងការអនុវត្តន៍លើការអង្កេតតាមដានជំងឺនៅតាម មូលដ្ឋាន ព្រោះភ្នាក់ងារសុខភាពសត្វភូមិជាអ្នកៈ

- រស់នៅក្នុងភូមិ
- ព្យាបាលសត្វ ដូចនេះពួកគេធ្វើដំណើរច្រើន
- ទទួលបានការបណ្តុះបណ្តាលជាក់លាក់ក្នុងការកំណត់ជំងឺ
- ត្រូវបានអ្នកភូមិជឿទុកចិត្ត
- ធ្វើការងារយ៉ាងជិតស្និទ្ធជាមួយពេទ្យសត្វស្រុក។



*ភ្នាក់ងារសុខភាពសត្វភូមិជាអ្នកទទួលខុសត្រូវ លើសុខភាពសត្វនៅតាមមូលដ្ឋាន*

## ២.៥. ការចាត់វិធានការជាបន្ទាន់

បន្ទាប់ពីមានការសង្ស័យលើជំងឺឆ្លងរាតត្បាត ភ្នាក់ងារសុខភាពសត្វភូមិត្រូវចាត់វិធានការបន្ទាន់ដូចជា:

១. ជូនដំណឹងពីការរកឃើញនៃការធ្វើរោគវិនិច្ឆ័យដល់អ្នកពាក់ព័ន្ធ

២. ធ្វើការព្យាបាលប្រសិនបើអាច

៣. ការពារកុំឱ្យមេរោគឆ្លងរាតត្បាតនៅក្នុងភូមិ

៤. ប្រកាសជូនដំណឹងដល់អ្នកភូមិ

៥. រាយការណ៍

៦. តាមដានការរាតត្បាតនៃជំងឺ





*មេរោគរាតត្បាតលឿននៅក្នុងមជ្ឈដ្ឋានកខ្វក់ ដូចនេះការសម្អាតភូមិគឺជាដំណាក់កាលដំបូងក្នុងការកាត់បន្ថយសកម្មភាពរាតត្បាតរបស់ជំងឺ*

### ២.៥.១. ជូនដំណឹងពីការរកឃើញនៃការធ្វើរោគវិនិច្ឆ័យ ដោយផ្អែក:

- រោគសញ្ញាខ្លះមានសភាពធម្មតា ហើយការត្រួតពិនិត្យដោយប្រុងប្រយ័ត្នអាចប្រកាសបាន ដូចជាជំងឺអុតក្តាមមានស្លាកស្នាមនៅលើមាត់ ជំងឺប៉េស្តជ្រូកមានចំណុចជាំឈាមនៅក្រោមស្បែកជាមួយនឹងកម្តៅឡើងខ្ពស់ ។ល។

- ភ្នាក់ងារសុខភាពសត្វភូមិអាចស្នើសុំជំនួយពីពេទ្យសត្វស្រុក ព្រោះពួកគេមានបទពិសោធន៍ច្រើន
- ការព្យាបាលជោគជ័យអាចជួយឱ្យប្រកាសពីការធ្វើរោគវិនិច្ឆ័យ ដូចជាអង់ទីប៊ីយ៉ូទិក មានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺបង្កឡើងដោយបាក់តេរីដូចជាសារទឹក អាសន្នរោគ ។ល ។
- យកសំណាកឈាម សាច់ ក្រម៉ារ...បញ្ជូនទៅកាន់មន្ទីរពិសោធន៍ ដើម្បីប្រកាសពីការធ្វើរោគវិនិច្ឆ័យ ។



*ជួនកាលរោគសញ្ញាមានតែមួយ*
*មិនគ្រប់គ្រាន់សម្រាប់បញ្ជាក់ជំងឺនោះទេ ដូចជាគេសង្ស័យខ្លាំងថាជាជំងឺប៉េស្ត ប្រសិនបើ*
*គេឃើញមានជាំឈាមក្រោមស្បែក រួមជាមួយនឹងកម្ដៅឡើងខ្ពស់*

## ២.៥.២. ភ្នាក់ងារសុខភាពសត្វភូមិព្យាបាលសត្វ

ការព្យាបាលមានសារៈសំខាន់ណាស់ ក្នុងការបញ្ឈប់ការរាតត្បាតជំងឺបង្កឡើងដោយបាក់តេរី ដូចជាជំងឺសារទឹកអាចព្យាបាលបានជោគជ័យ ប្រសិនបើគេចាប់ផ្ដើមទាន់ពេល ។

សំខាន់ទៅទៀតការព្យាបាលដើម្បីការពារ អាចជួយការពារសត្វដែលប៉ះផ្ទាល់ជាមួយសត្វឈឺកុំឱ្យទទួលជំងឺ ដូចជាការប្រើអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ក្នុងករណីមានផ្ទុះ ជំងឺសារទឹក ឬអាសន្នរោគ ឬប៉េនីស៊ីលីន (Penicilline) ក្នុងករណីជំងឺបួសខ្យល់ ។

ការព្យាបាលអាចការពារជំងឺឱកាសនិយម និងជួយឱ្យសត្វជាសះស្បើយ ដូចជាការប្រើទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ក្នុងករណីមានជំងឺអុតក្តាម ។



*ការចាក់អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) តាមសរសៃវ៉ែន អាចព្យាបាលគោដែលឈឺជំងឺសារទឹកបានជាសះស្បើយ ហើយអាចបញ្ឈប់ការរាតត្បាតរបស់មេរោគ*

## ២.៥.៣. ភ្នាក់ងារសុខភាពសត្វភូមិការពារការរាតត្បាតជំងឺ

**គោលបំណង សំខាន់គឺដើម្បី :**

- កុំឱ្យបាត់បង់លុយកាក់ ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ដោយសារជំងឺឆ្លងរាតត្បាត
- ព្យាយាមបញ្ឈប់ការរាតត្បាតរបស់ជំងឺ ប្រសិនបើគេកំណត់ពីជំងឺឆ្លងរាតត្បាតបានច្បាស់លាស់
- ធ្វើឱ្យជំងឺមិនអាចរាតត្បាតពេញក្នុងភូមិ ឬទៅភូមិផ្សេងទៀត ។



*ប្រសិនបើគោរបស់កសិករងាប់ តើប្រាក់សន្សំរបស់គាត់យ៉ាង ដូចម្តេចដែរ?*

**ការចាត់វិធានការការពារភ្លាមៗ ៖ ក្នុងករណីសត្វងាប់គេត្រូវ ៖**

- ដុត ឬកប់សាកសពសត្វ ពិសេសទៅទៀតមិនត្រូវចែកចាយមាន់ដែលងាប់ឱ្យអ្នកជិត ខាង ឬក្រុមគ្រួសារឡើយ
- គោដែលងាប់ដោយជំងឺបូសខ្យល់ ឬឈាមខ្មៅបានបញ្ចេញមេរោគទៅក្នុងដី ហើយមេរោគរស់នៅបានយូរឆ្នាំ តែការដុតសាកសពសត្វធ្វើឱ្យគេចំណាយលុយកាក់ជាច្រើន ដូចនេះគេត្រូវកប់សាកសពសត្វរួចចាចកំបោរពីលើ ហើយប្រកាសប្រាប់អ្នកភូមិថា តំបន់នោះមានមេរោគរស់នៅបានយូរឆ្នាំ
- មិនត្រូវធ្វើចរាចរសត្វ ហើយត្រូវហាមឃាត់រាល់ការធ្វើចរាចរសត្វឈឺ ពីព្រោះពួកវាផ្ទុកមេរោគ និងធ្វើការចម្លងរាតត្បាតជំងឺ
- បំបែកសត្វឈឺដាក់ដោយឡែកឱ្យឆ្ងាយពីសត្វជា។



*ភ្នាក់ងារសុខភាពសត្វភូមិកប់សាកសពមាន់ភ្លាមៗក្រោយពីងាប់ព្រោះគាត់សង្ស័យថាជាជំងឺផ្តាសាយបក្សី*



*ពេលសង្ស័យថាជ្រូកមានជំងឺប៉េស្តគេត្រូវយកវាទៅដាក់នៅទ្រុងដាច់ដោយឡែកឱ្យឆ្ងាយពីគេ*

សកម្មភាពបន្ទ: ការសម្លាប់មេរោគ

- គេចាំបាច់ត្រូវធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅទ្រុង និងសំភារៈដែលប៉ះពាល់ជាមួយ សត្វឈឺ (ធុងទឹក ស្បែកជើង និងដៃ...)
- នៅពេលមានបញ្ហាផ្ទុះជំងឺនៅក្នុងភូមិ ឬភូមិជិតខាង ត្រូវណែនាំពួកគាត់កុំឱ្យចូលមកក្នុងកសិដ្ឋាន ឬក្នុងភូមិឡើយ ព្រោះពួកគាត់ជាអ្នកចម្លងជំងឺពីកន្លែងមួយទៅកន្លែង



*ត្រូវចងចាំថាភ្នាក់ងារសុខភាពសត្វភូមិ អាចជាអ្នកនាំមេរោគតាមរយៈដៃ សំលៀកបំពាក់ និងស្បែកជើង ព្រោះ ពួកគេបានទៅព្យាបាលសត្វនៅតាមផ្ទះ កសិករជាច្រើន*





*នៅពេលមានផ្ទុះជំងឺអុតក្តាម ភ្នាក់ងារសុខភាពសត្វភូមិ ត្រូវព្យាយាមបញ្ចុះបញ្ចូលអ្នកភូមិឱ្យទុកគោនៅផ្ទះ*





ការចិញ្ចឹមជ្រូកកុំឱ្យដើរសេរីគឺជាកត្តាមួយដ៏ល្អក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងការឆ្លងជំងឺ ដូចជាប៉េស្ត ត្រចៀកខៀវ អុតក្តាម...



មាន់ចិញ្ចឹមលែងសេរីងាយទទួលរងជំងឺ

វីរុសជង្គោមិនងាយឆ្លងមកមាន់ទាំងនេះបានទេ



## ២.៥.៤. ភ្នាក់ងារសុខភាពសត្វភូមិជូនដំណឹងដល់អ្នកភូមិ

តើមានអ្វីកើតឡើង ពេលមានជំងឺឆ្លងរាតត្បាតនៅក្នុងភូមិ?

ពេលមានផ្ទុះជំងឺអុតក្តាម ដង្កោ ប៉េស្តជ្រូក... នៅក្នុងភូមិ ធ្វើឱ្យអ្នកភូមិបាត់បង់លុយកាក់ជាច្រើន ដោយសារៈ

- ជំងឺដង្កោធ្វើឱ្យមាន់ងាប់ច្រើន
- ជំងឺអុតក្តាមធ្វើឱ្យគោបាត់បង់លទ្ធភាពការងារ ឬងាប់ដោយសារជំងឺសារទឹក
- ជ្រូកលែងធំធាត់ ងាប់ ហើយកសិករចំណាយលុយកាក់លើថ្នាំព្យាបាល ដោយសារបញ្ហាជំងឺប៉េស្តជ្រូក។

*សរុបមកនៅក្នុងភូមិបាត់បង់លុយរាប់ម៉ឺនដុល្លា !*



*គ្មានវិធានការទប់ស្កាត់ជំងឺរាតត្បាត ធ្វើឱ្យមានការបាត់បង់លុយកាក់ជាច្រើន!*

ឥទ្ធិពលនៃការផ្ទុះជំងឺត្រូវបានបន្ថយប្រសិនបើភ្នាក់ងារសុខភាពសត្វភូមិ ៖

- ជូនដំណឹងដល់អ្នកភូមិពីការសង្ស័យលើជំងឺឆ្លងរាតត្បាតក្នុងភូមិ
- ពន្យល់ដល់អ្នកភូមិពីគ្រោះថ្នាក់ផ្សេងៗ
- ណែនាំអ្នកភូមិឱ្យរិតត្បិតលើចរាចរសត្វ

- បង្ហាញដល់អ្នកភូមិឱ្យបានច្បាស់លើការព្យាបាលបង្ការ ឬវិធានការផ្សេងទៀតដែលមានប្រសិទ្ធភាព ។

*កសិករធ្លាប់បានជួបប្រទះរួចទៅហើយលើបញ្ហាបាត់បង់លុយកាក់ដោយសារជំងឺដង្កៅ អុតក្តាម ប៉េស្តជ្រូក ហើយពួកគាត់នឹងស្វាគមន៍លើវិធានការការពារ !*



*ភ្នាក់ងារសុខភាពសត្វភូមិទទួលខុសត្រូវលើសុខភាពសត្វក្នុងភូមិ ពួកគេត្រូវបានអ្នកភូមិ វិតតែជឿជាក់ ប្រសិនបើពួកគេជូនដំណឹងបានច្បាស់លាស់*

## ២.៥.៥. ភ្នាក់ងារសុខភាពសត្វភូមិរាយការណ៍

ភ្នាក់ងារសុខភាពសត្វភូមិរាយការណ៍ដល់ពេទ្យសត្វស្រុក

- វាជាការល្អ ប្រសិនបើជំងឺអាចត្រូវបានគេបញ្ឈប់ ឬកម្ចាត់មុនរាតត្បាតទៅកាន់ភូមិផ្សេង ដែលអាចធ្វើឱ្យកសិករសន្សំលុយកាក់បានជាច្រើន
- ឧទាហរណ៍ វាជាការពិតដែលថាការគ្រប់គ្រងជំងឺប៉េស្តជ្រូកនៅតាមភូមិធ្វើឡើងតាមរយៈវិធានការជីវសុវត្ថិភាព និង វ៉ាក់សាំង ឬការគ្រប់គ្រងជំងឺសារទឹកដោយសារការ ប្រើអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)
- តែក្នុងកំឡុងពេលប្រជុំភ្នាក់ងារសុខភាពសត្វភូមិ ត្រូវតែធ្វើការរាយការណ៍ជូនដល់ ពេទ្យសត្វស្រុក និង ខេត្ត ព្រោះសំខាន់ដើម្បីឱ្យថ្នាក់កណ្តាលដឹងពីជំងឺដែលកំពុងកើត មាននៅក្នុងប្រទេស និងទីកន្លែងកំពុងកើត ។



*ការរាយការណ៍របស់ភ្នាក់ងារសុខភាពសត្វភូមិ ក្នុងកំឡុងពេលប្រជុំប្រចាំខែ គឺមានសារៈសំខាន់ណាស់ក្នុងការជួយគូផែនទីពីចលនាជំងឺនៅក្នុងប្រទេស*

ការគ្រប់គ្រងលើចរាចរសត្វ និងការទប់ស្កាត់ជំងឺកុំឱ្យឆ្លងទៅភូមិ ឬឃុំជិតខាងមិនមាន ភាព-ងាយស្រួលទេ។ ជាពិសេសនៅពេលមានផ្ទុះជំងឺឆ្លងរាតត្បាត ដូចជាអុតក្តាម នោះភ្នាក់ងារសុខភាពសត្វភូមិតែឯងមិនអាចគ្រប់គ្រងបានទេ ដូចនេះគេត្រូវតែរាយការណ៍ជាបន្ទាន់ទៅកាន់ពេទ្យសត្វស្រុក ដើម្បីសូមការជួយគាំទ្រ លើៈ

- ការចាត់វិធានការសមស្រប
- ការជូនដំណឹងដល់ភូមិ ឃុំជិតខាង...
- ការយកសំណាកចាំបាច់
- ការជូនដំណឹងដល់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត និង វិទ្យាស្ថាន ជាតិស្រាវជ្រាវបសុព្យាបាល ។






*ក្នុងករណីសង្ស័យពីជំងឺអុតក្តាម ឬផ្តាសាយបក្សី ភ្នាក់ងារសុខភាពសត្វភូមិត្រូវតែរាយការណ៍ជាបន្ទាន់ ទៅកាន់ពេទ្យសត្វស្រុក ដោយកុំរង់ចាំដល់ពេលប្រជុំ*

ជំងឺឆ្លងរាតត្បាតគឺជាបញ្ហាជាសាធារណៈ ព្រោះវាបង្កផលប៉ះពាល់លើ ៖

- បរិមាណ និងគុណភាពចំណីអាហាររបស់មនុស្ស
- ប្រាក់ចំណូល និងប្រាក់សន្សំរបស់អ្នកភូមិ
- សុខភាពរបស់មនុស្ស

រចនាសម្ព័ន្ធ និងសេវាកម្មគ្រប់គ្រង ការពារ និងប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងរាតត្បាត ដែលមានប្រសិទ្ធភាពបំផុតគឺត្រូវមានរដ្ឋាភិបាល ពេទ្យសត្វស្រុក ការិយាល័យផលិតកម្ម និង បសុពេទ្យាបាលខេត្ត នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល/វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល ហើយបន្ថែមទៀតគឺ កសិករ ឬភ្នាក់ងារសុខភាពសត្វភូមិ ។

ក្នុងដំណើរការនេះ សំខាន់បំផុតទាមទារឱ្យភ្នាក់ងារសុខភាពសត្វភូមិធ្វើការរាយការណ៍ឱ្យបានទាន់ពេល ។



*គ្មានវិធានការទប់ស្កាត់ជំងឺរាតត្បាត ធ្វើឱ្យមានការបាត់បង់លុយកាក់ជាច្រើន!*

## ២.៥.៦. តាមដានការរាតត្បាតនៃជំងឺ

នៅពេលជំងឺឆ្លងរាតត្បាតកំពុងមានសកម្មភាពនៅក្នុងភូមិ សំខាន់ភ្នាក់ងារសុខភាពសត្វ ភូមិត្រូវបន្តរាយការណ៍ព័ត៌មានថ្មីៗដល់អ្នកភូមិជាប្រចាំដូចជា៖ ការរាតត្បាត សកម្មភាពទប់ស្កាត់ជំងឺ អនុសាសន៍ថ្មីៗ។ល។

ការតាមដានជាប់ និងការធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ គឺជាគន្លឹះដ៏ល្អក្នុងការសហការជាមួយកសិករ។

ជាមួយគ្នានោះដែរ ក្នុងករណីមានផ្ទុះជំងឺឆ្លងរាតត្បាតខ្លាំង សំខាន់ពេទ្យសត្វស្រុកត្រូវជូនដំណឹងដល់ភ្នាក់ងារសុខភាពភូមិនូវព័ត៌មាន និងដំណោះស្រាយថ្មីៗនៅក្នុងស្រុក។



*បន្ទាប់ពីបណ្តុះបណ្តាលឡើងវិញរយៈពេល ២ ឆ្នាំ ភ្នាក់ងារសុខភាពសត្វភូមិបានជួបប្រជុំជាមួយពេទ្យសត្វស្រុក និងការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្តជាប្រចាំ ជាហេតុធ្វើឱ្យពួកគេងាយស្រួលចែកចាយព័ត៌មាន*

# ៣_ប្រព័ន្ធព័ត៌មាន

## ៣_១_ អ្វីទៅជាប្រពន្ធ័ព័ត៌មាន?

ក្នុងប្រព័ន្ធព័ត៌មានរួមមានមនុស្ស និងកំព្យូទ័ររួមជាមួយនឹងកម្មវិធីជាក់លាក់។ ក្នុងនោះសម្រាប់មនុស្សមានដូចជា :

១- អ្នកដែលប្រមូលទិន្នន័យរាល់ថ្ងៃនៅតាមភូមិ គឺភ្នាក់ងារសុខភាពសត្វភូមិ

២- អ្នកដែលប្រមូលផ្តុំទិន្នន័យនៅតាមភូមិដាក់បញ្ចូលគ្នា គឺពេទ្យសត្វស្រុក

៣- អ្នកដែលទទួលខុសត្រូវបញ្ចូលទិន្នន័យគឺ ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត

៤- អ្នកដែលទទួលខុសត្រូវវិភាគទិន្នន័យ គឺវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

*ប្រព័ន្ធព័ត៌មាននឹងមិនអាចដំណើរការបានល្អទេប្រសិន*
*បើគ្មានការចូលរួមពីភ្នាក់ងារសុខភាពសត្វភូមិ!*





*រយៈចំងាយនៃប្រព័ន្ធព័ត៌មានជំងឺអុតក្តាមពីភូមិទៅកាន់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល (NaVRI) មានរយៈចំងាយវែង*

## ៣.២. ហេតុអ្វីបានជាគេត្រូវការប្រព័ន្ធព័ត៌មាន?

មូលហេតុត្រូវការប្រព័ន្ធព័តិមានព្រោះក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល/វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលត្រូវការដើម្បី :

- ជូនដំណឹងត្រឡប់ទៅភូមិវិញតាមរយៈការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត ពីគ្រោះមហន្តរាយរបស់ជំងឺឆ្លងរាតត្បាត
- រៀបចំផែនការ និងចាត់វិធានការអនុវត្តកម្មវិធីទប់ស្កាត់ជំងឺ
- ជូនដំណឹងដល់អង្គការអន្តរជាតិដូចជា អង្គការសុខភាពសត្វពិភពលោក (OIE) និង អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) ពីដំណោះស្រាយលើ បញ្ហាជំងឺក្នុងប្រទេសកម្ពុជា។



*ភ្នាក់ងារសុខភាពសត្វភូមិស្នើសុំឱ្យមានការផ្តល់ព័ត៌មានថ្មីៗពីសកម្មភាពរបស់ជំងឺទើបកើតថ្មីៗ...*

## ៣.៣. ព័ត៌មាននៅថ្នាក់ភូមិ

ឧទាហរណ៍ ៖

នាដើមរដូវភ្លៀង ភ្នាក់ងារសុខភាពសត្វភូមិមានការរវល់ ព្រោះជ្រូករបស់កសិករ ៣ នាក់មានបញ្ហា ដូចជាមិនស៊ីចំណី និងមានចំណុចជាំពណ៌ស្វាយក្រោមស្បែក ។

ដូចនេះភ្នាក់ងារសុខភាពសត្វភូមិ បានចុះទៅ ៖

- ពិនិត្យលើខ្លួនសត្វទាំងមូល ហើយកំណត់ថាជាជំងឺប៉េស្ត
- ព្យាបាល ហើយសរសេរកំណត់ត្រាករណីនេះបញ្ចូលទៅក្នុងសៀវភៅ ដូចជា ថ្ងៃខែសត្វឈឺ ចំនួនជ្រូកឈឺ រោគសញ្ញា...



*ប្រព័ន្ធព័ត៌មានត្រូវការទិន្នន័យពិត ដូចនេះ អ្វីដែលសង្កេតឃើញត្រូវសរសេរទៅក្នុងសៀវភៅ (ព្រោះភ្នាក់ងារសុខភាពសត្វភូមិមិនអាចចងចាំបានយូររហូតដល់ ២-៣ អាទិត្យនោះទេ)*

ព័ត៌មានសំខាន់ៗដែលត្រូវតែរាយការណ៍ទៅកាន់ពេទ្យសត្វស្រុក មានដូចជា៖

- ថ្ងៃខែផ្ទុះជំងឺ
- ទីតាំង ( ឈ្មោះភូមិ និងឃុំ)
- ចំនួនសត្វឈឺ និងស្លាប់
- ចំនួសត្វសរុបក្នុងហ្វូង
- ភេទសត្វដែលទទួលរង ( ឈ្មោល ញី ឬចំរុះ)
- អាយុ ( សត្វក្មេង ឬពេញវ័យ)
- រោគសញ្ញាគ្លីនិច ។



*ក្នុងឆ្នាំ ២០០៩ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល (NaVRI) អាចគូសផែនទីតំណាងជំងឺ ដូចជាករណីជំងឺប៉េស្ត (ពណ៌បៃតង) និងអុតក្តាម (ពណ៌ក្រហម) ដែលកើតមាននៅខេត្តតាកែវ អរគុណចំពោះរបាយការណ៍ដ៏ច្បាស់លាស់ !*

## ៣.៤. ព័ត៌មាននៅថ្នាក់ស្រុក

- ភ្នាក់ងារសុខភាពសត្វភូមិចូលរួមប្រជុំប្រចាំខែនៅការិយាល័យពេទ្យសត្វស្រុក ហើយ នឹងរាយការណ៍ពីករណីជំងឺប៉េស្តជ្រូក (CSF)...
- ភ្នាក់ងារសុខភាពសត្វភូមិទាំងអស់ត្រូវតែរាយការណ៍ពីស្ថានភាពជំងឺដែលកើតមាន ក្នុងខែកន្លងមក
- ពេទ្យសត្វស្រុកធ្វើការកត់ត្រាសង្ខេបបញ្ចូលក្នុងតារាងរាល់ករណីជំងឺឆ្លងរាតត្បាតក្នុងស្រុកដែលបានរាយការណ៍ ។



*ភ្នាក់ងារសុខភាពសត្វភូមិចូល រួមប្រជុំប្រចាំខែ នៅការិយា ល័យពេទ្យសត្វស្រុក*

## ៣.៥. ព័ត៌មាននៅថ្នាក់ខេត្ត

- ពេទ្យសត្វស្រុកចូលរួមប្រជុំប្រចាំខែនៅការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត
- ពេទ្យសត្វស្រុកលើកជាអនុសាសន៍ និងផ្តល់ទំរង់ថតចម្លង ដែលបំពេញជាមួយភ្នាក់ងារសុខភាពសត្វភូមិ
- បុគ្គលិកការិយាល័យពេទ្យសត្វខេត្ត ដែលទទួលបានការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នឹងបញ្ចូលរាល់ទិន្នន័យទៅក្នុងកុំព្យូទ័រតាមកម្មវិធីមួយហៅថា TAD info system (ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដោយអង្គការ FAO ដើម្បីជាការសំរួលដល់ការធ្វើរបាយការណ៍) ។

*ពេទ្យសត្វស្រុកអាចទទួលព័ត៌មានពីការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្តពីស្ថានភាពនៅក្នុងខេត្ត និង ប្រទេសទាំងមូល!*



*បុគ្គលិកការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត បញ្ចូលទិន្នន័យពីការអង្កេតតាមដាននទៅក្នុងកុំព្យូទ័រ ដោយប្រើកម្មវិធី (TAD)*

## ៣.៦. ព័ត៌មាននៅថ្នាក់ជាតិ

- ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត ធ្វើរបាយការណ៍ប្រចាំខែផ្ញើរទៅវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល ដែលជាអ្នកទទួលខុសត្រូវក្នុងនាយកដ្ឋាន ដើម្បីប្រមូលរាល់ទិន្នន័យស្តីពីសកម្មភាពជំងឺក្នុងប្រទេសកម្ពុជា

- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលគឺជាថ្នាក់កណ្តាល (បេះដូង) នៃការអង្កេតតាមដានជំងឺសត្វនៅកម្ពុជា
- បច្ចុប្បន្ននេះការិយាល័យពេទ្យសត្វខេត្តអាចបញ្ជូនព័ត៌មានទាំងនេះតាមអ៊ិនធឺនែត ជាមួយកម្មវិធី TAD info ។




*វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលមានទីតាំងនៅក្នុងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល នាក្រុងភ្នំពេញ*

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលត្រូវបន្ថែមព័ត៌មានខ្លះទៅក្នុងប្រព័ន្ធព័ត៌មាន ដើម្បី បង្ហាញរូបភាពច្បាស់លាស់ពីស្ថានភាពនៅក្នុងប្រទេសមានដូចជា :

- លទ្ធផលរោគវិនិច្ឆ័យនៅតាមភូមិ និងតេស្តឈាម និងលទ្ធផលពីសកម្មភាពផ្សេងៗ ដូចជាការអង្កេតនៅទីសត្តឃាដ និងទីផ្សារ
- ការដឹងច្បាស់លាស់ពីទីតាំងភូមិសាស្ត្ររបស់កសិដ្ឋាន ឬភូមិមានផ្ទុះជំងឺគឺដើម្បីងាយស្រួលគូរផែនទី
- លទ្ធផលវិភាគនៅមន្ទីរពិសោធន៍ (ឈាមសត្វមានជំងឺ) ។



វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល
មានបំពាក់សំភារៈមន្ទីរពិសោធន៍ ដើម្ប
ធ្វើការវិភាគ និងប្រកាសពីជំងឺឆ្លង
រាតត្បាត ដូចជាផ្តាសាយបក្សី អុតក្តា
ប៉េស្តជ្រូក... លទ្ធផលវិភាគឃើញត្រូ
បានគេបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មាន

វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលត្រូវតែផ្តល់ព័ត៌មានច្បាស់លាស់ និងថ្មីៗស្តីពីស្ថាន ភា
ក្នុងប្រទេសទៅកាន់ :

- នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីស
ចិត្តធ្វើយុទ្ធនាការចាក់វ៉ាក់សាំង ហាមឃាត់ចរាចរសត្វ ។ល។
- ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត ដើម្បីឱ្យប្រាកដថាពេទ្យសត្វស្រុក និងភ្នា
សុខភាពសត្វភូមិ ដែលកំពុងធ្វើការនៅតាមភូមិមានការយល់ដឹងច្បាស់ពីគ្រោះ មហន្តរា
ជំងឺទាំងនោះ និងរាយការណ៍បន្ត។



វិទ្យាស្ថានជាតិស្រាវជ្រាវ បសុព្យាបាល
ជាកន្លែងមួយងាយ ស្រួលទំនាក់ទំនង
តួនាទីសំខាន់ គឺប្រមូល និងវិភាគព័ត៌មា
និង ជូនដំណឹងដល់អ្នកពាក់ព័ន្ធនឹង
សុខភាពសត្វទាំងអស់




ករណីលើកលែង: ក្នុងករណីមានជំងឺផ្តាសាយបក្សីផ្ទុះឡើង ភ្នាក់ងារសុខភាពសត្វភូមិត្រូវទូរសព្ទរាយការណ៍ផ្ទាល់ទៅកាន់លេខបន្ទាន់!

- ភ្នាក់ងារសុខភាពសត្វភូមិរាយការណ៍ទៅកាន់ពេទ្យសត្វស្រុក
- ពេទ្យសត្វស្រុករាយការណ៍ទៅកាន់ការិយាល័យផលិតកម្ម និង បសុព្យាបាលខេត្ត
- ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត រាយការណ៍ទៅកាន់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

## ៣.៧. ប្រពន្ធ័ព័ត៌មាននៅថ្នាក់អន្តរជាតិ

- កម្ពុជាជាសមាជិករបស់អង្គការសុខភាពសត្វពិភពលោក (OIE) ហើយត្រូវតែបញ្ជូនព័ត៌មានទៅកាន់អង្គការនេះ
- អង្គការសុខភាពសត្វពិភពលោក (OIE) ជាអង្គការអន្តរជាតិដែលទទួលខុសត្រូវលើការអង្កេតតាមដាន និងប្រមូលព័ត៌មានស្តីពីជំងឺឆ្លងរាតត្បាតនៅទូទាំងពិភពលោក

- អង្គការសុខភាពសត្វពិភពលោក (OIE) ផ្តល់ជាអនុសាសន៍ ផែនទីជូនដល់សមាជិកទាំងអ
(១៧៣ ប្រទេស) ពីចលនារបស់ជំងឺឆ្លងរាតត្បាតទូទាំងពិភពលោក
- កម្ពុជាអាចដឹងពីស្ថានភាពជំងឺនៅថៃ វៀតណាម ឡាវ... ហើយអាចការពារគ្រោះថ្នាក់ទាំ
នេះបាន ។



*ផែនទីបោះពុម្ពដោយអង្គការសុខភាពសត្វពិភពលោក (OIE) ស្តីពីស្ថានភាពជំងឺអុតក្តាម (ប្រភេទ អា) ក្នុងតំបន់*

## ៣-៨- ប្រព័ន្ធព័ត៌មាន (ផ្លូវកាត់)

### ករណីជំងឺអុតក្តាម (FMD)

- ជំងឺអុតក្តាមគឺជាជំងឺឆ្លងរាតត្បាតខ្លាំង និងបង្កផលប៉ះពាល់ខ្លាំងលើសេដ្ឋកិច្ច
- ភ្នាក់ងារសុខភាពសត្វភូមិត្រូវរាយការណ៍ជាបន្ទាន់ដល់ពេទ្យសត្វស្រុក ហើយមិនត្រូវដំអ
រងចាំរហូតដល់ពេលប្រជុំឡើយ
- ប្រសិនបើមិនមានការចាក់វ៉ាក់សាំងទេ នោះជំងឺនឹងអាចរាតត្បាតក្នុងកំឡុងពេលពី ២-
ថ្ងៃ បន្ទាប់ ។

ភ្នាក់ងារសុខភាពសត្វភូមិជួប ឬទូរស័ព្ទទៅកាន់ពេទ្យសត្វស្រុកជាបន្ទាន់
បន្ទាប់ពីកំណត់ថាជាជំងឺអុតក្តាម !



ការចាក់វ៉ាក់សាំងដល់គោនៅភូមិជិតខាង មុនពេលវីរុសទៅដល់ នាំឱ្យគេការពារសត្វបាន

**ករណីជំងឺផ្តាសាយបក្សី (Bird Flu)**

- ពេលសង្ស័យថាមានជំងឺផ្តាសាយបក្សី គេត្រូវរាយការណ៍ផ្ទាល់ទៅកាន់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលជាបន្ទាន់
- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលមានលេខបន្ទាន់ ហើយភ្នាក់ងារសុខភាពសត្វភូមិអាចទូរស័ព្ទរាល់ពេលរាល់ថ្ងៃ មានដូចខាងក្រោម :
    - ០១២ ៨៣៣ ៧៩៥
    - ០១២ ២១៤ ៩៧០



ឥឡូវនេះស្ថានភាពជំងឺហាក់ដូចជាស្ងប់ស្ងាត់ តែភ្នាក់ងារសុខភាពសត្វភូមិ មិនត្រូវមើលស្រាលពីគ្រោះថ្នាក់នៃជំងឺផ្តាសាយបក្សីឡើយ ហើយត្រូវតែរាយការណ៍ជាបន្ទាន់!

*សូមចងចាំថា: រាល់ព័ត៌មានត្រូវបានបញ្ជូនទៅវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលឱ្យ ប
ានទាន់ពេលវេលា ដូចនេះសូមកុំស្ទាក់ស្ទើរក្នុងការទំនាក់ទំនងទូរស័ព្ទលេខបន្ទាន់ ។*

## ៤_ ការអង្កេតតាមដាន + ប្រព័ន្ធព័ត៌មាន = ការទទួលខុសត្រូវ

### ៤_១_ មូលដ្ឋានគ្រឹះ

- ប្រសិនបើគេសង្កេតឃើញជំងឺទាន់ពេល នោះគេអាចមានលទ្ធភាពបញ្ឈប់ការរាតត្បាតរប ជំងឺ និងអាចជួយកាត់បន្ថយគ្រោះថ្នាក់ទៅលើផលិតកម្មសត្វ ដូចជាខាតបង់លុយកាក់ និ គ្រោះថ្នាក់សុខភាពមនុស្ស ។
- នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល/ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នក ទទួលខុសត្រូវក្នុងការគ្រប់គ្រងបញ្ហានេះឱ្យបានមុនសភាពការណ៍ ។

*ការអង្កេតតាមដានល្អ គឺបានមកពីការអង្កេតទាន់សភាពការណ៍!*
*ប្រព័ន្ធព័ត៌មានដែលមានប្រសិទ្ធភាពជួយសំរួលដល់រដ្ឋាភិបាលឱ្យឆ្លើយតបទាន់សភាពការណ៍!*



*ការឆ្លើយតបទាន់សភាពការណ៍លើការការពារជំងឺ*
*អុតក្តាមគោមានសារៈសំខាន់ដល់សន្តិសុខស្បៀងនៅកម្ពុជា*

### ៤_២_ អ្នកណាជាអ្នកចាត់វិធានការ?

- ប្រកាស ជាអនុសាសន៍ដែលធ្វើឡើងដោយថ្នាក់ក្រសួង

- តែការអនុវត្តន៍ត្រូវបានធ្វើឡើងដោយៈ
  - វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលធ្វើការអង្កេត
  - ពេទ្យសត្វខេត្ត/ស្រុកត្រួតពិនិត្យ លើចរាចរសត្វ និងវិធានការបសុពេទ្យ
  - ភ្នាក់ងារសុខភាពសត្វភូមិ អនុវត្តវិធានការជីវសុវត្ថិភាពនៅតាមមូលដ្ឋាន ។



*តួនាទីរបស់ភ្នាក់ងារសុខភាពសត្វភូមិក្នុងពេលមានផ្ទុះជំងឺផ្តាសាយបក្សីគឺពិតតែមានសារៈសំខាន់ ពួកគេជាអ្នកទទួលខុសត្រូវអនុវត្តភ្លាមៗ ព្រោះពួកគេទទួលបានការបណ្តុះបណ្តាល និងជាអ្នករស់នៅក្នុងភូមិ*

## ៤.៣. តើមានសកម្មភាពអ្វីខ្លះ?

### ៤.៣.១. យុទ្ធនាការផ្តល់ព័ត៌មានៈ

នៅពេលមានជំងឺឆ្លងរាតត្បាតបង្កគ្រោះថ្នាក់ខ្លាំង រាជរដ្ឋាភិបាលសម្រេចចេញយុទ្ធនាការផ្តល់ព័ត៌មានស្តីពីគ្រោះថ្នាក់ និងវិធានការការពារតាម ៖

- ទូរទស្សន៍
- ការចាក់ផ្សាយតាមវិទ្យុ
- កាសែត

- ការប្រជុំផ្តល់ព័ត៌មាន
- ការចែកខិត្តប័ណ្ណផ្សព្វផ្សាយទៅកាន់តំបន់គោលដៅ
- ការចែកក្រដាស់បិទផ្សព្វផ្សាយដល់អ្នកភូមិ...។



*ការចែកក្រដាសបិទដល់អ្នកភូមិ ដើម្បីផ្សព្វផ្សាយពីគ្រោះថ្នាក់ជំងឺអុតក្តាម។ យុទ្ធនាការផ្តល់ព័ត៌មាន អាចត្រូវបានគេរៀបចំធ្វើនៅក្នុងពេលមានអង្កេតតាមដាន និងប្រព័ន្ធព័ត៌មាន នោះគឺជាកិច្ចការដ៏ល្អមួយ*



*ផ្ទាំងរូបភាពផ្សព្វផ្សាយពីជំងឺ ផ្តាសាយបក្សី ត្រូវបានគេចែកទៅឱ្យឈ្មួញលក់មាន់*



*ការប្រជុំផ្តល់ព័ត៌មាន ដល់អ្នកភូមិ*

## ៤.៣.២. ការអង្កេតតាមដាន (១)

នៅពេលមានជំងឺផ្ទុះឡើងនៅក្នុងភូមិ សំខាន់គេត្រូវដឹងពីប្រភព និងផ្លូវនៃការរាតត្បាត ដូចនេះ គេត្រូវធ្វើការអង្កេតតាមដាន។

ក្រុមពេទ្យសត្វខេត្ត ឬក្រុមសិក្សាជំងឺឆ្លងរាតត្បាតរបស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នឹងចុះទៅដល់ភូមិដើម្បីសំភាសន៍អ្នកភូមិ ប្រមូលសំណាក ដើម្បីសិក្សាពីជំងឺឱ្យកាន់តែច្បាស់។

*ការយល់ដឹងច្បាស់លាស់ពីការរាតត្បាតជំងឺគឺស្មើរនឹងការការពារបានល្អ !*



*ការអង្កេតតាមដានជំងឺនៅក្នុង ភូមិ ចាប់ផ្តើមឡើងដោយការសំភាសន៍កសិករ។ ការអង្កេតត្រឹមត្រូវគឺត្រូវមានការសម្រប សម្រួលពីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បន្ទាប់ពីគេជូនដំណឹងពីសង្កេត ឃើញមានជំងឺ*

## ៤.៣.២. ការអង្កេតតាមដាន (២)

- ជួនកាលសត្វខ្លះជាអ្នកផ្ទុកមេរោគ តែពួកវាមិនឈឺទេ
- តែ "សត្វផ្ទុកជំងឺ" អាចធ្វើការចម្លងទៅសត្វផ្សេងទៀត
- វិទ្យាស្ថាជាតិស្រាវជ្រាវបសុព្យាបាលនឹងប្រមូលយកសំណាក ដើម្បីវិភាគរកមើលមេរោគលើ សត្វដែលមានសុខភាពល្អ តាមរយៈការធ្វើតេស្តឈាម។

*ការអង្កេតឃើញដំបូងតាមរយៈការអង្កេតតាមដានល្អ រួមនឹងប្រព័ន្ធព័ត៌មានមានប្រសិទ្ធ ភាពនឹងជួយសំរួលដល់ការអង្កេតតាមដាន។*

*ទាមើលទៅមានសុខភាពល្អ តែវាអាចផ្ទុក វីរុស $H_5N_1$ ហើយអាចធ្វើការចម្លងទៅមាន់។ វិទ្យាស្ថានជាតិ ស្រាវជ្រាវបសុព្យាបាល នឹងយកឈាមពីទាដើម្បី វិភាគរកមើលវីរុស តែ២ សប្តាហ៍ ក្រោយពេលផ្ទុះជំងឺវីរុស នឹងរលាយបាត់។*



## ៤.៣.៣. ហាមឃាត់ចរាចរសត្វ (១)

ការធ្វើចរាចរសត្វឈឺគឺជាសកម្មភាពមួយដែលធ្វើឱ្យមានការរាតត្បាតជំងឺដ៏ខ្លាំងក្លា។ ការហាមឃាត់ការធ្វើចរាចរសត្វក្នុងកំឡុងពេលផ្ទុះជំងឺគឺជាវិធានការការពារ និងទប់ស្កាត់ការឆ្លងរាតត្បាតរបស់ជំងឺដ៏មានប្រសិទ្ធភាពមួយ ដូចនេះ :

- ភ្នាក់ងារសុខភាពសត្វភូមិត្រូវពន្យល់ដល់អ្នកភូមិកុំឱ្យធ្វើចរាចរសត្វក្នុងពេលមានផ្ទុះជំងឺ ឆ្លងរាតត្បាត
- ភ្នាក់ងារសុខភាពសត្វភូមិ និងប្រធានភូមិអាចហាមឃាត់មិនឱ្យឈ្មួញកណ្តាល ឬអ្នកបរទេះគោចូលមកក្នុងភូមិ។



*គោអាចសាយភាយវីរុសអុតក្តាមតាមភូមិ បើទោះជាក្នុងដំណាក់កាលសម្ងំក៏ដោយ ដូចនេះប្រធានភូមិអាចចាត់វិធានការបានសមស្រប ប្រសិនបើមានដំណឹងមកដល់ទាន់ពេល*

**រដ្ឋាភិបាលអាចចេញប្រកាស :**

- ហាមឃាត់ចរាចរសត្វដូចជា:
  - គោក្នុងករណីផ្ទុះជំងឺអុតក្តាម
  - មាន់ក្នុងករណីមានផ្ទុះជំងឺផ្តាសាយបក្សី
- រៀបចំត្រួតពិនិត្យចរាចរសត្វ ដូចនេះមន្ត្រីពេទ្យសត្វត្រូវប្រាកដថាឈ្មួញកណ្តាលមិនបានដឹកជញ្ជូនសត្វឈឺ

- ការហាមឃាត់ ឬត្រួតពិនិត្យចរាចរសត្វអាចធ្វើនៅ
    - ព្រំប្រទល់ខេត្ត
    - ព្រំប្រទល់ប្រទេស




*នៅចំណុចត្រួតពិនិត្យ មន្ត្រីពេទ្យសត្វអាចត្រួតពិនិត្យចរាចរសត្វពីប្រទេសជិតខាង វាជាការទទួលខុសត្រូវលើប្រព័ន្ធព័ត៌មានល្អ*

## ៤.៣.៤. យុទ្ធនាការចាក់វ៉ាក់សាំង

ជំងឺសត្វខ្លះអាចត្រូវបានបញ្ឈប់ ប្រសិនបើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាយកផលិតកម្ម និងបសុព្យាបាលអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងជាបន្ទាន់ បន្ទាប់ពីសង្កេតឃើញសត្វឈឺ។ ពេទ្យសត្វខេត្ត/ស្រុកជាអ្នកអនុវត្តលើយុទ្ធនាការចាក់វ៉ាក់សាំងដោយចាក់ជារង្វង់ព័ទ្ធជុំវិញភូមិផ្ទុះជំងឺ ឧទាហរណ៍ ដូចជា ជំងឺអុតក្តាម ហើយនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ត្រូវមានវ៉ាក់សាំងទ្រីវ៉ាឡង់សមស្របដើម្បីបញ្ឈប់សកម្មភាពរាតត្បាតនេះ។

យុទ្ធនាការចាក់វ៉ាក់សាំងខ្លះត្រូវបានរៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង នាយកផលិតកម្ម និងបសុព្យាបាលផ្ទាល់ ជាពិសេសក្នុងតំបន់ដែលទទួលគ្រោះថ្នាក់របស់ជំងឺឆ្លងរាតត្បាតធ្ងន់ធ្ងរជាប្រចាំ ដូចជាជំងឺសារទឹក។




*ប្រព័ន្ធផ្តល់ព័ត៌មានល្អគឺ មានសារៈសំខាន់ណាស់ សម្រាប់ដឹងពីតំបន់ដែលមានគ្រោះថ្នាក់ ដោយសារជំងឺសារទឹកធ្ងន់ធ្ងរ និងដើម្បីរៀបចំយុទ្ធនាការចាក់វ៉ាក់សាំង ព្រោះគេគ្មានវ៉ាក់សាំងបំរុងគ្រប់គ្រាន់សម្រាប់ប្រទេសទាំងមូលនោះទេ!*

## ៤-៣-៥- សម្លាប់សត្វចោល

ជំងឺខ្លះមានការឆ្លងរាតត្បាតខ្លាំង ហើយមិនអាចមានវ៉ាក់សាំងការពារ ដូចនេះគេត្រូវធ្វើការសម្លាប់សត្វចោល ។ វិធីសាស្ត្រដ៏ល្អសម្រាប់បញ្ឈប់ជំងឺនេះគឺត្រូវតែសម្លាប់សត្វដែលឈឺ ឬសត្វដែលប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ (ក្នុងហ្វូងជាមួយ) ព្រោះពួកវាទំនងជាមានមេរោគ សម្ងំ ។

ការសម្រេចចិត្តសម្លាប់សត្វចោលនេះធ្វើឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ។



*ប្រសិទ្ធភាពនៃការសម្លាប់សត្វចោលមានកម្រិត ហើយអាចមានលទ្ធភាពបញ្ឈប់ជំងឺបានតែក្នុងករណីជំងឺចាប់ផ្តើមដំបូងប៉ុណ្ណោះ ហើយរួមជាមួយនឹងការមានព័ត៌មានច្បាស់លាស់ និង ឆាប់រហ័សទៅដល់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលប៉ុណ្ណោះ!*

## ៥. បញ្ហាដែលភ្នាក់ងារសុខភាពសត្វភូមិប្រឈមមុខក្នុងពេលអនុវត្តការអង្កេតតាមដាន/រាយការណ៍

### ៥.១. ខ្វះការរាយការណ៍

#### ៥.១.១. កសិករមិនរាយការណ៍ដល់ភ្នាក់ងារសុខភាពសត្វភូមិ ៖

បញ្ហានេះអាចកើតឡើងដោយសារ ៖

- ពួកគេធ្លាប់ជួបប្រទះបញ្ហាសត្វស្លាប់ច្រើន ជាពិសេសមាន់ (ជួនកាលពួកគាត់មិនជឿ ថា ជំងឺផ្តាសាយបក្សីអាចសម្លាប់មនុស្សនោះទេ)
- ពួកគេមិនជឿថាភ្នាក់ងារសុខភាពសត្វភូមិអាចជួយសំរាលបញ្ហាជំងឺបានទេ (ពួកគេមិនទុកចិត្ត ព្រោះភ្នាក់ងារសុខភាពសត្វភូមិមិនមានលទ្ធភាពគ្រប់គ្រាន់)
- នៅតាមភូមិ ពួកគេមិនដែលគិតពីតម្លៃនៃការបាត់បង់ក្នុងពេលសត្វឈឺឡើយ ។



*ជាទូទៅ ៩០ % នៃអ្នកចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារគឺមានអត្រាស្លាប់របស់មាន់ខ្ពស់ ហើយធ្វើឱ្យខាតបង់លុយកាក់។ ហេតុអ្វីបានជាគេមិនរាយការណ៍ ?*

#### ៥.១.២. កសិករលាក់ព័ត៌មាន៖

មូលហេតុដែលនាំឱ្យកសិករលាក់ព័តិមាន ព្រោះ ៖

- ពួកគាត់មិនចង់ឱ្យអ្នកភូមិផ្សេងទៀតដឹងពីការផ្ទុះជំងឺនៅក្នុងកសិដ្ឋានរបស់ពួកគាត់
- ពួកគាត់ចង់លក់សត្វឱ្យបានឆាប់នៅពេលសត្វផ្សេងទៀតមិនទាន់ឈឺ ហើយគាត់ខ្លាចឈ្មួញបញ្ចុះតម្លៃ ជាពិសេសជំងឺប៉េស្តជ្រូក

- ពួកគាត់ខ្លាចមានបញ្ហាជាមួយអាជ្ញាធរក្រោយពេលរាយការណ៍ ដូចជាការសម្លាប់សត្វ ចោលពេលមានផ្ទុះជំងឺផ្តាសាយបក្សី ។



*កសិករមានអំណួតនៅពេលសត្វធំធាត់ និងមានសុខភាពល្អ គឺមិនមែនសត្វឈឺនោះទេ!*

## ៥.១.៣. ភ្នាក់ងារសុខភាពសត្វភូមិស្ទាក់ស្ទើរក្នុងការរាយការណ៍

- ភ្នាក់ងារសុខភាពសត្វភូមិ ដឹងពីពាក្យចចាមអារាមពីសកម្មភាពរាតត្បាតជំងឺក្នុងភូមិ តែពួកគាត់គ្មានផលប្រយោជន៍ ហើយមិនចង់ចំណាយពេលវេលា ឬសាំងឥតប្រយោជន៍ ដើម្បីអង្កេតបន្តទៀត
- ភ្នាក់ងារសុខភាពសត្វភូមិមិនយល់ច្បាស់ពីសារៈសំខាន់នៃការរាយការណ៍ពីជំងឺ
- ប្រសិនបើរាយការណ៍ពីករណីជំងឺច្រើនពេកនៅក្នុងភូមិ តើមានន័យថាភ្នាក់ងារសុខភាពសត្វភូមិអសមត្ថភាពឬ?
- ភ្នាក់ងារសុខភាពសត្វភូមិខ្លាចមានផលប៉ះពាល់ ឬបញ្ហាជាមួយពេទ្យសត្វស្រុក ឬខេត្ត នៅពេលទូរស័ព្ទរាយការណ៍ទៅលេខបន្ទាន់ពីជំងឺឆ្លងរាតត្បាតដូចជា ផ្តាសាយបក្សី អុតក្តាម។



ភ្នាក់ងារសុខភាពសត្វមានការរវល់ ពួកគេជាអ្នកព្យាបាលសត្វ តែក៏ជាកសិករផងដែរ ដូចនេះត្រូវការពេលវេលាថែរក្សាគ្រួសារទាំងមូល

## ៥.១.៤. ស្ថានភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិក្នុងភូមិ

ស្ថានភាពរបស់ភ្នាក់ងារសុខភាពសត្វភូមិ គឺជាបញ្ហាចោទមួយ ព្រោះថា ៖

- ភ្នាក់ងាសុខភាពសត្វភូមិរស់នៅក្នុងភូមិ ដូចនេះពួកគាត់ក៏ជាកសិករដែរ
- ភ្នាក់ងារសុខភាពសត្វភូមិអាចរកចំណូលបានពីសកម្មភាពសេវាកម្មរបស់ពួកគាត់ ជា ពិសេស ប្រសិនបើអ្នកភូមិនៅតែទូរស័ព្ទហៅពួកគាត់ឱ្យព្យាបាលសត្វ
- ភ្នាក់ងារសុខភាពសត្វភូមិមិនមានអំណាចប្រឈមមុខជាមួយអ្នកភូមិ ឬប្រធានភូមិបានឡើយ ។

*ភ្នាក់ងារសុខភាពសត្វភូមិមិនអាចរាយការណ៍ប្រឆាំងនឹងបំណងរបស់អ្នកភូមិឡើយ!*



ការចងមិត្តភាពជាមួយអ្នកភូមិគឺជាកិច្ចការដ៏សំខាន់សម្រាប់ភ្នាក់ងារសុខភាពសត្វភូមិ

### ៥.១.៥. លំបាកក្នុងការធ្វើរោគវិនិច្ឆ័យ

- ជំងឺខ្លះបង្ហាញរោគសញ្ញាសាមញ្ញ (អុតក្តាម) ហើយខ្លះទៀតមានការលំបាកក្នុងការធ្វើរោគ វិនិច្ឆ័យ (ប៉េស្តជ្រូក)
- ក្នុងករណីមានអត្រាស្លាប់ស្រួចស្រាវ ជាទូទៅមិនមានរោគសញ្ញាលេចឡើងឡើយ ដូចជាជំ ផ្តាសាយបក្សី
- វាមិនមែនជាការធម្មតាទេសម្រាប់ការពិនិត្យសត្វស្លាប់ ព្រោះពួកគេមិនបានព្យាបាល រ៉ែ ត្រូវធ្វើរោគវិនិច្ឆ័យ ឧទាហរណ៍ដូចជាជំងឺបូសខ្យល់
- ភ្នាក់ងារសុខភាពសត្វភូមិមិនអាចវះកាត់សាកសពសត្វឡើយ ព្រោះកសិករចង់លក់សត្វទាំ មូលទៅឱ្យឈ្មួញកណ្តាល ។



*ជំងឺប៉េស្តជ្រូក ជួនកាលមានតែរោគសញ្ញាគ្រុនក្តៅខ្លាំង និងឈឺយូរថ្ងៃ។ ការវះកាត់សាកសពសត្វធ្វើឱ្យគេមើលឃើញនូវស្នាមអុចៗជាំឈាមនៅតម្រងនោម។*

### ៥.១.៦. កម្សោយខាងប្រព័ន្ធព័ត៌មាន

- ភ្នាក់ងារសុខភាពសត្វភូមិទទួលបានអនុសាសន៍ត្រឡប់មកវិញបានតិចតួចពីថ្នាក់ ស្រុក/ខេ ពីការអង្កេតតាមដាន
- ភ្នាក់ងារសុខភាពសត្វភូមិមិនសប្បាយចិត្តនឹងការរាយការណ៍ ប្រសិនបើពួកគេមិនឃើញមា ប្រសិទ្ធភាពលើការអង្កេតតាមដានតបមកដល់ថ្នាក់ភូមិវិញនោះ
- ប្រសិនបើរបាយការណ៍ពីការអង្កេតតាមដានមិនត្រូវបានគេប្រមូលជាប្រចាំទេ នោះសារៈ សំខាន់ពីការអង្កេតតាមដាន ក៏មិនច្បាស់លាស់ដែរ ។



*បន្ទាប់ពីប្រជុំប្រចាំខែ ពេទ្យសត្វស្រុកធ្វើការកត់ត្រាពីទិន្នន័យដែលទទួលបានពីភ្នាក់ងារសុខភាពសត្វភូមិ ដើម្បីរាយការណ៍ជូនការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត*

## ៥.២. ការអង្កេតតាមដាន/រាយការណ៍ដែលប្រសើរ

### ៥.២.១. ឥរិយាបទល្អរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ត្រូវឱ្យគេជឿទុកចិត្តថា ជាអ្នកមានជំនាញលើសុខភាពសត្វ ដូចនេះភ្នាក់ងារសុខភាព សត្វភូមិត្រូវសម្រេចជោគជ័យលើការព្យាបាលសត្វ
- បន្ទាប់ពីទទួលការបណ្តុះបណ្តាលឡើងវិញពីគម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប ភ្នាក់ងារសុខភាពសត្វភូមិទទួលបានចំណេះដឹងមូលដ្ឋានរឹងមាំលើការគ្រប់គ្រងសត្វ ។

*គោលជំហររបស់ភ្នាក់ងារសុខភាពសត្វភូមិត្រូវបានពង្រឹងឡើងវិញ ជាហេតុធ្វើកសិករមានជំនឿទុកចិត្ត ដូចនេះវាមានភាពងាយស្រួលបញ្ចុះបញ្ចូលអ្នកភូមិឱ្យជួយរាយការណ៍ !*



*ការព្យាបាលបានជោគជ័យគឺជាដំណាក់កាលសំខាន់ ក្នុងការទាក់ទាញកសិករឱ្យមានជំនឿទុកចិត្ត*

## ៥.២.២. ជំនាញក្នុងការធ្វើរោគវិនិច្ឆ័យជំងឺបានល្អ

- ការអង្កេតបានលឿនលើបញ្ហាជំងឺឆ្លងរាតត្បាត គឺជាលក្ខខណ្ឌសំខាន់សម្រាប់ការគ្រប់គ្រ ជំងឺ
- បន្ទាប់ពីបានបណ្តុះបណ្តាល និងមានជំនួយពីសៀវភៅបច្ចេកទេស ភ្នាក់ងារសុខភាពស ភូមិ មានលទ្ធភាពរឹងមាំក្នុងការត្រួតពិនិត្យសត្វ និង ធ្វើការប្រកាសរោគវិនិច្ឆ័យជំងឺបា ត្រឹមត្រូវ ។



*ការចូលរួមយ៉ាងសកម្មក្នុង កម្មវិធី បណ្តុះបណ្តាលឡើងវិញ ជួយពង្រឹង ដល់មូលដ្ឋានគ្រឹះ និងឥរិយាបទ ច្បាស់លាស់ក្នុងការកំណត់ជំងឺ*

## ៥.២.៣. ប្រព័ន្ធផ្តល់ព័ត៌មានបានល្អ

- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល បានធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកការិយាល័ ផលិតកម្ម និងបសុព្យាបាលខេត្ត ដូចនេះ TAD Info System ត្រូវបានប្រើប្រា ប្រកបដោយប្រសិទ្ធភាព
- ពេទ្យសត្វស្រុកត្រូវបានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល លើការអង្កេតតាមដានជំងឺ
- ពេទ្យសត្វស្រុកបានចូលរួមវគ្គបណ្តុះបណ្តាលពិសេសនៅភ្នំពេញ ស្តីពីការបំពេញទិន្នន័យ អង្កេតតាមដានជំងឺ ។

ភ្នាក់ងារសុខភាពសត្វភូមិនឹងរាយការណ៍កាន់តែប្រសើរ ប្រសិនបើរបាយការណ៍នេះត្រូវបាន មូលច្បាស់លាស់ និង បញ្ជូនទៅកាន់ការិយាល័យផលិតកម្ម និងបុព្យាបាលខេត្ត/វិទ្យា ស្ថានជា ស្រាវជ្រាវបសុព្យាបាល ហើយព្រមទាំងទទួលបានអនុសាសន៍ត្រឡប់មកវិញស្តីពីស្ថានភាពជំងឺ ។



*ទិន្នន័យត្រូវបានបញ្ចូលផ្ទាល់ទៅក្នុងកម្មវិធី TAD Info System ដើម្បីបញ្ជូនព័ត៌មាន និង វិភាគទិន្នន័យឱ្យកាន់តែលឿន*

## ៥.២.៤. សមាគម/ក្រុមភ្នាក់ងារសុខភាពសត្វភូមិ

- អំណាចរបស់ភ្នាក់ងារសុខភាពសត្វភូមិនឹងកើនឡើង ប្រសិនបើពួកគេធ្វើការរួមគ្នាជាក្រុម
- ដោយមានការគាំទ្រពីពេទ្យសត្វស្រុក និង អង្គការ AVSF ភ្នាក់ងារសុខភាពសត្វភូមិនឹងត្រូវជំរុញលើកទឹកចិត្តឱ្យបង្កើតក្រុមជាផ្លូវការ
- គម្រោងនឹងផ្តល់សំភារៈដើម្បីរៀបចំបន្ទប់ប្រជុំ សម្រាប់ក្រុមភ្នាក់ងារសុខភាពសត្វភូមិ នៅតាមការិយាល័យពេទ្យសត្វស្រុកគោលដៅនីមួយៗ ។

***ការអង្កេតតាមដាន និងការរាយការណ៍គឺជាការងារលំបាក ដូចនេះការធ្វើការរួមគ្នាជាក្រុម នឹងសំរួលដល់ទំនាក់ទំនងជាមួយអ្នកភូមិ និងអាជ្ញាធរ ។***



*បន្ទាប់ពីចូលរួមក្នុងក្រុមកសិករបាន ១ ឆ្នាំ (ខេត្តពោធិ៍សាត់) ពួកគេយល់ដឹងយ៉ាងច្បាស់ពីសារៈប្រយោជន៍នៃការធ្វើការរួមគ្នា*

# ៦-ការរំលឹកពីជំងឺមួយចំនួន ដែលត្រូវប្រកាសជូនដំណឹង

## ៦.១. ជំងឺផ្តាសាយបក្សី

### ក- សញ្ញាប្រកាសអាសន្ន

ការស្លាប់ដោយមានការសង្ស័យ ៖

- បក្សីស្លាប់ភ្លាមៗ
- បក្សីមានសុខភាពល្អ ហើយរយៈពេលតិចជាង ២៤ ម៉ោងពួកវាងាប់
- បក្សីមានអត្រាស្លាប់ខ្ពស់ ដោយចេះតែកើនឡើងក្នុងកំឡុងពេល ៤-៥ ថ្ងៃជាប់គ្នា
- នៅពេលមានអត្រាស្លាប់បក្សីដូចគ្នាខាងលើរបស់អ្នកជិតខាង។



*ភ្នាក់ងារសុខភាពសត្វភូមិនឹងសង្ស័យថាជាជំងឺផ្តាសាយបក្សី ប្រសិបើបក្សីមានអត្រាស្លាប់ខ្ពស់ និងស្រួចស្រាវ*



*សិរ និងណង់ជាំឈាម និងមានពណ៌ខៀវស្វាយ*

រោគសញ្ញាលើទា ៖

- ដេក ឬឈរនៅកន្លែងស្ងាត់ ឬចុះខ្សោយ



- ក្បាលសំយ៉ុងទៅដល់ដី
- ភ្នែកស
- ត្របកភ្នែក និងឆ្អឹងប្រឡង់ភ្នែកឡើងហើម
- រាគលាមកពណ៌ស ។

## ខ- ការចាត់វិធានការរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ទូរស័ព្ទទៅកាន់លេខបន្ទាន់: ០១២-៨៣៣-៧៩៥ ឬ ០១២-២១៤-៩៧០ ប្រសិនបើលេខខាងលើមិនដំណើរការត្រូវទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
  បញ្ចុះបញ្ចូល និងជួយកសិករ ដើម្បីកំទេចសាកសពសត្វ និងកប់ ឬដុតកាកសំណល់ផ្សេងទៀត
- រំលឹកអ្នកភូមិកុំឱ្យប៉ះពាល់បក្សីឈឺ ឬងាប់
- រំលឹកអ្នកភូមិផងដែរឱ្យលាងដៃ និងបោកសម្អាតសំលៀកបំពាក់ជាមួយសាប៊ូ បន្ទាប់ពីប៉ះពាល់ជាមួយបក្សីរួច ។



*ត្រូវទូរស័ព្ទទៅកាន់លេខបន្ទាន់ជាបន្ទាន់*
*ដើម្បីសូមជំនួយពីមន្ត្រីជំនាញ*

## គ- ការទទួលខុសត្រូវរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

- ពេលភ្នាក់ងារសុខភាពសត្វភូមិទូរស័ព្ទទៅកាន់លេខបន្ទាន់ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នឹងវាយតម្លៃពីបញ្ហានេះថាជាករណីសង្ស័យ ឬក៏អត់

- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល នឹងទូរស័ព្ទទៅកាន់ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត/ស្រុក ឱ្យធ្វើការអង្កេតបន្ថែមទៀត និងធ្វើការប្រមូលសំណាក
- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលធ្វើការវិភាគ ដើម្បីប្រកាសថាមានបញ្ហា ផ្តាសាយបក្សី ឬអត់
- ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត/ស្រុក ប្រកាសប្រាប់អ្នកភូមិពី បញ្ហាជំ ផ្តាសាយបក្សី និងធ្វើការហាមឃាត់លើចរាចរបក្សី ( ក្នុងករណីឃើញ មានផ្តាសាយបក្សី
- ប្រសិនបើមានប្រកាសពីជំងឺផ្តាសាយបក្សី គេត្រូវសម្លាប់បក្សី និងធ្វើការសម្លាប់ មេរោ នៅកន្លែងនោះ ។



*មុនសម្រេចចិត្តធ្វើការកំទេចបក្សីចោល វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលចេញលទ្ធផលវិភាគច្បាស់ ១០០% ថារកឃើញ វីរុស $H_5N_1$*

## ៦.២. ជំងឺអុតក្តាម

### ក- សញ្ញាប្រកាសអាសន្នសម្រាប់គោ

- ហូរទឹកមាត់
- គ្រុនក្តៅ និងមិនស៊ីចំណី
- ពងដោរ លើអណ្តាត អញ្ចាញធ្មេញ គល់ក្រចក ឬចង្វេកជើង បបូរមាត់ ហើយព ដោរនេះអាចមាននៅក្បាលដោះ និង កន្សោមដោះ
- ចំពោះកូនគោអាចងាប់ដោយសារបញ្ហាបេះដូង ។

 

## ខ- សញ្ញាប្រកាសអាសន្នសម្រាប់ជ្រូក



- គ្រុនក្តៅ និងពងដោរ នៅជើង មាត់ និង ក្បាលដោះ
- បញ្ហាខ្លាំងនៅក្រចកជើង ដោយមានពងដោរ នៅគល់ក្រចក និងចង្កែកជើង ។ សត្វមិនអាច ដើរ និងស៊ីចំណី ព្រោះវាមានការឈឺចាប់ខ្លាំង
- ពងដោរជានិច្ចកាលច្រើនមាននៅចុងច្រមុះ ។

## គ- ការចាត់វិធានការរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ទូរស័ព្ទទៅកាន់លេខបន្ទាន់: ០១២-៨៣៣-៧៩៥ ឬ ០១២-២១៤-៩៧០ ប្រសិន បើ លេខខាងលើមិនដំណើរការត្រូវទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
- ទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
- ជូនដំណឹងដល់អ្នកភូមិ
- បញ្ចុះបញ្ចូលអ្នកភូមិកុំឱ្យដឹកនាំសត្វឈឺ និងកុំទៅមើលគោផ្សេងទៀត
- ប្រសិនបើមានវ៉ាក់សាំងសមស្រប ត្រូវចាក់វ៉ាក់សាំងដល់គោដែលមានសុខភាពល្អ (វ៉ាក់សាំងមិនអាចព្យាបាលជំងឺទេ)
- ធ្វើការព្យាបាលសត្វឈឺ តែមិនត្រូវព្យាបាលដោយខ្លួនឯងឡើយ ។




*ការចាក់វ៉ាក់សាំង ត្រូវធ្វើឡើងភ្លាមៗលើគោដែលមានសុខភាពល្អ ដោយប្រើវ៉ាក់សាំងទ្រីវ៉ាឡង់*

## ឃ- ការទទួលខុសត្រូវរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

- ការិយាល័យផលិតកម្ម និងបសុព្យាបាលខេត្ត/ស្រុក នឹងចុះទៅយកសំណាកវិភាគ
- វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាលនឹងជូនដំណឹងថាមានជំងឺអុតក្ដាម ឬអត់ (ក្រោយបញ្ជូនសំណាកទៅមន្ទីរពិសោធន៍ប្រចាំតំបន់នៅប្រទេសថៃ)
- នាយកដ្ឋានផលិតកម្ម និងបសុព្យាបាលផ្ដល់សារធាតុសម្លាប់មេរោគជំងឺអុតក្ដាមខ្លះ ដូចជា ប៊្លឺឌឺមេទី ឡែន (Bleu de Methylene)..... .



*អ្នកបច្ចេកទេសប្រមូលយកភ្នាសស្ដើង ដោយផ្ទាល់នៅលើរបួស*

## ៦.៣. ជំងឺសារទឹក

### ក- សញ្ញាប្រកាសអាសន្ន

- ស្រួចស្រាវខ្លាំង សត្វចាប់ផ្ដើមឈឺ ២-៣ ម៉ោងក្រោយ
- ពិបាកដកដង្ហើម
- សត្វមិនចង់ដើរ គ្រុនក្ដៅ ហូរទឹកមាត់ ហូរសំបោរខ្លាំង
- ហើមនៅក្បាល ក និងតំបន់ទ្រូង
- ការស្លាប់កើតមានពី ៦-២៤ ម៉ោង បន្ទាប់ពីបង្ហាញរោគសញ្ញាដំបូង ។



ពិបាកដកដង្ហើម: គោដកក ហាមាត់ប្រឹងដកដង្ហើម

### ខ- ការចាត់វិធានការរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ទូរស័ព្ទទៅកាន់លេខបន្ទាន់: ០១២-៨៣៣-៧៩៥ ឬ ០១២-២១៤-៩៧០ ប្រសិន បើលេខខាងលើមិនដំណើរការ ត្រូវទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
- រាយការណ៍នៅពេលប្រជុំប្រចាំខែដល់ពេទ្យសត្វស្រុក
- ជូនដំណឹងដល់អ្នកភូមិឱ្យរាយការណ៍ ប្រសិនបើសង្កេតឃើញមានការសង្ស័យ ដើម្បីងាយស្រួលចាប់ផ្ដើមព្យាបាលជាបន្ទាន់
- ចាក់អុកស៊ីតេត្រាស៊ីគ្លីន ជាបន្ទាន់ ដល់គោផ្សេងទៀតដែលប៉ះពាល់ជាមួយសត្វឈឺ
- ចាក់វ៉ាក់សាំងប្រសិនបើមានសមស្រប ។



ប្រសិនបើចាក់អុកស៊ីតេត្រាស៊ី គ្លីន (OTC) តាមសរសៃវ៉ែន នោះធ្វើឱ្យការព្យាបាលមានប្រសិទ្ធភាពខ្ពស់

### គ- ការទទួលខុសត្រូវរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

- រៀបចំយុទ្ធនាការចាក់វ៉ាក់សាំងប្រសិនបើតំបន់នោះធ្លាប់មានបញ្ហាកើតឡើងពីឆ្នាំមុន




*វ៉ាក់សាំងសារទឹករបស់ក្រុមហ៊ុន Navetco (វៀតណាម) ត្រូវបានគេប្រើជាទូទៅនៅកម្ពុជា*

## ៣.៤. ជំងឺប៉េស្តជ្រូក

### ក- សញ្ញាប្រកាសអាសន្ន

- កម្ដៅឡើងខ្ពស់ ៤០,៥ - ៤១,៥ អង្សាសេ ហើយការប្រើអង់ទីប៊ីយ៉ូទិកនៅតែគ្មានប្រសិ ភាពជួយបន្ថយកម្ដៅ
- រលាកកែវភ្នែក
- ស្បែកមានស្នាមអុចៗពណ៌ស្វាយ
- ទ្រុឌទ្រោម និងខ្សោយ
- ពេលដើរមិនអាចបញ្ជាខ្លួនបាន ឬដើរទ្រេតទ្រោត
- ចំពោះជ្រូកសាច់ទម្ងន់ពី ៣០-៦០ គីឡូក្រាមមានអត្រាស្លាប់ខ្ពស់ កើតមានក្នុងកំឡុង ពេល ១ សប្ដាហ៍ បន្ទាប់ពីបង្ហាញរោគសញ្ញាដំបូង ។



## ខ- ការចាត់វិធានការរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ទូរស័ព្ទទៅកាន់លេខបន្ទាន់៖ ០១២-៨៣៣-៧៩៥ ឬ ០១២-២១៤-៩៧០ ប្រសិនបើ លេខខាងលើមិនដំណើរការ ត្រូវទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
- រាយការណ៍ដល់ពេទ្យសត្វស្រុកក្នុងពេលប្រជុំប្រចាំខែ
- ជូនដំណឹងដល់អ្នកភូមិ
- អនុវត្តវិធានការជីវសុវត្ថិភាព ដើម្បីការពារការរាតត្បាតរបស់វីរុស
- ពិនិត្យមើលលើកម្មវិធីវ៉ាក់សាំង
- ជុំរុញឱ្យចាក់វ៉ាក់សាំងលើ ជ្រូកដែលមានសុខភាពល្អ
- ព្យាបាលមេជ្រូកដើម្បីកាត់បន្ថយឥទ្ធិពលជំងឺ ។

*សម្រាប់ជំងឺប៉េស្ត ដំណាក់កាលដំបូងត្រូវ ប្រកាសជូនដំណឹងដល់អ្នកភូមិពីគ្រោះ មហន្តរាយ និងឥទ្ធិពលរបស់វា*



គ- ការទទួលខុសត្រូវរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

- ជំរុញឱ្យមានការចាក់វ៉ាក់សាំង
- បង្ហាញផែនទីពីតំបន់ជំងឺប៉េស្តនៅកម្ពុជា។

*វ៉ាក់សាំងខ្លះមិនសូវមានប្រសិទ្ធភាពទេ ដូចនេះត្រូវប្រើវ៉ាក់សាំងណា ដែលគេធ្លាប់ឃើញថាមានប្រសិទ្ធភាព (ក្នុងរូបភាពគឺជាវ៉ាក់សាំងមានគុណភាពល្អ)*




## ៣.៥. ជំងឺញូវកាស ឬដង្កោ

ក- សញ្ញាប្រកាសអាសន្ន

រោគសញ្ញាមានការប្រែប្រួលខ្លាំង អាស្រ័យលើវីរុស

- ការស្លាប់ភ្លាមៗ និងមានចំនួនច្រើន
- ហើមក្បាល (ជុំវិញភ្នែក)
- ពិបាកដកដង្ហើម/រាក/សំកុក
- សញ្ញាប្រព័ន្ធប្រសាទរួមមាន ពិការជើង និងរមួលក

បញ្ហាសំខាន់នោះគឺច្រើនច្រឡំជាមួយជំងឺផ្តាសាយបក្សី ដូចនេះមានតែការវិភាគដោយវិទ្យាស្ថា ជាតិស្រាវជ្រាវបសុព្យាបាលទេទើបអាចបញ្ជាក់បាន។





*ជាទូទៅយើងតែងតែថាពេលឃើញមាន់រមួលក ទើបថាជាជំងឺដង្កោ តែរោគសញ្ញាដែលបង្ហាញដំបូងគឺបញ្ហាផ្លូវដង្ហើម*

## ខ- ការចាត់វិធានការរបស់ភ្នាក់ងារសុខភាពសត្វភូមិ

- ទូរស័ព្ទទៅកាន់លេខបន្ទាន់៖ ០១២-៨៣៣-៧៩៥ ឬ ០១២-២១៤-៩៧០ ប្រសិន បើលេខខាងលើមិនដំណើរការ ត្រូវទូរស័ព្ទទៅពេទ្យសត្វស្រុក/ខេត្ត
- ត្រូវច្បាស់ថាវាមិនមែនជាជំងឺផ្តាសាយបក្សី
- រាយការណ៍ទៅកាន់ពេទ្យសត្វស្រុកក្នុងពេលប្រជុំប្រចាំខែ
- បញ្ចុះបញ្ចូលអ្នកភូមិដែលមានមាន់ឈឺឱ្យបង្ខាំងទុកមាន់ផ្សេងទៀតនៅក្នុងទ្រុង ហើយធ្វើការសម្លាប់មេរោគ ដើម្បីកុំឱ្យមានការរាតត្បាតទៅអ្នកជិតខាង
- រៀបចំចាក់វ៉ាក់សាំងដល់សត្វផ្សេងទៀតដែលមានសុខភាពល្អ ។

## គ- ការទទួលខុសត្រូវរបស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល

- ជំរុញឱ្យមានការចាក់វ៉ាក់សាំង
- បង្ហាញផែនទីពីតំបន់ជំងឺដង្កោនៅកម្ពុជា



*យុទ្ធនាការវ៉ាក់សាំងនៅតាមភូមិគឺជាការគ្រប់គ្រងលើជំងឺដង្កោដ៏ល្អ*



*ផែនទីបង្ហាញពីករណីជំងឺដង្កោក្នុង ឆ្នាំ មិថុនា ២០០៩*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការចិញ្ចឹមមាន់

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ

ជំពូក ១: កាយវិភាគវិទ្យា និងសរីរៈវិទ្យា ..... ២

ជំពូក ២: ការចិញ្ចឹមមាន់ ..... ៦

ជំពូក ៣: ការបន្តពូជ និងការលូតលាស់ ..... ១២

ជំពូក ៤: ជីវសុវត្ថិភាព និងការបង្ការជំងឺ ..... ១៩

ជំពូក ៥: ជំងឺ (ការត្រួតពិនិត្យមាន់) ..... ២១

ជំពូក ៦: ជំងឺ (រោគសញ្ញា និងការធ្វើរោគវិនិច្ឆ័យ) ..... ២៣

តារាង: តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត ..... ៤៣

# ជំពូក ១ កាយវិភាគវិទ្យា និងសរីរៈវិទ្យា

## I. ប្រព័ន្ធរំលាយអាហារ

- បំពង់កៈ ជាបំពង់ដែលតភ្ជាប់ពីមាត់ ទៅកាន់ក្រពះ ។ វាមានលក្ខណៈយឺតសម្រួលដល់ការលេបចំណី ។
- គែ : ចំណីត្រូវទុកក្នុងគែរយៈពេល ២ម៉ោងដើម្បីផ្សើម ហើយវាធ្វើឱ្យចំណីមានសភាពទន់ ។
- ក្រពះមានពីរផ្នែកគឺ :
  - ទងកោះ : ជាទីកន្លែងដែលចំណីត្រូវបានលាយជាមួយរសក្រពះយ៉ាងរហ័ស ។
  - កោះ : ដើរតួនាទីដូចជាក្រពះ ។ នៅទីនេះសាច់ដុំនោះកិនបំបែកចំណីដោយមានជំនួយពីគ្រាប់គ្រួស ឬកម្ទេចថ្មដែលមាន់បានលេបចូល ។
- ពោះវៀន : មានវត្ថុមានអង់ស៊ីម និងបាក់តេរីផ្សេងៗ ដើរតួនាទីក្នុងការរំលាយប្រូតេអ៊ីន កាបូអ៊ីដ្រាត និងសារធាតុខ្លាញ់ ។ ដំណើរការអាចប្រព្រឹត្តនៅក្នុងអំឡុងពេលពី ១២ ទៅ ១៨ម៉ោង ។

ត្រូវចងចាំថាពោះវៀនមិនអាចរំលាយជាតិសរសៃបានទេ។

- ផ្នែកដំបូងនៃពោះវៀនតូច គឺជា គល់ពោះវៀន ។
- ថង់ធំ២ ភ្ជាប់ជាមួយចុងពោះវៀន ហៅថាថ្នក់ពោះវៀន ។
- ខាងក្រោមថ្នក់ពោះវៀន គឺពោះវៀនធំ ហើយជាប់ជាមួយក្លូអាក់ ។
- ថ្លើមមានទំហំធំ ពណ៌ត្នោត មានបំពង់ទឹកប្រមាត់ពណ៌ខៀវ នៅជាប់ជាមួយ និងលំពែងពណ៌ផ្កាឈូក វាមានតួនាទីសំខាន់ចូលរួមការរំលាយអាហារ ។





លាមកមាន់ចែកជាពីរផ្នែក
ពណ៌ស និងប្រផេះ

### លាមកបក្សីចែកជាពីរផ្នែក :

- មួយផ្នែករឹង ពាសដោយពណ៌សចេញពីតម្រងនោម ។
- មួយផ្នែកទៀតម្សៅខ្មៅប្រផេះ ចេញពីពោះវៀន ( ក្លូអាក់) ។

*មិនត្រូវភ័ន្តច្រឡំជាមួយការរាគឡើយ*

## II. ប្រព័ន្ធដកដង្ហើម





- ច្រមុះ និងរន្ធច្រមុះភ្ជាប់ជាមួយនឹងប្រហោងឆ្អឹងលលាដ៍ក្បាល និងមានភ្នែកនៅសងខាង ហើយមានតម្រងខ្យល់មុនពេលចូលក្នុងសួត ។
- បំពង់ខ្យល់ គឺជាបំពង់តភ្ជាប់ទៅនឹងទងសួត ។
- សួតមានសភាពដូចអេប៉ុងពណ៌ក្រហមស្រស់ខ្យល់ចូលទៅសួតដើម្បីបំពេញថង់ខ្យល់ ។
- **ថង់ខ្យល់ :** ថង់ភ្នាសស្តើងដែលលេចឡើងច្បាស់ក្នុងសរីរាង្គ។ ថង់ខ្យល់ គឺជាផ្នែកទីមួយដែលងាយទទួលជំងឺផ្លូវដង្ហើម ។
- ការដកដង្ហើម គឺធ្វើឡើងដោយចលនារបស់ឆ្អឹងទ្រូង ព្រោះសត្វស្លាបគ្មានសន្ទះទ្រូងទេ ។
- ការដកដង្ហើមជួយរក្សាលំនឹងសីតុណ្ហភាពក្នុងខ្លួន ជាពិសេសនៅពេលអាកាសធាតុក្តៅ ។ នៅពេលសីតុណ្ហភាពខាងក្រៅលើសពី ៣០ អង្សាសេ មាន់ដកដង្ហើមញាប់រហូតដល់ ១៦០ដងក្នុងមួយនាទី ។



*ដាក់មាន់ក្នុងទ្រុងចង្អៀតពេលដឹកជញ្ជូនធ្វើឱ្យមាន់ពិបាកធ្វើចលនាឆ្អឹងទ្រូងដើម្បីដកដង្ហើម ។*

## III. ប្រព័ន្ធទឹកនោម និងសរីរាង្គបន្តពូជ

- តម្រងនោម : មាន់មានតម្រងនោមពីរពណ៌ត្នោតចាស់ និងមានបំពង់ទឹកនោមមួយ ។
- បំពង់នោម : គឺបំពង់បញ្ចេញទឹកនោមពីតម្រងនោម ទៅក្លូអាក់ ។



### សរីរាង្គបន្តពូជ:

- ជាធម្មតាមេមាន់ មានអូវែមួយ និងបំពង់នាំអូវុលមួយ ។ អូវែគឺជាកន្សោមពងពណ៌លឿង ហើយមានដំណាក់កាលលូតលាស់ជាច្រើន មានទីតាំងនៅក្បែរតម្រងនោម ។



- មាន់ឈ្មោលមានពងស្វាសពីរ នៅចន្លោះរវាងសួត និងតម្រងនោម ។

## IV. ប្រព័ន្ធឈាមរត់



- បេះដូងនៅស្ថិតនៅខាងលើថ្លើម មានតួនាទីសំខាន់សម្រាប់ការបូរឈាម ។



- ផាលមានរាងមូល ពណ៌ក្រហមត្នោត មានទីតាំងនៅចន្លោះថ្លើម និងកោះ ។
- ផាលមានតួនាទីសំខាន់បញ្ចេញកោសិកា ឈាមមិនល្អពីសរីរាង្គ និង កម្ទេចកំទីចេញពីប្រព័ន្ធឈាមរត់ ។

## V. ស៊ុត



- ជាទូទៅស៊ុតមាន់មានទម្ងន់ពី ៣៥-៧៧ ក្រាម ។

**សមាសធាតុ**

- សំបក ១០ ភាគរយ
- ស៊ុតពណ៌លឿង ៣០ ភាគរយ
- ស៊ុតពណ៌ស ៦០ ភាគរយ

- ស៊ុត មានប្រូតេអ៊ីនច្រើន ហើយមិនសូវមានខ្លាញ់ទេ ។ វាជាប្រភពវីតាមីនដ៏ល្អ ជាពិសេសវីតាមីន បេ ១២ ប៉ុន្តែមិនមានវីតាមីនសេទេ និងជាប្រភពជាតិដែក ។

# ជំពូក ២ ការចិញ្ចឹមមាន់

## I. ការជ្រើសរើស និងបង្កាត់ពូជ

ធ្វើឡើងក្នុងគោលបំណងដើម្បី ជំរុញការលូតលាស់ឱ្យបានឆាប់ (ពី៦ខែ មកត្រឹម៤ខែ) ឬ បង្កើនការផលិតស៊ុត កែលំអគុណភាពសាច់ដោយផលិតប្រភេទមាន់ដែលស្របនឹងតម្រូវការរបស់ប្រជាជន និងរក្សាឱ្យបាននូវលក្ខណៈស៊ាំទៅនឹងបរិយាកាស ។

### ១. ការជ្រើសរើសមេមាន់ :

- មានភាពរវៀសរវៃ ពូកែរកចំណី និង ធន់នឹងជំងឺ ។
- មានលំនឹង ចំពុះបិទជិត ភ្នែកភ្លឺថ្លា និង សិរពណ៌ក្រហម ។
- ជាមាន់ដែលកើតមកពីមេបាដែលមិនជាប់ស្រឡាយគ្នា ។
- មិនធ្លាប់កើតជំងឺឆ្លង ដូចជា: ជំងឺញូវកាស (ដង្កោរ) ។
- មានគូទទូលាយ: ចន្លោះឆ្អឹងគូទ និង ឆ្អឹងទ្រូង ទូលាយ អាចដាក់ម្រាមដៃ ៣ បាន) ។
- មានមាឌធំ ធំធាត់លឿន ទម្ងន់លើសពី ១.៥០ គីឡូក្រាម និង រោមក្រាស់ល្អ ។
- មានអាយុមិនលើសពី ៣ឆ្នាំ ។
- ពូជដែលមានពងច្រើន ពងធំ ញាស់បានច្រើន និង សាយកូនខ្លាំង: កូន៤ដង/១ឆ្នាំ យ៉ាងតិច ។

### ២. ការជ្រើសរើសបាមាន់ :

- មានមាឌធំ (ទម្ងន់២គីឡូក្រាមឡើង) ។
- មានភាពរហ័សរហួន និង ពូកែជាន់មេ ហើយកូនញាស់បានច្រើន ។
- មិនធ្លាប់កើតជំងឺឆ្លង និងមានអាយុមិនលើសពី ៣ឆ្នាំ ។
- មិនមែនជាមាន់ដែលកើតពីមេបាដែលជាប់ស្រឡាយគ្នា និង មិនជាប់ស្រឡាយជាមួយមេមាន់ដែលត្រូវបង្កាត់ជាមួយ ។
- បាដែលធំលឿន និងសុខភាពល្អ ហើយពូកែជាន់មេ ។
- បាដែលមានភ្នែកភ្លឺថ្លា និងរវៀសរវៃ

▪ បាដែលមានជើងធំ និងរឹងមាំ ។

នៅពេលខ្លះយើងត្រូវជ្រើសរើសពូជមាន់ដោយផ្តោតទៅលើ សំបុរ រោម និងពណ៌របស់មាន់ដែលជាតម្រូវការ របស់អ្នកបរិភោគ ។

## ៣. ការបង្កាត់ពូជ :

គម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប បានផ្តួចផ្តើមការបង្កាត់មាន់ក្នុងស្រុក ជាមួយនឹងបាមាន់កូនកាត់ ( អ៊ីសាប្រូន ជាមួយមាន់ជល់) ។



ទម្ងន់ ១.២ គក្រ នៅអាយុ ១១២ថ្ងៃ (កូនកាត់)
ទម្ងន់ ១.០៥ គក្រ នៅអាយុ ១៣៥ថ្ងៃ
(ក្នុងស្រុក)



បាកូនកាត់ចិញ្ចឹមជាមួយមាន់ក្នុងស្រុក
បន្ទាប់ពីយកបាចាស់ (ក្នុងស្រុក) ចេញ

## II. ការផ្តល់ចំណី

ត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវទៅនឹងតម្រូវការរបស់មាន់ដើម្បីការធំធាត់ និងផលិតកម្មពង ។ ការផ្តល់ចំណីមិនបានគ្រប់គាន់ និងគ្មានគុណភាពសម្រាប់តម្រូវការរបស់មាន់ ធ្វើឱ្យមាន់ធំធាត់យឺត ផលិតពងបានតិច និងខាតពេលវេលាទៀតផង ។ មាន់ដើរស៊ីដោយខ្លួនឯងតែងជួបនូវបណ្តាកង្វះបរិមាណ ក៏ដូចគុណភាពចំណីផងដែរ ។



▪ រកចំណីស៊ីតាមទីវាល (មាន់ចិញ្ចឹមព្រលែង)៖ មាន់ដើររកជន្លេន ខ្យង កណ្ដៀរ សត្វល្អិត គ្រាប់ធញ្ញជាតិ ស្លឹករុក្ខជាតិ បន្លែផ្សេងៗ នៅតាមបរិវេណផ្ទះ និង ភូមិដែលវារស់នៅ ។

ប៉ុន្តែវាគ្រោះថ្នាក់ច្រើនព្រោះការចិញ្ចឹមមាន់ ព្រលែងក្នុងភូមិ ប្រភពចំណីនៅតាមភូមិមិនគ្រប់គ្រាន់ និងងាយទទួលរងជំងឺផ្សេងៗ ។



មាន់ជាច្រើនពិបាកស្វែងរកចំណីនៅក្នុងភូមិ ហើយ មាន់ដែលខ្សោយ (កូនមាន់) អាចប្រឈមនឹងការងាប់ បាន ។ ការផ្ដល់ចំណីដូចជា កាកសំណល់ផ្ទះបាយ កន្ទក់ ស្រូវ អង្ករ ធញ្ញជាតិ សម្រាប់មាន់ចិញ្ចឹមព្រលែង សំខាន់ខ្លាំងណាស់ ។



▪ ផ្ដល់ចំណីបន្ថែម ៖ ចាំបាច់ត្រូវផ្ដល់ចំណី ឧស្សាហកម្មសម្រាប់កូនមាន់ក្នុងអំឡុង ៣ អាទិត្យ ដំបូង ។

ការផ្ដល់ចំណីឧស្សាហកម្មដែលមានប្រូតេអីន ថាមពល សារធាតុរ៉ែ និងសមាសធាតុជំរុញឱ្យ ស្បែក និងជើងមាន់មានពណ៌លឿងគ្រប់គ្រាន់ធ្វើឱ្យមាន់ធំធាត់លឿន សុខភាពល្អចាប់ពី អាយុ ៣អាទិត្យរហូត ដល់លក់ ។

▪ វត្ថុធាតុដើមក្នុងស្រុក ៖

វត្ថុធាតុដើមក្នុងស្រុកដែលមានប្រយោជន៍ផ្តល់ប្រូតេអ៊ីន និងថាមពលសម្រាប់មាន់ចិញ្ចឹមដូចជា ៖

**កន្ទក់អង្ករ ៖** ផ្តល់ថាមពល និងប្រូតេអ៊ីន ហើយវាមានផងដែរនូវ ផូស្វ័រ និងវីតាមីន បេ។

**កម្ទេចពោត ៖** ជាប្រភពសំខាន់នៃថាមពល ប្រូតេអ៊ីន និង សារធាតុដែលធ្វើឱ្យមាន់មាន ស្បែក និងជើងពណ៌លឿង



ចិញ្រ្ចាំស្លឹកដំឡូងមី ហើយហាល ១ ទៅ ២ថ្ងៃ

**ស្លឹកដំឡូងមីក្រៀមម៉ដ្ឋ ៖** ផ្តល់ត្រឹម ១០ក្រាម មួយក្បាលក្នុងមួយថ្ងៃ ជាមួយកន្ទក់ ចុងអង្ករ អង្ករ ធ្វើឱ្យមានថាមពល ប្រូតេអ៊ីន និងសារធាតុដែលធ្វើឱ្យ មាន់មានស្បែក និងជើងពណ៌លឿងដែលជាចំណូលចិត្ត អ្នកបរិភោគ ។



ជន្លេនជាប្រភពប្រូតេអ៊ីន

**ជន្លេន ៖** កសិករអាចរៀបចំកន្លែងចិញ្ចឹមជន្លេន ដោយដាក់លាមកគោដើមពោតស្លឹកឈើស្រស់ផ្សេងៗ រួចស្រោចទឹក និងគ្របឱ្យជិតរយៈពេល ២ អាទិត្យ ។

**កណ្តៀរ ៖** កាត់ចំបើងខ្លីៗ( លាយជាមួយលាមក គោ) ដាក់ក្នុងក្អមរួចផ្សើមវា។ យកមាត់ក្អមដាក់ជាប់ នឹងសំបុកកណ្តៀរទើបពូនថ្មីៗរយៈពេល ២-៣ ថ្ងៃ។ បន្ទាប់មកយកវាមកដាក់នៅកន្លែងដែលយើងចង់ចិញ្ចឹម វាក្នុងរយៈពេល ៤អាទិត្យ ទើបអាចចាប់ផ្តើមយកពង និងកូនទើបញាស់ឱ្យមាន់ស៊ី ។



▪ ស្នូកទឹក និងស្នូកចំណី ៖ ប្រើវាដើម្បី ជៀសវាង ការខ្ជះខ្ជាយចំណី និង ទឹក ហើយមាន់អាចមានចំណី និងទឹកពេញមួយថ្ងៃ ។

- មេមាន់ ១០ក្បាល ផឹកទឹក៥ លីត្រក្នុងមួយថ្ងៃ
- មាន់សាច់ទម្ងន់ ១គ.ក្រ ចំនួន ៥០ក្បាល ផឹកទឹក ១០ លីត្រក្នុងមួយថ្ងៃ



ទិញស្នូកទឹក និងស្នូកចំណីដែលលក់នៅហាងគឺជាការដាក់ទុនដ៏ត្រឹមត្រូវ

## III. ការសង់ទ្រុង

ទ្រុងមានប្រយោជន៍ណាស់សម្រាប់មាន់ មិនថាតូច ឬធំនោះទេ។ វាជាកន្លែងជ្រកភ្លៀង និងកម្តៅ សម្រាប់ដេកនៅពេលយប់ មាន់ដេកក្នុងទ្រុងអាចជៀសផុតពីការយាយីរបស់សត្វចង្រៃ ងាយតាមដានជំងឺ ងាយប្រមូលលាមកសម្រាប់ការដាំដុះ។ ទ្រុងមាន់អាចធ្វើតាមធនធានដែលមាននៅតាមតំបន់ផ្សេងៗ គ្រាដោយគ្រាន់តែសង់នៅលើដីទួលមិនលិចទឹកនិងខាងក្រោមទិសខ្យល់បក់ហើយមានខ្យល់ចេញចូលល្អ ។

### ១. ទ្រុងកូនមាន់ ៖ មានសារៈសំខាន់ដូចជា ៖

- កាត់បន្ថយការយាយីរបស់សត្វចង្រៃលើកូនមាន់ ។
- ធ្វើឱ្យកូនមាន់កក់ក្តៅ មិនរួញខ្នុល ។
- ងាយផ្តល់ចំណីដែលត្រឹមត្រូវដល់កូនមាន់ ។
- សម្រួលដល់ការធ្វើវ៉ាក់សាំង ។
- កាត់បន្ថយជំងឺមួយចំនួនលើកូនមាន់ពេលចិញ្ចឹមវានៅលើកម្រាលល្អ និងស្ងួត ។



គំរូទ្រុងកូនមាន់ច្រើនប្រភេទដែលសមស្របសំរាប់ការចិញ្ចឹម
(ទទឹង ០.៦០ ម៉ែត្រ បណ្ដោយ ១.៥ ម៉ែត្រ កំពស់ ០.៧៥ ម៉ែត្រ)

## ២. ទ្រុងមេមាន់ :

- ផ្ដល់នូវភាពស្ងាត់ស្ងៀម និងម្លប់សម្រាប់ មាន់ក្រាប និងភ្ញាស់ពង ។
- រៀបចំសំបុកត្រឹមត្រូវ ដោយរង្វង់ខាងលើ ៤០ ស.ម ខាងក្រោម ២៥ ស.ម និង ជម្រៅ ១៨ ស.ម
- ការពារមេមាន់ និង ពងមាន់ពីសត្វចង្រៃ ផ្សេងៗ ។





## ៣. ទ្រុងមាន់សាច់ :

- ការពារការបៀតបៀនពីសត្វចង្រៃផ្សេងៗ។
- ងាយស្រួលតាមដានសុខភាព និងចាប់វា។
- ងាយស្រួលប្រមូលលាមកសម្រាប់ធ្វើជី ព្រោះមាន់ជុះ ៥០% នៅពេលយប់ ។



ទ្រុងចំហនៅពេលថ្ងៃ និងបិទនៅពេលយប់

# ជំពូក ៣ ការបន្តពូជ និងការលូតលាស់

## I. ការបន្តពូជ

### ១. ភាពពេញវ័យ

- មាន់ញីពេញវ័យ និងចាប់ផ្តើមពងនៅពេល វាមានអាយុ ៥ខែ តែវាអាចបង្កកំណើតបាន លុះត្រាមានអាយុ ៦ ខែ។
- ដូចគ្នានឹងមាន់ញីដែរ មាន់ឈ្មោល អាចបង្កាត់បានលុះត្រាមានអាយុ ៦ ខែ។
- ដើម្បីបង្កើនផលិតកម្ម យើងត្រូវផ្តាច់កូនមាន់ដែលទើបញាស់ដាក់ទ្រុងកូនមាន់ ថែរក្សាដោយដាក់ ទឹក និងចំណី ពេលយប់ត្រូវការពារកូនមាន់នឹងភាពត្រជាក់ (ដុតធ្យូងដាក់ក្នុងខ្ទម) ឬរុំបាវជុំវិញទ្រុងកូនមាន់។



មេមាន់ និងមាន់ឈ្មោលនៅអាយុ ៦ខែ

### ២. ការបន្តពូជ (ការបង្កកំណើត) :

- បន្ទាប់ពីពាក់មេ ស្ពែមរស់នៅក្នុងបំពង់នាំអូវ៉ុល បានពី ២-៣ សប្តាហ៍។
- ស្ពែមអាចមានលទ្ធភាពបង្កកំណើតពេញលេញបានតែ ក្នុងរយៈពេល ៦ ថ្ងៃទេ។

ពងមាន់ដែលអាចញាស់បានលុះត្រាតែមានបាពាក់ ប៉ុន្តែមិនមែនពងដែលមានបាពាក់ទាំងអស់សុទ្ធតែញាស់ទេ ដោយសារ អំប្រីយ៉ុង ខ្លះបានងាប់មុនចាប់ផ្តើមភ្ញាស់។



មាន់ពងជាទូទៅ ៨-១៣ ក្នុងមួយសំបុក (មួយថ្ងៃពង ១)

## ៣. បាមាន់

- បាមាន់មួយក្បាលអាចបង្កាត់ជាមួយ មេ១៥ក្បាល ។
- វាមានកត្តាផ្សេងៗទៀតធ្វើអោយអត្រាបង្កកំណើតទាបដោយសារ អាកាសធាតុក្តៅ មានជំងឺបរាសិត មាន់ឈឺជើង មាន់ក្មេង ឬចាស់ពេកចំណីអាហារមិនល្អ..



បើមានបាមាន់ច្រើនពេក អត្រាបង្កកំណើតទាបដោយសារវាជល់គ្នាពេក

## ៤. ការជ្រើសរើសស៊ុត

- រើសពងមាន់ដែលមានទំហំធំល្អ ពណ៌ល្អ ដើម្បីញាស់បានកូនថ្លោស ។
- កុំភ្ញាស់ពងមាន់បែក ឬខុសប្រក្រតី ។
- សីតុណ្ហភាព និងសំណើមពេលភ្ញាស់វាអំណោយផលសម្រាប់ការលូតលាស់របស់បាក់តេរី ។



កុំភ្ញាស់ស៊ុតកខ្វក់ (វាមិនល្អទេដែលលាងស៊ុតកខ្វក់ហើយយកទៅភ្ញាស់ ព្រោះវាបានបំផ្លាញការការពារធម្មជាតិ) ប្រសើរបំផុតត្រូវយកវាចេញ

## ៥. ភ្ញាស់តាមធម្មជាតិ (ត្រូវច្បាស់ថាសំបុកមាន់គ្មាន ចៃ និងស្រមើល)

- ស៊ុតត្រូវការសំណើម និងសីតុណ្ហភាពសមស្របដើម្បីញាស់ (សីតុណ្ហភាពពី ៣៨-៣៩អង្សាសេ) ។
- មេមាន់ក្រាបលើស៊ុត (៨-១៣ ស៊ុត) រហូត ។ វាទៅរកចំណី និងទឹកត្រឹមតែ ១៥នាទី ទេក្នុងមួយថ្ងៃ ។ មេមាន់នឹងមិនស៊ីចំណីច្រើនទេពេលក្រាបពង ដូចនេះ មេមាន់ត្រូវមានសុខភាពល្អមុនចាប់ផ្តើមក្រាបពង ។
- មេមាន់ប្រើចំពុះបង្វិលស៊ុតជាប្រចាំ ដើម្បីការពារ កុំឱ្យអំប្រីយ៉ុងស្អិតជាប់សំបក និងដើម្បីផ្តល់អុកស៊ីសែនគ្រប់គ្រាន់ ។



មាន់ក្រាបក្នុងរយៈពេល ២១ ថ្ងៃ

## ៦. ទូភ្ញាស់

- ស៊ុតមាន់ត្រូវប្រញាប់ដាក់ក្នុងទូភ្ញាស់



ស៊ុតត្រូវរក្សាទុកក្នុង ឡាំងក្រដាស ឬថង់កៅស៊ូ ដាក់ក្នុងបន្ទប់ត្រជាក់ ( មិនឲ្យលើស ៦ថ្ងៃ)

ទូភ្ញាស់សិប្បនិម្មិត (អគ្គិសនី ឬធម្មតា) ត្រូវ :

- អាចធ្វើឱ្យអុកស៊ីសែនចូលក្នុងទូបានគ្រប់គ្រាន់ ហើយបញ្ចេញជាតិពុល និង សំណើមទៅក្រៅ ។
- អាចគ្រប់គ្រងសីតុណ្ហភាពឱ្យនៅថេរបានក្នុងចន្លោះ ៣៧.៥០ អង្សាសេ ។

## ៧. ការបង្វិលស៊ុត

- ដើម្បីអាចឱ្យស៊ុតលឿងនៅចំកណ្ដាលស៊ុតស ។
- បើមិនបង្វិលទេ អំប្រ៊ីយ៉ុងនឹងងាប់ អត្រាញាស់ទាប ។
- ពេលមេក្រាបពងវាប្រើចំពុះបង្វិលស៊ុតជាប្រចាំ ដើម្បីកម្ដៅពងបានសព្វ ។
- ក្នុងទូភ្ញាស់ ស៊ុតត្រូវបានបង្វិលក្នុងមួយថ្ងៃ ៤ដង ។
- ស៊ុតមិនចាំបាច់បង្វិលទេបន្ទាប់ពីដាក់វាបាន ១៤ថ្ងៃ ក្នុងទូ។



៣ថ្ងៃមុនញាស់អំប្រ៊ីយ៉ុងផ្លាស់ទីទៅទីតាំងញាស់ ដូចនេះកុំបង្វិលវា

## ៨. ការឆ្លុះស៊ុត

- គោលបំណងនៃការឆ្លុះស៊ុត គឺដើម្បីឱ្យពន្លឺឆ្លងកាត់ស៊ុតដែលអាចធ្វើឱ្យយើងឃើញពីការវិវត្តន៍អំប្រ៊ីយ៉ុង ខាងក្នុងស៊ុត ។
- ត្រូវយកស៊ុតដែលខូចចេញដើម្បីជៀសវាងក្លិនអាក្រក់ក្នុងទូ។



- បន្ទាប់ពីដាក់ភ្ញាស់បាន ១អាទិត្យ យើងអាច ឃើញសរសៃឈាម ព័ទ្ធជុំវិញខ្នរខ្មៅមានន័យថា អំប្រីយ៉ុងកំពុងលូតលាស់ ។



## ៩. ការញាស់

- ធម្មតាកូនមាន់ទាំងអស់នឹងញាស់ក្នុងរយៈពេល ២-៣ម៉ោង ។
- កូនមាន់កើតមក មានសភាពសើម និងអស់កំលាំង វាត្រូវការសំដិលឱ្យស្ងួត និងសំរាក ។
- ប៉ុន្មានម៉ោងក្រោយមកកូនមាន់នឹងស្ងួត និង មានកំលាំង ។
- ស៊ុតលឿងដែលនៅក្នុងខ្លួនកូនមាន់អាចចិញ្ចឹម វាលើសពី ៤៨ម៉ោង ហើយវាមិនចាំបាច់ស៊ីអ្វី ភ្លាម១ទេ ។
- គួរដឹកជញ្ជូនកូនមាន់អាយុមួយថ្ងៃប្រសើរជាងកូន មាន់អាយុបាន ៣-៤ថ្ងៃ ព្រោះវាមិនសូវមាន ស្ត្រេស និងមិនចាំបាច់ខ្វល់ខ្វាយពីចំណីរបស់វា ។



ដំណើរការញាស់អាចមានរយៈពេល ៤-១២ ម៉ោងមុនកូនមាន់អាចបោះសំបកចេញរួច

# II. ការលូតលាស់របស់មាន់សាច់

- **ពី ០-២១ ថ្ងៃ :** ដាក់កូនមាន់ក្នុងទ្រុងកូនមាន់ គឺសំខាន់ណាស់
  - កម្រាលត្រូវស្ងួត ដើម្បីការពារជំងឺ
  - សីតុណ្ហភាពៈ ខ្ពស់បំផុត ៣៥អង្សាសេ និង ទាបបំផុត ២៦ អង្សាសេ ។



ផ្ទៃ ១ម៉ែត្រការ៉េ ដាក់បានកូនមាន់ ២០ក្បាល

- ជៀសវាងខ្យល់នៅពេលយប់ ។
- ធ្វើវ៉ាក់សាំងញូវកាស នៅអាយុ១ថ្ងៃ ។

◆ ពី០-២១ថ្ងៃ : ការផ្តល់ចំណី :

- ថ្ងៃទី ១ ដាក់ចំណីក្នុងថាសទាបដើម្បីឱ្យកូនមាន់អាចស៊ីបានស្រួល ។
- ថ្ងៃទី ២-២១ ប្រើស្នូកចំណីសំរាប់ដាក់ឱ្យវា ។
- ចំណី : ត្រូវឱ្យចំណីសម្រាប់កូនមាន់ ( បើគ្មានគួរតែប្រើកម្ទេចគ្រាប់ពោត)



ស្នូកចំណី: ៥០ សម សម្រាប់ ២០-២៥ ក្បាល ត្រូវប្រាកដថាកូនមាន់អាចស៊ីបានទាំងអស់គ្នា

- ត្រូវថែមបរិមាណចំណីឱ្យកូនមាន់ជារៀងរាល់ថ្ងៃ: អាយុ២ថ្ងៃ ១៥ ក្រាមក្នុង១ថ្ងៃសម្រាប់១ក្បាល ហើយការថែមនេះត្រូវធ្វើរហូតដល់ថ្ងៃទី ២១ ដោយ ៦០ក្រាម ក្នុង១ថ្ងៃសម្រាប់១ក្បាល ។
- ស្នូកទឹក : បរិមាណ ២លីត្រសម្រាប់ ២០-២៥ ក្បាល ។
- ទឹក : ត្រូវថែមបរិមាណទឹករាល់ថ្ងៃ ។ ៣០ ម.ល ក្នុង១ក្បាលក្នុងមួយថ្ងៃហើយការថែមនេះត្រូវធ្វើរហូតដល់ ថ្ងៃទី ១៤ ដោយ ១២០ ម.ល ក្នុង១ថ្ងៃសម្រាប់១ក្បាល ។

◆ លើសពី ២១ថ្ងៃ : ទ្រុង ( ការរស់នៅរបស់មាន់)

- ជាទូទៅកសិករនឹងព្រលែងមាន់ឱ្យដើរស៊ីចំណីដោយសេរី និងឱ្យចុងអង្ករ ស្រូវ កាកសំណល់ផ្ទះបាយបន្តិចបន្តួចតែប៉ុណ្ណោះ ។
- ជាការល្អត្រូវដាក់មាន់ក្នុងទ្រុងនៅពេលយប់ ។
- ទ្រុង : មាន់ ១០ក្បាលសម្រាប់ផ្ទៃ ១ម៉ែត្រការ៉េ ។

◆ លើសពី ២១ថ្ងៃ : ការផ្តល់ចំណី និងទឹក

- មាន់ត្រូវការទឹកពី ១៨០ ទៅ ៣០០ម.ល ក្នុងមួយក្បាលក្នុងមួយថ្ងៃ ។
- ការផ្តល់ចំណី : បើកសិករផ្តល់ចំណីសម្រេចគឺ ៩០-១៥០ ក្រាម ក្នុងមួយក្បាល ។



ព័ទ្ធរបងកន្លែងមាន់ដើរកស៊ីយ៉ាងតិច ១០០០ ម៉ែត្រការ៉េ សម្រាប់មាន់ ១០០ក្បាល

- ចិញ្ចឹមពាក់កណ្ដាលព្រលែង៖

ចំណីរកបានដោយមាន់ផ្ទាល់តាមទីវាលអាចចូលរួម ៧០% នៃតម្រូវការចំណីទាំង អស់ ។ ផ្ដល់ ៣០-៤៥ ក្រាមទៀតក្នុងមួយថ្ងៃសម្រាប់ការលូតលាស់ល្អ ។

## III. ការលូតលាស់ពងមាន់

- ធ្វើការជ្រើសរើសមេមាន់ជាការសំខាន់ដើម្បីទទួលបានពងច្រើន និងកូនល្អ ។
- មេមាន់ចាប់ផ្ដើមពងនៅអាយុ ២០-២២ អាទិត្យ ។
- ទម្ងន់ស៊ុតធម្មតា ៦០ ក្រាម នៅពេល មេមាន់មានអាយុ ៣០អាទិត្យ ។
- នៅអាយុ ១៨ខែ មេមាន់នឹងជម្រុះរោម ពេលនោះវានឹងផ្អាកពងមួយរយៈពេលខ្លី ។
- មេមាន់សុខភាពល្អអាចពងបានច្រើនឆ្នាំ ( ១០-១២ ឆ្នាំ) ។



ពូជមាន់ពង ១ក្បាលពងបាន ២៥០គ្រាប់ ក្នុងមួយឆ្នាំ (ពូជអ៊ីសាប្រ៊ូន)

### ១. ការផ្ដល់ចំណីសម្រាប់មាន់ពង

- មេមាន់ត្រូវការចំណីដែលមានប្រូតេអ៊ីន ពី ១៦-១៨% ។
- មេមាន់មួយស៊ី ១២០ក្រាម( ១.២ខាំ) ក្នុងមួយថ្ងៃ ( ចំណីសម្រេចដែលមានគុណភាពល្អ) ។
- មេមាន់ចិញ្ចឹមព្រលែងត្រូវបន្ថែម ២.៥-៣.៥ ក្រាមនៃកាល់ស្យូមក្នុងមួយថ្ងៃ ហើយកាល់ស្យូមអាចរកបានតាមរយៈ សំបកខ្យង ខ្ចៅ ឬម្សៅ ដេសេប៉េ (DCP) ។



មេមាន់ចិញ្ចឹមព្រលែងត្រូវបន្ថែមចំណីឧស្សាហកម្ម ៣០-៧០%ដើម្បីមានតុល្យភាពចំណី

- ស្លឹកដំឡូងមីស្ងួតមានប្រូតេអ៊ីន ២០-២៤ % និងជាតិសង់តូភីល ដែលជួយឱ្យស្បែក និងជើងមាន់មានពណ៌លឿង។ យើងអាចលាយម្សៅស្លឹកដំឡូងមីស្ងួត ១គ.ក្រ ជាមួយនឹងកន្ទក់ ឬចុងអង្ករ ៥គ.ក្រ សម្រាប់ឱ្យមាន់ស៊ី។
- ស្លឹកកន្ទំថេតស្ងួតក៏មានប្រយោជន៍ផងដែរ សម្រាប់ការលូតលាស់របស់មាន់។ យើងអាចលាយម្សៅ ស្លឹកកន្ទំថេតស្ងួត ១គ.ក្រ ជាមួយនឹងកន្ទក់ ឬចុងអង្ករ ៥គ.ក្រ សម្រាប់ឱ្យមាន់ស៊ី។

# ជំពូក ៤ ជីវសុវត្ថិភាព និងការបង្ការជំងឺ

## I. ការប្រុងប្រយ័ត្ន

គ្រោះថ្នាក់ចំបងគឺការយកមាន់ឈឺចូលក្នុងភូមិ។ មាន់អាចចម្លងជំងឺតាមរយៈលាមក ទឹកសំបោរ ហើយវាសាយភាយពីផ្ទះមួយទៅផ្ទះមួយ ហើយអាចពេញទាំងភូមិតែម្តងបើ យើងគ្មានវិធានការណ៍ទប់ស្កាត់។

- មាន់អាចឈឺដោយបង្ហាញរោគសញ្ញាតិចតួច។
- មាន់អាចមើលទៅមានសុខភាពល្អតែមានផ្ទុកមេរោគខាងក្នុង។



គ្រោះថ្នាក់កាន់តែខ្ពស់បើទិញមាន់រស់ពីផ្សារមកចិញ្ចឹម

## II. ការក្រុងមាន់ (បង្ខាំង)

### ១. ការសម្ងំជំងឺ

វាជារយៈពេលមានវត្តមានរបស់មេរោគរហូតដល់បង្ហាញរោគសញ្ញាដំបូង។

- រយៈពេលសម្ងំជំងឺញូវកាសពី ២ថ្ងៃ-២ អាទិត្យ។
- រយៈពេលសម្ងំជំងឺផ្តាសាយបក្សី ពី ២ទៅ៣ម៉ោង ឬរហូតទៅ ១៤ថ្ងៃ។

### ២. ការបង្ខាំង

គឺជាការក្រុងមាន់ទើបមកថ្មីរយៈពេល ១៤ថ្ងៃ ដើម្បីតាមដានសុខភាពសត្វ និងជៀសវាងការសាយភាយមេរោគ បើមាន់នោះឈឺ ឬមានផ្ទុកមេរោគ។



មាន់គកនេះមើលទៅមានសុខភាពល្អប៉ុន្តែអាចមានមេរោគក្នុងលាមក និងអាចចម្លងទៅមាន់ ផ្សេងទៀតបើវាមានការសម្ងំជំងឺញូវកាស។

- កសិករត្រូវអង្កេតមាន់ដែលក្រុងនោះរាល់ថ្ងៃ ដើម្បីដឹងពីរោគសញ្ញារបស់ជំងឺ ។
- បើ ១៤ថ្ងៃ ហើយមាន់នៅមានសុខភាពល្អ យើងអាចព្រលែងវាឱ្យនៅជាមួយមាន់ចាស់បានហើយ ។
- បើក្នុងកំឡុងពេលតាមដានយើងឃើញមាន់មានជំងឺយើងត្រូវកម្ទេច រួចកប់ឱ្យបានត្រឹមត្រូវ ។



## III. អនាម័យ

មូលដ្ឋានគ្រឹះនៃអនាម័យគឺអាចកាត់បន្ថយនូវគ្រោះថ្នាក់ដោយជំងឺ ។



មេរោគជាច្រើនអាចសម្លាប់ដោយកម្ដៅ និងពន្លឺ ប៉ុន្តែមេរោគខ្លះទៀតអាចរស់នៅបានយូរក្នុងបរិយាកាសសើម និងងងឹត។

- បោសសំអាតសំរាម ទ្រុង និងធ្លាភក់ជ្រាំនៅតាមផ្ទះ និងក្នុងភូមិព្រោះវាជាប្រភព មេរោគលូតលាស់ និងកើតមូសរុយ ។
- កុំហូបសាច់សត្វឈឺ ឬងាប់ដោយជំងឺ
- ចម្អិនសាច់ឱ្យឆ្អិនល្អ ដោយកម្ដៅអាចសម្លាប់វីរុស និងបាក់តេរី (មេរោគផ្ដាសាយបក្សីអាចងាប់នៅសីតុណ្ហភាព ៧០ អង្សាសេ)
- លាងដៃនឹងសាប៊ូបន្ទាប់ពីប៉ះពាល់មាន់ ឬសាច់មាន់ឆៅ ។



កប់ ឬដុតសត្វមាន់ដែលងាប់ភ្លាមៗ ឬមានរោគសញ្ញាសង្ស័យថាមានជំងឺ

# ជំពូក ៥ ជំងឺ (ការត្រួតពិនិត្យមាន់)

ដើម្បីធ្វើរោគវិនិច្ឆ័យលើជំងឺរបស់មាន់ ជាចំបងត្រូវពិនិត្យទៅលើៈ

- **ស្ថានភាពរាងកាយ**



សិរ និង ណង់មានពណ៌ផ្កាឈូក សភាពភ្លឺថ្លា ភ្នែករវៀងវៃ គ្មានហូរទឹកសំបោរ រោមស្លាបរលោងស្អាត និងដកដង្ហើមពេញលេញ មានន័យថាវាមានសុខភាពល្អ។



ការស្គមកំព្រឹង និងស្ថានភាពស្លាបមិនធម្មតា គឺជាលក្ខណៈមិនល្អ *ដែលអាចបណ្តាលពីកង្វះចំណី (មាន់ច្រើនលើសចំណុះរកស៊ីនៅទីធ្លាតូច) ឬដោយជំងឺរ៉ាំរ៉ៃ ឬស្រួចស្រាវ ដូចជា: ព្រូន ជំងឺកុកស៊ីដ្យូស...*

- **អាកប្បកិរិយា**



ក្បាល និងកន្ទុយងើបឡើង ហើយមាន់មានសភាពក្លាហាន

### ▪ ចលនា (ការដើរ)



មាន់ចិញ្ចឹមព្រលែងត្រូវមានជើងរឹងមាំ ដើម្បីដើររកចំណីប្រចាំថ្ងៃ

គ្មានការថែទាំត្រឹមត្រូវ និង គ្មានលក្ខខណ្ឌល្អអាចធ្វើឱ្យមាន់ងាយយាយីពីសត្វចង្រៃ និង ជំងឺ។ *បើមាន់មានអាការៈមិនប្រក្រតី* ជាញឹកញាប់ច្រើនជាសញ្ញានៃជំងឺឆ្លង ដូចនេះត្រូវតែវិភាគរោគសញ្ញាឱ្យបានឆាប់រហ័ស។

### ▪ លាមក

ការពិនិត្យលាមករបស់មាន់ព្រលែងមិនមែនជាការងាយស្រួលទេ ប៉ុន្តែបើគេដាក់វាក្នុងទ្រុងពេលយប់ វានឹងងាយស្រួលពិនិត្យ។





# ជំពូក ៦ ជំងឺ (រោគសញ្ញា និងការធ្វើរោគវិនិច្ឆ័យ)

## I. ការងាប់ស្រួចស្រាវ



ជំងឺជាច្រើនអាចបង្កឱ្យមាន់ងាប់ស្រួចស្រាវ គឺមានន័យថា មុនពេលងាប់ ១ថ្ងៃ មាន់មានសុខភាពធម្មតា ហើយព្រឹកថ្ងៃបន្ទាប់វាក៏ងាប់ ។ សាកសពមានសភាពធម្មតា ។ ជាញឹកញយ ជំងឺទាំងនេះធ្វើការសាយភាយនៅក្នុងហ្វូងយ៉ាងលឿន ហើយធ្វើឱ្យមាន់ងាប់យ៉ាងច្រើន ដែលគេហៅថាជាការផ្ទុះជំងឺ ។

មាន់ងាប់យ៉ាងរហ័ស ដោយមិនបញ្ចេញរោគសញ្ញា ឬ ស្លាកស្នាមច្បាស់លាស់ ដែលជាហេតុធ្វើឱ្យមានការលំបាក ក្នុងការធ្វើរោគវិនិច្ឆ័យ ដូចនេះចាំបាច់ត្រូវមានជំនួយវិភាគ ពីមន្ទីរពិសោធន៍ ។

ជំងឺផ្តាសាយបក្សី ញូវកាស ប៉ាំបូរ៉ូ អាសន្នរោគ... អាចបណ្តាលឱ្យមានការស្លាប់ស្រួចស្រាវ ។

### ជំងឺផ្តាសាយបក្សី

### បង្កឡើងដោយវីរុស

- មានអត្រាស្លាប់ខ្ពស់ និងលឿន សូមនឹកគិត ទៅដល់ផ្តាសាយបក្សី
- កុំវះកាត់សាកសពសត្វ
- ទូរស័ព្ទទៅពេទ្យសត្វស្រុក ឬខេត្ត ឬទូរស័ព្ទផ្ទាល់ទៅកាន់លេខ ០១២ ៨៣៣-៧៩៥ ឬ ០១២ ២១៤-៩៧០ របស់នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល (DAHP) ។

រោគសញ្ញាផ្សេងទៀតរួមមាន :

- ពិបាកដកដង្ហើម
- ខ្វិន ញ័រក្បាល



– ហើម ជាំឈាមនៅសិរ និងណង់



– ជាំឈាមនៅជើង



– មិនស៊ីចំណី សំកុក រោមបះ

ជំងឺផ្តាសាយបក្សីត្រូវ តែប្រុងប្រយ័ត្ន ព្រោះវាអាចចម្លងមកមនុស្សបាន។

## II. ជំងឺមានរោគសញ្ញាផ្លូវដង្ហើម

គ្រប់ជំងឺផ្លូវដង្ហើមទាំងអស់បង្ហាញប្រភេទរោគសញ្ញាដូចគ្នាគឺ :

- ពិបាកដកដង្ហើម
- ហូរសំបោរ ទឹកតាមភ្នែក និងច្រមុះ
- កណ្តាស
- ហើមឆ្អឹងរន្ធច្រមុះ





- ងើយ ក ពេលដកដង្ហើម

គេមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យចែកឱ្យដាច់ពីជំងឺផ្សេងៗដែលបង្កដោយបាក់តេរីដូចជា :

- កូរីសា (Coryza)
- ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ (CRD) ដូចជាមីកូប្លាស្មា
- ជំងឺអាសន្នរោគ

**អង់ទីប៊ីយ៉ូទិកមានប្រសិទ្ធភាពប្រឆាំងនឹងពួកជំងឺខាងលើបាន។**

ជំងឺខ្លះបង្កឡើងដោយវីរុស ដូចជា :

- ជំងឺផ្តាសាយបក្សី
- ជំងឺញ៉ូវកាស (ND)
- ជំងឺរលាកទងសួត(IB)
- ជំងឺរលាកដើមក និងបំពង់ខ្យល់ (ILT)

**អង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពប្រឆាំងនឹងពួកវាបានទេ។**

## ជំងឺញ៉ូវកាស

### រោគសញ្ញា

រោគសញ្ញាលើផ្លូវដង្ហើមកើតឡើងដោយប្រភេទវីរុសជំងឺញ៉ូវកាសប្រភេទខ្សោយវាយលុក។

- រោគសញ្ញាផ្លូវដង្ហើម រួមមានដង្ហក់ ក្អក កណ្តាស
- រោគសញ្ញាប្រព័ន្ធប្រសាទរួមមានញាក់ញ័រ ធ្លាក់ស្លាប ខ្វិន រមួលក ដែលជាទូទៅច្រើនកើតមានបន្ទាប់ពីមានសញ្ញាផ្លូវដង្ហើម
- ការជ្រៀតចូលពួកបាក់តេរីឆ្លៀតឱកាសផ្សេងទៀត នឹងរឹតតែធ្វើឱ្យមានបញ្ហាផ្លូវដង្ហើមកាន់តែធ្ងន់ធ្ងរឡើង។







ការចម្លង រួមមាន :

- ដោយផ្ទាល់ តាមលាមក និង ទឹកសំបោរ ។
- ដោយប្រយោល តាមរយៈមជ្ឈដ្ឋានដែលមានមេរោគរួមមាន ចំណី ទឹក សំភារៈ និង សំលៀកបំពាក់ ។
- ចរាចរបក្សីរស់ដែលមានមេរោគ និង មនុស្ស គឺជាប្រភពដ៏ចំបងក្នុងការសាយភាយជំងឺទៅប្រទេសកម្ពុជា ។
- ការធ្វើវ៉ាក់សាំងមិនបានត្រឹមត្រូវ ។

ព្យាបាល :

- គ្មានការព្យាបាលទេ ព្រោះវាបង្កឡើងដោយវីរុស ហើយអត្រាងាប់ខ្ពស់ ។

ការពារ :

- គេប្រើវ៉ាក់សាំង អាយធូ (I2) ដោយបន្តក់តាមភ្នែក
- គេបន្តក់វ៉ាក់សាំងនៅពេលមាន់អាយុ ១ ថ្ងៃ និង ៣ សប្តាហ៍ ទើបអាចការពារបានលើស ៦ខែ (ធ្វើវ៉ាក់សាំង ពីរលើក)
- មាន់ខ្លះមានភាពស៊ាំតាមរយៈការជាសះស្បើយពីជំងឺ (ប៉ុន្តែវាអាចចម្លងជំងឺទៅសត្វផ្សេងទៀតតាមរយៈលាមក...) ។

## ជំងឺរលាកទងសួត (IB)





ជំងឺនេះបង្កឡើងដោយវីរុស

រោគសញ្ញា :

- ក្អក
- កណ្ដាស
- ដកដង្ហើមមានឮសូរគ្រិកៗរណ្ដំគ្នា
- ផលិតកម្មស៊ុតថយចុះ រួមជាមួយនឹងស៊ុតមានគុណភាពអន់ ។

ជាទូទៅស៊ុតមានទម្រង់មិនប្រក្រតី សំបកស្តើង ហើយផ្នែក ស៊ុតសមានសភាពរាវ ។

*ជំងឺរលាកទងសួតមានសភាពឆ្លងរាតត្បាតខ្លាំង ដោយធ្វើការចម្លងតាមខ្យល់ សត្វស្លាប់ និងសត្វកកេរ។*

## ជំងឺរលាកបំពង់សំលេង និង បំពង់ខ្យល់ (Laryngotracheitis)



រោគសញ្ញាផ្លូវដង្ហើម :

- ថប់ដង្ហើមយ៉ាងខ្លាំង
- ក្អក
- ដកចង្កាមាន់
- មាត់ និងចំពុះមានឈាម និងស្លេស ដោយសារហូរចេញពី បំពង់ខ្យល់ ព្រោះវាបង្កដោយការវាយលុកបំពងខ្យល់ ។

# ជំងឺកូរីសា (Coryza)



ជំងឺនេះបង្កឡើងដោយបាក់តេរី

រោគសញ្ញា :

- មានហូរសំបោរខ្លាំងចេញពីរន្ធច្រមុះ និង កណ្ដាស
- ភ្នែកឡើងក្រហម
- ហើមមុខនៅខាងក្រោមភ្នែក
- មិនឃើញមានរោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ
- សត្វមានអាយុកាន់តែច្រើនកាន់តែងាយ ទទួលជំងឺ



ការចម្លង :

- ការចម្លង សំខាន់ជាងគេនោះគឺការប៉ះពាល់ ផ្ទាល់រវាងសត្វឈឺ និងជា
- ចរន្តខ្យល់បក់នាំមកជាមួយនូវធូលីដែលមានមេរោគ
- ទឹកផឹកដែលមានមេរោគរបស់ជំងឺនេះ ។

ព្យាបាល :



- ប្រើ អេរីត្រូមីស៊ីន (Erythromycin) និង អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) លាយក្នុងទឹកឱ្យផឹករយៈពេល ៥ ថ្ងៃ
- ក្នុងករណីធ្ងន់ធ្ងរ ( មាន់មិនស៊ីចំណី) គេត្រូវ ចាក់អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)

## មីកូប្លាស្មា (Mycoplasma)

រោគសញ្ញា :

- បញ្ហាដង្ហើមមានសភាពប្រែប្រួល
- ដកដង្ហើមឮសូរក្រិកៗ
- ក្អករន្ទើន ឬកណ្តាស
- អត្រាឈឺខ្ពស់ តែអត្រាស្លាប់ទាប



ស្លាកស្នាម :

- រលាករន្ធច្រមុះ
- រលាកបំពង់ខ្យល់
- រលាកថង់ខ្យល់

ការព្យាបាល :

- មាន់ឈឺជំងឺនេះ តែងតែមានភាពស្មុគស្មាញដោយការវាយលុករបស់បាក់តេរីផ្សេងទៀត ។
- គ្រប់ប្រភេទពួកមីកូប្លាស្មា កបនឹងប្រភេទថ្នាំ ក្លរតែត្រាស៊ីគ្លីន (Chlortetracycline) អេរីត្រូមីស៊ីន (Erythromycin) ទីឡូស៊ីន (Tylosin) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin) ។ គេប្រើពួកវាដោយលាយក្នុងទឹកឱ្យផឹករយៈពេល ៧ ថ្ងៃ ។

ការការពារ :

- គេប្រើ ទីឡូស៊ីន ជាមួយ វីតាមីន សេ (Tylosin+Vitamin C) នៅពេលសត្វមកដល់ ដំបូង ដោយប្រើរយៈពេល ៧ថ្ងៃ បើអត្រា ប្រេវ៉ាឡង់របស់ជំងឺផ្លូវដង្ហើមខ្ពស់ ។

## ជំងឺអាសន្នរោគ (Fowl Cholera)

ជំងឺនេះបង្កឡើងដោយបាក់តេរី ប៉ាស្ទឺរេឡា (Pasteurella) វាច្រើនកើតឡើងដោយជាប់ទាក់ទង ជាមួយ ពួក មីកូប្លាស្មា បរាសិត កង្វះជីវជាតិ កង្វះអនាម័យ ។

រោគសញ្ញា :



- ងាប់លឿន
- ហើមណង់ ខ្ទង់ច្រមុះ បាតជើង និង សរសៃពួរ
- ភ្នែកមានខ្ទុះ
- ដង្ហក់
- មានហូរសំបោរចេញពីរន្ធច្រមុះ និងមាត់

ស្លាកស្នាម :



ការពារ :

- ប៉ាស្ទឺរេឡាអាចរស់នៅក្នុងមជ្ឈដ្ឋានសើមបានយូរថ្ងៃ (ដូចជាសំរាម ភក់ជ្រាំកន្លែងកខ្វក់)
- វាអាចរស់នៅបានយូរខែក្នុងសាកសពសត្វដែលរលួយ និងសើម
- តែវាងាយងាប់នៅពេល ត្រូវពន្លឺព្រះអាទិត្យ កម្តៅ ការសម្ងួត ។ ដូចនេះការសំអាត និង សម្ងួតនៅមជ្ឈដ្ឋានជុំវិញអាចជួយការពារ ជំងឺនេះបាន ។ មជ្ឈដ្ឋានល្អគឺជាវិធានការ ដ៏ល្អក្នុងការការពារជំងឺអាសន្នរោគ ។



ព្យាបាល :

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន ៥០ ម.ក្រ/ក្បាល
- លាយតេត្រាស៊ីគ្លីន ក្នុងចំណីឱ្យមាន់ស៊ី ៣០ ថ្ងៃ ព្រោះបាក់តេរីប៉ាស្ទឺរេឡាអាចរស់នៅក្នុងទឹក និងដីបាន ដល់ ៣ សប្តាហ៍
- ដូចនេះដើម្បីជៀសវាងកុំឱ្យមេរោគឆ្លងទៅក្នុងទឹក និងដី នៅពេលមាន់ស្លាប់គេចាំបាច់ត្រូវដុតសាកសពចោល ។

## III. ជំងឺរលាកពោះវៀន

ជំងឺរលាកពោះវៀនតែងបង្ហាញរោគសញ្ញាដូចជា :

- រាក
- រោមនៅជុំវិញក្លូអាក់មានសភាពកខ្វក់
- ស្រេកទឹក ខ្សោះទឹក
- សត្វអស់កំលាំង និងស្គមលឿន

**ការពិនិត្យលាមក និងការវះកាត់សាកសព អាចជាជំនួយក្នុងការធ្វើរោគវិនិច្ឆ័យ ។**

ជំងឺរលាកពោះវៀនអាចបណ្តាលមកពី :

- ព្រូន : អាស្ការីស កុកស៊ីដ្យូស៊ីស
- បាក់តេរី : អឺ កូលី សាល់ម៉ូណែឡា
- វីរុស : ហ្គុមបូរ៉ូ

## ព្រូនខាងក្នុង

ព្រូនមូល ( គ្រួសារអាស្ការី) និងព្រូនសំប៉ែតគឺកើតមានជាញឹកញាប់ចំពោះមាន់ចិញ្ចឹមព្រលែង ។



រោគសញ្ញា :

- លូតលាស់យឺត ពងបានតិច ហើយ សត្វងាយទទួលជំងឺ ។
- ជារឿយៗវាត្រូវបានរកឃើញនៅពេល វះកាត់សាកសពសត្វ ។

ការព្យាបាល និងការការពារ ( រាល់បីខែ)

- តេត្រាមីសូល (Tetramisole) សម្រាប់មាន់ ទម្ងន់ ២ គីឡូក្រាម ប្រើ ១០០ម.ក្រ
- ឬ ពីពែរ៉ាស៊ីន (Piperazine) ឬឡឺវ៉ាមីសូល (Levamisole) ...

## កុកស៊ីដ្យូស៊ីស

បង្កដោយពួកប្រូតូសូអ៊ែ ដែលហៅថាអ៊ែមីរីយ៉ា



រោគសញ្ញា :

- កើតមានលើកូនមាន់
- ស្គមកំព្រឹង
- ស្រេកទឹក
- ស្លឹកស្រពន់
- រោមបះ



- រាក ដោយសារលាកពោះវៀន
- ជារឿយៗវាមានការរាំយលុកបន្ទាប់ បន្សំដ៏សាំញ៉ាំរបស់មីកូប្លាស្មា។

ស្លាកស្នាម :



- មានខ្ទុះខាប់នៅក្នុងថង់ខ្យល់ ស្រោមបេះដូង និងនៅលើ ផ្ទៃនៃបេះដូង ថ្លើម និងសួត

ព្យាបាល :

- ត្រូវចាំថាអ៊ីកូលី ជាជំងឺឆ្លៀតឱកាស ដែលកើតមាន ក្រោយពីមានមីកូប្លាស្មា
- អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) គឺជាឱសថដែលមាន ប្រសិទ្ធភាព ប្រឆាំងបានបាក់តេរី ទាំង ២ ប្រភេទនេះ។

## សាល់ម៉ូណេឡូស៊ីស (Salmonellosis)

វាមានពួកសាល់ម៉ូណេឡាជាច្រើនប្រភេទ (Gallinarum, Pullorum...)

នៅពេលមានបញ្ហារលាកពោះវៀន គេគួរធ្វើរោគវិនិច្ឆ័យ ប្រៀបធៀប លើសាល់ម៉ូណេឡានេះ

រោគសញ្ញា ( ប្រភេទពុលឡូរ៉ូស Pullorose) :



- កើតមានលើកូនមាន់អាយុតិចជាង ២ សប្តាហ៍
- លាមករាកពណ៌សលឿង
- ក្លូអាក់បើកចំហដោយសារលាមកស្អិតជាប់។
- មាន់មិនស៊ីចំណី សំយ៉ុងក្បាលចុះក្រោម។

រោគសញ្ញា ( ប្រភេទទីហ្វូស Typhose):

- កើតមានលើមាន់ជំទង់
- មិនស៊ីចំណី សំកុក
- លាមកវាកពណ៌លឿងទៅខៀវមានឆ្អួតឈាម

ការចម្លង : ការចម្លង តាមរយៈស៊ុត ឬការប៉ះពាល់ផ្ទាល់ជាមួយសត្វ ដែលមានផ្ទុកជំងឺ

ស្លាកស្នាម :



- ពុលឡូរ៉ូស (Pullorose) : មានដុំពកពណ៌ប្រផេះនៅលើ ថ្លើម ផាល សួត បេះដូង កោះ និងពោះវៀន
- ទីហ្វូស (Typhose) : ថ្លើម និងផាលរីក ( មានពណ៌ លឿង) ផ្លូវអាហារគ្របដណ្តប់ដោយហ្វីប្រីន (Fibrin)

ការព្យាបាល :

- ប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine)
- ករណីកើតមានលើមនុស្ស ច្រើនបណ្តាលមកពីការបរិភោគ សាច់មាន់ ឬស៊ុតដែលមានមេរោគ ដោយមិនបានចម្អិន ឱ្យបានឆ្អិនល្អ ។

## ហ្គុំបូរ៉ូ (Gumboro)

- ជំងឺនេះបង្កឡើងដោយវីរុស

រោគសញ្ញា ៖



- កើតចំពោះមាន់អាយុតិចជាង ១០ អាទិត្យ ។
- មានសភាពអស់កម្លាំងខ្លាំង មិនអាចបញ្ជាខ្លួនវាបាន ។
- រាកទឹកពណ៌ស ប្រឡាក់ជាប់នៅរោមក្លូអាក់ មាន់ចឹកក្លូអាក់ និងរលាកក្លូអាក់

ស្លាកស្នាម ៖




- ថង់ក្លូអាក់មានសភាពហើម ពណ៌លឿង ហើយជួនកាលអាចមានឈាម

ការព្យាបាល ៖

- គ្មានការព្យាបាលទេ តែសត្វខ្លះអាចជាក្រោមមួយអាទិត្យ ។

## IV. ជំងឺលើប្រព័ន្ធសរសៃប្រសាទ

ជំងឺនេះបង្ហាញនូវរោគសញ្ញាប្រសាទដែលបណ្តាលដោយ ៖

- បាក់តេរី ៖ botulism
- វីរុស ៖ ដង្កោរែក ម៉ារិក
- សារធាតុគីមី ៖ ពុល ( ថ្នាំពុលសត្វល្អិត)

រោគសញ្ញាប្រសាទមានដូចជា ៖

- ប្រកាច់ តែវ៉ៃ
- ពិការ

## បូទុយលីស (Botulism)

- បង្កឡើងដោយបាក់តេរីក្លូសស្ទ្រីដ្យូម Clostridium botulimum
- បាក់តេរីនេះរស់នៅក្នុងបំពង់អាហាររបស់មាន់ និង បក្សីព្រៃ ក្នុងសំបុក ចំណី ទឹក ដែលមាន នៅក្នុងទ្រុងមាន់



- បន្ទាប់ពីសត្វងាប់ ពួកបាក់តេរីបានបញ្ចេញជាតិពុល
- ដង្កូវដែលមាននៅក្នុងសាកសពសត្វនេះពោរពេញទៅដោយជាតិពុល
- នៅពេលមាន់ស៊ីដង្កូវនេះ ធ្វើឱ្យវាកើតមានជំងឺ។

រោគសញ្ញា :



- ទន់ជើង ធ្លាក់ស្លាប ទន់ក និងធ្លាក់ត្របកភ្នែក
- ភាពទន់នេះផ្ដើមចេញពីជើង ទៅស្លាប ក និង ត្របកភ្នែក

ការការពារ :

- ប្រមូល និងកប់សាកសពសត្វ

ការព្យាបាល :

- អង់ទីប៊ីយ៉ូទិកមិនសូវមានប្រសិទ្ធភាពទេ ព្រោះវាសម្រាប់តែបាក់តេរី និងមិនសម្រាប់ការពុលទេ។ តែគេអាចប្រើប៉ង់ស្ទ្រឹប (Pen-Strep) បាន។

## ជំងឺញូវកាស (Newcastle)

រោគសញ្ញា :

- ជំងឺញូវកាសបង្កឱ្យមានការស្លាប់ ឬបញ្ហាដង្ហើមស្រួចស្រាវ តែរោគសញ្ញាប្រព័ន្ធប្រសាទអាច សង្កេតឃើញមានតែ លើមាន់ដែលឈឺបាន ២-៣ថ្ងៃ ប៉ុណ្ណោះ។

- ជាធម្មតា មាន់ដែលមានអាយុ ២-៣ សប្តាហ៍ បង្ហាញរោគសញ្ញា ពិបាកដកដង្ហើម ហើយបន្តមកទៀតគឺរាក និងសញ្ញាប្រព័ន្ធប្រសាទ។
- ធ្លាក់ស្លាប និងរមួលក



## ជំងឺមារិក (Marek)

ជំងឺមារិកបង្កឡើងដោយវីរុស ហើយវាជាប្រភេទមហារីកបក្សី។

រោគសញ្ញា :

- ខ្វិនជើងបណ្តោះអាសន្ន
- ជើងលាតសន្ធឹងទៅទិសផ្សេងគ្នា (ជើងមួយសណ្តូកទៅមុខ ឯជើងមួយទៀតសណ្តូកទៅក្រោយ) មាន់មានដំណើរវិលវល់មួយរយៈពេល ហើយនឹងត្រឡប់មកសភាពដើមវិញ។



ស្លាកស្នាម :



*សរសៃនៅ ផ្នែកខាងក្រោយជើង មានសភាពធម្មតា*

- រីកសរសៃប្រសាទ ជាពិសេសសរសៃនៅ ផ្នែកខាងក្រោយជើង
- មានដុំពកនៅថ្លើម ផាល តម្រងនោម បេះដូង សួត សាច់ដុំ និងទងកោះ

ការព្យាបាល : គ្មាន

ការការពារ :

- ការពារដោយធ្វើវ៉ាក់សាំងនៅពេលកំពុងញាស់ មិនត្រូវបានអនុវត្តទេចំពោះមាន់ចិញ្ចឹមព្រលែង។

## IV. បញ្ហាលើស្បែក និងរោម

បញ្ហាលើស្បែកអាចបង្កឡើងដោយ :

- បរាសិត : ចៃ ស្រមើល...
- វីរុស: អុតមាន់
- ការចឹកគ្នា : ទ្រុងចង្អៀត កង្វះសារធាតុរ៉ែ
- កង្វះវីតាមីន និងអាស៊ីតអាមីនេ

### បរាសិតខាងក្រៅ

- បរាសិតខាងក្រៅដែលច្រើនកើតនោះគឺចៃ
- ចៃបង្កឱ្យដាច់រលាត់ស្បែក
- មាន់នៅមិនស្ងៀម មិនសូវស៊ី ឬដេកមិនស្រួល
- កត្តាទាំងនេះធ្វើឱ្យការលូតលាស់យឺត ពងបានតិច និង ងាយទទួលជំងឺ

រោគសញ្ញា :

- មាន់មិនសូវបានសម្រាក មិនសូវស៊ីចំណីដូចធម្មតា
- វាធ្វើឱ្យធំយឺត និងថយពង
- បរាសិតអាចឃើញវានៅតាមគល់រោម



ការព្យាបាល ៖

ប្រើម៉ាឡាសុន ៥ % (Malathion 5%) បាញ់ផ្ទាល់ លើមាន់ ហើយរំលឹករៀងរាល់ ៣ ខែ ម្តង។

គេត្រូវធ្វើការសំអាតសំបុកផងដែរ។

ប្រើថ្នាំជក់ ឬស្លឹកស្តៅដាក់ក្នុងសំបុកមាន់ដើម្បីការពារស្រមើរ។

## ជំងឺអុត

បង្កឡើងដោយវីរុស។

រោគសញ្ញា ៖



- ស្លាកស្នាមដុំពកនៅត្រង់កន្លែងដែលគ្មានរោម (ភ្នែក គល់ចំពុះ...)

- ទំហំរបស់ដុំពកនេះរីកធំយ៉ាងរហ័ស ហើយរួមបញ្ចូលគ្នាទៅជា ទំហំធំពណ៌លឿង និងមានក្រមរក្រៀម
- ក្នុងទម្រង់ជាខាន់ស្លាក់ គេឃើញមានស្លាកស្នាមនៅក្នុងមាត់ បំពង់អាហារ និងបំពង់ខ្យល់ ដែលធ្វើឱ្យមានការពិបាកដកដង្ហើម



ការចម្លង :



- ការចម្លងកើតមានដោយសារប៉ះផ្ទាល់ជាមួយ នឹងស្បែកដែលដាច់
- ការខាំរបស់មូស និងសត្វល្អិតផ្សេងទៀត ក៏ជាការចម្លងជំងឺផងដែរ ។

ការព្យាបាល :

- គ្មានការព្យាបាល តែទោះយ៉ាងណាក៏ដោយ អុតមានការសាយភាយយឺតយើងអាចចាក់វ៉ាក់សាំងដើម្បីទប់ការរីករាលដាលរបស់វាបាន ។
- លាយ ស៊ុលហ្វា ទ្រីមេតូព្រីម ចំនួនមួយអ ៊ ដើម្បីបង្ការការចម្លងផ្សេងទៀតសម្រាប់មាន់ជំទង់ ។

ការចាក់វ៉ាក់សាំង :



- គ្មានការព្យាបាលទេ តែជំងឺអុតមានការសាយភាយយឺត ដូចនេះការចាក់វ៉ាក់សាំងអាចបញ្ឈប់ការសាយភាយបាន
- ចាក់វ៉ាក់សាំងការពារ ដោយការជួសស្លាប
- គេចាប់ធ្វើនៅពេលមាន់មានអាយុចាប់ពី ៧-១០ ថ្ងៃ
- ត្រូវប្រយ័ត្ន វ៉ាក់សាំងអុតជាប្រភេទវ៉ាក់សាំងរស់ ហើយវា បង្កជាជំងឺក្នុងទម្រង់ស្រាល ដូចនេះគេត្រូវចាក់តែមាន់ណា ដែលមានសុខភាពល្អ ។

## ការចឹកគ្នា

**រោគសញ្ញា :**

មាន់ចឹកគ្នារហូតដល់ស្លាប់

- ការចឹកគ្នាចាប់ផ្ដើមនៅពេលមិនទាន់ដុះរោមពេញ ឬនៅពេលមានអាយុ ២-៣ សប្ដាហ៍
- សភាពបែបនេះអាចបណ្ដាលឱ្យមានការចឹកគ្នាដ៏សាហាវ ជាពិសេសប្រសិនបើមានរបួសកើតមាន។



មាន់អាចរងរបួសយ៉ាងខ្លាំងដោយមាន់ផ្សេងទៀត

**មូលហេតុ :**

- កង្វះអំបិល សារធាតុរ៉ែ និងដោយសារបរាសិតខាងក្នុង
- ទីកន្លែងចង្អៀតពេក

**ការការពារ :**

- កាត់ចំពុះ
- ផ្ដល់ចំណីមានជាតិសរសៃខ្ពស់
- រៀបចំទីកន្លែងដែលសមស្របទៅនឹងបរិមាណមាន់ដែលមាន

## កង្វះពពួកវីតាមីន

- កង្វះវីតាមីន អា: ស្លាកស្នាមមាននៅលើភ្នែក ត្របកភ្នែកស្អិតជាប់គ្នា (វីតាមីនអា ជួយបង្កើតភ្នាសសើម)
- កង្វះវីតាមីន ដេ: ធ្វើឱ្យមាន់ដែលមានរោមពណ៌ខ្មៅពីកំណើតក្លាយទៅជាក្រហម និងត្នោត។
- កង្វះវីតាមីន បេកំប្លិច: ឃើញមានក្រមរក្រៀមនៅជុំវិញភ្នែក និងចំពុះ។ បាតជើងមានសភាពស្ងួតបែកក្រហែង និងក្រិនរួមជាមួយនឹងមានឈាម។



## កង្វះពពួកអាស៊ីតអាមីនេ



- លីស៊ីន (Lysine)៖ កង្វះលីស៊ីនធ្វើឱ្យអស់ពណ៌នៅរោមស្លាប
- មេត្យូនីន (Methionine)៖ រោមដុះមិនស្មើគ្នា រោមវែងខុសធម្មតា រោមមិនក្រាបរាបស្មើ ។

## តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត

| ឈ្មោះជំងឺ | ចាក់លើកទី ១ | ចាក់លើកទី ២ | ចាក់លើកក្រោយដើម្បីបន្តការពារ |
|---|---|---|---|
| ញូវកាស (I2) | អាយុ ១ថ្ងៃ | ២អាទិត្យ ក្រោយមក | |
| អាសន្នរោគ | អាយុ ៦អាទិត្យ | ៤អាទិត្យ ក្រោយមក | បន្ទាប់មក ២អាទិត្យមុនពង |
| អុត | កូនមាន់អាយុ ១អាទិត្យ ដល់ ១០អាទិត្យ | | |

ត្រូវកត់ត្រាថ្ងៃខែចាក់វ៉ាក់សាំងឱ្យច្បាស់ ដើម្បីប្រាកដថាសត្វទាំងអស់ត្រូវបានធ្វើវ៉ាក់សាំងទៀងទាត់ ។ បើសិនជាមិនធ្វើតាមកម្មវិធីឱ្យបានត្រឹមត្រូវទេនោះមានន័យថាសត្វមិនអាចការពារជំងឺបានល្អឡើយ ។

### កំណត់សម្គាល់ ៖

- ១០០ ក្រាម (ក្រ) = ១ ខាំ
- ១០ សង់ទីម៉ែត្រ (ស.ម) = ១ តឹក
- ១ មីលីលីត្រ (ម.ល) = ១ សេ សេ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការពិនិត្យ និងការព្យាបាល
# ជំងឺគោក្របី

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ

ជំពូក ១: ការពិនិត្យ និងព្យាបាលជំងឺ ........ ៤
ក. ការពិនិត្យទូទៅផ្នែកខាងក្រៅ ........ ៤
១- ការពិនិត្យស្ថានភាពដងខ្លួន ........ ៤
២- ការពិនិត្យលើស្បែកសត្វ ........ ៥
៣- ការពិនិត្យការឈរ និងចលនារបស់សត្វ ........ ៦
៤- ការពិនិត្យការដកដង្ហើម ........ ៧
៥- ការពិនិត្យការរំលាយអាហារ ........ ៩
៦- ការពិនិត្យទឹកនោម ........ ១១
ខ. ការពិនិត្យរោគសញ្ញាជាក់លាក់ ........ ១១
១- ការវាស់ស្ទង់សីតុណ្ហភាព ........ ១១
២- ការពិនិត្យស្បែក ........ ១២
៣- ការពិនិត្យភ្នែក ........ ១៣
៤- ការពិនិត្យមាត់ ........ ១៥
៥- ការពិនិត្យការហើម ........ ១៦
៦- ការពិនិត្យផ្លូវដង្ហើម ........ ១៧
៧- ការពិនិត្យផ្លូវរំលាយអាហារ ........ ១៩
៨- ការពិនិត្យចលនាដើរ ........ ២១
៩- ការពិនិត្យប្រដាប់បន្តពូជ ........ ២២
១០- ការពិនិត្យដោះ ........ ២៤
ជំពូក ២: បញ្ហា រោគសញ្ញា ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺ ........ ២៥
ក. ការងាប់ភ្លាមៗ ........ ២៥
១- ងាប់ដោយរន្ទះបាញ់ ........ ២៥
២- ជំងឺឈាមខ្មៅ (អង់ត្រាក់) ........ ២៦
៣- ជំងឺបូសខ្យល់ ........ ២៧

៤- ជំងឺសារទឹក ........ ២៩
៥- ការពុល ........ ៣១
៦- ពស់ចឹក ........ ៣២

**ខ. ភាពខ្សោយ និងការបាត់បង់ការឃ្លានចំណី** ........ ៣៣
១- គ្រុនក្តៅ ........ ៣៣
២- ជំងឺឆ្លង ........ ៣៤
៣- បរាសិត ........ ៣៨
៤- ការខ្វះសារធាតុចិញ្ចឹម ........ ៤៤

**គ. បញ្ហាលើស្បែក** ........ ៥០
១- បរាសិត ........ ៥០
២- ការបាត់បងជាតិពណ៌សំបុរ ........ ៥១
៣- ការជ្រុះរោម ........ ៥១
៤- ក្រម៉ ........ ៥២
៥- ដំបៅ ........ ៥៣
៦- ឬស្ស ........ ៥៣

**ឃ. បញ្ហាលើភ្នែក** ........ ៥៤
១- ការរលាកភ្នាសស្តើងភ្នែក ........ ៥៤
២- កែវភ្នែកពណ៌ផ្កាឈូក ........ ៥៥
៣- ការផ្លាស់ប្តូរពណ៌ភ្នាសស្តើងភ្នែក ........ ៥៦
៤- ភ្នែកខ្វាក់ ........ ៥៨

**ង. បញ្ហាដុំពក** ........ ៥៨
១- បូស ........ ៥៨
២- ការហើមមានឈាម ........ ៥៩
៣- ដុំពករឹង ........ ៥៩
៤- ការហើម ........ ៦១
៥- ក្លន ........ ៦១

**ច. ជំងឺលើផ្លូវដង្ហើម** ........ ៦២
១- ក្អក ........ ៦៣

២- ការហូរសំបោរ ..... ៦៥
៣- កណ្ដាស់ ..... ៦៧
៤- ពិបាកដកដង្ហើម ..... ៦៧
**ឆ. បញ្ហាលើផ្លូវរំលាយអាហារ** ..... ៧០
១- ការមិនស៊ីចំណី ..... ៧០
២- ការហូរទឹកមាត់ ..... ៧១
៣- ជំងឺរាក ..... ៧៥
៤- ហើមពោះ ..... ៧៩
៥- ការក្អៀន ..... ៨១
៦- ការខូចថ្លើម ..... ៨២
**ជ. បញ្ហា និងជំងឺលើការបន្តពូជ** ..... ៨៣
១- បញ្ហាមិនរកឈ្មោល ..... ៨៤
២- ការរកឈ្មោលឡើងវិញ ..... ៨៥
៣- ការហូរខ្ទុះតាមប្រដាប់បន្តពូជ ..... ៨៦
៤- ការរលូត ..... ៨៧
៥- បញ្ហាលំបាកកើតកូន ..... ៨៩
៦- បញ្ហាសុកធ្លាក់មិនអស់ ..... ៩២
៧- ស្បូនស្រុត ..... ៩២
**ឈ. ជំងឺលាសដោះ** ..... ៩៣
**ញ. បញ្ហា និងជំងឺលើជើង** ..... ៩៥
១- ពិការ ..... ៩៥
២- ខ្វិន ..... ១០០
**ជំពូក ៣: ការគ្រប់គ្រង និងចាក់ថ្នាំឱ្យបានត្រឹមត្រូវ** ..... ១០៣
១- សាឡុង ..... ១០៣
២- ការប្រើខ្សែគោ ..... ១០៤
៣- ការចាប់កាន់ក្បាល ..... ១០៤
៤- ការការពារការជុល ..... ១០៤
៥- ការចាក់ថ្នាំ ..... ១០៤

# ជំពូក ១ ការពិនិត្យ និងការព្យាបាលជំងឺ

ការធ្វើរោគវិនិច្ឆ័យជំងឺត្រឹមត្រូវមានសារៈសំខាន់ណាស់ដើម្បីឱ្យការព្យាបាលមានប្រសិទ្ធភាព។ ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវទាមទារការពិនិត្យសត្វអោយបានល្អិតល្អន់ និង គ្រប់ជ្រុងជ្រោយ។ នៅពេលសត្វឈឺ ជាជំហានដំបូងយើងត្រូវសាកសួរកសិករ អំពីរោគសញ្ញាជំងឺដែលគាត់បានឃើញ ។



រូបភាពទី ១: យើងដាច់ខាតត្រូវសាកសួរកសិករ មុននឹងធ្វើការពិនិត្យគោក្របី

ជាធម្មតា កសិករព្យាយាមព្យាបាលគោក្របីដោយខ្លួនឯង ដោយប្រើប្រាស់ថ្នាំបូរាណ ឬថ្នាំដែលគាត់ទិញពីកន្លែងលក់ថ្នាំសត្វ។ ការប្រើប្រាស់ថ្នាំខុសអាចធ្វើឱ្យបាត់បង់ ឬប្រែប្រួលនូវរោគសញ្ញាដំបូង ដែលជាចំណុចសំខាន់ណាស់ក្នុងការធ្វើរោគវិនិច្ឆ័យ ។

## ក. ការពិនិត្យទូទៅផ្នែកខាងក្រៅ

ការពិនិត្យទូទៅផ្នែកខាងក្រៅធ្វើឡើង នៅពេលយើងទៅជិតសត្វ។ យើងអាចធ្វើការអង្កេត និងអាច ឃើញនូវរោគសញ្ញាគួរឱ្យកត់សម្គាល់មួយចំនួនក្នុងចំងាយពី២ ទៅ ៣ម៉ែត្រពីសត្វ។

### ១. ការពិនិត្យស្ថានភាពដងខ្លួន

ការវាយតម្លៃស្ថានភាពដងខ្លួនសត្វ អាចជួយឱ្យយើងធ្វើរោគវិនិច្ឆ័យបាន។ ជាការពិត គោស្គម យើងនឹងសង្ស័យថា បណ្តាលមកពីការស៊ីចំណីមិនគ្រប់គ្រាន់ ខ្វះវីតាមីន និងសារធាតុរ៉ែមួយចំនួន ឬអាចជាជំងឺរ៉ាំរ៉ៃ។ គោស្គមអាចងាយទទួលរងនឹងជំងឺផ្សេងៗ ហើយពិបាកនឹងជាសះស្បើយណាស់ ។



រូបភាពទី២: ថ្ងៃនេះមេគោអត់ស៊ីចំណីហើយពិបាកធ្វើចលនា ប៉ុន្តែវាមិនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរដូចនេះក្នុងរយៈពេលយូរឡើយ

ផ្ទុយមកវិញបើគោមានកាយសម្បទាល្អមានជំងឺ ជំងឺនោះជារឿយៗមានលក្ខណៈស្រួចស្រាវ ។ ជាធម្មតាគោនឹងឈឺពី ២ ទៅ៣ ថ្ងៃ ប៉ុន្តែមិនបណ្តាលឱ្យប្រែប្រួលកាយសម្បទាឡើយ ។ ប្រសិនបើយើងធ្វើរោគវិនិច្ឆ័យ និងការព្យាបាលបានត្រឹមត្រូវ និងទាន់ពេលវេលា នោះសត្វនឹងជាសះស្បើយយ៉ាងរហ័ស។

*រូបភាពទី ៣: ថ្ងៃនេះគោបាត់អត់ស៊ីចំណី និងចុះខ្សោយ ប៉ុន្តែរោគសញ្ញានេះទើប នឹងកើតប៉ុណ្ណោះ*



## ២. ការពិនិត្យលើស្បែកសត្វ

ការពិនិត្យលើស្បែកអាចផ្តល់នូវព័ត៌មានល្អៗដូចជា :

- រោមបះ
- ទំពែកដោយសារជ្រុះរោម
- ប្រែពណ៌ ។ល ។

រោគសញ្ញាខាងលើនេះបង្ហាញពីការខ្វះសារធាតុចិញ្ចឹមច្រើនមុខ ។





*រូបភាពទី ៤ និង ទី ៥: ស្លាកស្នាមលើស្បែកប៉ះពាល់ដោយពន្លឺអាចបណ្តាលមកពីការខូចមុខងាររបស់ថ្លើម*



*រូបភាពទី ៦: ជំងឺងាយនឹងមើលឃើញ ប្រសិនបើយើងដើរពិនិត្យជុំវិញសត្វ*



រូបភាពទី ៧:
ដំបៅដោយសារប៉ះទង្គិចជាមួយវត្ថុអ្វីមួយ

## ៣. ការពិនិត្យការឈរ និងចលនារបស់សត្វ

នៅពេលយើងដើរទៅជិតគោ គោនឹងស្ទុះក្រោកឈរឡើង ធ្វើឱ្យយើងងាយស្រួលក្នុងការពិនិត្យថាតើ គោងើបឡើងដោយធម្មតា យឺត ពិបាកងើប ឬក៏មានបង្ហាញការឈឺចាប់ ។ល ។







រូបភាពទី ៨. ៩ និង ១០: អាកប្បកិរិយាងើបឈរធម្មតារបស់គោ

គោក្រោកឈរពិបាក ដោយសារ:

- គោចុះខ្សោយ: នៅពេលគោមានសីតុណ្ហភាពក្នុងខ្លួនខ្ពស់ ឬឈឺជាច្រើនថ្ងៃ ។
- ការខ្វះសារធាតុចិញ្ចឹម: ជាពិសេស កាល់ស្យូម (Ca) និងផូស្វ័រ (P) ក្រោយពេលកើតកូន ។
- បញ្ហាសរសៃប្រសាទ: ជំងឺពុលចំណីរលួយស្អុយ
- ការឈឺជើង: បណ្ដាលមកពីដំបៅ ឬរលាកសន្លាក់ជាដើម ។

យើងមានការងាយស្រួលក្នុងការកត់សម្គាល់ពីភាពមិនធម្មតា ឬពិការ នៅពេលគោឈរ :

- ងើបឈរ ប៉ុន្តែដើរចាវនៅលើជើង
- ដេកទៅវិញក្រោយពីឈរបានពីរបីនាទី
- យួរជើងម្ខាង





*រូបភាពទី ១១ និង ១២: យើងអាចមើលឃើញភ្លាមៗ ពេលសត្វមានរបួស ឬហើមសន្លាក់*

ស្លាកស្នាមលើក្រចក (ងាយមើលឃើញ)

- ក្រចកមិនលូតលាស់
- អាប់សែនៅឆ្អឹងខ្ចីនៃក្រចក
- សង្វែកជើងខុសធម្មតា

*រូបភាពទី ១៣: គោមានស្លាកស្នាមលើក្រចកបែប នេះមិនប៉ះពាល់ទេនៅពេលសត្វដើរ ធម្មតា ប៉ុន្តែវាប៉ះពាល់នៅពេលប្រើ វាធ្វើស្រែចំការឬជាកំលាំងអូសទាញ*



## ៤. ការពិនិត្យការដកដង្ហើម

គេអាចពិនិត្យឃើញការដកដង្ហើមនៅចំណាយពី ២ ទៅ ៣ម៉ែត្រ តែដើម្បីឱ្យការពិនិត្យមានភា ជាក់លាក់សត្វត្រូវ:

- សម្រាក ១០ នាទី មុនពេលពិនិត្យ
- សីតុណ្ហភាពបរិស្ថានជុំវិញមិនក្តៅពេក



*រូបភាពទី ១៤: យើងអង្កេតការដង្ហើមសត្វមើលត្រង់ កន្លែង ៣ភាគ៤នៃដងខ្លួនសត្វ*

ការដកដង្ហើមធម្មតា

គឺជាចលនាព្រមគ្នារវាងប្រអប់ទ្រូង និង ពោះ ។ ការដកដង្ហើមធម្មតាមានលក្ខណៈដូចខាងក្រោម:

- ១០-២០ដងក្នុងមួយនាទីសម្រាប់គោធំ
- ១៥-៣០ដងក្នុងមួយនាទីសម្រាប់កូនគោ

ការស្ទះដកដង្ហើម: ការដកដង្ហើមខុសធម្មតា

- ចលនាដង្ហើមកើនឡើងខុសធម្មតា
- ការដកដង្ហើមមិនមែនជាចលនាព្រមគ្នារវាងប្រអប់ទ្រូង និងពោះ:
  - ចលនាតែពោះ ប្រសិនបើសួតមានការឈឺចាប់
  - ចលនាតែប្រអប់ទ្រូង ប្រសិនបើពោះមានបញ្ហា

*រូបភាពទី ១៥: សត្វ ដកក និងហារមាត់ដកដង្ហើម ជាសញ្ញានៃការស្ទះដង្ហើម*



ការក្អក: នៅពេលសត្វក្អកយើងត្រូវធ្វើរោគវិនិច្ឆ័យ ប៉ុន្តែគួរសំគាល់ថា ជាធម្មតា សត្វក្អកនៅពេល ព្រឹកព្រលឹមដែលសីតុណ្ហភាពទាប និងនៅពេលមានសំណើមខ្ពស់ ឬ បន្ទាប់ពីការធ្វើការងារ ។



*រូបភាពទី ១៦: សត្វប្រឹងក្អក*

- ការក្អករយៈពេលវែង ប៉ុន្តែការក្អកនេះមិនបង្កដោយមេរោគទេ: សត្វដកដង្ហើមស្រូបចូលវែង រួចក្អក ចេញមកក្រៅខ្លាំង ជាទូទៅបណ្តាលមកពីរមាស់បំពង់ក ។

- ការក្អករយៈពេលខ្លី និងអាចបង្កដោយមេរោគ: សត្វដកដង្ហើមស្រូបចូលខ្លី រួចក្អកបញ្ចេញស្លេ មកក្រៅ ជាទូទៅអាចបង្កឡើងដោយមេរោគនៅក្នុងសួត ដែលអាចបង្កជា ជំងឺធ្ងន់ធ្ងរ ។

## ៥. ការពិនិត្យការរំលាយអាហារ

**ការស៊ីចំណី:** នៅពេលយើងសាកសួរកសិករ សំណួរសំខាន់ជាងគេគឺ តើសត្វស៊ីចំណីធម្មតាឬអ ប្រសិនបើការស៊ីចំណីថយចុះ ឬឈប់តែម្តង ជាចាំបាច់យើងត្រូវសួរថា តើសត្វលែ ស៊ីចំណីចាប់ពីពេលណាមក ?



*រូបភាពទី ១៧: សត្វឈប់ស៊ីចំណី ជាសញ្ញានៃបញ្ហាធ្ងន់ធ្ងរ*

**ការទំពាអៀង:** ជាសកម្មភាពដែលដុំចំណីដែលសត្វបានស៊ីរួចហើយ រុញច្រាលតាមបំពង់កមកវិ ហើយចូលទៅក្នុងមាត់ រួចសត្វចាប់ផ្តើមទំពាជាធម្មតា ដោយបញ្ចេញនូវទឹកមា បន្ថែម ដើម្បីបំបែកជាតិសរសៃឱ្យទៅជាបំណែកតូចៗ ។

*រូបភាពទី ១៨: នៅពេលសំរាកឬក្រោយពេលស៊ី ចំណីរួច គោនឹងធ្វើការទំពាអៀង ដោយស្ងៀមស្ងាត់*



**ហើមពោះ:** ការឡើងមេនៅក្នុងពោះធំបង្កើតបានជាឧស្ម័នយ៉ាងច្រើនពី ៣០-៥០ លីត្រក្នុងមួ ម៉ោង ។ នៅពេលដែលឧស្ម័ននេះមិនបានភាយចេញ ដោយមូលហេតុណាមួយ យើងនឹ ឃើញពោះខាងឆ្វេងឡើងហើមធំ និងឈឺចាប់ ។

លាមកៈ គេអាចឃើញលាមកសត្វនៅជុំវិញសត្វ និងបរិវេណជុំវិញ។



*រូបភាពទី ១៩: ក្នុងករណីមានរាក យើងនឹងឃើញមានប្រលាក់នៅលើកន្ទុយ*

**ព័ត៌មានតាមរយៈការពិនិត្យលាមកៈ**

- រាក
- ទល់លាមក
- ព័ណ៌លាមក
- លាមកមានលាយឈាម ឬសំបោរជាដើម



*រូបភាពទី ២០: លាមកធម្មតា*



*រូបភាពទី ២១: រាកមានសំបោរ*



*រូបភាពទី ២២: អាចរាកដោយសារស្មៅ*



*រូបភាពទី ២៣: គ្លៀន*

### ៦. ការពិនិត្យទឹកនោម

**ទឹកនោម:** ជាការល្អយើងត្រូវពិនិត្យសកម្មភាពនោមរបស់គោដោយខ្លួនឯងផ្ទាល់ ប៉ុន្តែជួនកាល អាចបង្កជាស្ត្រេស ដែលជាហេតុធ្វើឱ្យរាកនោម។ ដូចនេះ ចាំបាច់ត្រូវសាកសួរកសិករអំពីទឹកនោមរបស់គោ។



*រូបភាពទី ២៤: ទឹកនោមធម្មតាមានពណ៌លឿងស្រាល មានចំណុះ ១-២ លីត្រ និងនោមម្តងអស់តែម្តង*

**ជាការចាំបាច់យើងត្រូវដឹង:**

- ប្រសិនបើគោនោមតិច និងមានការឈឺចាប់នៅពេលឈប់នោម យើងអាចសង្ស័យថាគោមានជំងឺរលាកប្លោកនោម។
- ប្រសិនបើទឹកនោមមានពណ៌ត្នោត នោះមូលហេតុបណ្តាលមកពីការខូចថ្លើម (ដូចជាបង្កដោយ ជំងឺឡេបតូស្ពីរូស-Leptospirosis) ឬបែកគោសិកាឈាមក្រហម (ដូចជាបង្កដោយមេរោគបាបេស៊ីយ៉ា-Babesia)។

## ខ. ការពិនិត្យរោគសញ្ញាជាក់លាក់

ការពិនិត្យជាទូទៅ និង ដោយភ្នែកជួយឱ្យយើងធ្វើរោគវិនិច្ឆ័យដំបូង ប៉ុន្តែយើងត្រូវពិនិត្យឱ្យបានលំអិត ដោយការស្ទាប និងមធ្យោបាយផ្សេងៗដើម្បីបញ្ជាក់អំពីការធ្វើរោគវិនិច្ឆ័យ។

### ១. ការវាស់សីតុណ្ហភាព

ការវាស់សីតុណ្ហភាពត្រូវធ្វើជាប្រចាំ។

*រូបភាពទី ២៥: ការវាស់សីតុណ្ហភាពគោធំ*





*រូបភាពទី ២៦: ការវាស់សីតុណ្ហភាពកូនគោ*

សីតុណ្ហភាពខ្លួនខ្ពស់ ជាទូទៅជារោគសញ្ញានៃជំងឺឆ្លង ។

សីតុណ្ហភាពធម្មតាគឺៈ

- ៣៨,៥ អង្សាសេ សំរាប់គោធំ
- ៣៩,២ អង្សាសេ សំរាប់កូនគោ

ជាការល្អត្រូវវាស់សីតុណ្ហភាពខ្លួនសត្វនៅពេលព្រឹកក្នុងពេលដែលសត្វនៅស្ងៀម ពីព្រោះនៅពេលថ្ងៃ ក្រោមកំដៅ ថ្ងៃ ឬបន្ទាប់ពីធ្វើការងារ សីតុណ្ហភាពដងខ្លួងសត្វនឹងកើនឡើង ។

## ២. ការពិនិត្យស្បែក

ដើម្បីធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវយើងត្រូវស្ទាបស្បែករបស់សត្វ ។



*រូបភាពទី ២៧: ការស្ទាបស្បែកសត្វដោយផ្ទាល់*

- ការពិនិត្យជិត និងវែករោមដើម្បីរកមើលឃើញពពួកបរាសិត ជាពិសេសនៅតំបន់ជុំវិញកចន្លោះជើង និងជុំវិញផ្លូវបញ្ចេញចោល ។



*រូបភាពទី ២៨: សូមព្យាយាមបេះយកចេញពួកជាង្កែទាំងអស់នេះ*

- គេត្រូវស្ទាបស្បែកផ្ទាល់ដើម្បីរកកន្ទួល ឬក្រម៉



*រូបភាពទី ២៩: ក្រម៉តូចៗនៅក្រោមរោមអាចជារោគសញ្ញានៃជំងឺអង្គែ*

- ដំបៅអាចមើលដោយការពិនិត្យខាងក្រៅ ប៉ុន្តែជាចាំបាច់យើងត្រូវលាងសំអាតតំបន់ដំបៅនេះ ឱ្យបានស្អាត ដោយប្រើច្រាស់ និងសាប៊ូ ដើម្បីកំណត់កន្លែងរបួសឱ្យបានត្រឹមត្រូវ ។



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*

- ចាប់ទាញស្បែកសត្វថ្នមៗដើម្បីពិនិត្យមើល **ការបាត់បង់ជាតិទឹក** ។

*រូបភាពទី ៣១: នៅពេលសត្វមានបញ្ហាខ្សោះទឹក នោះធ្វើឱ្យស្បែករបស់វាអស់ភាពរស់ ជាពិសេសពេលទាញស្បែករួចវារួញទៅរកភាពដើមវិញ*



## ៣. ការពិនិត្យភ្នែក

ភ្នែកល្អមានសារៈសំខាន់ណាស់ចំពោះសត្វធ្វើការភ្ជួររាស់ ភ្នែកពិការធ្វើឱ្យថយចុះនូវគុណតម្លៃរបស់គោ ។

- ការពិនិត្យយ៉ាងជិតដើម្បីមើលការហូរទឹកភ្នែក

*រូបភាពទី ៣២: សត្វហូរទឹកភ្នែក*



- យើងត្រូវតែបើកតំបកភ្នែកសត្វ ដើម្បីមើលភ្នាសស្ដើងភ្នែក ជាពិសេសពណ៌របស់វា :
    - ភ្នែកពណ៌ស មានន័យថា កើតជំងឺខ្វះគ្រាប់ឈាមក្រហម ។
    - ពណ៌ក្រហមជាំ មានន័យថា មានជំងឺឆ្លងទូទៅធ្ងន់ធ្ងរ ។
    - ពណ៌លឿង មានន័យថា អាចមានជំងឺបាបេស្យាជាដើម ។



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*

- យើងត្រូវពិនិត្យកែវភ្នែក ដើម្បីរកដំបៅ ឬ ការប្រែពណ៌ទៅជាពណ៌ស ។

## ៤. ការពិនិត្យមាត់

ការហូរទឹកមាត់មិនធម្មតាជារោគសញ្ញាដែលគេជួបប្រទះជាទូទៅ ដូច្នេះយើងត្រូវបើកមាត់ដើម្បីពិនិត្យ ។

- ពិនិត្យអញ្ចាញធ្មេញៈ ជាពិសេសនៅពេលសត្វគោចេញទឹកមាត់ច្រើន ដើម្បីរកស្លាកស្នាមជំងឺអុតក្តាម ។

រូបភាពទី ៣៥: ការពិនិត្យអញ្ចាញធ្មេញដើម្បីដឹងពីជំងឺអុតក្តាម



- ពិនិត្យអណ្តាតៈ ដើម្បីរកស្លាកស្នាមជំងឺអុតក្តាម និងជំងឺផ្សេងៗទៀត ។

រូបភាពទី ៣៦: ការពិនិត្យអណ្តាត



- ស្ទាបបំពង់កដើម្បីពិនិត្យបូស ឬការស្លាក់ ( ដើមពោត...)

រូបភាពទី ៣៧: ការពិនិត្យក



- ការពិនិត្យធ្មេញជួយកំណត់អាយុរបស់សត្វគោ



រូបភាពទី ៣៨

(១) ក្រោមអាយុពីរឆ្នាំ (គ្មានធ្មេញអចិន្ត្រៃយ៍)

(២) អាយុពីរឆ្នាំ និងបីខែ (មានធ្មេញអចិន្ត្រៃយ៍ ២)

(៣) អាយុបីឆ្នាំ (មានធ្មេញអចិន្ត្រៃយ៍ ៤)

(៤) អាយុបីឆ្នាំ និងប្រាំមួយខែ (មានធ្មេញអចិន្ត្រៃយ៍៦)

(៥) អាយុបួនឆ្នាំ (មានធ្មេញអចិន្ត្រៃយ៍ ៨)

(៦) សត្វចាស់ អាយុលើសពីបួនឆ្នាំ

## ៩. ការពិនិត្យការហើម

ការស្ទាប ជាគោលការណ៍សំខាន់ក្នុងការកំណត់ពីមូលហេតុនៃការហើម។

- ស្ទាបដោយប្រើម្រាមដៃៈ ដើម្បីដឹងថាតើវា រឹង (ជាបូសអាប់សែ) ទន់ (ជាបូសមានឈាម) ហើយជួនកាលរឹងនៅផ្នែកខាងក្រៅ និងទន់ផ្នែកខាងក្នុង (អាចជាបូសអាប់សែកើតបាន ៨ថ្ងៃ)



រូបភាពទី ៣៩: ស្ទាបដុំពកនៅលើផ្នែកក

ក្នុងករណីហើម (ដោយគ្មានខ្ទុះ ឬឈាម) គេឃើញមានស្នាមទ្រុតនៅតែបន្តបន្ទាប់ពីដកម្រាមដៃ ចេញពី ២ ទៅ ៣ វិនាទីក្រោយមក ។



រូបភាពទី ៤០: ចំណុចហើមនៅលើក

- ស្ទាបដោយដៃ: ដើម្បីពិនិត្យមើលភាពក្តៅ ឬធម្មតា និង ឈឺចាប់ ឬអត់
- ការប្រើម្ជុល: ដើម្បីបូមយកវត្ថុរាវដើម្បីពិនិត្យមើលថាតើជា ខ្ទុះ ឈាម ឬសេរ៉ូម



រូបភាពទី ៤១: ចាក់ទំលុះដើម្បីដឹងថាវាជាខ្ទុះ ឬឈាម



រូបភាពទី ៤២: ខ្ទុះដែលបូមចេញពីដុំពក

## ៦. ការពិនិត្យផ្លូវដង្ហើម

គោឈឺជាទូទៅបណ្តាលមកពី ជំងឺផ្លូវដង្ហើម ។

**ការពិនិត្យចុងច្រមុះ**

- រន្ធច្រមុះត្រូវតែសើម និងស្អាត



*រូបភាពទី ៤៣: ពិនិត្យច្រមុះ*

• ជាការពិបាកក្នុងការពិនិត្យសំបោរ ពីព្រោះជាធម្មតាគោតែងតែលិឍសំអាតរន្ធច្រមុះវា ដូច្នេះ យើងត្រូវប្រើពិលដើម្បីពិនិត្យរន្ធច្រមុះ ។



*រូបភាពទី ៤៤: គោលិឍសំបោរ*



*រូបភាពទី ៤៥: ពិនិត្យមើលសំបោរគោ*

ការពិនិត្យបំពង់ខ្យល់

• ការសង្កត់នៅដើមបំពង់ក និង បំពង់ខ្យល់ បណ្តាលឱ្យសត្វក្អកៈ ការរាយការណ៍ពីកសិករ អំពីការក្អកញឹកញាប់ មានសារៈសំខាន់ណាស់ ពីព្រោះជាទូទៅពេលធ្វើការពិនិត្យសត្វមិនក្អកចេញ ។

*រូបភាពទី ៤៦: ពិនិត្យបំពង់ក និងបំពង់ខ្យល់គោ*



ការពិនិត្យសួត

• នៅពេលធ្វើការពិនិត្យជាទូទៅ យើងត្រូវគណនាចង្វាក់ដង្ហើមក្នុងមួយនាទី ដោយអង្កេត លើការឡើង និងចុះនៃឆ្អឹងជំនី ឬឆ្អកក្នុងមួយនាទី ដើម្បីកំណត់ពីបញ្ហាលំបាកដកដង្ហើម ។

• ដើម្បីធ្វើការអង្កេតបានល្អ យើងត្រូវគោះតំបន់ទ្រូងសត្វ ដើម្បីរកគេមើលពីតំបន់ ដែលមាន ភាពស្ពឹកកើនឡើង ( ខ្ទុះក្នុងសួត) ឬ ភាពខ្វះនៃសម្លេង ( សួរធម្មតា)



រូបភាពទី ៤៧: គោះទ្រូងគោដើម្បីដឹងពីសម្លេងនៅខាងក្នុង

- ការស្តាប់ដោយប្រើស្តេតូស្កុបវាមានការងាយស្រួលៈ គេអាចស្តាប់សម្លេងបេះដូង និងសួតបាន។



រូបភាពទី ៤៨: ការស្តាប់សម្លេងបេះដូង និងសួតដោយប្រើឧបករណ៍

## ៧. ការពិនិត្យផ្លូវរំលាយអាហារ

ជាទូទៅនៅពេលកំដៅដងខ្លួនឡើងខ្ពស់ ធ្វើឱ្យសត្វមិនស៊ីចំណី ឬស៊ីតិចតួ ដូចនេះយើងត្រូវពិនិត្យឱ្យបានហ្មត់ចត់ ដើម្បីស្វែងរកបុព្វហេតុបង្កជំងឺ។

មាត់ គឺជាចំនុចចាប់ផ្តើមនៃប្រព័ន្ធរំលាយអាហារ។ គោប្រើអណ្តាតបួងឬប្រមូលស្មៅស៊ី។ នៅពេលដែលគោមិនស៊ីស្មៅ យើងត្រូវបើកមាត់រកមើលថាតើអណ្តាត អញ្ចាញ និងធ្មេញមានសភាពធម្មតាឬអត់។



រូបភាពទី ៤៩: ពិនិត្យមើលក្រអូមមាត់គោ

បំពង់អាហារ គឺជាបំពង់សាច់ដុំដែលតភ្ជាប់ពីមាត់ទៅក្រពះ។ ក្នុងករណីសត្វកើតជំងឺហើមពោះ (Bloat) ជាការសំខាន់ត្រូវស្ទាបផ្នែកដើមក និងបំពងអាហារ។



រូបភាពទី ៥៧: គោះទ្រូងគោដើម្បីដឹងពីសម្លេងនៅខាងក្នុង

វត្ថុចំឡែកពីខាងក្រៅអាចធ្វើឱ្យស្ទះបំពង់ក និងធ្វើឱ្យឧស្ម័នមិនអាចចេញមកក្រៅបាន ដែលមូលហេតុបណ្តាលឱ្យពោះឡើងប៉ោងធំ ។

ពោះធំ គឺដូចជាអាងធំមួយដែលចំណី និងទឹកត្រូវបានបំលែងដោយមីក្រុប ដើម្បីផលិតប្រូតេអ៊ីន ថាមពល និងឧស្ម័ន។ មីក្រុបនៅក្នុងពោះធំអាចធ្វើការរំលាយប្រភេទចំណីផ្សេងៗបាន ប៉ុន្តែវាឆាប់នឹងទទួលរងការប្រែប្រួល នៅពេលមានការផ្លាស់ប្តូរចំណី។ នៅពេល ប៉េ ហាស (pH) នៅក្នុងពោះធំថយចុះ ពោះធំនឹងឈប់ដំណើរការ ហើយសត្វនឹងឈឺ។ នៅពេលសត្វឈប់ទំពារអៀង បញ្ជាក់ថាសត្វមានបញ្ហាប្រព័ន្ធរំលាយអាហារ ហើយពោះធំមិន ដំណើរសមស្របទៀតឡើយ ។

រូបភាពទី ៥១ : យើងត្រូវស្តាប់ការកន្ត្រាក់របស់ពោះធំ (១ ទៅ ៣ដង ក្នុងមួយនាទី) ដើម្បីប្រាកដថាពោះធំដំណើរការល្អ



ពោះចក គឺ ផ្នែកមួយរបស់ក្រពះសត្វទំពាអៀង មានតួនាទីជាអន្ទាក់នៅពេលសត្វលេបចូលវត្ថុចំឡែកចូលទៅ។ វត្ថុចំឡែកជាលោហៈធាតុអាចចាក់ទំលុះពោះចក និងបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ។



រូបទី ៥២ : ការស្វែងរកមូលហេតុនៃការស្រែករបស់សត្វបណ្តាលមកពីការឈឺពោះចក

## ៨. ការពិនិត្យចលនាដើរ

សាច់ដុំ ឆ្អឹង សន្លាក់ និងក្រចកទ្រទ្រង់ដងខ្លួនសត្វ និងអនុញ្ញាតឱ្យមានការផ្លាស់កន្លែង និង អកប្បកិរិយាធម្មតា ដើម្បីធ្វើរោគវិនិច្ឆ័យ ភ្នាក់ងារសុខភាពសត្វភូមិត្រូវអង្កេតចលនារបស់សត្វ។

រូបភាពទី ៥៣: ដើម្បីពិនិត្យបញ្ហាជើងផ្នែកខាងស្តាំ គេត្រូវដេញគោឱ្យដើរខាងស្តាំដៃយើង



**ការដើរសាក់ស្ទើរ:** សត្វមិនចង់ដើរនៅពេលដែលយើងរុញច្រាន ឬបង្ខំឱ្យវាដើរ។

រូបភាពទី ៥៤: សត្វមិនព្រមដើរទោះបីជាទាញវា



- រោគសញ្ញាឈឺក្រចកជើងធ្ងន់ធ្ងរ។
- ដោយសារសត្វខ្សោយខ្លាំងពេក ដូចជាបង្កដោយជំងឺស្រួចស្រាវ (ដែលមានសីតុណ្ហភាពក្នុងខ្លួនឡើងខ្ពស់) និងសារពាង្គកាយទាំងមូលឈឺចាប់។





រូបភាពទី ៥៥: ការពិនិត្យជើងមុខ រូបភាពទី ៥៦: ការពិនិត្យជើងក្រោយ រូបទី៥៧ ការពិនិត្យចង្អែកជើង

**ភាពពិការៈ** ភាពពិការបន្តិចបន្តួចក៏អាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើសត្វដែលធ្វើការភ្ជួររាស់។ ភាពពិការបង្ករឡើងជាចំបងដោយ ការឈឺសន្លាក់ ឬ ស្លាកស្នាមលើក្រចកជើងរយៈពេលយូរ។



*រូបភាពទី ៥៨: ការស្ទាបជង្គង់ដើម្បីដឹងពីទំហំ និងកំដៅរបស់សន្លាក*



*រូបភាពទី ៥៩: បត់ជង្គុងដើម្បីស្ទង់ពីការឈឺចាប់*

**ខ្វិនៈ** ជាស្ថានភាពដែលមិនអាចឈរបាន។ ទោះបីយើងព្យាយាមលើកសត្វឱ្យឈរដោយប្រើ មនុស្ស៤ទៅ ៥នាក់ក៏ដោយ ក៏សត្វនៅតែពុំអាចឈរត្រង់បានដែរ។

## ៩. ការពិនិត្យប្រដាប់បន្តពូជ

**ការពិនិត្យយោនីៈ** ការពិនិត្យយោនីជាការចាំបាច់ដើម្បីរកមើលពីៈ

- ការចេញទឹករំអិលខុសធម្មតា
- ដំបៅដែលធ្វើឱ្យសត្វមិនរកឈ្មោល

*រូបភាពទី ៦០: លើកកន្ទុយគោឡើងលើ ដើម្បីមើលយោនី ហើយគេអាចបើកបបូរមាត់យោនីដើម្បីមើលរន្ធយោនី។*



# ជំពូក ៦ ជំងឺ (រោគសញ្ញា និងការធ្វើរោគវិនិច្ឆ័យ)

## I. ការងាប់ស្រួចស្រាវ



ជំងឺជាច្រើនអាចបង្កឱ្យមាន់ងាប់ស្រួចស្រាវ គឺមានន័យថា មុនពេលងាប់ ១ថ្ងៃ មាន់មានសុខភាពធម្មតា ហើយព្រឹកថ្ងៃបន្ទាប់វាក៏ងាប់។ សាកសពមានសភាពធម្មតា។ ជាញឹកញាប់ ជំងឺទាំងនេះធ្វើការសាយភាយនៅក្នុងហ្វូងយ៉ាងលឿន ហើយធ្វើឱ្យមាន់ងាប់យ៉ាងច្រើន ដែលគេហៅថាជាការផ្ទុះជំងឺ។

មាន់ងាប់យ៉ាងរហ័ស ដោយមិនបញ្ចេញរោគសញ្ញា ឬ ស្លាកស្នាមច្បាស់លាស់ ដែលជាហេតុធ្វើឱ្យមានការលំបាក ក្នុងការធ្វើរោគវិនិច្ឆ័យ ដូចនេះចាំបាច់ត្រូវមានជំនួយវិភាគ ពីមន្ទីរពិសោធន៍។

ជំងឺផ្តាសាយបក្សី ញូវកាស ហ្គំបូរ៉ូ អាសន្នរោគ... អាចបណ្តាលឱ្យមានការស្លាប់ស្រួចស្រាវ។

### ជំងឺផ្តាសាយបក្សី

#### បង្កឡើងដោយវីរុស

- មានអត្រាស្លាប់ខ្ពស់ និងលឿន សូមនឹកគិត ទៅដល់ផ្តាសាយបក្សី
- កុំវះកាត់សាកសពសត្វ
- ទូរស័ព្ទទៅពេទ្យសត្វស្រុក ឬខេត្ត ឬទូរស័ព្ទផ្ទាល់ទៅកាន់លេខ ០១២ ៨៣៣-៧៩៥ ឬ ០១២ ២១៤-៩៧០ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល (DAHP)។

រោគសញ្ញាផ្សេងទៀតរួមមាន :

- ពិបាកដកដង្ហើម
- ខ្វិន ញ័រក្បាល



- ហើម ជាំឈាមនៅសិរ និងណង់



- ជាំឈាមនៅជើង



- មិនស៊ីចំណី សំកុក រោមបះ

ជំងឺផ្តាសាយបក្សីត្រូវ តែប្រុងប្រយ័ត្ន ព្រោះវាអាចចម្លងមកមនុស្សបាន។

## II. ជំងឺមានរោគសញ្ញាផ្លូវដង្ហើម

គ្រប់ជំងឺផ្លូវដង្ហើមទាំងអស់បង្ហាញប្រភេទរោគសញ្ញាដូចគ្នាគឺ :

- ពិបាកដកដង្ហើម
- ហូរសំបោរ ទឹកតាមភ្នែក និងច្រមុះ
- កណ្តាស
- ហើមឆ្អឹងរន្ធច្រមុះ





- ងើយ ក ពេលដកដង្ហើម

គេមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យចែកឱ្យដាច់ពីជំងឺផ្សេងៗដែលបង្កដោយបាក់តេរីដូចជា :

- កូរីសា (Coryza)
- ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ (CRD) ដូចជាមីកូប្លាស្មា
- ជំងឺអាសន្នរោគ

**អង់ទីប៊ីយ៉ូទិកមានប្រសិទ្ធភាពប្រឆាំងនឹងពួកជំងឺខាងលើបាន។**

ជំងឺខ្លះបង្កឡើងដោយវីរុស ដូចជា :

- ជំងឺផ្តាសាយបក្សី
- ជំងឺញូវកាស (ND)
- ជំងឺរលាកទងសួត(IB)
- ជំងឺរលាកដើមក និងបំពង់ខ្យល់ (ILT)

**អង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធភាពប្រឆាំងនឹងពួកវាបានទេ។**

## ជំងឺញូវកាស

### រោគសញ្ញា

រោគសញ្ញាលើផ្លូវដង្ហើមកើតឡើងដោយប្រភេទវីរុសជំងឺញូវកាសប្រភេទខ្សោយវាយលុក។



- រោគសញ្ញាផ្លូវដង្ហើម រួមមានដង្ហក់ ក្អក កណ្តាស
- រោគសញ្ញាប្រព័ន្ធប្រសាទរួមមានញាក់ញ័រ ធ្លាក់ស្លាប ខ្វិន រមួលក ដែលជាទូទៅច្រើនកើតមានបន្ទាប់ពីមានសញ្ញាផ្លូវដង្ហើម
- ការជ្រៀតចូលពួកបាក់តេរីឆ្លៀតឱកាសផ្សេងទៀត នឹងរឹតតែធ្វើឱ្យមានបញ្ហាផ្លូវដង្ហើមកាន់តែធ្ងន់ធ្ងរឡើង។





ការចម្លង រួមមាន ៖

- ដោយផ្ទាល់ តាមលាមក និង ទឹកសំបោរ ។
- ដោយប្រយោល តាមរយៈមជ្ឈដ្ឋានដែលមានមេរោគរួមមាន ចំណី ទឹក សំភារៈ និងសំលៀកបំពាក់ ។
- ចរាចរបក្សីរស់ដែលមានមេរោគ និង មនុស្សគឺជាប្រភពដ៏ចំបងក្នុងការសាយភាយជំងឺនៅប្រទេសកម្ពុជា ។
- ការធ្វើវ៉ាក់សាំងមិនបានត្រឹមត្រូវ ។

ព្យាបាល ៖

- គ្មានការព្យាបាលទេ ព្រោះវាបង្កឡើងដោយវីរុស ហើយអត្រាងាប់ខ្ពស់ ។

ការពារ ៖

- គេប្រើវ៉ាក់សាំង អាយធូ (I2) ដោយបន្តក់តាមភ្នែក
- គេបន្តក់វ៉ាក់សាំងនៅពេលមាន់អាយុ ១ ថ្ងៃ និង ៣ សប្តាហ៍ ទើបអាចការពារបានលើស ៦ខែ (ធ្វើវ៉ាក់សាំង ពីរលើក)
- មាន់ខ្លះមានភាពស៊ាំតាមរយៈការជាសះស្បើយពីជំងឺ (ប៉ុន្តែវាអាចចម្លងជំងឺទៅសត្វផ្សេងទៀតតាមរយៈលាមក...) ។

## ជំងឺរលាកទងសួត (IB)



ជំងឺនេះបង្កឡើងដោយវីរុស

រោគសញ្ញា :

- ក្អក
- កណ្តាស
- ដកដង្ហើមមានឮសូរក្រិកៗរណ្តំគ្នា
- ផលិតកម្មស៊ុតថយចុះ រួមជាមួយនឹងស៊ុតមានគុណភាពអន់ ។



ជាទូទៅស៊ុតមានទម្រង់មិនប្រក្រតី សំបកស្តើង ហើយផ្ទៃក ស៊ុតសមានសភាពរាវ ។

*ជំងឺរលាកទងសួតមានសភាពឆ្លងរាតត្បាតខ្លាំង ដោយធ្វើការចម្លងតាមខ្យល់ សត្វស្លាប់ និងសត្វកកេរ។*

## ជំងឺរលាកបំពង់សំលេង និង បំពង់ខ្យល់ (Laryngotracheitis)



រោគសញ្ញាផ្លូវដង្ហើម :

- ថប់ដង្ហើមយ៉ាងខ្លាំង
- ក្អក
- ដកចង្កាមាន់
- មាត់ និងចំពុះមានឈាម និងស្លេស ដោយសារហូរចេញពី បំពង់ខ្យល់ ព្រោះវាបង្កដោយការវាយលុកបំពងខ្យល់ ។

# ជំងឺកូរីសា (Coryza)



ជំងឺនេះបង្កឡើងដោយបាក់តេរី

រោគសញ្ញា :

- មានហូរសំបោរខ្លាំងចេញពីរន្ធច្រមុះ និងកណ្ដាស
- ភ្នែកឡើងក្រហម
- ហើមមុខនៅខាងក្រោមភ្នែក
- មិនឃើញមានរោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ
- សត្វមានអាយុកាន់តែច្រើនកាន់តែងាយទទួលជំងឺ



ការចម្លង :

- ការចម្លង សំខាន់ជាងគេនោះគឺការប៉ះពាល់ផ្ទាល់រវាងសត្វឈឺ និងជា
- ចរន្តខ្យល់បក់នាំមកជាមួយនូវធូលីដែលមានមេរោគ
- ទឹកផឹកដែលមានមេរោគរបស់ជំងឺនេះ ។

ព្យាបាល :



- ប្រើ អេរីត្រូមីស៊ីន (Erythromycin) និង អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) លាយក្នុងទឹកឱ្យផឹករយៈពេល ៥ ថ្ងៃ
- ក្នុងករណីធ្ងន់ធ្ងរ ( មាន់មិនស៊ីចំណី) គេត្រូវចាក់អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)

## មីកូប្លាស្មា (Mycoplasma)

រោគសញ្ញា ៖

- បញ្ហាដង្ហើមមានសភាពប្រែប្រួល
- ដកដង្ហើមឮសូរក្រិកៗ
- ក្អករន្ទើន ឬកណ្តាស
- អត្រាឈឺខ្ពស់ តែអត្រាស្លាប់ទាប



ស្លាកស្នាម ៖

- រលាករន្ធច្រមុះ
- រលាកបំពង់ខ្យល់
- រលាកថង់ខ្យល់

ការព្យាបាល ៖

- មាន់ឈឺជំងឺនេះ តែងតែមានភាពស្មុគស្មាញដោយការវាយលុករបស់បាក់តេរីផ្សេងទៀត ។
- គ្រប់ប្រភេទពួកមីកូប្លាស្មា កបនឹងប្រភេទថ្នាំ ក្លរតេត្រាស៊ីគ្លីន (Chlortetracycline) អេរីត្រូមីស៊ីន (Erythromycin) ទីឡូស៊ីន (Tylosin) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin)។ គេប្រើពួកវាដោយលាយក្នុងទឹកឱ្យផឹករយៈពេល ៧ ថ្ងៃ ។

ការការពារ ៖

- គេប្រើ ទីឡូស៊ីន ជាមួយ វីតាមីន សេ (Tylosin+Vitamin C) នៅពេលសត្វមកដល់ ដំបូង ដោយប្រើរយៈពេល ៧ថ្ងៃ បើអត្រា ប្រេវ៉ាឡង់របស់ជំងឺផ្លូវដង្ហើមខ្ពស់ ។

## ជំងឺអាសន្នរោគ (Fowl Cholera)

ជំងឺនេះបង្កឡើងដោយបាក់តេរី ប៉ាស្ទឺរេឡា (Pasteurella) វាច្រើនកើតឡើងដោយជាប់ទាក់ទង ជាមួយ ពួក មីកូប្លាស្មា បរាសិត កង្វះជីវជាតិ កង្វះអនាម័យ ។

រោគសញ្ញា :



- ងាប់លឿន
- ហើមណង់ ខ្ទង់ច្រមុះ បាតជើង និង សរសៃពួរ
- ភ្នែកមានខ្ទុះ
- ដង្ហក់
- មានហូរសំបោរចេញពីរន្ធច្រមុះ និងមាត់

ស្លាកស្នាម :



ការពារ :

- ប៉ាស្ទឺរេឡាអាចរស់នៅក្នុងមជ្ឈដ្ឋានសើមបានយូរថ្ងៃ (ដូចជាសំរាម ភក់ជ្រាំកន្លែងកខ្វក់)
- វាអាចរស់នៅបានយូរខែក្នុងសាកសពសត្វដែលរលួយ និងសើម
- តែវាងាយងាប់នៅពេល ត្រូវពន្លឺព្រះអាទិត្យ កម្ដៅ ការសម្ងួត ។ ដូចនេះការសំអាត និង សម្ងួតនៅមជ្ឈដ្ឋានជុំវិញអាចជួយការពារ ជំងឺនេះបាន ។ មជ្ឈដ្ឋានល្អគឺជាវិធានការ ដ៏ល្អក្នុងការការពារជំងឺអាសន្នរោគ ។



ព្យាបាល :

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន ៥០ ម.ក្រ/ក្បាល
- លាយតេត្រាស៊ីគ្លីន ក្នុងចំណីឱ្យមាន់ស៊ី ៣០ ថ្ងៃ ព្រោះបាក់តេរីប៉ាស៊្ទឺរេឡាអាចរស់នៅក្នុងទឹក និងដីបាន ដល់ ៣ សប្ដាហ៍
- ដូចនេះដើម្បីជៀសវាងកុំឱ្យមេរោគឆ្លងទៅក្នុងទឹក និងដី នៅពេលមាន់ស្លាប់គេចាំបាច់ត្រូវដុតសាកសពចោល ។

## III. ជំងឺរលាកពោះវៀន

ជំងឺរលាកពោះវៀនតែងបង្ហាញរោគសញ្ញាដូចជា :

- រាក
- រោមនៅជុំវិញក្លូអាក់មានសភាពកខ្វក់
- ស្រេកទឹក ខ្សោះទឹក
- សត្វអស់កំលាំង និងស្គមលឿន

ការពិនិត្យលាមក និងការវះកាត់សាកសព អាចជាជំនួយក្នុងការធ្វើរោគវិនិច្ឆ័យ ។

ជំងឺរលាកពោះវៀនអាចបណ្ដាលមកពី :

- ព្រូន : អាស្ការីស កុកស៊ីដ្យូស៊ីស
- បាក់តេរី : អ៊ី កូលី សាល់ម៉ូណែឡា
- វីរុស : ហ្គុមបូរ៉ូ

## ព្រូនខាងក្នុង

**ព្រូនមូល** ( គ្រួសារអាស្ការី) និងព្រូនសំប៉ែតគឺកើតមានជាញឹកញាប់ចំពោះមាន់ចិញ្ចឹមព្រលែង។



រោគសញ្ញា ៖

- លូតលាស់យឺត ពងបានតិច ហើយ សត្វងាយទទួលជំងឺ។
- ជារឿយៗវាត្រូវបានរកឃើញនៅពេល វះកាត់សាកសពសត្វ។

ការព្យាបាល និងការការពារ ( រាល់បីខែ)

- តេត្រាមីសូល (Tetramisole) សម្រាប់មាន់ ទម្ងន់ ២ គីឡូក្រាម ប្រើ ១០០ម.ក្រ
- ឬ ពីពែរ៉ាស៊ីន (Piperazine) ឬឡីវ៉ាមីសូល (Levamisole) ...

## កុកស៊ីដ្យូស៊ីស

បង្កដោយពួកប្រូតូសូអ៊ែ ដែលហៅថាអ៊ែមីរីយ៉ា

រោគសញ្ញា ៖



- កើតមានលើកូនមាន់
- ស្គមកំព្រឹង
- ស្រេកទឹក
- ស្លឹកស្រពន់
- រោមបះ



- លាមកអាចមានឈាម ដោយសារមេរោគធ្វើឱ្យដាច់រលាត់ភ្នាសពោះវៀន។



- ក្នុងករណីធ្ងន់ធ្ងរលាមកមានពពុះលាយឈាម

ការការពារ ៖

អនាម័យជាប្រចាំ កម្រាលត្រូវស្ងួតល្អ (ជាពិសេស សំអាតស្នូកទឹក)។

ការព្យាបាល ៖

- ប្រើស៊ុលហ្វា ៣៣ (Sulfadimerazine) លាយក្នុងទឹក ឱ្យផឹក ចំនួន ៣ថ្ងៃ ក្នុងកំរិត ១០ ម.ល ទឹកមួយលីត្រ ឬ
- ស៊ុលហ្វាឌីមីឌីន (Sulfadimidine) អំប្រូលីយ៉ូម (Amprolium) ឬ Toltrazuril (Baycox) ជាដើម ។

## កូលីបាក់ស៊ីឡូស៊ីស (Colibacillosis)

បង្កឡើងដោយ អ៊ី កូលី (E coli)

រោគសញ្ញា ៖

អ៊ីកូលីបំបែកខ្លួននៅក្នុងពោះវៀន តែ*រោគសញ្ញាដែល លេចចេញដំបូងគឺផ្លូវដង្ហើម* ដូច ទៅនឹង មីកូប្លាស្មា ដែរ ។

- ព្រោះបាក់តេរី អ៊ីកូលី សាយភាយចូលទៅក្នុងថង់ខ្យល់។
- មាន់ស្លឹកស្រពន់ រោមបះ ប្រឹងដកដង្ហើម ក្អក និងដកដង្ហើមឮសូរ។



- រាក ដោយសារលាកពោះវៀន
- ជារឿយៗវាមានការវាយលុកបន្ទាប់ បន្សំដ៏សាំញ៉ាំរបស់មីកូប្លាស្មា ។



ស្លាកស្នាម :

- មានខ្ទុះខាប់នៅក្នុងថង់ខ្យល់ ស្រោមបេះដូង និងនៅលើ ផ្ទៃនៃបេះដូង ថ្លើម និងសួត

ព្យាបាល :

- ត្រូវចាំថាអ៊ីកូលី ជាជំងឺឆ្លៀតឱកាស ដែលកើតមាន ក្រោយពីមានមីកូប្លាស្មា
- អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) គឺជាឱសថដែលមាន ប្រសិទ្ធភាព ប្រឆាំងបានបាក់តេរី ទាំង ២ ប្រភេទនេះ ។

## សាល់ម៉ូណេឡូស៊ីស (Salmonellosis)

វាមានពួកសាល់ម៉ូណេឡាជាច្រើនប្រភេទ (Gallinarum, Pullorum...)

នៅពេលមានបញ្ហារលាកពោះវៀន គេគួរធ្វើរោគវិនិច្ឆ័យ ប្រៀបធៀប លើសាល់ម៉ូណេឡានេះ



រោគសញ្ញា ( ប្រភេទពុលឡូរ៉ូស Pullorose) :

- កើតមានលើកូនមាន់អាយុតិចជាង ២ សប្ដាហ៍
- លាមករាកពណ៌សឡើង
- ក្លូអាក់បើកចំហដោយសារលាមកស្អិតជាប់ ។
- មាន់មិនស៊ីចំណី សំយ៉ុងក្បាលចុះក្រោម ។

រោគសញ្ញា ( ប្រភេទទីហ្វូស Typhose)៖

- កើតមានលើមាន់ជំទង់
- មិនស៊ីចំណី សំកុក
- លាមករាកពណ៌លឿងទៅខៀវមានឆ្នូតឈាម

ការចម្លង ៖ ការចម្លង តាមរយៈស៊ុត ឬការប៉ះពាល់ផ្ទាល់ជាមួយសត្វ ដែលមានផ្ទុកជំងឺ

ស្លាកស្នាម ៖



- ពុលឡូរ៉ូស (Pullorose) ៖ មានដុំពកពណ៌ប្រផេះនៅលើ ថ្លើម ផាល សួត បេះដូង កោះ និងពោះវៀន
- ទីហ្វូស (Typhose) ៖ ថ្លើម និងផាលរីក ( មានពណ៌ លឿង) ផ្លូវអាហារគ្របដណ្ដប់ដោយហ្វីប្រីន (Fibrin)

ការព្យាបាល ៖

- ប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine)
- ករណីកើតមានលើមនុស្ស ច្រើនបណ្ដាលមកពីការបរិភោគ សាច់មាន់ ឬស៊ុតដែលមានមេរោគ ដោយមិនបានចម្អិន ឱ្យបានឆ្អិនល្អ ។

## ហ្គុំបូរ៉ូ (Gumboro)

- ជំងឺនេះបង្កឡើងដោយវីរុស

រោគសញ្ញា :



- កើតចំពោះមាន់អាយុតិចជាង ១០ អាទិត្យ ។
- មានសភាពអស់កម្លាំងខ្លាំង មិនអាចបញ្ជាខ្លួនវាបាន ។
- រាកទឹកពណ៌ស ប្រឡាក់ជាប់នៅរោមក្លូអាក់ មាន់ចឹក ក្លូអាក់ និងរលាកក្លូអាក់

ស្លាកស្នាម :




- ថង់ក្លូអាក់មានសភាពហើម ពណ៌លឿង ហើយជួនកាលអាចមានឈាម

ការព្យាបាល :

- គ្មានការព្យាបាលទេ តែសត្វខ្លះអាចជាក្រោមមួយអាទិត្យ ។

## IV. ជំងឺលើប្រព័ន្ធសរសៃប្រសាទ

ជំងឺនេះបង្ហាញនូវរោគសញ្ញាប្រសាទដែលបណ្តាលដោយ :

- បាក់តេរី : botulism
- វីរុស : ដង្កោរែក ម៉ារិក
- សារធាតុគីមី : ពុល (ថ្នាំពុលសត្វល្អិត)

រោគសញ្ញាប្រសាទមានដូចជា :

- ប្រកាច់ តែរ៉ៃ
- ពិការ

## បូទុយលីស (Botulism)

- បង្កឡើងដោយបាក់តេរីក្លូសស្ទ្រីដ្យូម Clostridium botulimum
- បាក់តេរីនេះរស់នៅក្នុងបំពង់អាហាររបស់មាន់ និង បក្សីព្រៃ ក្នុងសំបុក ចំណី ទឹក ដែលមាន នៅក្នុងទ្រុងមាន់
- បន្ទាប់ពីសត្វងាប់ ពួកបាក់តេរីបានបញ្ចេញជាតិពុល
- ដង្កូវដែលមាននៅក្នុងសាកសពសត្វនេះពោរពេញទៅដោយជាតិពុល
- នៅពេលមាន់ស៊ីដង្កូវនេះ ធ្វើឱ្យវាកើតមានជំងឺ។



រោគសញ្ញា :

- ទន់ជើង ធ្លាក់ស្លាប ទន់ក និងធ្លាក់ត្របកភ្នែក
- ភាពទន់នេះផ្ដើមចេញពីជើង ទៅស្លាប ក និង ត្របកភ្នែក



ការការពារ :

- ប្រមូល និងកប់សាកសពសត្វ

ការព្យាបាល :

- អង់ទីប៊ីយ៉ូទិកមិនសូវមានប្រសិទ្ធភាពទេ ព្រោះវាសម្រាប់តែបាក់តេរី និងមិនសម្រាប់ការពុលទេ។ តែគេអាចប្រើប៉ង់ស្ត្រិប (Pen-Strep) បាន។

## ជំងឺញូវកាស (Newcastle)

រោគសញ្ញា :

- ជំងឺញូវកាសបង្កឱ្យមានការស្លាប់ ឬបញ្ហាដង្ហើមស្រួចស្រាវ តែរោគសញ្ញាប្រព័ន្ធប្រសាទអាច សង្កេតឃើញមានតែ លើមាន់ដែលឈឺបាន ២-៣ថ្ងៃ ប៉ុណ្ណោះ។

- ជាធម្មតា មាន់ដែលមានអាយុ ២-៣ សប្តាហ៍ បង្ហាញរោគសញ្ញា ពិបាកដកដង្ហើម ហើយបន្តមកទៀតគឺរាក និងសញ្ញាប្រព័ន្ធប្រសាទ។
- ធ្លាក់ស្លាប និងរមួលក



## ជំងឺមារិក (Marek)

ជំងឺមារិកបង្កឡើងដោយវីរុស ហើយវាជាប្រភេទមហារីកបក្សី។

រោគសញ្ញា ៖

- ខ្វិនជើងបណ្តោះអាសន្ន
- ជើងលាតសន្ធឹងទៅទិសផ្សេងគ្នា (ជើងមួយសណ្តូកទៅមុខ ឯជើងមួយទៀតសណ្តូកទៅក្រោយ) មាន់មានដំណើរវិលវល់មួយរយៈពេល ហើយនឹងត្រឡប់មកសភាពដើមវិញ។



ស្លាកស្នាម ៖



សរសៃទៅ ផ្នែកខាងក្រោយជើង មានសភាពធម្មតា

- រីកសរសៃប្រសាទ ជាពិសេសសរសៃទៅ ផ្នែកខាងក្រោយជើង
- មានដុំពកនៅថ្លើម ផាល តម្រងនោម បេះដូង សួត សាច់ដុំ និងទងកោះ

ការព្យាបាល ៖ គ្មាន

ការការពារ ៖

- ការពារដោយធ្វើវ៉ាក់សាំងនៅពេលកំពុងញាស់ មិនត្រូវបានអនុវត្តទេចំពោះមាន់ចិញ្ចឹមព្រលែង។

## IV. បញ្ហាលើស្បែក និងរោម

បញ្ហាលើស្បែកអាចបង្កឡើងដោយ ៖

- បរាសិត ៖ ចៃ ស្រមើល...
- វីរុសៈ អុតមាន់
- ការចីកគ្នា ៖ ទ្រុងចង្អៀត កង្វះសារធាតុរ៉ែ
- កង្វះវីតាមីន និងអាស៊ីតអាមីនេ

### បរាសិតខាងក្រៅ

- បរាសិតខាងក្រៅដែលច្រើនកើតនោះគឺចៃ
- ចៃបង្កឱ្យដាច់រលាត់ស្បែក
- មាន់នៅមិនស្ងៀម មិនសូវស៊ី ឬដេកមិនស្រួល
- កត្តាទាំងនេះធ្វើឱ្យការលូតលាស់យឺត ពងបានតិច និង ងាយទទួលជំងឺ

រោគសញ្ញា ៖

- មាន់មិនសូវបានសម្រាក មិនសូវស៊ីចំណីដូចធម្មតា
- វាធ្វើឱ្យធំយឺត និងថយពង
- បរាសិតអាចឃើញវានៅតាមគល់រោម



ការព្យាបាល ៖

ប្រើម៉ាឡាសុន ៥ % (Malathion 5%) បាញ់ផ្ទាល់ លើមាន់ ហើយរំលឹករៀងរាល់ ៣ ខែ ម្តង ។ គេត្រូវធ្វើការសំអាតសំបុកផងដែរ ។

ប្រើថ្នាំជក់ ឬស្លឹកស្តៅដាក់ក្នុងសំបុកមាន់ដើម្បីការពារស្រមើរ ។

## ជំងឺអុត

បង្កឡើងដោយវីរុស ។

រោគសញ្ញា ៖



- ស្លាកស្នាមដុំពកនៅត្រង់កន្លែងដែលគ្មានរោម (ភ្នែក គល់ចំពុះ...)



- ទំហំរបស់ដុំពកនេះរីកធំយ៉ាងរហ័ស ហើយរួមបញ្ចូលគ្នាទៅជា ទំហំធំពណ៌លឿង និងមានក្រមរក្រៀម
- ក្នុងទម្រង់ជាខាន់ស្លាក់ គេឃើញមានស្លាកស្នាមនៅក្នុងមាត់ បំពង់អាហារ និងបំពង់ខ្យល់ ដែលធ្វើឱ្យមានការពិបាកដកដង្ហើម

## ការចម្លង :



- ការចម្លងកើតមានដោយសារប៉ះផ្ទាល់ជាមួយនឹងស្បែកដែលដាច់
- ការខាំរបស់មូស និងសត្វល្អិតផ្សេងទៀត ក៏ជាការចម្លងជំងឺផងដែរ ។

## ការព្យាបាល :

- គ្មានការព្យាបាល តែទោះយ៉ាងណាក៏ដោយ អុតមានការសាយភាយយឺតយើងអាចចាក់វ៉ាក់សាំងដើម្បីទប់ការរីករាលដាលរបស់វាបាន ។
- លាយ ស៊ុលហ្វា ទ្រីមេតូព្រីម ចំនួនមួយអាទិត្យដើម្បីបង្ការការចម្លងផ្សេងទៀតសម្រាប់មាន់ជំទង់ ។

## ការចាក់វ៉ាក់សាំង :



- គ្មានការព្យាបាលទេ តែជំងឺអុតមានការសាយភាយយឺត ដូចនេះការចាក់វ៉ាក់សាំងអាចបញ្ឈប់ការសាយភាយបាន
- ចាក់វ៉ាក់សាំងការពារ ដោយការជួសស្លាប
- គេចាប់ធ្វើនៅពេលមាន់មានអាយុចាប់ពី ៧-១០ ថ្ងៃ
- ត្រូវប្រយ័ត្ន វ៉ាក់សាំងអុតជាប្រភេទវ៉ាក់សាំងរស់ ហើយវា បង្កជាជំងឺក្នុងទម្រង់ស្រាល ដូចនេះគេត្រូវចាក់តែមាន់ណា ដែលមានសុខភាពល្អ ។

## ការចឹកគ្នា

រោគសញ្ញា ៖



មាន់អាចរងរបួសយ៉ាងខ្លាំងដោយ
មាន់ជៀងទៀត

- មាន់ចឹកគ្នារហូតដល់ស្លាប់
- ការចឹកគ្នាចាប់ផ្តើមនៅពេលមិនទាន់ដុះរោមពេញ ឬនៅពេលមានអាយុ ២-៣ សប្តាហ៍
- សភាពបែបនេះអាចបណ្តាលឱ្យមានការចឹកគ្នាដ៏សាហាវ ជាពិសេសប្រសិនបើមានរបួសកើតមាន ។

មូលហេតុ ៖

- កង្វះអំបិល សារធាតុរ៉ែ និងដោយសារបរាសិតខាងក្នុង
- ទីកន្លែងចង្អៀតពេក

ការការពារ ៖

- កាត់ចំពុះ
- ផ្តល់ចំណីមានជាតិសរសៃខ្ពស់
- រៀបចំទីកន្លែងដែលសមស្របទៅនឹងបរិមាណមាន់ដែលមាន

## កង្វះពពួកវីតាមីន

- កង្វះវីតាមីន អា៖ ស្លាកស្នាមមាននៅលើភ្នែក ត្របកភ្នែកស្អិតជាប់គ្នា (វីតាមីនអា ជួយបង្កើតភ្នាសសើម)



- កង្វះវីតាមីន ដេ៖ ធ្វើឱ្យមាន់ដែលមានរោមពណ៌ខ្មៅពីកំណើតក្លាយទៅជាក្រហម និងត្នោត ។
- កង្វះវីតាមីន បេកំប្លិច៖ ឃើញមានក្រមរក្រៀមនៅជុំវិញភ្នែក និងចំពុះ ។ បាតជើងមានសភាពស្ងួតបែកក្រហែង និងក្រិនរួមជាមួយនឹងមានឈាម ។

## កង្វះពពួកអាស៊ីតអាមីនេ



- លីស៊ីន (Lysine)៖ កង្វះលីស៊ីនធ្វើឱ្យអស់ពណ៌នៅរោមស្លាប
- មេត្យូនីន (Methionine)៖ រោមដុះមិនស្មើគ្នា រោមវែងខុសធម្មតា រោមមិនក្រាបរាបស្មើ។

## តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត

| ឈ្មោះជំងឺ | ចាក់លើកទី ១ | ចាក់លើកទី ២ | ចាក់លើកក្រោយដើម្បីបន្តការពារ |
|---|---|---|---|
| ញូវកាស (I2) | អាយុ ១ថ្ងៃ | ២អាទិត្យ ក្រោយមក | |
| អាសន្នរោគ | អាយុ ៦អាទិត្យ | ៤អាទិត្យ ក្រោយមក | បន្ទាប់មក ២អាទិត្យមុនពង |
| អុត | កូនមាន់អាយុ ១អាទិត្យ ដល់ ១០អាទិត្យ | | |

ត្រូវកត់ត្រាថ្ងៃខែចាក់វ៉ាក់សាំងឱ្យច្បាស់ ដើម្បីប្រាកដថាសត្វទាំងអស់ត្រូវបានធ្វើវ៉ាក់សាំងទៀងទាត់។ បើសិនជាមិនធ្វើតាមកម្មវិធីឱ្យបានត្រឹមត្រូវទេនោះមានន័យថាសត្វមិនអាចការពារជំងឺបានល្អឡើយ។

### កំណត់សម្គាល់ ៖

- ១០០ ក្រាម (ក្រ) = ១ ខាំ
- ១០ សង់ទីម៉ែត្រ (ស.ម) = ១ តឹក
- ១ មីលីលីត្រ (ម.ល) = ១ សេ សេ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការពិនិត្យ និងការព្យាបាល ជំងឺគោក្របី

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ


**ជំពូក ១: ការពិនិត្យ និងព្យាបាលជំងឺ** ..... ៤

ក. ការពិនិត្យទូទៅផ្នែកខាងក្រៅ ..... ៤

១- ការពិនិត្យស្ថានភាពដងខ្លួន ..... ៤

២- ការពិនិត្យលើស្បែកសត្វ ..... ៥

៣- ការពិនិត្យការឈរ និងចលនារបស់សត្វ ..... ៦

៤- ការពិនិត្យការដកដង្ហើម ..... ៧

៥- ការពិនិត្យការរំលាយអាហារ ..... ៩

៦- ការពិនិត្យទឹកនោម ..... ១១

ខ. ការពិនិត្យរោគសញ្ញាជាក់លាក់ ..... ១១

១- ការវាស់ស្ទង់សីតុណ្ហភាព ..... ១១

២- ការពិនិត្យស្បែក ..... ១២

៣- ការពិនិត្យភ្នែក ..... ១៣

៤- ការពិនិត្យមាត់ ..... ១៥

៥- ការពិនិត្យការហើម ..... ១៦

៦- ការពិនិត្យផ្លូវដង្ហើម ..... ១៧

៧- ការពិនិត្យផ្លូវរំលាយអាហារ ..... ១៩

៨- ការពិនិត្យចលនាដើរ ..... ២១

៩- ការពិនិត្យប្រដាប់បន្តពូជ ..... ២២

១០-ការពិនិត្យដោះ ..... ២៤

**ជំពូក ២: បញ្ហា រោគសញ្ញា ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺ** ..... ២៥

ក. ការងាប់ភ្លាមៗ ..... ២៥

១- ងាប់ដោយរន្ទះបាញ់ ..... ២៥

២- ជំងឺឈាមខ្មៅ (អង់ត្រាក់) ..... ២៦

៣- ជំងឺបូសខ្យល់ ..... ២៧

៤- ជំងឺសារទឹក ........................................ ២៩
៥- ការពុល ........................................ ៣១
៦- ពស់ចឹក ........................................ ៣២
ខ. ភាពខ្សោយ និងការបាត់បង់ការឃ្លានចំណី ........................................ ៣៣
១- គ្រុនក្ដៅ ........................................ ៣៣
២- ជំងឺឆ្លង ........................................ ៣៤
៣- បរាសិត ........................................ ៣៨
៤- ការខ្វះសារធាតុចិញ្ចឹម ........................................ ៤៤
គ. បញ្ហាលើស្បែក ........................................ ៥០
១- បរាសិត ........................................ ៥០
២- ការបាត់បងជាតិពណ៌សំបុរ ........................................ ៥១
៣- ការជ្រុះរោម ........................................ ៥១
៤- ក្រម៉ ........................................ ៥២
៥- ដំបៅ ........................................ ៥៣
៦- ឬស្ស ........................................ ៥៣
ឃ. បញ្ហាលើភ្នែក ........................................ ៥៤
១- ការរលាកភ្នាសស្តើងភ្នែក ........................................ ៥៤
២- កែវភ្នែកពណ៌ផ្កាឈូក ........................................ ៥៥
៣- ការផ្លាស់ប្តូរពណ៌ភ្នាសស្តើងភ្នែក ........................................ ៥៦
៤- ភ្នែកខ្វាក់ ........................................ ៥៨
ង. បញ្ហាដុំពក ........................................ ៥៨
១- បូស ........................................ ៥៨
២- ការហើមមានឈាម ........................................ ៥៩
៣- ដុំពករឹង ........................................ ៥៩
៤- ការហើម ........................................ ៦១
៥- ក្លូន ........................................ ៦១
ច. ជំងឺលើផ្លូវដង្ហើម ........................................ ៦២
១- ក្អក ........................................ ៦៣

២- ការហួរសំបោរ ........ ៦៥
៣- កណ្ដាស់ ........ ៦៧
៤- ពិបាកដកដង្ហើម ........ ៦៧
ឆ. បញ្ហាលើផ្លូវរំលាយអាហារ ........ ៧០
១- ការមិនស៊ីចំណី ........ ៧០
២- ការហូរទឹកមាត់ ........ ៧១
៣- ជំងឺរាក ........ ៧៥
៤- ហើមពោះ ........ ៧៩
៥- ការក្អៀន ........ ៨១
៦- ការខូចធ្មេញ ........ ៨២
ជ. បញ្ហា និងជំងឺលើការបន្តពូជ ........ ៨៣
១- បញ្ហាមិនរកឈ្មោល ........ ៨៤
២- ការរកឈ្មោលឡើងវិញ ........ ៨៥
៣- ការហូរខ្ទុះតាមប្រដាប់បន្តពូជ ........ ៨៦
៤- ការរលូត ........ ៨៧
៥- បញ្ហាលំបាកកើតកូន ........ ៨៩
៦- បញ្ហាសុកធ្លាក់មិនអស់ ........ ៩២
៧- ស្បូនស្រុត ........ ៩២
ឈ. ជំងឺលាសដោះ ........ ៩៣
ញ. បញ្ហា និងជំងឺលើជើង ........ ៩៥
១- ពិការ ........ ៩៥
២- ខ្វិន ........ ១០០
**ជំពូក ៣: ការគ្រប់គ្រង និងចាក់ថ្នាំឱ្យបានត្រឹមត្រូវ** ........ ១០៣
១- សាឡុង ........ ១០៣
២- ការប្រើខ្សែគោ ........ ១០៤
៣- ការចាប់កាន់ក្បាល ........ ១០៤
៤- ការការពារការជុល ........ ១០៤
៥- ការចាក់ថ្នាំ ........ ១០៤

# ជំពូក ១ ការពិនិត្យ និងការព្យាបាលជំងឺ

ការធ្វើរោគវិនិច្ឆ័យជំងឺត្រឹមត្រូវមានសារៈសំខាន់ណាស់ដើម្បីឱ្យការព្យាបាលមានប្រសិទ្ធភាព ។ ការធ្វើរោគវិនិច្ឆ័យត្រឹមត្រូវទាមទារការពិនិត្យសត្វអោយបានល្អិតល្អន់ និង គ្រប់ជ្រុងជ្រោយ ។ នៅពេលសត្វឈឺ ជាជំហានដំបូងយើងត្រូវសាកសួរកសិករ អំពីរោគសញ្ញាជំងឺដែលគាត់បានឃើញ ។



*រូបភាពទី ១: យើងដាច់ខាតត្រូវសាកសួរកសិករ មុននឹងធ្វើការពិនិត្យគោក្របី*

ជាធម្មតា កសិករព្យាយាមព្យាបាលគោក្របីដោយខ្លួនឯង ដោយប្រើប្រាស់ថ្នាំបូរាណ ឬថ្នាំដែលគាត់ទិញពីកន្លែងលក់ថ្នាំសត្វ ។ ការប្រើប្រាស់ថ្នាំខុសអាចធ្វើឱ្យបាត់បង់ ឬប្រែប្រួលនូវរោគសញ្ញាដំបូង ដែលជាចំណុចសំខាន់ណាស់ក្នុងការធ្វើរោគវិនិច្ឆ័យ ។

## ក. ការពិនិត្យទូទៅផ្នែកខាងក្រៅ

ការពិនិត្យទូទៅផ្នែកខាងក្រៅធ្វើឡើង នៅពេលយើងទៅជិតសត្វ ។ យើងអាចធ្វើការអង្កេត និងអាច ឃើញនូវរោគសញ្ញាគួរឱ្យកត់សម្គាល់មួយចំនួនក្នុងចំងាយពី២ ទៅ ៣ម៉ែត្រពីសត្វ ។

### ១. ការពិនិត្យស្ថានភាពដងខ្លួន

ការវាយតម្លៃស្ថានភាពដងខ្លួនសត្វ អាចជួយឱ្យយើងធ្វើរោគវិនិច្ឆ័យបាន ។ ជាការពិត គោស្គម យើងនឹងសង្ស័យថា បណ្តាលមកពីការស៊ីចំណីមិនគ្រប់គ្រាន់ ខ្វះវីតាមីន និងសារធាតុរ៉ែមួយចំនួន ឬអាចជាជំងឺរ៉ាំរ៉ៃ ។ គោស្គមអាចងាយទទួលរងនឹងជំងឺផ្សេងៗ ហើយពិបាកនឹងជាសះស្បើយណាស់ ។



*រូបភាពទី២: ថ្ងៃនេះមេគោអត់ស៊ីចំណីហើយពិបាកធ្វើចលនា ប៉ុន្តែវាមិនស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរដូចនេះក្នុងរយៈពេលយូរឡើយ*

ផ្ទុយមកវិញបើគោមានកាយសម្បទាល្អមានជំងឺ ជំងឺនោះជារឿយៗមានលក្ខណៈស្រួចស្រាវ ។ ជាធម្មតាគោនឹងឈឺពី ២ ទៅ៣ ថ្ងៃ ប៉ុន្តែមិនបណ្តាលឱ្យប្រែប្រួលកាយសម្បទាឡើយ ។ ប្រសិនបើយើងធ្វើរោគវិនិច្ឆ័យ និងការព្យាបាលបានត្រឹមត្រូវ និងទាន់ពេលវេលា នោះសត្វនឹងជាសះស្បើយយ៉ាងរហ័ស ។

*រូបភាពទី ៣: ថ្ងៃនេះគោបាអត់ស៊ីចំណី និងចុះខ្សោយ ប៉ុន្តែរោគសញ្ញានេះទើប នឹងកើតប៉ុណ្ណោះ*



## ២. ការពិនិត្យលើស្បែកសត្វ

ការពិនិត្យលើស្បែកអាចផ្តល់នូវព័ត៌មានល្អៗដូចជា :

- រោមបះ
- ទំពែកដោយសារជ្រុះរោម
- ប្រែពណ៌ ។ល ។

រោគសញ្ញាខាងលើនេះបង្ហាញពីការខ្វះសារធាតុចិញ្ចឹមច្រើនមុខ ។





*រូបភាពទី ៤ និង ទី ៥: ស្លាកស្នាមលើស្បែកប៉ះពាល់ដោយពន្លឺអាចបណ្តាលមកពីការខូចមុខងាររបស់ថ្លើម*



*រូបភាពទី ៦: ជំពៅងាយនឹងមើលឃើញ ប្រសិនបើយើងដើរពិនិត្យជុំវិញសត្វ*



រូបភាពទី ៧:
ដំបៅដោយសារប៉ះទង្គិចជាមួយវត្ថុអ្វីមួយ

## ៣. ការពិនិត្យការឈរ និងចលនារបស់សត្វ

នៅពេលយើងដើរទៅជិតគោ គោនឹងស្ទុះក្រោកឈរឡើង ធ្វើឱ្យយើងងាយស្រួលក្នុងការពិនិត្យថាតើ គោងើបឡើងដោយធម្មតា យឺត ពិបាកងើប ឬក៏មានបង្ហាញការឈឺចាប់ ។ល ។







រូបភាពទី ៨. ៩ និង ១០: អាកប្បកិរិយាងើបឈរធម្មតារបស់គោ

គោក្រោកឈរពិបាក ដោយសារ:

- គោចុះខ្សោយ: នៅពេលគោមានសីតុណ្ហភាពក្នុងខ្លួនខ្ពស់ ឬឈឺជាច្រើនថ្ងៃ ។
- ការខ្វះសារធាតុចិញ្ចឹម: ជាពិសេស កាល់ស្យូម (Ca) និងផូស្វ័រ (P) ក្រោយពេលកើតកូន ។
- បញ្ហាសរសៃប្រសាទ: ជំងឺពុលចំណីរលួយស្អុយ
- ការឈឺជើង: បណ្តាលមកពីដំបៅ ឬរលាកសន្លាក់ជាដើម ។

យើងមានការងាយស្រួលក្នុងការកត់សម្គាល់ពីភាពមិនធម្មតា ឬពិការ នៅពេលគោឈរ :

- ងើបឈរ ប៉ុន្តែដើរចារនៅលើជើង
- ដេកទៅវិញក្រោយពីឈរបានពីរបីនាទី
- យួរជើងម្ខាង




រូបភាពទី ១១ និង ១២: យើងអាចមើលឃើញភ្លាមៗ ពេលសត្វមានរបួស ឬហើមសន្លាក់

ស្លាកស្នាមលើក្រចក (ងាយមើលឃើញ)

- ក្រចកមិនលូតលាស់
- អាប់សៃនៅឆ្អឹងខ្ចីនៃក្រចក
- សង្វែកជើងខុសធម្មតា



រូបភាពទី ១៣: គោមានស្លាកស្នាមលើក្រចកបែប នេះមិនប៉ះពាល់ទេនៅពេលសត្វដើរ ធម្មតា ប៉ុន្តែវាប៉ះពាល់នៅពេលប្រើ វាធ្វើស្រែចំការឬជាកំលាំងអូសទាញ

## ៤. ការពិនិត្យការដកដង្ហើម

គេអាចពិនិត្យឃើញការដកដង្ហើមនៅចំណាយពី ២ ទៅ ៣ម៉ែត្រ តែដើម្បីឱ្យការពិនិត្យមានភាព ជាក់លាក់សត្វត្រូវ:

- សម្រាក ១០ នាទី មុនពេលពិនិត្យ
- សីតុណ្ហភាពបរិស្ថានជុំវិញមិនក្តៅពេក



រូបភាពទី ១៤: យើងអង្កេតការដង្ហើមសត្វមើលត្រង់ កន្លែង ៣ភាគ៤នៃដងខ្លួនសត្វ

**ការដកដង្ហើមធម្មតា**

គឺជាចលនាព្រមគ្នារវាងប្រអប់ទ្រូង និង ពោះ ។ ការដកដង្ហើមធម្មតាមានលក្ខណៈដូចខាងក្រោមៈ

- ១០-២០ដងក្នុងមួយនាទីសម្រាប់គោធំ
- ១៥-៣០ដងក្នុងមួយនាទីសម្រាប់កូនគោ

**ការស្ទះដកដង្ហើមៈ ការដកដង្ហើមខុសធម្មតា**

- ចលនាដង្ហើមកើនឡើងខុសធម្មតា
- ការដកដង្ហើមមិនមែនជាចលនាព្រមគ្នារវាងប្រអប់ទ្រូង និងពោះ:
  - ចលនាតែពោះ ប្រសិនបើសួតមានការឈឺចាប់
  - ចលនាតែប្រអប់ទ្រូង ប្រសិនបើពោះមានបញ្ហា

*រូបភាពទី ១៥: សត្វ ដកក និងហារមាត់ដកដង្ហើម ជាសញ្ញានៃការស្ទះដង្ហើម*



**ការក្អកៈ** នៅពេលសត្វក្អកយើងត្រូវធ្វើរោគវិនិច្ឆ័យ ប៉ុន្តែគួរសំគាល់ថា ជាធម្មតា សត្វក្អកនៅពេល ព្រឹកព្រលឹមដែលសីតុណ្ហភាពទាប និងនៅពេលមានសំណើមខ្ពស់ ឬ បន្ទាប់ពីការធ្វើការងារ ។



*រូបភាពទី ១៦: សត្វប្រឹងក្អក*

- ការក្អករយៈពេលវែង ប៉ុន្តែការក្អកនេះមិនបង្កដោយមេរោគទេៈ សត្វដកដង្ហើមស្រូបចូលវែង រួចក្អក ចេញមកក្រៅខ្លាំង ជាទូទៅបណ្ដាលមកពីរមាស់បំពង់ក ។

- ការក្អករយៈពេលខ្លី និងអាចបង្កដោយមេរោគៈ សត្វដកដង្ហើមស្រូបចូលខ្លី រួចក្អកបញ្ចេញស្លេស មកក្រៅ ជាទូទៅអាចបង្កឡើងដោយមេរោគនៅក្នុងសួត ដែលអាចបង្កជា ជំងឺធ្ងន់ធ្ងរ ។

## ៥. ការពិនិត្យការរំលាយអាហារ

**ការស៊ីចំណីៈ** នៅពេលយើងសាកសួរកសិករ សំណួរសំខាន់ជាងគេគឺ តើសត្វស៊ីចំណីធម្មតាឬអត់ ប្រសិនបើការស៊ីចំណីថយចុះ ឬឈប់តែម្តង ជាចាំបាច់យើងត្រូវសួរថា តើសត្វលែងស៊ីចំណីចាប់ពីពេលណាមក ?



*រូបភាពទី ១៧: សត្វឈប់ស៊ីចំណី ជាសញ្ញានៃបញ្ហាធ្ងន់ធ្ងរ*

**ការទំពាអៀងៈ** ជាសកម្មភាពដែលដុំចំណីដែលសត្វបានស៊ីរួចហើយ រុញច្រាលតាមបំពង់កមកវិញ ហើយចូលទៅក្នុងមាត់ រួចសត្វចាប់ផ្តើមទំពាជាធម្មតា ដោយបញ្ចេញនូវទឹកមាត់បន្ថែម ដើម្បីបំបែកជាតិសរសៃឱ្យទៅជាបំណែកតូចៗ ។

*រូបភាពទី ១៨: នៅពេលសំរាកឬក្រោយពេលស៊ីចំណីរួច គោនឹងធ្វើការទំពាអៀងដោយស្ងៀមស្ងាត់*



**ហើមពោះៈ** ការឡើងមេនៅក្នុងពោះធំបង្កើតបានជាឧស្ម័នយ៉ាងច្រើនពី ៣០-៥០ លីត្រក្នុងមួយម៉ោង ។ នៅពេលដែលឧស្ម័ននេះមិនបានភាយចេញ ដោយមូលហេតុណាមួយ យើងនឹងឃើញពោះខាងឆ្វេងឡើងហើមធំ និងឈឺចាប់ ។

លាមកៈ គេអាចឃើញលាមកសត្វនៅជុំវិញសត្វ និងបរិវេណជុំវិញ ។



រូបភាពទី ១៩: ក្នុងករណីមានរាក យើងនឹងឃើញមានប្រលាក់នៅលើកន្ទុយ

**ព័ត៌មានតាមរយៈការពិនិត្យលាមកៈ**

- រាក
- ទល់លាមក
- ព័ណ៌លាមក
- លាមកមានលាយឈាម ឬសំបោរជាដើម



រូបភាពទី ២០: លាមកធម្មតា



រូបភាពទី ២១: រាកមានសំបោរ



រូបភាពទី ២២: អាចរាកដោយសារស្មៅ



រូបភាពទី ២៣: ក្អៀន

### ៦. ការពិនិត្យទឹកនោម

**ទឹកនោម:** ជាការល្អយើងត្រូវពិនិត្យសកម្មភាពនោមរបស់គោដោយខ្លួនឯងផ្ទាល់ ប៉ុន្តែជួនកាល អាចបង្កជាស្រេស ដែលជាហេតុធ្វើឱ្យរាកនោម ។ ដូចនេះ ចាំបាច់ត្រូវសាកសួរកសិក រអំពីទឹកនោមរបស់គោ ។



*រូបភាពទី ២៤: ទឹកនោមធម្មតាមានពណ៌លឿងស្រាល មានចំណុះ ១-២ លីត្រ និងនោមម្តងអស់តែម្តង*

**ជាការចាំបាច់យើងត្រូវដឹង:**

- ប្រសិនបើគោនោមតិច និងមានការឈឺចាប់នៅពេលឈប់នោម យើងអាចសង្ស័យថានឹង មានជំងឺរលាកប្លោកនោម ។
- ប្រសិនបើទឹកនោមមានពណ៌ត្នោត នោះមូលហេតុបណ្តាលមកពីការខូចថ្លើម (ដូចជាបង្ក ដោយ ជំងឺឡេបតូស្ពីរូស-Leptospirosis) ឬបែកគោសិកាឈាមក្រហម (ដូចជាបង្ក ដោយមេរោគបាបេស៊ីយ៉ា-Babesia) ។

## ខ. ការពិនិត្យរោគសញ្ញាជាក់លាក់

ការពិនិត្យជាទូទៅ និង ដោយភ្នែកជួយឱ្យយើងធ្វើរោគវិនិច្ឆ័យដំបូង ប៉ុន្តែយើងត្រូវពិនិត្យឱ្យបាន លំអិត ដោយការស្ទាប និងមធ្យោបាយផ្សេងៗដើម្បីបញ្ជាក់អំពីការធ្វើរោគវិនិច្ឆ័យ ។

### ១. ការវាស់សីតុណ្ហភាព

ការវាស់សីតុណ្ហភាពត្រូវធ្វើជាប្រចាំ ។

*រូបភាពទី ២៥: ការវាស់សីតុណ្ហភាពគោធំ*





*រូបភាពទី ២៦: ការវាស់សីតុណ្ហភាពកូនគោ*

សីតុណ្ហភាពខ្លួនខ្ពស់ ជាទូទៅជារោគសញ្ញានៃជំងឺឆ្លង ។

សីតុណ្ហភាពធម្មតាគឺ:

- ៣៨,៥ អង្សាសេ សំរាប់គោធំ
- ៣៩,២ អង្សាសេ សំរាប់កូនគោ

ជាការល្អត្រូវវាស់សីតុណ្ហភាពខ្លួនសត្វនៅពេលព្រឹកក្នុងពេលដែលសត្វនៅស្ងៀម ពីព្រោះនៅពេលថ្ងៃ ក្រោមកំដៅ ថ្ងៃ ឬបន្ទាប់ពីធ្វើការងារ សីតុណ្ហភាពដងខ្លួងសត្វនឹងកើនឡើង ។

## ២. ការពិនិត្យស្បែក

ដើម្បីធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវយើងត្រូវស្ទាបស្បែករបស់សត្វ ។



រូបភាពទី ២៧: ការស្ទាបស្បែកសត្វដោយផ្ទាល់

- ការពិនិត្យជិត និងវែករោមដើម្បីរកមើលឃើញពពួកបរាសិត ជាពិសេសនៅតំបន់ជុំវិញកចន្លោះជើង និងជុំវិញផ្លូវបញ្ចេញចោល ។



រូបភាពទី ២៨: សូមព្យាយាមបេះយកចេញ ពួកជាង្កែទាំងអស់នេះ

- គេត្រូវស្ទាបស្បែកផ្ទាល់ដើម្បីរកកន្ទួល ឬក្រម៉



រូបភាពទី ២៩: ក្រម៉តូចៗនៅក្រោមរោមអាចជារោគសញ្ញានៃជំងឺអង្គែ

- ដំបៅអាចមើលដោយការពិនិត្យខាងក្រៅ ប៉ុន្តែជាចាំបាច់យើងត្រូវលាងសំអាតតំបន់ដំបៅនេះ ឱ្យបានស្អាត ដោយប្រើច្រាស់ និងសាប៊ូ ដើម្បីកំណត់កន្លែងរបួសឱ្យបានត្រឹមត្រូវ ។



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*

- ចាប់ទាញស្បែកសត្វថ្នមៗដើម្បីពិនិត្យមើល **ការបាត់បង់ជាតិទឹក** ។



*រូបភាពទី ៣១: នៅពេលសត្វមានបញ្ហាខ្សោះទឹក នោះធ្វើឱ្យស្បែករបស់វាអស់ភាពរស់ ជាពិសេសពេលទាញស្បែករួចវារួញ ទៅរកភាពដើមវិញ*

## ៣. ការពិនិត្យភ្នែក

ភ្នែកល្អមានសារៈសំខាន់ណាស់ចំពោះសត្វធ្វើការភ្ជួររាស់ ភ្នែកពិការធ្វើឱ្យថយចុះនូវគុណតម្លៃរបស់គោ ។

- ការពិនិត្យយ៉ាងជិតដើម្បីមើល**ការហូរទឹកភ្នែក**



*រូបភាពទី ៣២: សត្វហូរទឹកភ្នែក*

- យើងត្រូវតែបើកតំបកភ្នែកសត្វ ដើម្បីមើលភ្នាសស្តើងភ្នែក ជាពិសេសពណ៌របស់វា ៖
  - ភ្នែកពណ៌ស មានន័យថា កើតជំងឺខ្វះគ្រាប់ឈាមក្រហម ។
  - ពណ៌ក្រហមជាំ មានន័យថា មានជំងឺឆ្លងទូទៅធ្ងន់ធ្ងរ ។
  - ពណ៌លឿង មានន័យថា អាចមានជំងឺបាបេស្យាជាដើម ។



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*



*រូបភាពទី ៣០: ការលាងសំអាតកន្លែងដំបៅ*

- យើងត្រូវពិនិត្យកែវភ្នែក ដើម្បីរកដំបៅ ឬ ការប្រែពណ៌ទៅជាពណ៌ស ។

## ៤. ការពិនិត្យមាត់

ការហូរទឹកមាត់មិនធម្មតាជារោគសញ្ញាដែលគេជួបប្រទះជាទូទៅ ដូច្នេះយើងត្រូវបើកមាត់ដើម្បីពិនិត្យ ។

- ពិនិត្យអញ្ចាញធ្មេញ: ជាពិសេសនៅពេលសត្វគោចេញទឹកមាត់ច្រើន ដើម្បីរកស្លាកស្នាមជំងឺអុតក្តាម ។



*រូបភាពទី ៣៥: ការពិនិត្យអញ្ចាញធ្មេញដើម្បីដឹងពីជំងឺអុតក្តាម*

- ពិនិត្យអណ្តាត: ដើម្បីរកស្លាកស្នាមជំងឺអុតក្តាម និងជំងឺផ្សេងៗទៀត ។



*រូបភាពទី ៣៦: ការពិនិត្យអណ្តាត*

- ស្ទាបបំពង់កដើម្បីពិនិត្យបូស ឬការស្លាក់ (ដើមពោត...)



*រូបភាពទី ៣៧: ការពិនិត្យក*

- ការពិនិត្យធ្មេញជួយកំណត់អាយុរបស់សត្វគោ




*រូបភាពទី ៣៨*

(១) ក្រោមអាយុពីរឆ្នាំ (គ្មានធ្មេញអចិន្ត្រៃយ៍)

(២) អាយុពីរឆ្នាំ និងបីខែ (មានធ្មេញអចិន្ត្រៃយ៍ ២)

(៣) អាយុបីឆ្នាំ (មានធ្មេញអចិន្ត្រៃយ៍ ៤)

(៤) អាយុបីឆ្នាំ និងប្រាំមួយខែ (មានធ្មេញអចិន្ត្រៃយ៍៦)

(៥) អាយុបួនឆ្នាំ (មានធ្មេញអចិន្ត្រៃយ៍ ៨)

(៦) សត្វចាស់ អាយុលើសពីបួនឆ្នាំ

## ៥. ការពិនិត្យការហើម

ការស្ទាប ជាគោលការណ៍សំខាន់ក្នុងការកំណត់ពីមូលហេតុនៃការហើម។

- ស្ទាបដោយប្រើម្រាមដៃ ដើម្បីដឹងថាតើវា រឹង (ជាបូសអាប់សែ) ទន់ (ជាបូសមានឈាម) ហើយជួនកាលរឹងនៅផ្នែកខាងក្រៅ និងទន់ផ្នែកខាងក្នុង (អាចជាបូសអាប់សែកើតបាន ៨ថ្ងៃ)



រូបភាពទី ៣៩: ស្ទាបដុំពកនៅលើផ្ទៃកក

ក្នុងករណីហើម (ដោយគ្មានខ្ទុះ ឬឈាម) គេឃើញមានស្នាមទ្រុតនៅតែបន្តបន្ទាប់ពីដកម្រាមដៃ ចេញពី ២ ទៅ ៣ វិនាទីក្រោយមក។



រូបភាពទី ៤០: ចំណុចហើមនៅលើក

- ស្ទាបដោយដៃ: ដើម្បីពិនិត្យមើលភាពក្ដៅ ឬធម្មតា និង ឈឺចាប់ ឬអត់
- ការប្រើម្ជុល: ដើម្បីបូមយកវត្ថុរាវដើម្បីពិនិត្យមើលថាតើជា ខ្ទុះ ឈាម ឬសេរ៉ូម



រូបភាពទី ៤១: ចាក់ទំលុះដើម្បីដឹងថាវាជាខ្ទុះ ឬឈាម



រូបភាពទី ៤២: ខ្ទុះដែលបូមចេញពីដុំពក

## ៦. ការពិនិត្យផ្លូវដង្ហើម

គោឈឺជាទូទៅបណ្ដាលមកពី ជំងឺផ្លូវដង្ហើម។

**ការពិនិត្យចុងច្រមុះ**

- រន្ធច្រមុះត្រូវតែសើម និងស្អាត



រូបភាពទី ៤៣: ពិនិត្យច្រមុះ

• ជាការពិបាកក្នុងការពិនិត្យសំបោរ ពីព្រោះជាធម្មតាគោតែងតែលិឍសំអាតរន្ធច្រមុះវា ដូច្នេះ យើងត្រូវប្រើពិលដើម្បីពិនិត្យរន្ធច្រមុះ ។



រូបភាពទី ៤៤: គោលិឍសំបោរ



រូបភាពទី ៤៥: ពិនិត្យមើលសំបោរគោ

## ការពិនិត្យបំពង់ខ្យល់

• ការសង្កត់នៅដើមបំពង់ក និង បំពង់ខ្យល់ បណ្តាលឱ្យសត្វក្អកៈ ការរាយការណ៍ពីកសិករ អំពីការក្អកញ៏កញាប់ មានសារៈសំខាន់ណាស់ ពីព្រោះជាទូទៅពេលធ្វើការពិនិត្យសត្វមិនក្អកចេញ ។



រូបភាពទី ៤៦: ពិនិត្យបំពង់ក និងបំពង់ខ្យល់គោ

## ការពិនិត្យសួត

• នៅពេលធ្វើការពិនិត្យជាទូទៅ យើងត្រូវគណនាចង្វាក់ដង្ហើមក្នុងមួយនាទី ដោយអង្កេត លើការឡើង និងចុះនៃឆ្អឹងជំនី ឬឆ្វកក្នុងមួយនាទី ដើម្បីកំណត់ពីបញ្ហាលំបាកដកដង្ហើម ។

• ដើម្បីធ្វើការអង្កេតបានល្អ យើងត្រូវគោះតំបន់ទ្រូងសត្វ ដើម្បីរកគេមើលពីតំបន់ ដែលមាន ភាពស្អឹកកើនឡើង (ខ្ទុះក្នុងសួត) ឬ ភាពខ្ទរនៃសម្លេង (សួរធម្មតា)



រូបភាពទី ៥០: គោះទ្រូងគោដើម្បីដឹងពីសម្លេងនៅខាងក្នុង

វត្ថុចំឡែកពីខាងក្រៅអាចធ្វើឱ្យស្ទះបំពង់ក និងធ្វើឱ្យឧស្ម័នមិនអាចចេញមកក្រៅបាន ដែលមូលហេតុបណ្តាលឱ្យពោះឡើងប៉ោងធំ ។

ពោះធំ គឺដូចជាអាងធំមួយដែលចំណី និងទឹកត្រូវបានបំលែងដោយមីក្រុប ដើម្បីផលិតប្រូតេអ៊ីន ថាមពល និងឧស្ម័ន។ មីក្រុបនៅក្នុងពោះធំអាចធ្វើការរំលាយប្រភេទចំណីផ្សេងៗបាន ប៉ុន្តែវាឆាប់នឹងទទួលរងការប្រែប្រួល នៅពេលមានការផ្លាស់ប្តូរចំណី។ នៅពេល ប៉េ ហាស (pH) នៅក្នុងពោះធំថយចុះ ពោះធំនឹងឈប់ដំណើរការ ហើយសត្វនឹងឈឺ។ នៅពេលសត្វឈប់ទំពារអៀង បញ្ជាក់ថាសត្វមានបញ្ហាប្រព័ន្ធរំលាយអាហារ ហើយពោះធំមិន ដំណើរសមស្របទៀតឡើយ ។

រូបភាពទី ៥១ : យើងត្រូវស្តាប់ការកន្ត្រាក់របស់ពោះធំ (១ ទៅ ៣ដង ក្នុងមួយនាទី) ដើម្បីប្រាកដថាពោះធំដំណើរការល្អ



ពោះចក គឺ ផ្នែកមួយរបស់ក្រពះសត្វទំពាអៀង មានតួនាទីជាអន្ទាក់នៅពេលសត្វលេបចូលវត្ថុចំឡែកចូលទៅ។ វត្ថុចំឡែកជាលោហៈធាតុអាចចាក់ទំលុះពោះចក និងបណ្តាលឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ។



រូបទី ៥២ : ការស្វែងរកមូលហេតុនៃការស្រែករបស់សត្វបណ្តាលមកពីការឈឺពោះចក

## ៨. ការពិនិត្យចលនាដើរ

សាច់ដុំ ឆ្អឹង សន្លាក់ និងក្រចកទ្រទ្រង់ដងខ្លួនសត្វ និងអនុញ្ញាតឱ្យមានការផ្លាស់កន្លែង និងអកប្បកិរិយាធម្មតា ដើម្បីធ្វើរោគវិនិច្ឆ័យ ភ្នាក់ងារសុខភាពសត្វភូមិត្រូវអង្កេតចលនារបស់សត្វ។



រូបភាពទី ៥៣: ដើម្បីពិនិត្យបញ្ហាជើងផ្នែកខាងស្តាំ គេត្រូវដេញគោឱ្យដើរខាងស្តាំដៃយើង

**ការដើរសាក់ស្ទើរ:** សត្វមិនចង់ដើរនៅពេលដែលយើងរុញច្រាន ឬបង្ខំឱ្យវាដើរ។



រូបភាពទី ៥៤: សត្វមិនព្រមដើរទោះបីជាទាញវា

- រោគសញ្ញាឈឺក្រចកជើងធ្ងន់ធ្ងរ។
- ដោយសារសត្វខ្សោយខ្លាំងពេក ដូចជាបង្កដោយជំងឺស្រួចស្រាវ (ដែលមានសីតុណ្ហភាពក្នុងខ្លួនឡើងខ្ពស់) និងសារពាង្គកាយទាំងមូលឈឺចាប់។







រូបភាពទី ៥៥: ការពិនិត្យជើងមុខ រូបភាពទី ៥៦: ការពិនិត្យជើងក្រោយ រូបទី៥៧ ការពិនិត្យចង្កេះជើង

**ភាពពិការ:** ភាពពិការបន្តិចបន្តួចក៏អាចធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងទៅលើសត្វដែលធ្វើការភ្ជួររាស់។ ភាពពិការបង្ករឡើងជាចំបងដោយ ការឈឺសន្លាក់ ឬ ស្លាកស្នាមលើក្រចកជើងរយៈពេលយូរ។



*រូបភាពទី ៥៨: ការស្ទាបជង្គង់ដើម្បីដឹងពីទំហំ និងកំដៅរបស់សន្លាក*



*រូបភាពទី ៥៩: បត់ជង្គងដើម្បីស្ទង់ពីការឈឺចាប់*

**ខ្វិន:** ជាស្ថានភាពដែលមិនអាចឈរបាន។ ទោះបីយើងព្យាយាមលើកសត្វឱ្យឈរដោយប្រើ មនុស្ស៤ទៅ៥នាក់ក៏ដោយ ក៏សត្វនៅតែពុំអាចឈរត្រង់បានដែរ។

## ៩. ការពិនិត្យប្រដាប់បន្តពូជ

**ការពិនិត្យយោនី:** ការពិនិត្យយោនីជាការចាំបាច់ដើម្បីរកមើលពី:

- ការចេញទឹករំអិលខុសធម្មតា
- ដំបៅដែលធ្វើឱ្យសត្វមិនរកឈ្មោល

*រូបភាពទី ៦០: លើកកន្ទុយគោឡើងលើ ដើម្បីមើលយោនី ហើយគេអាចបើកបបូរមាត់យោនីដើម្បីមើលរុន្ធយោនី។*



ការពិនិត្យពងស្វាសៈ ដោយប្រើប្រាស់ដៃស្ទាបមើលដើម្បីៈ

*រូបភាពទី ៦៥: ការស្ទាបពងស្វាស*



- ដឹងថាតើពងស្វាសអាចធ្វើចលនានៅក្នុងស្រោបពងស្វាសដោយសេរី
- ដឹងពីទំហំមិនស្មើគ្នារវាងពងស្វាសទាំងពីរ អាចបញ្ជាក់ពីភាពរលាកពងស្វាស ភាពអន់ថយ ឬជំងឺកូន ។

## ១០. ការពិនិត្យដោះ

នៅពេលដែលកូនគោខ្សោយ វានឹងព្យាយាមបៅដោះមេវាជាញឹកញាប់ ដូច្នេះយើងត្រូវតែពិនិត្យដោះ ក្នុងគោលបំណងខាងក្រោមៈ

- ពិនិត្យមើលជំងឺរលាកដោះដែលធ្វើឱ្យខូចដល់ផលិតកម្ម និងគុណភាពទឹកដោះ ។ ដោះនឹងមានសភាព រឹង និងឈឺចាប់ ។

*រូបភាពទី ៦៦: ច្របាច់ក្បាលដោះដើម្បីយកទឹកដោះ*



- រកមើលពីស្នាកស្នាមលើក្បាលដោះ
- រកមើលពីទំហំក្បាលដោះសមស្របទៅនឹងមាត់កូនគោ



*រូបភាពទី ៦៧: ដោះល្អ*



*រូបភាពទី ៦៨: កូនគោមិនអាចបៅក្បាលដោះទាំងអស់កើតទេ*

ការពិនិត្យពងស្វាសៈ ដោយប្រើប្រាស់ដៃស្ទាបមើលដើម្បីៈ



រូបភាពទី ៦៥: ការស្ទាបពងស្វាស

- ដឹងថាតើពងស្វាសអាចធ្វើចលនានៅក្នុងស្រោបពងស្វាសដោយសេរី
- ដឹងពីទំហំមិនស្មើរគ្នារវាងពងស្វាសទាំងពីរ អាចបញ្ជាក់ពីភាពរលាកពងស្វាស ភាពអន់ថយ ឬជំងឺក្លូន ។

## ១០. ការពិនិត្យដោះ

នៅពេលដែលកូនគោខ្សោយ វានឹងព្យាយាមបៅដោះមេវាជាញឹកញាប់ ដូច្នេះយើងត្រូវតែពិនិត្យដោះ ក្នុងគោលបំណងខាងក្រោមៈ

- ពិនិត្យមើលជំងឺរលាកដោះដែលធ្វើឱ្យខូចដល់ផលិតកម្ម និងគុណភាពទឹកដោះ ។ ដោះនឹងមានសភាព រឹង និងឈឺចាប់ ។



រូបភាពទី ៦៦: ច្របាច់ក្បាលដោះដើម្បីយកទឹកដោះ

- រកមើលពីស្នាកស្នាមលើក្បាលដោះ
- រកមើលពីទំហំក្បាលដោះសមស្របទៅនឹងមាត់កូនគោ



រូបភាពទី ៦៧: ដោះល្អ



រូបភាពទី ៦៨: កូនគោមិនអាចបៅក្បាលដោះទាំងអស់កើតទេ

# ជំពូក ២ បញ្ហា រោគសញ្ញា ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺ

បន្ទាប់ពីការពិនិត្យជាទូទៅ និងជាក់លាក់រួចហើយ យើងនឹងអាចកំណត់នូវរោគសញ្ញាគួរឱ្យកត់សម្គាល់ទាំងអស់ ហើយបន្ទាប់មកអាចធ្វើរោគវិនិច្ឆ័យ និងអនុវត្តការព្យាបាលបានយ៉ាងសមស្រប។ ជំពូកនេះនឹងបង្ហាញពី ជំងឺសំខាន់ៗដែលតែងតែជួបប្រទះជាញឹកញាប់នៅប្រទេសកម្ពុជា ហើយយើងធ្វើចំណែកថ្នាក់ជំងឺទាំងនេះទៅតាម បញ្ហា ឬរោគសញ្ញា។

## ក. ការងាប់ភ្លាមៗ

ជាញឹកញាប់គេប្រទះឃើញសត្វងាប់តែម្តង ឬងាប់តិចជាង២៤ម៉ោង ដោយមាន ឬគ្មាន ស្លាកស្នាម និងរោគសញ្ញា ជាក់លាក់។ យើងមិនអាចជួយអ្វីបានឡើយប៉ុន្តែត្រូវធ្វើរោគវិនិច្ឆ័យឱ្យបានត្រឹមត្រូវដើម្បីការពារសត្វដទៃទៀត កុំឱ្យប៉ះពាល់ជាមួយសត្វដែលងាប់។



*រូបភាពទី ៦៩: សត្វងាប់ភ្លាមៗដោយគ្មានមូលហេតុ*

### ១. ងាប់ដោយរន្ទះបាញ់

- គោក្របីជាញឹកញាប់ត្រូវរន្ទះបាញ់ ជាពិសេសនៅពេលវាស៊ីស្មៅក្បែរដើមឈើ។
- ជាញឹកញាប់ គេឃើញគោក្របីជាច្រើនក្បាលងាប់ ដោយមានស្ថានភាពដងខ្លួនល្អ បន្ទាប់ពីមានផ្គររន្ទះនៅក្នុងឃុំ។



*រូបភាពទី ៧០: ការពិនិត្យជិត អាចមើលឃើញពីសភាពលោកនៅលើស្បែក*

## ២. ជំងឺឈាមខ្មៅ (អង់ត្រាក់)

ជំងឺនេះបង្កឡើងដោយបាក់តេរី បាក់ស៊ីលុសអង់ត្រាក់ស៊ីស និងអាចចម្លងទៅលើមនុស្សបាន ។

រោគសញ្ញា

- សត្វមានសុខភាពធម្មតា តែ២-៣ម៉ោងក្រោយ គេឃើញវាងាប់
- សត្វភាគច្រើនគេប្រទះឃើញងាប់តែម្តង ។
- ការហូរឈាមខ្មៅពីមាត់ និងរន្ធគូទក្រោយពេលងាប់ ។

រូបភាពទី ៧១: សត្វងាប់ដោយជំងឺឈាមខ្មៅ ឬអង់ត្រាក់



- សាកសពទន់ និងរលួយយ៉ាងលឿនបន្ទាប់ពីងាប់ ។

ក្នុងសភាពមិនសូវស្រួចស្រាវមានរោគសញ្ញាដូចខាងក្រោមៈ

- សត្វខ្សោយយ៉ាងខ្លាំង
- ក្រុនក្តៅ ៤១,៥ អង្សាសេ
- ពិបាកដកដង្ហើម
- ទឹកនោម ទឹកដោះ និងលាមកលាយឈាម
- ចលនាធឹងធោង និងប្រកាច់

គោក្របីឆ្លងរាលដាលមេរោគទៅក្នុងដីតាមរយៈឈាម ហើយមេរោគអាចរស់ក្នុងដីបានរយៈពេលជា ច្រើនឆ្នាំ ។

ការព្យាបាល

ត្រូវអនុវត្តឱ្យបានមុនដោយចាក់ប៉េនីស៊ីស៊ីលីន ឬតេត្រាស៊ីគ្លីន ប៉ុន្តែជាញឹកញាប់គោត្រូវបានគេប្រទះ ឃើញងាប់រួចទៅហើយ ។

## ២. ជំងឺឈាមខ្មៅ (អង់ត្រាក់)

ជំងឺនេះបង្កឡើងដោយបាក់តេរី បាក់ស៊ីលុសអង់ត្រាក់ស៊ីស និងអាចចម្លងទៅលើមនុស្សបាន។

រោគសញ្ញា

- សត្វមានសុខភាពធម្មតា តែ២-៣ម៉ោងក្រោយ គេឃើញវាងាប់
- សត្វភាគច្រើនគេប្រទះឃើញងាប់តែម្តង។
- ការហូរឈាមខ្មៅពីមាត់ និងរន្ធគូទក្រោយពេលងាប់។



រូបភាពទី ៧១: សត្វងាប់ដោយជំងឺឈាមខ្មៅ ឬអង់ត្រាក់

- សាកសពទន់ និងរលួយយ៉ាងលឿនបន្ទាប់ពីងាប់។

ក្នុងសភាពមិនសូវស្រួចស្រាវមានរោគសញ្ញាដូចខាងក្រោមះ

- សត្វខ្សោយយ៉ាងខ្លាំង
- ក្រុនក្តៅ ៤១,៥ អង្សាសេ
- ពិបាកដកដង្ហើម
- ទឹកនោម ទឹកដោះ និងលាមកលាយឈាម
- ចលនាធីងធោង និងប្រកាច់

គោក្របីឆ្លងរាលដាលមេរោគទៅក្នុងដីតាមរយះឈាម ហើយមេរោគអាចរស់ក្នុងដីបានរយៈពេលជា ច្រើនឆ្នាំ។

ការព្យាបាល

ត្រូវអនុវត្តឱ្យបានមុនដោយចាក់ប៉េនីស៊ីស៊ីលីន ឬតេត្រាស៊ីគ្លីន ប៉ុន្តែជាញឹកញាប់គោត្រូវបានគេប្រទះ ឃើញងាប់រួចទៅហើយ។

**ការការពារ**

- ចាក់វ៉ាក់សាំងគឺមានប្រសិទ្ធិភាពបំផុតប៉ុន្តែវាត្រូវការរយៈពេល១០ទៅ១៤ថ្ងៃដើម្បីបង្កើតភាពស៊ាំពេញលេញ។ គោក្របីត្រូវចាក់វ៉ាក់សាំងម្តងក្នុងមួយឆ្នាំឱ្យបានមុនរដូវភ្លៀង។
- គោដែលប្រឈមនិងគ្រោះថ្នាក់គឺជាគោដែលស៊ីស្មៅនៅកន្លែងតែមួយដែលគេប្រទះឃើញមានគោងាប់ រួចទៅហើយ។ គេត្រូវព្យាបាលភ្លាមៗជាមួយអង់ទីបីយ៉ូទិកដែលមានសកម្មយូរដើម្បីបញ្ឈប់សក្តានុពលនៃការ សំងំរបស់មេរោគ។
- ការចាក់វ៉ាក់សាំងអាចធ្វើឡើងពី ៧ ទៅ ១០ថ្ងៃ បន្ទាប់ពីព្យាបាលដោយប្រើប្រាស់អង់ទីបីយ៉ូទិក។ អង់ទីបីយ៉ូទិកមិនអនុញ្ញាតឱ្យប្រើជាមួយវ៉ាក់សាំងក្នុងពេលតែមួយនោះទេ។

**ការចម្លងទៅមនុស្ស**

ជាទូទៅការបរិភោគសត្វដែលងាប់ភ្លាមៗត្រូវតែជៀសវាងឱ្យបាន។

ការឆ្លងជំងឺអង់ត្រាក់មានបីទំរង់:

- សើស្បែក(មេរោគចូលតាមដំបៅលើស្បែក)គឺជាទំរង់ដែលគេជួបប្រទះជាញឹកញាប់



*រូបភាពទី ៧២: រោគសញ្ញាកើតលើមនុស្ស*

- ការដកដង្ហើមស្រូបចូល (មេរោគនៅក្នុងខ្យល់ចូលតាមសួត)
- តាមក្រពះពោះវៀន (មេរោគនៅក្នុងសាច់)

## ៣. ជំងឺបូសខ្យល់

ជំងឺនេះបង្កឡើងដោយបាក់តេរី ក្លូស្ទ្រីឌីយ៉ូម សូវី។ ជំងឺនេះមិនអាចសាយភាយពីសត្វមួយទៅសត្វមួយទៀតបានទេ។ សត្វលេបចូលបាក់តេរីទៅក្នុងខ្លួននៅពេលដែលសត្វស៊ីស្មៅខ្លីៗ ដែលជាប់ជាមួយដីដែលមានមេរោគ។



រូបភាពទី ៧៣: សត្វស៊ីស្មៅដោយមេរោគ ក្លូស្ទ្រីឌីយ៉ូម

រោគសញ្ញា

- ជំងឺនេះច្រើនកើតមានលើគោក្មេងអាយុពី ៦-២៤ ខែ ហើយ ពួកវាមើលទៅមានសុខភាពល្អ ។
- ការស្លាប់ភ្លាម កើតមានរវាងពី ១២-២៤ ម៉ោង ដោយមិនបញ្ចេញរោគសញ្ញាអ្វីឡើយ ។
- ករណីជាច្រើន គោត្រូវបានគេប្រទះ ឃើញងាប់ដោយពុំមានបង្ហាញថាឈឺពីមុនមក ។

ក្នុងករណីមិនសូវស្រួចស្រាវ

- ពិការធ្ងន់ធ្ងរ
- ដោយមានលក្ខណៈជាកូនកណ្ដុរ ហើម និងឮសំលេង នៅក្នុងសាច់ដុំត្រគៀក ក និងស្មាមុខ



រូបភាពទី ៧៤: តំបន់ជាលិការរលួយនិងហើម ពណ៌ខ្មៅ រីកលូតលាស់នៅក្នុង សាច់ដុំបានបញ្ចេញជាសំលេងនៅ ពេលដែលយើងស្ទាបសាច់ដុំ

- ពេលដំបូងការហើមតូច ក្ដៅ និងឈឺចាប់
- នៅពេលជំងឺមានការវិវត្តន៏យ៉ាងរហ័ស ការហើមបានរីកធំឡើង ហើយឮសំឡេងខ្យល់ពេលស្ទាប
- ស្បែកក្លាយជាត្រជាក់ និង ស្ពឹក

ការព្យាបាល

ត្រូវអនុវត្តឱ្យបានទាន់ពេលនៅដំណាក់កាលដំបូងនៃជំងឺ ដោយចាក់ប៉េនីស៊ីស៊ីលីន ឬអាម៉ុកស៊ីស៊ីលីន ។

ការការពារ

- ការចាក់វ៉ាក់សាំងគឺមានប្រសិទ្ធិភាពៈធម្មតាកសិករប្រើវ៉ាក់សាំង៧មុខ សម្រាប់ការពារជំងឺបង្ក ដោយ មេរោគក្លូស្ទ្រីឌីយ៉ូម ដូចជា បូសខ្យល់ តេតាណូស បូតាលីស...




*រូបភាពទី ៧៥: វ៉ាក់សាំង៧មុខសម្រាប់ការពារជំងឺបង្កដោយមេរោគក្លូស្ទ្រីឌីយ៉ូម*

- គោដែលប្រឈមនិងគ្រោះថ្នាក់ត្រូវព្យាបាលភ្លាមៗជាមួយ អាម៉ុកស៊ីស៊ីលីនដែលមានរយៈពេលយូរ ដើម្បីបញ្ឈប់សក្តានុពលនៃការសំងំរបស់មេរោគ ។
- ការចាក់វ៉ាក់សាំងអាចធ្វើឡើងរយៈពេល៧-១០ថ្ងៃបន្ទាប់ពីព្យាបាលដោយប្រើប្រាស់អង់ទីប៊ីយ៉ូទិក ។ អង់ទីប៊ីយ៉ូទិកមិនអនុញ្ញាតអោយប្រើជាមួយវ៉ាក់សាំងក្នុងពេលតែមួយនោះទេ ។

## ៤. ជំងឺសារទឹក

ជំងឺនេះបង្កឡើងដោយបាក់តេរី ប៉ាស្ទ័រវ៉េឡា ម៉ូតូស៊ីដាប្រភេទបេ ។ ជំងឺនេះសាយភាយតាមរយៈការប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលៈ វាជាប្រភេទជំងឺឆ្លង ។

ការសំងំរបស់មេរោគមានរយៈពេលខ្លីៈ សត្វនឹងឈឺពី២ទៅ៣ម៉ោងបន្ទាប់ពីឆ្លងជំងឺ និងងាប់ក្នុងរយៈពេលពី៦-២៤ម៉ោង ។ ជំងឺនេះអាចឱ្យយើងពិនិត្យឃើញរោគសញ្ញាមុនសត្វងាប់ ។

*រូបភាពទី ៧៦: ក្របីងាយទទួលរងជំងឺសារទឹកខ្លាំងណាស់*



រោគសញ្ញា

- សត្វមិនចង់ដើរ
- សីតុណ្ហភាពលើស ៤១អង្សាសេ
- ហូរទឹកមាត់ និងហៀរសំបោរធ្ងន់ធ្ងរ

រូបភាពទី ៧៧: ក្របីហើមក៏ដោយសារជំងឺសារទឹក



- ឈឺចាប់ប្រព័ន្ធដកដង្ហើម និងសំបោរមានលាយឈាម
- ហើមប៉ោងនៅក្បាល ក និង ទ្រូង

រូបភាពទី ៧៨: ប្រសិនបើយើងធ្វើការវះកាត់ យើងនឹងឃើញការហើមប៉ោង កូនកណ្តុរច្រើននៅតំបន់ក



ការព្យាបាល

- ជំងឺនេះធ្វើការវិវត្តន៍យ៉ាងលឿន ហើយវាពិបាកធ្វើព្យាបាលទាន់ពេលណាស់
- ចាក់ស៊ុលហ្វូណាមីដ តាមសរសៃវ៉ែន តេត្រាស៊ីគ្លីន (លីកាមីស៊ីន តាមសរសៃវ៉ែន) ត្រូវបានគេយកមក ធ្វើការព្យាបាល ។

រូបភាពទី ៧៩: ការចាក់តេត្រាស៊ីគ្លីនតាមសសៃវ៉ែន ជំរុញប្រសិទ្ធភាពឱសថ



- ការចាក់លើកទីមួយគឺត្រូវទ្វេដូស (២០មីលីក្រាមក្នុងមួយគីឡូក្រាម)

ការការពារ

- វាមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការព្យាបាលគោដែលនៅជិតសត្វដែលឈឺដើម្បីបញ្ឈប់ការសំងំរបស់ជំងឺនៅលើខ្លួនសត្វ ។




*រូបភាពទី ៨០:វ៉ាក់សាំងសារទឹកមកពីប្រទេសវៀតណាម*

- វ៉ាក់សាំងប្រភេទនេះត្រូវចាក់ ចន្លោះ៦ខែម្តង ជាពិសេសត្រូវចាក់មុនរដូវភ្លៀង ។ អង់ទីកររបស់មេអាចបន្តដល់កូន ។ មេគោផើមត្រូវចាក់វ៉ាក់សាំងនៅខែចុងក្រោយនៃការផើម ។

## ៥. ការពុល

សត្វងាប់បណ្តាលមកពីការធ្វេសប្រហែសរបស់កសិករនៅពេលដែលគោស៊ីសារធាតុគីមីដែលមានក្លិន ឬរសជាតិទាក់ទាញ ។

**ការពុលដោយអ៊ុយរ៉េ**



*រូបភាពទី ៨១: ជីអ៊ុយរ៉េ*

- ដំណាក់កាលចាប់តាំងពីពេលសត្វលេបអ៊ុយរ៉េចូលរហូតដល់ចេញរោគសញ្ញាគ្លីនិកគឺ ២០ទៅ៦០ នាទី ។
- សត្វនឹងងាប់រយៈពេល២ម៉ោងក្រោយ ។

**រោគសញ្ញាដំបូង**

- សាច់ដុំញ័ររហូតដល់បាត់បង់លំនឹង ច្រាស់ច្រាល និងប្រកាច់ ។
- ការទំពារអៀងថយចុះ (ហើមពោះ) ។
- ហូរទឹកមាត់ ពិបាកដកដង្ហើម និង ដកខ្យល់ ។

**ការព្យាបាលជាបន្ទាន់**

- បញ្ច្រកទឹកខ្មេះពី ២ ទៅ៥លីត្រ ។

**ការពុលដោយនីត្រាត**

- ការពុលបណ្តាលមកពីការលេបចូលនូវ ជី ឬសារធាតុគីមីផ្សេងទៀត(ប្រេងម៉ាស៊ីន) ។



រូបភាពទី ៨២: គោស៊ីប៉ះចំវត្ថុដែលមានផ្ទុកសារធាតុគីមីផ្សេងៗ

- សត្វនឹងងាប់ភ្លាមៗក្នុងរយៈពេលពី ១ ទៅ ២៤ម៉ោង ដោយមុននឹងងាប់សត្វមានសភាពប្រកាច់ខ្លាំង។

រោគសញ្ញានៃការពុល កើតឡើងភ្លាមៗ ហើយជាទូទៅកើតឡើងដូចៗគ្នាចំពោះការពុលទាំងអស់រួមមាន:

- ពិបាកដកដង្ហើម
- អន្ទះអន្ទែង
- ដកដង្ហើមញាប់
- នោមញឹក

ការព្យាបាល

ចាក់សេរ៉ូមប្រៃ (Isotonic saline) ចំនួន ៥០០មីលីលីត្រ ដែលមានបញ្ចូល មេទីឡែនប្លឺ (methylene bleu) ១% តាមសរសៃវ៉ែនយឺតៗ។

## ៦. ពស់ចឹក

ពីសរបស់ពស់វែកឬពស់មានពីសធ្វើឱ្យពុលដល់ប្រព័ន្ធប្រសៃប្រសាទនិងធ្វើឱ្យស្ទះប្រព័ន្ធដកដង្ហើម។ សត្វនឹងងាប់ភ្លាមៗ បន្ទាប់ពីពស់ចឹកត្រូវច្រមុះ ក្បាល និង ក។ ការងាប់បណ្តាលមកពីការស្ទះឬពិបាកដកដង្ហើម ដោយសារការឡើងហើមហួសប្រមាណ។



រូបភាពទី ៨៣: ពស់មានពីស

ការព្យាបាល

- ថ្នាំព្យាបាលសមស្របមិនមានលក់នៅតាមភូមិទេ (ថ្នាំប្រឆាំងពស់ចឹក-អេប៉ារីន)

- យើងអាចចាក់ជីចសាមេតាសូន ទ្រីមេតូព្រីមលាយជាមួយស៊ុលហ្វាដើម្បីការពារការថប់ដង្ហើម និងជំងឺ ឱកាសនិយម ។

## ខ. ភាពខ្សោយ និងការបាត់បង់ការឃ្លានចំណី

ជាធម្មតារោគសញ្ញាវិវត្តជាបន្តបន្ទាប់ៗ ដូចជា: ការស៊ីចំណីធ្លាក់ចុះ កំលាំងថយចុះ និងបាត់បង់ផលិតកម្ម ។ កសិករ នឹងហៅយើងឱ្យទៅព្យាបាលនៅពេលសត្វចុះខ្សោយ ។ រោគសញ្ញា និងការព្យាបាលមានលក្ខណៈស្មុគស្មាញ ។

### ១. គ្រុនក្តៅ

នៅពេលសត្វចាប់ផ្តើមខ្សោយ និងបាត់បង់ការស៊ីចំណី ធ្វើឱ្យសត្វមិនចង់ដើរ យើងត្រូវវាស់ សីតុណ្ហភាពសត្វជាបន្ទាន់ជាមួយទែម៉ូម៉ែត្រ ។ ជាធម្មតាសីតុណ្ហភាពខ្ពស់ហើយថេរគឺជាសញ្ញា នៃជំងឺឆ្លងដែលបង្កឡើងដោយបាក់តេរី ឬវីរុស ។

**សីតុណ្ហភាពធម្មតារបស់គោ**

- គោពេញវ័យ: ៣៨,៥អង្សាសេ
- កូនគោ: ៣៩,២អង្សាសេ

យើងត្រូវវាស់កម្តៅខ្លួនសត្វនៅពេលសត្វនៅស្ងៀម និងនៅពេលព្រឹក ។ ជួនកាលគ្រុនក្តៅកើតឡើងដោយអន្លើ ដូច្នេះយើងគួរតែវាស់ស្ទង់កំដៅឱ្យបានញឹកញាប់ និងច្រើនដង ។ កំដៅឡើងចុះ ជាសញ្ញានៃវត្តមានប៉ារ៉ាស៊ីតក្នុង ឈាម ។



*រូបភាពទី ៨៤: ការវាស់ស្ទង់កម្តៅដោយប្រើប្រាស់ទែម៉ូម៉ែត្រ*

**រោគសញ្ញា:**

សីតុណ្ហភាពលើសពី៤០អង្សាសេ បាត់បង់ការស៊ីចំណី ផលិតកម្មទាប (ទឹកដោះ) ។ យើងត្រូវពិនិត្យបានហ្មត់ចត់ ដើម្បីស្វែងរករោគសញ្ញានៃជំងឺឆ្លងជាច្រើនដែលធ្វើឱ្យកំដៅឡើងខ្ពស់ ។ ពេលខ្លះយើង មិនអាចឃើញរោគសញ្ញាអ្វីផ្សេងទៀតក្រៅពីខ្សោយ និង ក្តៅខ្លួននោះទេ ដូចនេះយើងត្រូវផ្ញើរសំណាកទៅវិទ្យាស្ថាន ជាតិស្រាវជ្រាវបសុព្យាបាលដើម្បីជួយធ្វើរោគវិនិច្ឆ័យជំងឺរ៉ាំរ៉ៃ ដែលមិនបង្ហាញរោគសញ្ញាច្បាស់លាស់ ។



រូបភាពទី ៨៥: ការយកសំណាកឈាមលើគោ

ការព្យាបាល

- ប្រសិនបើសត្វគ្រុនក្តៅ ត្រូវដាក់វាដាច់ដោយឡែកពីគោដទៃ ដើម្បីការពារការចម្លងមេរោគ ។
- រក្សាវានៅក្នុងម្លប់ កន្លែងត្រជាក់ អនាម័យល្អ និងផ្តល់ទឹកស្អាត ។



រូបភាពទី ៨៦: ការបំបែកសត្វឈឺដាច់ដោយឡែក

ប្រសិនបើគោមិនបង្ហាញរោគសញ្ញាអ្វីក្រៅពីគ្រុនក្តៅយើងត្រូវ:

- ត្រូវចាំពិនិត្យមួយថ្ងៃពេញ ដោយមិនព្យាបាលអ្វីឡើយ ។
- នៅថ្ងៃទី ២ យើងត្រូវចាក់ថ្នាំអង់ទីប៊ីយូទិក (ដែលមានសកម្មភាពទូលាយ) ដូចជាអុកស៊ីតេត្រាស៊ីគ្លីន ឬ TMP/Sulfa

## ២. ជំងឺឆ្លង

ជាទូទៅប៉ារ៉ាសិតក្នុងឈាមអាចបង្កឱ្យមានជំងឺរ៉ាំរ៉ៃ និងមិនបង្ហាញរោគសញ្ញាច្បាស់លាស់ដូចជា:

- គ្រុនក្តៅដោយអន្លើ
- ខ្សោយ
- ស្លេកស្លាំង (ខ្វះគ្រាប់ឈាមក្រហម)
- ការស៊ីចំណីថយចុះ
- ស្រកទំងន់
- រោមបះ



*រូបភាពទី ៨៧: សត្វក្រោកមិនរួចដោយសារ បាត់បង់កំលាំង*

នៅពេលសត្វបាត់បង់នូវភាពស៊ាំក្នុងខ្លួនដោយសារមូលហេតុជាច្រើនដូចជា ការស៊ីចំណីមិនបានល្អ និងគ្រប់គ្រាន់ ការធ្វើការលើសកំណត់ នឹងធ្វើឱ្យសត្វទទួលរងនូវជំងឺដែលមានរោគសញ្ញាដូចខាងលើ។ ប៉ារ៉ាស៊ីតក្នុងឈាមអាចរកឃើញនៅមន្ទីរពិសោធន៍ដោយធ្វើគំនៀសឈាម និងការដាក់ពណ៌ពិសេស។



*រូបភាពទី ៨៨: ការរៀបចំគំនៀសឈាម និងដាក់ព៌ណពិសេសនៅលើ បន្ទះឡាម គេអាចធ្វើផ្ទាល់ នៅនឹងភូមិ*

អាណាផ្លាស្មា

ដង្កែជាភ្នាក់ងារចម្លងជំងឺនេះ។ ជាធម្មតាគោក្របីក្នុងស្រុក មានភាពធន់នៅនឹងជំងឺនេះ ប៉ុន្តែនៅពេលដែលភាពធន់របស់សត្វថយចុះ ជំងឺនឹងវាយលុកហើយធ្វើការលូតលាស់នឹងជះឥទ្ធិពលមិនល្អដល់សត្វ។ គោក្របីដែលនាំ ចូលពីបរទេសងាយទទួលរងនូវជំងឺនេះណាស់។ ភាពសំងំនៃជំងឺមានរយៈពេលយូររហូតដល់ ១០ សប្តាហ៍។ មេរោគ នៃជំងឺរស់នៅនិងរីកលូតលាស់ក្នុងគោលិកាឈាមក្រហម។



*រូបភាពទី ៨៩: មេរោគនៃជំងឺស្ថិតក្នុង គោលិកាឈាមក្រហម*

រោគសញ្ញាៈ ជាទូទៅរោគសញ្ញារួមមានៈ

- ក្តៅខ្លួន
- រសាប់រសល់

ការព្យាបាលៈ ប្រើប្រាស់អុកស៊ីតេត្រាស៊ីគ្លីនដូចខាងក្រោមៈ

- ១០ម.ក្រ ក្នុងមួយគីឡូក្រាមសត្វរស់រៀងរាល់ថ្ងៃ ក្នុងរយៈពេល១០ថ្ងៃ ឬ
- ២០ម.ក្រ ក្នុងមួយគីឡូក្រាមសត្វរស់រៀងរាល់ថ្ងៃ ក្នុង រយៈពេល៥ថ្ងៃ

## ទ្រីប៉ាណូសូម៉ា

ជំងឺនេះឆ្លងដោយសាការរុយខាំ ។ ជំងឺមានសភាពធ្ងន់ធ្ងរចំពោះក្របី ។ មេរោគស្ថិតនៅក្នុងឈាម ។ ផលប៉ះពាល់គឺ មានខ្លាំងទៅលើក្របី ។ បរាសិតរស់នៅក្នុងឈាម ។

*រូបភាពទី ៩០: តាមរយៈមីក្រូទស្សន៍ យើងឃើញបរាសិតក្នុងឈាម*



រោគសញ្ញាៈ មិនមានលក្ខណៈជាក់លាក់ទេ ប៉ុន្តែជំងឺធ្វើឱ្យថយចុះលទ្ធភាពភ្ជួររាស់ ហើយ ការធ្វើការងារអាចធ្វើ ឱ្យជំងឺកាន់តែដុនដាបឡើង ។

*រូបភាពទី ៩១: កំលាំងអូសទាញមានការថយចុះ បើសិនជាសត្វមានផ្ទុកជំងឺ*



## ការព្យាបាល

ប្រើប្រាស់ បេរ៉េនីល (Berenil) ក្នុងកំរិត ៣,៥ម.ក្រ ក្នុងមួយគីឡូក្រាមសត្វរស់ ។

## បាបេស្យា

បាបេស្យា ប៊ីហ្សេមីណា (Babesia Bigemina) និង បាបេស្យា បូវីស (Babesia Bovis) បានសាយភាយ ក្នុងប្រទេសកម្ពុជា។ ដង្កៃជាភ្នាក់ងារចម្លងជំងឺបរាសិតក្នុងឈាមនេះ មេរោគនៃជំងឺនេះរស់នៅក្នុងគោលិកា ឈាមក្រហម។



*រូបភាពទី ៩២: មេរោគនៅក្នុងឈាមតាមរយៈ ការពិនិត្យរបស់មីក្រូទស្សន៍*

### រោគសញ្ញា:

រោគសញ្ញា ជំងឺបង្កដោយ បាបេស្យា ប៊ីហ្សេមីណា រួមមាន:

- ជំងឺខាន់លឿង: ទឹកនោមពណ៌ត្នោត



*រូបភាពទី ៩៣: ទឹកនោមរបស់គោមានពណ៌ខៀវ*

- រាកពណ៌ខ្មៅ
- ងាយទទួលប្រតិកម្មទៅនឹងពន្លឺថ្ងៃ

រោគសញ្ញា ជំងឺបង្កដោយ បាបេស្យា ប៊ីហ្សេមីណា រួមមាន:

- គោដើរទ្រេតទ្រោតដូចស្រវឹង
- ឆ្កួល្ហា

### ការព្យាបាល:

ប្រើប្រាស់ បេរ៉េនីល (Berenil) ៥ម.ក្រ ក្នុងមួយគីឡូក្រាមសត្វរស់




រូបភាពទី ៩៤: ការរៀបចំបេរ៉េនីល

## តេលេរៀល

ដង្កែជាភ្នាក់ងារចម្លងជំងឺនេះ ហើយមានតែ បេនីញ តេលេរៀលថៃ (benign Theleria Thai) តែមួយគត់ដែល បានសាយភាយក្នុងប្រទេសកម្ពុជា។ បរាសិតនេះត្រូវបានគេរកឃើញក្នុងកោសិការឈាមក្រហមដោយការធ្វើគំនាសឈាម។

រោគសញ្ញាៈ មិនមានអ្វីកត់សំគាល់ច្បាស់លាស់នោះទេ ប៉ុន្តែកត្តាខាងក្រោមនេះនឹងធ្វើឱ្យជំងឺកាន់តែធ្ងន់ធ្ងរដូចជា

- ស្ត្រេស (ភ្ជួររាស់ខ្លាំង)
- ការឆ្លងជំងឺបង្កដោយពួក បាបេស្យា និងអាណាផ្លាស្មា រួមគ្នា
- ភាពចុះខ្សោយ

ការព្យាបាលៈ ប្រើប្រាស់ អុកស៊ីតេត្រាស៊ីគ្លីន

ដំបូន្មានៈ ក្នុងករណីដែលរកឃើញករោគសញ្ញាធ្ងន់ធ្ងរប្រហាក់ប្រហែលនិងរោគសញ្ញាដែលបានរៀបរាប់ខាងលើ យើងត្រូវចាក់ អុកស៊ីតេត្រាស៊ីគ្លីន និងបេរ៉េនីល លើគោ។

## ៣. បរាសិត

ឥទ្ធិពលរបស់បរាសិតលើសុខភាពគោ គឺវាអាស្រ័យលើបរិមាណនៃបរាសិត។ បរាសិតច្រើនលើសលុបអាច ចេញមកក្រៅ និង បំផ្លាញសុខភាពគោតែម្តង។

• ព្រូនៈ ប៊ឺតយកសារជាតិចិញ្ចឹមនៅក្នុងពោះវៀនសត្វ ដែលធ្វើឱ្យសត្វមិនអាចប្រើប្រាស់សារធាតុចិញ្ចឹម នេះដើម្បីការរីកធំធាត់បាន។

• ដង្កែៈ បឺតឈាម (២ម.ល. ឈាម ក្នុងមួយវដ្តជីវិតរបស់ដង្កែមួយក្បាល) ដែលធ្វើឱ្យសត្វចុះខ្សោយ និងស្លេកស្លាំង។

### បរ៉ាស៊ីតខាងក្នុង

ពពួកព្រូនៈ មានច្រើនប្រភេទ (១៤ប្រភេទ) រស់នៅផ្នែកផ្សេងៗគ្នានៃពោះវៀន។

• ព្រូនពេញវ័យរស់នៅក្នុងក្រពះ និងពោះវៀន ហើយវាបញ្ចេញពងមកក្រៅតាមលាមក ។ នៅពេលដែល ពងព្រូនត្រូវល័ក្ខខ័ណ្ឌ សីតុណ្ហភាព និង សំណើមសមស្រប វា នឹងវិវត្តទៅជាកូនដង្កូវ ។ គោក្របីនឹងឆ្លងនៅ ពេលស៊ីស្មៅដោយកូនដង្កូវ ។

រោគសញ្ញា

• ស្រកទំងន់ / ចុះស្គម
• ការស៊ីចំណីថយចុះ
• រាកពណ៌បៃតង
• រោមបះ



*រូបភាពទី ៩៥: គោមានសភាពស្គមស្គាំង និងខ្សោយកំលាំង*

ការព្យាបាល

• ប្រើប្រាស់ថ្នាំដូចជា លីវ៉ាមីសូល (Levamisole) ឬ អាល់បង់ដាហ្សូល (Albendazole) ជាដើម ។
• ប្រើប្រាស់អ៊ីវ៉ែមិចទីន១% ក្នុងកំរិត ១ ម.ល. ក្នុង ៥០ គីឡូក្រាមសត្វរស់ ដោយចាក់ក្រោមស្បែក។

ព្រូនសួត

ព្រូនសួតពេញវ័យរស់នៅក្នុងទងសួត ហើយបញ្ចេញពង ដែលអាចបណ្តាលឱ្យកើតជំងឺរលាកសួត ឬទងសួត

រោគសញ្ញា

• សីតុណ្ហភាពខ្ពស់ (៤០-៤១អង្សាសេ) និងមិនស៊ីចំណី
• ដកដង្ហើម និងក្អកញាប់
• ហូរសំបោរ
• ស្រែករោទ៍



*រូបភាពទី ៩៦: ព្រូន (Dictyocaulus) នៅក្នុងទងសួត ធ្វើឱ្យពិបាកដកដកដង្ហើម និង រមាស់*

## ការព្យាបាល

- ប្រើ លីវ៉ាមីសូល (Levamisole) ឬ អាល់បង់ដាហ្សូល ( Albendazole)
- ប្រើ អ៊ីវើមិចទីន (Ivermectine)

## តូសូការ៉ា

នៅតំបន់ខ្លះ កូនគោអាចខ្សោយ និងងាប់នៅពេលវាមានអាយុតែ ២ ទៅ ៣ខែ។ កូនគោលេបចូលនូវកូនដង្កូវតាម រយៈទឹកដោះនៅពេលវាមានអាយុ២សប្តាហ៍ដំបូងបន្ទាប់ពីកើត បន្ទាប់មកដង្កូវលូតលាស់នៅក្នុងកូនគោ ដែលបង្ក ឱ្យកូនគោខ្សោយ ហើយជូនកាលធ្វើឱ្យងាប់ក៏មាន។



*រូបភាពទី ៩៧: កូនគោលេបកូនដង្កូវ តាមរយៈទឹកដោះមេ*

ដើម្បីការពារកូនគោកុំឱ្យខ្សោយ និងជៀសផុតពីការងាប់បាន យើងត្រូវផ្តល់ ពីរ៉ង់តែល (pirentel) ២៥០មីលីក្រាមដល់កូនគោនៅអាយុ១៤ ថ្ងៃ។

## ហ្វាសសូឡា

បរាសិតរស់នៅក្នុងបំពង់ទឹកប្រមាត់។ គោបញ្ចេញពងបរាសិតតាមរយៈលាមក។ ពងបរាសិតដែលបញ្ចេញមកបរិស្ថានខាងក្រៅនេះ នឹងត្រូវបានពពួកខ្យងលេបចូល ហើយវិវត្តលូតលាស់ទៅជាដង្កូវ ។




*រូបទី ៩៨: វដ្តជីវិត របស់ហ្វាសូឡា*

គោលេបចូលកូនដង្កូវទាំងនេះនៅដំបន់ដែលសើមជាទីដែលខ្ចងរស់នៅ។ កូនដង្កូវទាំងនោះនឹងក្លាយទៅ ជាដង្កូវពេញវ័យនៅក្នុងថ្លើម ហើយបណ្តាលឱ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរ។



*រូបភាពទី ៩៩: ដង្កូវពេញវ័យ*



*រូបភាពទី ១០០: ថ្លើមខូចខាតដោយសារដង្កូវ*

### រោគសញ្ញា

- ស្រកទំងន់ និងស្គមកំប្រឹង
- ស្លេកស្លាំង
- រាករ៉ាំរ៉ៃ
- ហើមថ្គាម



*រូបភាពទី ១០១: គោស្គមនេះអាចមានដង្កូវថ្លើម*

### ការព្យាបាល

- ឌូវើនិច (Dovernix )
- អាល់បង់ដាសូល (Albendazole )

## ព្រូនសំប៉ែត

ព្រូនសំប៉ែតពេញវ័យ (តេញ៉ា សាស៊ីណាតា) រស់នៅក្នុងខ្លួនមនុស្ស និងឆ្កែ។
តេញ៉ាប្រភេទនេះមានប្រវែងពី ២ទៅ៧ម៉ែត្រ និងអាចរស់នៅក្នុងខ្លួនមនុស្សរហូតដល់២៥ឆ្នាំ។

*រូបភាពទី ១០២: ព្រូនសំប៉ែត*



## វដ្តជីវិត

គោនឹងស៊ីដោយពងតេញ៉ា តាមរយៈលាមករបស់មនុស្ស និងឆ្កែ។ ពងវិវត្តជាកូនដង្កូវហៅថា ស៊ីស្ទីសែរកូស៊ីស (Cysticercosis) ហើយស្ថិតក្នុងទម្រង់ជាគីសក្នុងសាច់ដុំ ថ្លើម និងខួរក្បាលនៃសត្វ។ មនុស្សនឹងឆ្លងនៅពេល ដែលបានបរិភោគសាច់សត្វដែលមិនឆ្អិនល្អ។

*រូបភាពទី ១០៣: នៅពេលដែលគ្មានបង្គន់ មនុស្សកើតតេញ៉ាបញ្ចេញពងតេញ៉ានៅលើវាលស្មៅ និងទឹកតាមរយៈ លាមក រួចហើយចម្លងទៅសត្វ។*



## ការការពារ

ចំពោះគោ:

- ពេលដែលមានឆ្កែរស់នៅជាមួយគោ ត្រូវទំលាក់តេញ៉ាឆ្កែឱ្យបានញឹកញាប់ជាមួយ ប្រាហ្ស៊ីលកង់តែល (Praziquantel) ឬ ហ្វេបង់ដាសូល (Febendazole)។
- មិនត្រូវផ្តល់ចំណីជាសាច់ដែលមានគីសដល់ឆ្កែទេ។

ចំពោះមនុស្ស:

- មិនត្រូវបរិភោគសាច់ដែលមិនឆ្អិនល្អ។
- អនាម័យ: ត្រូវសាងសង់បង្គន់។
- លាងដៃមុនបរិភោគ ជាពិសេស សំរាប់ក្មេងដែលលេងដី។

## បរាសិតខាងក្រៅ

ដង្កែជាបរាសិតដែលរស់នៅលើសត្វគ្រប់ប្រភេទ និងមនុស្ស ហើយជាភ្នាក់ងារចម្លងជំងឺផ្សេងៗ។ ឈាមជាប្រភពចំណីអាហារតែមួយគត់ដែលដង្កែបឺតពីសត្វ។ មាត់ដង្កែដូចជាស្នាសម្រាប់ចោះទំលុះស្បែក ហើយធ្វើឱ្យដង្កែមិនងាយសូតចេញពីសត្វ។

រូបភាពទី ១០៤:
ដង្កែជាបរាសិតខាងក្រៅដ៏សំខាន់



## វដ្តជីវិតៈ

ដង្កែញីរស់នៅលើសត្វ និងបឺតឈាមជាអាហារ នៅពេលវាធ្លាក់ទៅលើដី វានឹងបញ្ចេញពង ហើយបន្ទាប់មកវាក៏ងាប់។ ពងនឹងវិវឌ្ឍន៍ទៅជាកូនដង្កូវ ហើយផ្លាស់ទីទៅក្នុងគុម្ពស្មៅដើម្បីស្វែងរកអាហារដំបូង (ឈាម) របស់វា។ ប្រសិនបើមានសត្វណា ឆ្លងកាត់តាមនោះ ពួកវា នឹងតោងហើយបឺតយកឈាម។

រូបភាពទី ១០៥:
ដង្កែ រង់ចាំ នៅតាមគុម្ពស្មៅដើម្បីតោងសត្វ និង បឺតឈាម



## តួនាទីរបស់ដង្កែគោៈ

- ដង្កែ ជញ្ជក់ឈាមសត្វ ហើយដង្កែច្រើន អាចធ្វើឱ្យសត្វបាត់បង់ឈាម និង ចុះខ្សោយ ជាពិសេសកូនគោ
- ដង្កែ មានមាត់ស្រួចវែង ហើយអាចធ្វើឱ្យធ្លុះធ្លាយស្បែកសត្វ និងផ្តល់ឱកាសដល់រុយរោម និងឆ្លងបាក់តេរី
- ង្កែចម្លងជម្ងឺដូចពួកបាបេស្យា

## ការទប់ស្កាត់ពួកដង្កែះ

នៅប្រទេសកម្ពុជា សត្វគោមានភាពធន់នឹងដង្កែ (ពួកគោឡើងក និង គោបាយ)។ ដង្កែអាចកំចាត់បានជាបណ្តោះអាសន្នតែប៉ុណ្ណោះ នៅពេលដែលយើងឃើញមានដង្កែញឹកច្រើនពី ៤០ ទៅ ៥០ក្បាល ពេញដោយឈាមនៅលើខ្លួនសត្វ។ ដង្កែក្នុងចំនួនដ៏តិចតួចនៅលើខ្លួនសត្វ មិនធ្វើឱ្យសត្វឈឺស្រួចស្រាវឡើយ។ ថ្នាំប្រើសម្រាប់កំចាត់ដង្កែទាំងអស់ គឺតែងតែប៉ះពាល់ដល់ការបំពុលបរិស្ថាន ដូចជា ប៊ុយតុក អាមីត្រាស ឡាំងដង។ ដោយឡែកអ៊ីវ៉ូមិចទីន មិនប៉ះពាល់ដល់បរិស្ថានទេ។



*រូបភាពទី ១០៦: ការទប់ស្កាប់តាមបែបជីវសាស្ត្រ*

## ៤-ការខ្វះខាតសារធាតុចិញ្ចឹម

នៅប្រទេសកម្ពុជាជាទូទៅគេសង្កេតឃើញសារពាង្គកាយរបស់គោមិនល្អ ដែលបណ្តាលមកពីការខ្វះខាតសារធាតុចិញ្ចឹមចម្រុះដូចជា វីតាមីន សារធាតុរ៉ែ ប្រូតេអ៊ីន និង ថាមពល ដែលធ្វើឱ្យ សត្វខ្សោយផលិតកម្មថយចុះ ដូចជា ការផលិតទឹកដោះ ការភ្ជួររាស់មិនបានល្អ និងធ្វើឱ្យសត្វទទួលជំងឺរ៉ាំរ៉ៃ។ ដូច្នេះចំនុចសំខាន់បំផុត គឺ ការផ្តល់ចំណើដល់សត្វគោក្របីឱ្យបានសមស្រប។



*រូបភាពទី ១០៧: សារពាង្គកាយមិនល្អ*

## តម្រូវការចំណីអាហាររបស់គោក្របីៈ

តម្រូវការរបស់សត្វគោក្របី ប្រែប្រួលទៅស្ថានភាព ការមានកូន ការផ្តល់ទឹកដោះ ទំហំការងារ ឬការបំប៉ន និងអាស្រ័យលើទម្ងន់ដងខ្លួន។

## ប្រូតេអ៊ីនៈ

ប្រូតេអ៊ីនដែលផ្តល់ទៅឱ្យសត្វ បានមកប្រភពពីរផ្សេងគ្នាៈ

- ប្រូតេអ៊ីននៅក្នុងចំណីៈ ស្លឹកដំឡូងមី (២៤%), ពោត (៩%), កន្ទក់ (១២%) ...

*រូបភាពទី ១០៨: ស្លឹកដំឡូងមីជាប្រភពប្រូតេអ៊ីន*



- មីក្រូសារពាង្គកាយនៅក្នុងពោះធំៈ នៅក្នុងលក្ខខណ្ឌល្អ ល្បឿងមេរបស់ចំបើង ផ្តល់នូវប្រភពថាមពល ដល់មីក្រូសារពាង្គកាយដើម្បីលូតលាស់និងបំបែកខ្លួនបានរាប់លាននៅក្នុងពោះធំ។ មីក្រូសារពាង្គកាយទាំងនេះ មានប្រូតេអ៊ីនចំនួន ៨០% ហើយធ្លាក់ចុះទៅក្នុងពោះវៀនរំលាយទៅជាសារធាតុចិញ្ចឹម។

*រូបភាពទី ១០៩: មីក្រូសារពាង្គកាយ សំបូរទៅដោយពពួកប្រូតេអ៊ីន កំពុងលូតលាស់នៅក្នុងរសពោះធំ*



## ថាមពលៈ

ថាមពល បានមកពីពពួកសែលុយឡូស (ចំណីសត្វ និង ចំបើង ឬសៅស្ងួត) ពួកអាមីដុង (មើមដំឡូងមី ពោត) និង សារធាតុខ្លាញ់ (កន្ទក់)។

*រូបភាពទី ១១០: មានតែគោក្របីទេ ដែលអាចបំលែងចំបើងឱ្យទៅជាប្រភពថាមពល*



នៅពេលដែលចំណីសត្វមានគុណភាពទាប សត្វគោក្របី មិនបានស៊ីចំណីគ្រប់គ្រាន់ ហើយក៏មិនអាចទទួលបានថាមពលគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការដែរ ។

សារធាតុរ៉ែ:

- សារធាតុរ៉ែមានមួយផ្នែកតូចក្នុងចំណីអាហាររបស់គោក្របី ប៉ុន្តែសត្វត្រូវការនូវ សារធាតុរ៉ែយ៉ាងច្រើន ( ម៉ាក្រូ និងមីក្រូ) សម្រាប់ដំណើរការទ្រទ្រង់ ការធំធាត់ និងការបន្តពូជ ។
- សារធាតុរ៉ែ ប្រភេទម៉ាក្រូមាន ៧ប្រភេទ ដូចជា កាល់ស្យូម (Ca) ប៉ូតាស្យូម (P) ម៉ាញ៉េស្យូម (Mg) ក្លរ (Cl) និង ស្ពាន់ធ័រ (S) ជាដើម ។
- សារធាតុរ៉ែ ប្រភេទមីក្រូ មាន ១៨ប្រភេទចាំបាច់សម្រាប់សត្វ ដូចជា ជាតិដែក (Fe), ទង់ដែង (Cu), កូបាល់ (Co), ស័ង្កសី (Zn), អ៊ីយ៉ូត (I), ម៉ង់កាណែស (Mn), សេលេញ៉ូម (Se) ជាដើម ។
- សារធាតុរ៉ែដែលមានប្រភពមកពីដីនិងរុក្ខជាតិ មានឥទ្ធិពលលើស្ថានភាពរ៉ែនៅក្នុងខ្លួនសត្វ ។

វីតាមីន:

វីតាមីន ដើរតួនាទីសំខាន់ជំរុញឱ្យការប្រើប្រាស់សារធាតុចិញ្ចឹមផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព ។

- វីតាមីន អា គឺជាប្រភេទជីវជាតិជាងគេចំពោះគោក្របី ក្នុងការលូតលាស់ធម្មតា ការបន្តពូជ ការទ្រទ្រង់ស្បែក និង ការលូតលាស់ឆ្អឹង ។



*រូបភាពទី ១១១: ចំណីដែលមានគុណភាពខ្ពស់ និងស្លឹក ផ្តល់នូវវីតាមីន អា គ្រប់គ្រាន់ ប៉ុន្តែចំបើងពុំបានផ្តល់ដូចនេះទេ*

រោគសញ្ញាដែលតែងជួបប្រទះ:

- សារពាង្គកាយមិនល្អ ។
- សីតុណ្ហភាពដងខ្លួនធម្មតា ។
- មិនសូវស៊ីចំណី ។



រូបភាពទី ១១២: រោមបះ និងរដេករដុប



រូបភាពទី ១១៣: រោមប្រែពណ៌ពីលឿងទៅប្រផេះ

- រកឈ្មោលមិនទៀងទាត់ ។
- បរិមាណទឹកដោះតិច ធ្វើឱ្យកូនគោលូតលាស់មិនសូវល្អ ។
- កង្វះខាតសារធាតុចិញ្ចឹមច្រើនមុខ ធ្វើឱ្យសត្វងាយនឹងទទួលរងជំងឺផ្សេងៗ ។

ការផ្តល់ចំណីដោយប្រើប្រាស់ដំណាំចំណីសត្វល្អ:

- ដំណាំចំណីសត្វ ដូចជា ស្លឹកដំឡូងមី ស្មៅ ស្លឹកកន្ទំថេតជាដើម ផ្តល់នូវប្រូតេអ៊ីន វីតាមីន និងសារធាតុរ៉ែជាច្រើន ។



រូបភាពទី ១១៤: ដំណាំចំណីសត្វ

- គោក្របីដែលស៊ីស្មៅមិនសូវមានគុណភាព និងចំបើង ការផ្តល់ដំណាំចំណីសត្វដែលមានគុណភាពល្អ និងគ្រប់គ្រាន់ក្នុងអំឡុងពេល១ខែ នឹងជួយកែលំអសារពាង្គកាយឱ្យកាន់តែប្រសើរជាងមុន ។
- យើងគួរតែធ្វើការបញ្ចុះសត្វល្អិត ដោយប្រើប្រភេទថ្នាំ អាល់បង់ដាហ្សុល (Albendazole) ព្រមទាំងធ្វើការចាក់វីតាមីន អាដេអឺ (ADE) នៅពេលជាមួយគ្នាផងដែរ ។

**ការផ្តល់ចំណីដោយប្រើប្រាស់ចំបើងផ្អាប់:**

- ការអនុវត្តន៍បែបនេះ ជួយបង្កើនគុណភាពចំបើងយ៉ាងច្រើន:
- ជីអ៊ុយរ៉េ ចំនួន ៥ គ.ក លាយជាមួយទឹក ៥០លីត្រ ហើយបាញ់សាចទៅលើចំបើងស្ងួតចំនួន ១០០គ.ក ។
- ត្រូវគ្របអាងផ្អាប់ចំបើងឱ្យជិតល្អ កុំឱ្យខ្យល់ចូល ហើយរង់ចាំរយៈពេលប្រមាណ ៣ អាទិត្យ ទើបយើងយកឱ្យសត្វស៊ី ។

  ការផ្តល់ចំបើងផ្អាប់ឱ្យសត្វមានប្រសិទ្ធភាពណាស់ ហើយធ្វើឱ្យសារពាង្គកាយ ស្បែក និងរោមកាន់តែ ប្រសើរជាពិសេសយើងនឹងអាចឃើញលទ្ធផលច្បាស់ នៅពេលដែលយើងឱ្យស៊ីបានកំឡុង ៣ អាទិត្យ (ថ្នាំអាល់បង់ដាសូល និង ការចាក់វីតាមីនអាដេអី ១ដង ក៏គួរ ប្រើនៅក្នុងអំឡុងពេលនោះដែរ) ។

**ការសាងសង់អាងធ្វើចំបើងផ្អាប់:**

- គោក្របីទម្ងន់ ៣០០ គ.ក្រ ស៊ីចំបើងអស់ ៦ គ.ក ក្នុង ១ថ្ងៃ ដូច្នេះ គោ ២ក្បាល ស៊ីអស់ ១២ គ.ក្រ
- អាងចំបើងផ្អាប់មួយ ត្រូវមានទំហំអាចផ្ទុកចំបើងបានរយៈពេល ៣ អាទិត្យ:

  ២១ (ថ្ងៃ) ខ ៦ គ.ក្រ (គោ ១ក្បាល) ខ គោ ២ ក្បាល=២៥២គ.ក្រ
- អាងទំហំ ១ ម៣ = ចំបើង ១០០ គ.ក្រ ដូច្នេះ អាងត្រូវមានទំហំពី ២,៥-៣ ម$^{៣}$ សម្រាប់ផ្គត់ផ្គង់សត្វគោដែលមានទម្ងន់ ៣០០ គ.ក ចំនួន ២ ក្បាល
- កសិករត្រូវតែសាងសង់នូវអាងចំនួន ២ មានន័យថា សត្វគោ នឹងស៊ីចំបើងនៅក្នុងអាងទី ១ នៅពេលដែលដំណើការផ្អាប់ចំបើង (៣អាទិត្យ) នៅអាងទី២ កំពុងតែដំណើរការ ។



*រូបភាពទី ១១៥: ការសាងសង់អាងចំបើងផ្អាប់*

**មូលដ្ឋានគ្រឹះក្នុងការធ្វើចំបើងផ្អាប់:**

- បរិមាណជីអ៊ុយរ៉េ ចំនួន ៥ គ.ក្រ សម្រាប់លាយទឹកស្រោចលើចំបើងស្ងួតចំនួន ១០០ គ.ក្រ ។
- ទឹក ៥០ លីត្រ ទុកប្រើសម្រាប់លាយជាមួយជីអ៊ុយរ៉េ ស្រោចលើចំបើងស្ងួត ១០០ គ.ក្រ ។
- រយៈពេលផ្អាប់ គឺ ២ អាទិត្យ នៅរដូវប្រាំង និង ៣ អាទិត្យ នៅរដូវវស្សា (រដូវភ្លៀង) ។
- គ្របចំបើងបិទឱ្យជិត កុំឱ្យខ្យល់ចូលឱ្យសោះ (មិនត្រូវមានខ្យល់អុកស៊ីសែន ក្នុងអាងផ្អាប់នោះទេ) ។
- ចំបើងត្រូវតែស្ងួតល្អ ។



រូបភាពទី ១១៦: សាងសង់អាង ២ ប៉ុនគ្នា



រូបភាពទី ១១៧: ការរៀបចំចំបើង



រូបភាពទី ១១៨: ការថ្លឹងជីអ៊ុយរ៉េ



រូបភាពទី ១១៩: ការលាយជីអ៊ុយរ៉េជាមួយទឹក



រូបភាពទី ១២០: ការស្រោចជីអ៊ុយរ៉េលាយជាមួយទឹក



រូបភាពទី ១២១: គ្របបិទអាងផ្លាប់ បើងឱ្យជិតកុំឱ្យខ្យល់ចូល

ការរៀបចំធ្វើចំបើងផ្អាប់ដោយប្រើជីអ៊ុយរ៉េ

## ការផ្តល់ចំណីដោយប្រើប្រាស់ចំណីបន្ថែម:

ការផ្តល់នូវអាហារផ្សំស្រេចក៏អាចផ្តល់នូវប្រូតេអ៊ីន ថាមពល វីតាមីន និងសារធាតុរ៉ែបន្ថែម។

ចំណីផ្សំស្រេចដែលធ្វើដោយខ្លួនឯង អាចរៀបចំធ្វើនៅតាមកសិដ្ឋាននានា។ ធាតុផ្សំខាងក្រោមនេះត្រូវតែលាយច្របល់បញ្ចូលគ្នា:

| | |
|---|---|
| - កន្ទក់ | ១២ គ.ក្រ |
| - មើមដំឡូងមីក្រៀម | ៧ គ.ក្រ |
| - ស្លឹកដំឡូងមីក្រៀម | ៣ គ.ក្រ |
| - ជីអ៊ុយរ៉េ | ០,៣ គ.ក្រ |
| - អំបិល | ០,២៥ គ.ក្រ |
| - ស្ករត្នោត | ០,២៥ គ.ក្រ |



រូបភាពទី ១២២: ការផ្តល់ចំណីផ្សំស្រេចចំនួន ២០០ក្រាម ក្នុង១ថ្ងៃទើបអាចរក្សាតុល្យភាព សម្រាប់សត្វស៊ីចំណីកង្វះជីវជាតិបាន

## គ. បញ្ហាលើស្បែក

### ១. បរាសិត

**ដង្កែ និងរុយ:**

- ដង្កែ បឺតឈាមពីសត្វ។ ដង្កែច្រើនធ្វើឱ្យបាត់បង់ឈាម និងចុះខ្សោយ ជាពិសេសចំពោះកូនគោ។



រូបភាពទី ១២៣: ដង្កែបឺតឈាម

- ដង្កែ មានមាត់ស្រួចវែង ហើយអាចធ្វើឱ្យខូចខាតស្បែកសត្វ
- ដង្កែ ជាភ្នាក់ងារចម្លងជំងឺផ្សេងៗ ដូចជា ជំងឺ បាបេស្យា អាណាប្លូស្មា



រូបភាពទី ១២៤: រុយដែលកំពុងខាំ អាចបង្កឱ្យមានការរលាកស្បែក

**ការព្យាបាល:**

- ប៊ុយតុក អាមីត្រាស ឡាំងដង អ៊ីវើម៉ិចទីន (សម្រាប់តែពួកដង្កែប៉ុណ្ណោះ)។ ការព្យាបាលនេះអាចមានប្រសិទ្ធភាពរយៈពេលប្រមាណជា ២ អាទិត្យ។

*រូបភាព ១២៥: ការបាញ់ថ្នាំប៊ុយតុក (លាយប៊ុយតុក ២ មីលីលីត្រ ជាមួយទឹក ១ លីត្រ), ចំណុះទឹកថ្នាំលាយរួច ៣ លីត្រ ល្មមសម្រាប់បាញ់លើសត្វមួយក្បាល*



## ២. ការបាត់បង់ពណ៌សំបុរ

*រូបភាពទី ១២៦: គោប្រែសំបុរអាចដោយ-សារកង្វះសារធាតុរ៉ែ និងវីតាមីន*



ការបាត់បង់ពណ៌នៃរោមសត្វ តែងតែកើតមានឡើងជាញឹកញាប់ ដោយជាប់ពាក់ព័ន្ធជាមួយលក្ខខណ្ឌសារពាង្គកាយមិនល្អ។

- មូលហេតុជាទូទៅ គឺដោយសារតែកង្វះវីតាមីន អា សារធាតុស័ង្កសី និងទង់ដែង

**ការព្យាបាលៈ** ការចាក់បញ្ចូលសារធាតុវីតាមីនពី១ដង ទៅ ២ដង កម្រនឹងទទួលបានជោគជ័យណាស់។

- សារធាតុរ៉ែ និង វីតាមីនធ្វើសកម្មភាពជាមួយគ្នានៅក្នុងខ្លួនសត្វ។ ការកែតម្រូវការកង្វះខាតនេះមានលក្ខណៈស៊ាំញ៉ាំ។
- ការព្យាបាលនេះ ត្រូវការឱ្យសត្វទទួលបាននូវសារធាតុវីតាមីន និងសារធាតុរ៉ែដែលមានតុល្យភាពឱ្យបានរៀងរាល់ថ្ងៃ
- មធ្យោបាយដែលល្អបំផុត គឺ ត្រូវផ្តល់ឱ្យសត្វនូវប្រភេទចំណីអាហារផ្សំស្រេច (ទោះធ្វើខ្លួនឯងឬទិញពីផ្សារក៏ដោយ) រយៈពេល ៣-៤ អាទិត្យម្តង។

## ៣. ការជ្រុះរោម

កង្វះសារធាតុចិញ្ចឹម អាចនាំឱ្យមានការជ្រុះរោមនេះបាន។



*រូបភាពទី ១២៧:*
*សត្វជ្រុះរោមដោយសារពពួកផ្សិត*

- យើងគួរកត់សម្គាល់ថា នៅពេលយើងឃើញមានតំបន់ពណ៌ប្រផេះរាងមូលនៅលើក្បាល ឬក វាអាចបង្កឡើងដោយពពួកផ្សិតដែលធ្វើឱ្យមានស្នាមមូលនិងគ្មានរោមនៅកន្លែងដែលកើតនោះ (ស្រែង) ។
- ស្រែងអាចចម្លងទៅមនុស្សបាន ។

## ៤. ក្រម៉

ភាពងាយទទួលរងប៉ះពាល់ដោយពន្លឺថ្ងៃ ជាមូលហេតុចំបងធ្វើឱ្យខូចខាតស្បែក ។

- ស្បែកអាចប្រែជាពណ៌ក្រហម និងហើម
- ពងបែក
- បំណែកនៃស្បែកអាចបែកចេញ



*រូបភាពទី ១២៨: គោកើតក្រម៉នៅលើជើង*

បញ្ហាចំបង១មានៈ

- ប្រតិកម្មជាមួយថ្នាំដូចជា ស៊ុលហ្វា
- បង្កដោយពពួកផ្សិតនៅលើស្មៅ ប្រាការីយ៉ា
- ថ្លើមខូចខាត (បង្កដោយហ្វាសូឡាជាដើម) ដែលជាហេតុធ្វើឱ្យមិនអាចបំបាត់ជាតិពុលពីខ្លួនសត្វបាន ។

ការព្យាបាល

- ដាក់សត្វក្រោមម្លប់
- ប្រសិនបើមានស្នាមប្រេះខ្លាំង ប្រើប្រាស់អាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពយូរ

## ៥. ដំបៅ

ដំបៅជារបួសនៅលើស្បែក។ គ្រប់ដំបៅទាំងអស់ចេញឈាម មានការឈឺចាប់ ហើយអាច-មានដង្កូវ និងមេរោគ ងាយឆ្លងចូល



រូបភាពទី ១២៩: ដំបៅនៅលើជើង

ការព្យាបាល

- លាងដំបៅជាមួយទឹកឱ្យបានច្រើន និង ដុះថ្នមៗ។ ការធ្វើដូចនេះ បានន័យថា យើងព្យាបាលដំបៅបាន៩០%។
- កាត់រោមចេញ
- លាបទឹកអ៊ីយ៉ូឌីន (បើដំបៅស្អាត)
- ប្រសិនបើដំបៅជ្រៅ ត្រូវចាក់ អាម៉ុកស៊ីស៊ីលីន និងអុកស៊ីតេត្រាស៊ីគ្លីនដែលមានសកម្មភាពយូរ។

## ៦. ឬស្ស

ឬស្សបណ្ដាលមកពីវីរុសឈ្មោះថា ប៉ាពីឡូម៉ាវីរុស (ផាផិលល្ងមាវិរុស)

- វីរុសរាតត្បាតទៅគោក្របីផ្សេងទៀត នៅពេលស៊ីស្មៅតាមកំពតព្រៃ (វីរុសនៅលើមែកឈើ ហើយអាចជ្រាបចូលតាមស្បែករបួស)
- ជាធម្មតាគោមិនឈឺទេ

គ្មានការព្យាបាលទេ

ឬស្សគោក្របីជាញឹកញាប់នឹងរួញទៅវិញ ហើយជ្រុះបន្ទាប់ពី៣-៦ខែ។



រូបភាពទី ១៣០: គោកើតឬស្ស

## ឃ. បញ្ហាលើភ្នែក

### ១. ការរលាកភ្នាសស្តើងភ្នែក

ភ្នែកឡើងក្រហម ហើម និងហៀរទឹកភ្នែក គឺជារោគសញ្ញាទូទៅ នៃគ្រប់ទម្រង់នៃការរលាកភ្នាសស្តើងភ្នែក ។

*រូបភាពទី ១៣១: គោមានជំងឺនៅលើភ្នែក*



**មូលហេតុសំខាន់មាន :**

- វត្ថុផ្សេងទៀតចូល ដូចជាដីខ្សាច់ ធូលី ឬគ្រាប់ស្មៅ...
- របួស ឬស្នាមដាច់មាននៅលើកែវភ្នែក
- ជំងឺភ្នែកបង្កឡើងដោយសារមេរោគ ឬកង្វះអនាម័យ...

ប្រសិនបើភ្នែកទាំងសងខាង ឡើងក្រហម ហើម និងហៀរទឹកភ្នែក វាជារោគសញ្ញាជំងឺឆ្លងទូទៅ ដូចនេះត្រូវ វាស់សីតុណ្ហភាព ។ ជំងឺភាគច្រើន ច្រើនតែបង្កបញ្ហាលើភ្នែក ។

**ព្យាបាលៈ**

ត្រូវធ្វើការពិនិត្យភ្នែកឱ្យបានហ្មត់ចត់ និងប្រើក្រណាត់ស្អាតទន់ ដើម្បីជូតយកសារធាតុផ្សេងៗចេញពីភ្នែក។

*រូបភាពទី ១៣២: សំអាតភ្នែកឱ្យស្អាតជាមុន មុនចាប់ផ្តើមព្យាបាល*



- បន្តក់ថ្នាំដាក់ភ្នែកឱ្យបានឆាប់
- គេអាចប្រើថ្នាំដាក់ភ្នែករបស់មនុស្ស ប្រសិនបើកែវភ្នែកមិនរលាក

*រូបភាពទី ១៣៣: បន្តក់ថ្នាំដើម្បីព្យាបាលជំងឺភ្នែក*



- ហើយប្រសិនបើមានរលាកកែវភ្នែកត្រូវចាក់ :
  - ហ្សង់តាមីស៊ីន ជាមួយដិចសាមេតាសូន (Gentamycine + dexamethasone) ឬ
  - ក្លរំហ្វេនីកុល ជាមួយដិចសាមេតាសូន (Chloramphenicol + dexamethasone)
- គេមិនត្រូវប្រើថ្នាំដាក់ភ្នែកជាមួយដិចសាមេតាសូន ទេ គេប្រើតែអង់ទីប៊ីយ៉ូទិកប៉ុណ្ណោះ ត្រូវរក្សាទុកគោក្របីនៅក្រោមម្លប់

## ២. ភ្នែកពណ៌ផ្កាឈូក

បុព្វហេតុបង្កជំងឺ

- បង្កឡើងដោយបាក់តេរីឈ្មោះម៉ូរ៉ាសែឡា (Moraxella)
- បាក់តេរីនេះបញ្ចេញជាតិពុល ដោយបង្កបញ្ហាទៅភ្នាសស្តើងភ្នែក ហើយបណ្តាលឱ្យរលាក និង ដំបៅ ។

រោគសញ្ញា: ដែលគេមើលឃើញមាន:

- មានហូរទឹកភ្នែកច្រើនលើសលុប
- ភ្នែកចាញ់ពន្លឺ
- សញ្ញានៃការរមាស់ភ្នែកដូចជា ព្រិចភ្នែកជាប់ជាដើម
- ត្របកភ្នែកឡើងក្រហម និងហើម

រូបភាពទី ១៣៤: ទឹកភ្នែកដែលហូរចេញ អាចបន្តចម្លងទៅសត្វផ្សេង ទៀតតាមរយៈរុយ



រូបភាពទី ១៣៥: ពេលឃើញហូរទឹកភ្នែក ជាពេល ដ៏ល្អដែលគេត្រូវព្យាបាលដោយ បន្តក់ថ្នាំភ្នែក តេរ៉ាមីស៊ីន (terramycine)



ការព្យាបាលៈ

ប្រសិនបើមិនព្យាបាល នោះក្នុងកំឡុងពេល ២ ថ្ងៃបន្ទាប់ ផ្នែកកណ្តាលនៃភ្នែកនឹងមានឡើងដូចពពក ហើយដំបៅភ្នាសស្តើងភ្នែក។ ក្នុងដំណាក់កាលនេះ សត្វភាគច្រើននឹងជាសះស្បើយមកវិញភ្លាម ប៉ុន្តែភ្នែកនឹងខ្វាក់បើដំបៅវិវត្តទៅជាបូស។

រូបភាពទី ១៣៦: សត្វអាចខ្វាក់បើមិនព្យាបាល ទាន់ពេល



## ៣. ការផ្លាស់ប្តូរពណ៌ភ្នាស់ស្តើងភ្នែក

ភ្នាសស្តើងភ្នែកគឺជាកន្លែងសំរាប់ធ្វើការត្រួតពិនិត្យពណ៌របស់កែវភ្នែក។ ភ្នាសស្តើងភ្នែក ដែលមានសភាព ធម្មតា គឺសើម និង ពណ៌ផ្កាឈូក។



*រូបភាពទី ១៣៧: ភ្នាសស្តើងភ្នែក មានសភាពធម្មតា*

សភាពពណ៌របស់ភ្នែកអាចបញ្ជាក់ពី ស្ថានភាពសុខភាពដូចជា:

- ពណ៌សគឺជាសភាពស្លេកស្លាំង ដោយសារគោលិកាឈាមក្រហមមិនគ្រប់គ្រាន់
- ពណ៌លឿង បញ្ជាក់ថាមានខាន់លឿង ដោយសារ មានបញ្ហានៅថ្លើម ឬដោយសារការបំផ្លាញគោលិកា ឈាមក្រហមច្រើនពេក ។
- នៅពេលពណ៌ផ្លាស់ប្តូរពីក្រហមចាស់ ទៅស្វាយ ជាសញ្ញានៃការឆ្លងមេរោគក្នុងឈាម ។

បុព្វហេតុចំបង៧បង្កឱ្យមានបញ្ហាស្លេកស្លាំង និងខាន់លឿង និងការព្យាបាល

- ចំពោះកូនគោកើតឡើងដោយសារការមានដង្កែច្រើនពេក ដូចនេះត្រូវបាញ់ ថ្នាំប៊ុយតុក (Butox) តាក់ទិច (Tactik) អ៊ីវែមិចទីន (Ivermectine)
- ហ្វាស្យូឡា (Fasciola) គេត្រូវព្យាបាលដោយប្រើអាល់បង់ដាសូល (Albendazole)
- អាណាប្លាស្មា (Anaplasma) ត្រូវព្យាបាលដោយប្រើអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline)
- ទ្រីប៉ាណូសូម៉ា (Trypanosoma) ឬ បាបេស្យា (Babesia) ត្រូវព្យាបាលដោយប្រើបេរេនីល (Berenil)
- ឡិបតូស្ពីរ៉ូស៊ីស (Leptospirosis) ជំងឺនេះឆ្លងតាមរយៈទឹកនោមសត្វដែលឈឺ ។

**ជំងឺឡិបតូស្ពីរ៉ូស៊ីស**

**រោគសញ្ញា:**

- គ្រុនក្តៅ
- មិនស៊ីចំណី អស់កំលាំង
- ទឹកនោមពណ៌ស្រអាប់ ឬក្រហមត្នោត
- ពិបាកដកដង្ហើម
- ខាន់លឿង ស្លេកស្លាំង



*រូបភាពទី ១៣៨: ពិនិត្យភាពស្លេកស្លាំងរបស់សត្វតាមរយៈភ្នែក*

ការព្យាបាលៈ

ត្រូវព្យាបាលដោយប្រើអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) ឬ ប៉េនី-ឌីអេចអេស (Peni-DHS)

## ៤. ភ្នែកខ្វាក់

គេងាយដឹងថាសត្វពិការភ្នែក ជាពិសេសនៅ ពេលវាដើរបុករបស់របរផ្សេងៗ។ គេពិបាកចិញ្ចឹមសត្វខ្វាក់ភ្នែកណាស់។

គោអាចមានបញ្ហាខ្វាក់ភ្នែក ដោយមិនឃើញ មានស្លាកស្នាមដំបៅលើភ្នែក

- បុព្វហេតុសំខាន់នោះគឺបណ្ដាលមកពី ការពុលដោយសំណ ដោយសារគោលិឍអាគុយចាស់ៗ

រូបភាពទី ១៣៩: គេមិនត្រូវបោះចោលអាគុយនៅលើវាលស្មៅ ឬកន្លែងដទៃទៀតឡើយ



# ៦. បញ្ហាដុំពក

## ១. បូស

បូស គឺជាការប្រមូលផ្ដុំខ្ទុះ ដែលមានក្នុងជាលិកា វាជាការដំណើរការនៃការឆ្លងមេរោគ។ វាជាប្រតិកម្មការពាររបស់ជាលិកា ដើម្បីទប់ទល់ការពារការឆ្លងមេរោគទៅផ្នែកផ្សេងទៀតនៃសារពាង្គកាយ។

ជាញឹកញាប់ បូសបង្កឡើងដោយ មេរោគចូលទៅនៅក្រោមស្បែកនៅពេលយើង ចាក់វ៉ាក់សាំង ឬចាក់ថ្នាំដោយប្រើម្ជុលកខ្វក់។ បូសភាគច្រើន គេឃើញកើតមាននៅតំបន់ក។

រោគសញ្ញាៈ

- បូស គឺជាបញ្ហានៅក្រោមស្បែក ដោយមានសភាពហើម និងការឈឺចាប់។
- វាមានខ្ទុះ (សារធាតុរាវពណ៌លឿងឬប្រផេះ)



រូបភាពទី ១៤០: បូសនៅលើខ្លួនសត្វ

ការព្យាបាលៈ

- លាងសំអាតនៅមុខរបួស និងតំបន់ជុំវិញបូសរួចកោររោមចេញ
- ប្រើកាំបិទ ឬឡាមវះកាត់មុខបូស
- រួចបាញ់ទឹកអ៊ីយ៉ូឌីនចូលទៅក្នុងបូស

*រូបភាពទី ១៤១: ចាក់ទំលុះដើម្បីយកខ្ទុះចេញ*



## ២. ការហើមមានឈាម

វាកើតឡើងដោយសារគេវាយ ឬជល់គ្នា ហើយការហើមមានសភាពទន់តែមិនក្តៅ ឬឈឺចាប់ទេ។

*រូបភាពទី ១៤២: ឈាមដែលបូមចេញពីដុះពក*



ការព្យាបាលៈ

- ការកកឈាម នឹងបាត់ដោយមិនបាច់ធ្វើការព្យាបាលក្នុងរយៈពេល ២ ទៅ ៣ សប្តាហ៍។
- កុំប៉ះពាល់វា
- ប៉ុន្តែប្រសិនបើមានស្នាមរបួស មេរោគនឹងចូលក្នុងថង់ឈាម ហើយបង្កជាបូស ដូច្នេះត្រូវចាក់អាម៉ុកស៊ីលីន (Amoxillin) ដើម្បីការពារ។

## ៣. ដុំពករឹង

ដុំពករឹងអាចបន្តរីកធំ ឬឈប់រីកធំតែម្តង។

ដុំពកមិនបន្តរីកធំ៖

- រីកធំក្នុងដែនកំណត់មួយច្បាស់លាស់
- មិនបន្តរីកធំរហូត
- គ្មានការឈឺចាប់ នៅពេលប៉ះ

*រូបភាពទី ១៤៣៖ ជាការល្អយើងត្រូវរងចាំ និងធ្វើការតាមដានសិន និងមិនចាំបាច់ព្យាបាលដុំពកនោះទេ*



ដុំពករីកធំ៖

- ដុំពករីកធំសន្សឹមៗ
- មានការឈឺចាប់នៅពេលប៉ះវា
- បង្កការរំខានដល់គោ

យើងអាចសង្ស័យថាជាបញ្ហារលាករ៉ាំរ៉ៃ ជាមួយនឹងការឆ្លងរោគដែលមិនទាន់បង្ហាញឱ្យឃើញ។

*រូបភាពទី ១៤៤៖ ដុំពកហើមរឹងស្ថិតនៅជិតលិង្គ មិនដឹងពីមូលហេតុច្បាស់លាស់*



ការព្យាបាល៖

- ចាក់ដិចសាមេតាសូនរយៈពេល ៣ ថ្ងៃ
- ចាក់អង់ទីប៊ីយ៉ូទិច ដូចជា ទ្រីមេតូព្រីមជាមួយ ស៊ុលហ្វា (TMP-Sulfa) ឬអាម៉ុកស៊ីស៊ីលីន (Amoxillin) យ៉ាងតិច ៥ ថ្ងៃ។

## ៤. ការហើម

ការហើម គឺជាដំណើរការជ្រាបទឹកនៅក្រោមស្បែក បើយើងសង្កត់លើកន្លែងហើម នឹងមានស្នាម ទ្រុតជាប់ ពី២ ទៅ ៣ វិនាទី ។



*រូបភាពទី ១៤៥: ការហើមនៅក*

- ការហើមនៅលើគោក្របី ច្រើនកើតមានជាមួយភាពស្លេកស្លាំង ជាទូទៅនៅប្រទេសយើង ច្រើនបណ្ដាលមកពីហ្វាស្យូឡា (Fasciola) ។
- ការហើមក៏មានជាប់ទាក់ទងនឹងជំងឺឆ្លងខ្លះ ដូចជាសារទឹក (Hemorrhagic Septicemia) ជាដើម ។



*រូបភាពទី ១៥៦: គោហើមនៅតំបន់ក្ដាម*

**ការព្យាបាល:** ទៅតាមប្រភេទនៃការហើម

## ៥. ក្លូន

- ក្លូន ឬ ធ្លាក់ពោះវៀន ច្រើនកើតមានលើកូនគោ ។
- ក្លូននៅផ្ចិត កើតមានដោយសារការឆ្លងមេរោគតាមទងផ្ចិត ។
- ជារឿយៗសត្វមិនឈឺ តែគេគ្រាន់តែឃើញដុំពកប៉ុណ្ណោះ ។
- ម៉ាសរបស់ដុំពកអាចរុញឱ្យចូលក្នុងពោះវិញបាន ។



រូបភាពទី ១៤៧ : ក្លូន (ដែលគ្មានពោះវៀនចូលក្នុងដុំពក) គ្មានការ ប្រែប្រួល ទេ និងជារឿយៗ ទំហំរបស់វា នឹងថយចុះ ជា ច្រើនខែបន្ទាប់



រូបភាពទី ១៤៨: យើងមិនគួរទុកគោដែលមានក្លូនទំហំធំ (បណ្តាលមកពីការធ្លាក់ពោះវៀន ឬសរីរាង្គ)

ការព្យាបាលៈ

- គ្មានការព្យាបាល ក្រៅពីការវះកាត់ទេ។
- ប្រសិនបើក្លូននេះមានទំហំតូច កូនគោនឹងលូតលាស់ធម្មតា។
- ប្រសិនបើមានបញ្ហាជំងឺនៅទងផ្ចិត យកល្អត្រូវចាក់ អង់ទីប៊ីយ៉ូទិច ដូចជា អាម៉ុកស៊ីស៊ីលីន (Amoxillin) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP-Sulfa) ជាដើម។

## ច. បញ្ហាលើផ្លូវដង្ហើម

ជំងឺលើផ្លូវដង្ហើមជារឿយៗកើតឡើងដោយកត្តាមួយចំនួនដូចជា មេរោគរាតត្បាតលើបំពង់ខ្យល់ ហើយ ស្ថិតនៅទីនោះជាប្រចាំ ប៉ុន្តែនៅពេលមានលក្ខខណ្ឌសមស្របណាមួយ មេរោគនឹងធ្វើការបំបែកខ្លួនយ៉ាងលឿន និងធ្វើឱ្យលេចចេញនូវរោគសញ្ញាឡើង។

ស្ត្រេសសំខាន់ៗដែលបង្កឱ្យកើតជំងឺលើផ្លូវដង្ហើមមានៈ

- ក្តៅ ឬត្រជាក់ខ្លាំង
- ធូលីច្រើន
- អស់កំលាំង ខ្សោះទឹក និងហេវហត់បន្ទាប់ពីភ្ជួររាស់ និងដឹកជញ្ជូន
- ខ្វះសារធាតុចិញ្ចឹម



រូបភាពទី ១៤៩: រដូវភ្លៀងធ្វើឱ្យសត្វងាយ ទទួលជំងឺផ្លូវដង្ហើម

## ១. ក្អក

### រោគសញ្ញាទូទៅ

ការក្អកគឺជាសកម្មភាពនៃការខំប្រឹងបញ្ចេញខ្យល់ ចេញតាមមាត់ និងមានសំលេង។



រូបភាពទី ១៥០: គោប្រឹងក្អក

**ក្អកបង្កឡើងដោយ :**

- ជំងឺឆ្លងនៅសួត ឬបំពង់ខ្យល់ដែលធ្វើឱ្យរលាក
- បរាសិតនៅសួត
- ទឹក ឬសំបោរនៅក្នុងសួត ឬបំពង់ខ្យល់

**ជំងឺរលាកទងសួត និងសួត** *(Broncho-pneumonia)* **:**

វាជាជំងឺឆ្លងដែលបង្កឡើងដោយបាក់តេរីឈ្មោះគឺប៉ាស្ទឺរេឡា *(Pasteurella)* ។ ជាធម្មតា បាក់តេរី ប៉ាស្ទឺរេឡា (មិនបង្កជំងឺ) មាននៅដើមក មិនមែននៅក្នុងសួតទេ។ បាក់តេរីប៉ាស្ទឺរេឡា លូតលាស់ និងធ្វើការបង្កជំងឺដល់សួតដោយបញ្ចេញរោគសញ្ញាច្បាស់លាស់ នៅពេលប្រព័ន្ធការពាររបស់សួតចុះខ្សោយ (ដោយសារស្ត្រេស កង្វះជីវជាតិ និងការឆ្លងដោយវីរុស) ។



រូបភាពទី ១៥១: បាក់តេរីប៉ាស្ទឺរេឡាផលិត ជាតិពុល និងធ្វើការបំផ្លាញ ជាលិកាសួត

រោគសញ្ញា

- មិនស៊ីចំណី
- រលាកកែវភ្នែក (ភ្នែកក្រហម និងហូរទឹកភ្នែក)
- ហូរសំបោរ
- ក្អក
- គ្រុនក្តៅរយៈពេលពី ៣-៤ ថ្ងៃ (កំដៅលើស ៤0 អង្សាសេ)

ការព្យាបាល :

ប្រើតេត្រាស៊ីគ្លីនមានសកម្មភាពយូរ ដូចជា: រីម៉ាស៊ីគ្លីន (Remacycline) ឬទែរ៉ាអិលអេ (Terra LA) ឬឡុងជីស៊ីន (Longicine) ដោយចាក់ចំនួន ១ថ្ងៃម្តង ក្នុងចន្លោះ២ថ្ងៃម្តង (ចំនួនសរុប ៣ដង)។

ដង្កូវសួត (Dictyocaulus) : ដង្កូវពេញវ័យរស់នៅ និងពងនៅក្នុងទងសួត បង្កឱ្យមានជំងឺរលាកសួត ឬទងសួត។

រូបភាពទី ១៥៧: ដង្កូវនៅក្នុងសួត



រោគសញ្ញា

- ក្អក
- ជាទូទៅ កំដៅអាចឡើងដល់ ៤0 អង្សាសេក្នុងករណីធ្ងន់ធ្ងរ
- ហូរសំបោរ
- មានឮសំលេងក្រឹតក្រតនៅក្នុងសួត

ការព្យាបាល :

- អាល់បង់ដាសូល (Albendazole) : ១0 ម.ល សម្រាប់គោទំងន់ ១00 គ.ក្រ ឬអ៊ីវែមិចទីន (Ivermectine) : ១ ម.ល សម្រាប់គោទំងន់ ៥0 គ.ក្រ
- អុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) រយៈពេល ៣ថ្ងៃ

**ដំបៅនៅដើមក**

របួស ឬប៉ូស បង្កឡើងដោយសារការមុតវត្ថុផ្សេងៗនៅពេលស៊ីស្មៅ ឬជាពិសេសពេលវាស៊ីនៅកន្លែ

សម្រាម។

**រោគសញ្ញា**

- ពិបាកដកដង្ហើម ជាពិសេសពេលសត្វដកដង្ហើមចូល
- ពេលស្រូបដង្ហើមចូលមានឮសូរសំឡេងក្រិកៗ
- ពេលស្ទាបនៅដើមក ធ្វើឱ្យសត្វឈឺចាប់ និងក្អក



*រូបភាពទី ១៥៣: ស្ទាបដើមកដើម្បីដឹងពីការឈឺចាប់របស់សត្វ*

**ការព្យាបាល:** ប្រើទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) រយៈពេល ៥ ថ្ងៃ

## ២. ការហូរសំបោរ

ការហូរសំបោរតិចតួចពេលខ្លះវាធ្វើឱ្យយើងពិបាកមើលឃើញដោយគោវាតែងតែលិតច្រមុះរបស់វា

ឱ្យស្អាត។



*រូបភាពទី ១៥៤: ពិបាកពិនិត្យសំបោរព្រោះគោចូលចិត្តលិឍសំបោររបស់វា*

**រលាកឆ្អឹងខ្ទង់ច្រមុះ** (Sinusitis) **:** ជាទូទៅការរលាកនេះវាជាប់ទាក់ទងនឹងការបាក់ស្នែង ឬជំងឺធ្មេញ

**រោគសញ្ញា :**

- ហូរសំបោរឬខ្ទុះចេញពីរន្ធច្រមុះម្ខាង ឬសងខាង
- គ្មានគ្រុនក្តៅ

• បើប៉ះ ឬគោះថ្ងាស វាមានសំលេងស្ទក់ និងឈឺចាប់



*រូបភាពទី ១៥៥: គោះថ្ងាសគោ*

ការព្យាបាល :

ប្រើអាម៉ុកស៊ីលីនមានសកម្មភាពបានយូរ ចាក់ ១ថ្ងៃម្តង ក្នុងចន្លោះ២ថ្ងៃម្តង ( ចំនួនសរុប ៣ដង) ។

**រលាកសួត** (Pneumonia) :

ការហូរសំបោរបង្កឡើងដោយសារការរលាកទងសួតដែលមានខ្ទុះ ប្រសិនបើមិនព្យាបាលទេ វានឹង នឹងក្លាយទៅជាជំងឺរលាកសួតរ៉ាំរ៉ៃ និង វិវត្តនៅជាដំបៅនៅក្នុងសួត ។



*រូបភាពទី ១៥៦: សួតត្រូវបានបំផ្លាញ*

រោគសញ្ញា:

• ក្អក
• គ្រុនក្តៅ ៣-៤ ថ្ងៃ ( កំដៅលើស ៤0 អង្សាសេ)
• រលាកកែវភ្នែក ( ភ្នែកក្រហម និងហៀរទឹកភ្នែក)

ការព្យាបាល :

• ប្រើអង់ទីប៊ីយូទិកមានសកម្មភាពបានយូរ រួមមាន អុកស៊ីតេត្រាស៊ីគ្លីន (OTC) ឬហ្វ្លរផេនីកុល (Florfenicol) ឬទីឡូស៊ីន (Tylosin)
• ក្រោយពេលជាហើយ ( លែងឃើញមានរោគសញ្ញា) គេត្រូវបន្តព្យាបាល ៣ ថ្ងៃថែមទៀត ។

## ៣. កណ្តាស

កណ្តាសគឺជាសកម្មភាពនៃការខំប្រឹងបញ្ចេញខ្យល់តាមច្រមុះ ។

- វាអាចបណ្តាលមកពីមានបញ្ហាឆ្លងជំងឺនៅក្នុងច្រមុះ ។
- ឬ ដោយសារវត្តមានវត្ថុផ្សេងៗ ឬដង្កូវនៅក្នុងរន្ធច្រមុះ ។

*រូបភាពទី ១៥៧: ជាការចាំបាច់ត្រូវពិនិត្យក្នុងរន្ធច្រមុះ*



ការព្យាបាលៈ

- ប្រើអង់ទីប៊ីយូទិក
- ប្រសិនបើមានដង្កូវត្រូវលាយថ្នាំលីនដាន (Lindane) ២ទៅ៣ ដំណក់ ជាមួយប្រេងប៉ារ៉ាហ្វីន (Parafine) រួចដាក់ត្រង់កន្លែងមានដង្កូវនោះ ។

## ៤. ពិបាកដកដង្ហើម

ការធ្វើអង្កេតត្រឹមត្រូវអាចឱ្យយើងដឹងៈ

**ពិបាកដកដង្ហើម :**

- គោក្របីមិនអាចស្រូបយកខ្យល់បានគ្រប់គ្រាន់ ដូចនេះពេលដកដង្ហើមសត្វប្រឹងដកក និងហារមាត់ ។

*រូបភាពទី ១៥៨: សត្វប្រឹងដកដង្ហើម*



- ពេលស្រូបខ្យល់ចូលតាមបំពង់ខ្យល់ ធ្វើឱ្យគោមានការឈឺចាប់ ។

## ៣. កណ្ដាស

កណ្ដាសគឺជាសកម្មភាពនៃការខំប្រឹងបញ្ចេញខ្យល់តាមច្រមុះ។

- វាអាចបណ្ដាលមកពីមានបញ្ហាឆ្លងជំងឺនៅក្នុងច្រមុះ ។
- ឬ ដោយសារវត្តមានវត្ថុផ្សេងៗ ឬដង្កូវនៅក្នុងរន្ធច្រមុះ។



*រូបភាពទី ១៥៧: ជាការចាំបាច់ត្រូវពិនិត្យក្នុងរន្ធច្រមុះ*

ការព្យាបាលៈ

- ប្រើអង់ទីប៊ីយូទិក
- ប្រសិនបើមានដង្កូវ ត្រូវលាយថ្នាំលីនដាន (Lindane) ២ទៅ៣ ដំណក់ ជាមួយប្រេងប៉ារ៉ាហ្វីន (Parafine) រួចដាក់ត្រង់កន្លែងមានដង្កូវនោះ។

## ៤. ពិបាកដកដង្ហើម

ការធ្វើអង្កេតត្រឹមត្រូវអាចឱ្យយើងដឹងៈ

**ពិបាកដកដង្ហើម :**

- គោក្របីមិនអាចស្រូបយកខ្យល់បានគ្រប់គ្រាន់ ដូចនេះពេលដកដង្ហើមសត្វប្រឹងដកក និងហារមាត់។



*រូបភាពទី ១៥៨: សត្វប្រឹងដកដង្ហើម*

- ពេលស្រូបខ្យល់ចូលតាមបំពង់ខ្យល់ ធ្វើឱ្យគោមានការឈឺចាប់។



រូបភាពទី ១៥៩: សត្វឈឺចាប់ពេលដកដង្ហើម

**ការដកដង្ហើមញាប់ :**

នៅពេលសត្វសំរាក ចង្វាក់ដង្ហើមធម្មតាមានពី ១០ទៅ២០ ដងក្នុង១នាទី (គោធំ) និងកូនគោមានពី ១៥ទៅ៣០ ដងក្នុង១នាទី ប៉ុន្តែនៅពេលមានបញ្ហាផ្លូវដង្ហើមចង្វាក់ដង្ហើមកើនឡើងខ្លាំងពីព្រោះមានតែផ្នែកខ្លះនៃសួតប៉ុណ្ណោះ ដែលអាចស្រូបយកអុកស៊ីសែនបាន ។

**បញ្ហាលំបាកដកដង្ហើម (Dyspnea) :**

ការដកដង្ហើមរបស់សត្វជាធម្មតា កើតឡើងដោយការធ្វើចលនាទ្រូង និងពោះ ប៉ុន្តែនៅពេលសួតមានបញ្ហា សត្វដកដង្ហើមដោយធ្វើចលានាតែពោះប៉ុណ្ណោះ ។

**រលាកសួត (ជំងឺសារទឹក) :**

ការឆ្លងមេរោគនៅសួតបណ្តាលឱ្យមានជំងឺរលាកសួត ។ ជំងឺសារទឹកបណ្តាលឱ្យមានជំងឺរលាកសួតធ្ងន់ធ្ងរនិងធ្វើការវិវត្តន៍លឿនដែលធ្វើឱ្យសត្វងាប់ភ្លាមៗ ។

**រោគសញ្ញា**

- ដំណាក់កាលសម្ងំជំងឺមានរយៈពេលខ្លី សត្វឈឺក្នុងកំឡុងពេលពី២ទៅ៣ ម៉ោងក្រោយ
- ដំបូង សត្វមិនចង់ដើរ គ្រុនក្តៅ ហូរទឹកមាត់ និងហូរសំបោរខ្លាំង
- បញ្ហាផ្លូវដង្ហើម មានហូរសំបោរលាយឈាម
- ហើមនៅក្បាល ក និង តំបន់ទ្រូង
- ការស្លាប់អាចកើតមានក្នុងកំឡុងពេលពី ៦ទៅ២៤ ម៉ោង ក្រោយពីលេចចេញរោគសញ្ញាដំបូង ។

**ការព្យាបាល :**

- ត្រូវព្យាបាលឱ្យទាន់ពេលៈ គ្រប់បញ្ហាជំងឺផ្លូវដង្ហើមត្រូវតែធ្វើការព្យាបាលជាបន្ទាន់ ដើម្បីការពារ

កុំឱ្យសត្វស្លាប់ (ដូចជាជំងឺសារទឹក) ការពារកុំឱ្យបាក់តេរីបញ្ចេញជាតិពុល (ប៉ាស្ទេរេឡា) និងដំបៅ ភ្នំរ៉ៃ។



រូបភាពទី ១៦០: ព្យាបាលសត្វឱ្យទាន់ពេលវេលា

- ការចាក់ថ្ងៃដំបូងត្រូវប្រើកិរិតគុណនឹង ២ ហើយប្រសិន បើអាចធ្វើទៅបានអាចចាក់តាមសរសៃវ៉ែន
- បន្តព្យាបាល ២ ថ្ងៃទៀត ក្រោយពេលរោគសញ្ញាបាត់ទៅវិញ
- អង់ទីប៊ីយ៉ូទិកដែលត្រូវប្រើមាន អុកស៊ីតេត្រាស៊ីគ្លីន ឡុងអាក់ទីន ឬ ហ្វ្លរហ្វេនីកុល *(Florfenicol)* ឬទីឡូស៊ីន *(Tylosin)*។

**មុតវត្ថុផ្សេងៗ :**

គោអាចលេបចូលនូវលួស ឬដែលគោលពេលវាស៊ីស្មៅនៅកន្លែងដែលគេចោលសម្រាម។



រូបភាពទី ១៦១: សត្វស៊ីដោយវត្ថុរឹង

បំណែកដែកអាចទំលុះពោះចក និងបណ្តាលឱ្យឆ្លងជំងឺដូចជា រលាកភ្នាសស្តើងរវាងក្រពះនិងពោះវៀន (ឆ្លងនៅផ្ទៃពោះ) ឬ រលាកសាច់ដុំបេះដូង (ឆ្លងនៅម្ខុំបេះដូង) និងជួនកាលរលាកព្រមគ្នា។

**រោគសញ្ញា :**

- ពេលដកដង្ហើមខំប្រឹងហារមាត់ (ពិបាកដកដង្ហើម)
- គ្រុនក្តៅ
- មានការឈឺចាប់នៅពោះ



*រូបភាពទី ១៦២: ការតាមដានការឈឺចាប់នៅផ្នែកពោះដោយធ្វើឱ្យសត្វស្រែក*

ឈឺនៅតំបន់ទ្រូងនៅពេលមានវត្ថុមុតនៅតំបន់បេះដូង

**ការព្យាបាល :**

- ចាក់អង់ទីប៊ីយ៉ូទិក ប៉េនី ឌីអេចអេស ឬ អុកស៊ីតេត្រាស៊ីគ្លីន *(Peni DHS or Oxytetracycline)* រួមជាមួយ ដិចសាមេតាសូន
- ចាក់លើកដំបូងធ្វើឡើងត្រង់ពោះ



*រូបភាពទី ១៦៣: ចាក់ថ្នាំតាមប្រអប់ពោះ*

## ធ.បញ្ហាការរំលាយអាហារ

### ១. ការមិនស៊ីចំណី

ការមិនស៊ីចំណីគឺជារោគសញ្ញានៃការ ថយចុះនូវចំណង់ស៊ីអាហារ ឬមិនស៊ីចំណីតែម្តង។ ការឈប់ស៊ីចំណីភ្លាមៗ ជាសញ្ញានៃបញ្ហាធ្ងន់ធ្ងរ យើងត្រូវចាត់វិធានការឱ្យបានទាន់ពេលវេលា។ ពេលខ្លះយើងឃើញមានតែរោគសញ្ញាមិនស៊ីចំណីតែមួយ ប៉ុន្តែនៅពេលយើងធ្វើរោគវិនិច្ឆ័យឱ្យបានល្អិតល្អន់ យើងនឹងឃើញមានលាយឡំ និងរោគសញ្ញាផ្សេងៗទៀតដូចជា រាគខ្លាំង សញ្ញានៃការពុលជាដើម។

**ពោះធំលែងធ្វើចលនា** *(Rumen stasis)* **:**

បញ្ហានេះជាញឹកញាប់ច្រើនកើតមានឡើង ក្រោយពេលសត្វជាសះស្បើយពីជំងឺធ្ងន់ធ្ងរ ជាដំបូងធ្វើឱ្យសត្វ បាត់បង់ការស្រេកឃ្លាន។ យើងនឹងអង្កេតឃើញពោះធំឈប់ធ្វើចលានា។

រូបភាពទី ១៦៤: ក្រពះគោជាធម្មតាកន្ត្រាក់ ១ទៅ ៣ដងក្នុងមួយនាទី



គោនឹងងាប់ ប្រសិនបើគ្មានការជួយធ្វើឱ្យពោះធំ (ក្រពះ) ដំណើរការឡើងវិញនោះទេ។

មូលហេតុ :

ជាធម្មតាពោះធំធ្វើការកន្ត្រាក់រៀងរាល់នាទីដើម្បីលាយច្របល់ចំណី។ នៅពេលគោមានបញ្ហាគ្រុនក្តៅខ្លាំង ពោធំនឹងឈប់កន្ត្រាក់ ពេលនោះភាពអាស៊ីតរបស់ពោះធំថយចុះ ហើយសត្វមិនស៊ីចំណី កត្តានេះបណ្តាលឱ្យអតិសុខុមប្រាណនៅក្នុងពោះធំងាប់ទាំងអស់។

រូបភាពទី ១៦៥: នៅក្នុងពោះធំមានចំណី និង អតិសុខុមប្រាណរាប់រយកោដិ



ប្រសិនបើគ្មានស៊ីតុណ្ហភាព ប៉េហាស (ផះ) សារធាតុចិញ្ចឹម និងលក្ខខណ្ឌចាំបាច់ផ្សេងៗ សមស្រប នោះទេ ពួកអតិសុខុមប្រាណនៅក្នុងពោធំ មិនអាចរស់នៅ និងធ្វើការលូតលាស់បានឡើយ។

ការព្យាបាល

ទឹកខ្មេះ ១ លីត្រ លាយជាមួយស្ករមួយពែង និង មេដំបែមួយពែងរួចលាយជាមួយទឹកកន្លះលីត្រ។

ការការពារ

- ត្រូវព្យាបាលសត្វឈឺឱ្យបានឆាប់កុំទុកឱ្យការមិនស៊ីចំណីពន្យារយៈពេលយូរ។
- ប្រសិនបើសត្វមិនស៊ីចំណីរយៈពេល ២៤ ម៉ោង គេត្រូវផ្តោតការយកចិត្តទុកដាក់លើពោះធំ (ក្រពះ)។
- នៅពេលគោឈឺ គេចាំបាច់ត្រូវផ្តល់ទឹកឱ្យបានគ្រប់គ្រាន់។

## ២. ការហូរទឹកមាត់

ការផលិតទឹកមាត់អាចលើស៤០លីត្រក្នុងមួយថ្ងៃ ទឹកមាត់នឹងហូរចេញមកក្រៅបើសិនមានដំបៅនៅក្នុងមាត់ដែល ធ្វើឱ្យឈឺចាប់ពេលលេបទឹកមាត់ចូល ឬបើមានឧបសគ្គនៅត្រង់បំពង់កពេលលេបចូលទៅទៅក្រពះ។

**ឈ្លក់ ឬស្ទះ** (Choking):

ស្ទះចំណី (ស្នូលពោត) នៅក្នុងបំពង់អាហារបណ្តាលឱ្យ :

- ចេញទឹកមាត់ច្រើន
- ហើមពោះ



*រូបភាពទី ១៦៦: ស្នូលពោតអាចធ្វើឱ្យគោស្ទះនៅបំពង់អាហារ*

**ចាំបាច់ត្រូវយកដុំស្ទះចេញដោយៈ**

- នៅពេលស្ទាបដឹងថាមានដុំស្ទះនៅបំពង់អាហារ គេត្រូវទាញយកមកតាមមាត់វិញ
- បញ្ចូកប្រេងឆាពី ២០ទៅ៥០ ម.ល
- យកបំពង់ជ័រទន់ស៊កតាមបំពង់អាហារ ដើម្បីរុញដុំចំណីដែលស្ទះ (ត្រូវប្រុងប្រយ័ត្នព្រោះវាអាចធ្វើឱ្យដាច់ធ្លុះបំពង់អាហារ) ។

សកម្មភាពទំពារ ហូរទឹកមាត់ ច្រើន គឺជាសញ្ញានៃ :

- វត្តមានវត្ថុផ្សេងៗ (បន្លា ដែកគោល ដុំចំណី) នៅ ក្នុងមាត់ ឬចន្លោះធ្មេញ
- បញ្ហាធ្មេញ និងបូស

ការព្យាបាល :

- បើកមាត់សត្វពិនិត្យរកមើលមូលហេតុដែលបង្កបញ្ហា
- ទាញយកវត្ថុដែលមុតចេញ ។
- ក្នុងករណីមានបូស ត្រូវចាក់អង់ទីប៊ីយូទិក ដូចជា អាម៉ុកស៊ីលីន ឬ ស្ត្រិភាមីស៊ីន (ស៊ូនណ្ឌើវីល) ។

**ដំបៅមាត់ :**

ដំបៅមាននៅមាត់ ឬអណ្តាត ឬបបូរមាត់ធ្វើឱ្យសត្វឈឺចាប់ពេលលេបចូល សត្វបញ្ចេញទឹកមាត់មកក្រៅជាជាង លេបចូល ។ នៅប្រទេសយើង មូលហេតុសំខាន់គឺបណ្តាលមកពីជំងឺអុតក្តាម ។

**មូលហេតុ**

ជំងឺនេះបង្កដោយវីរុស ដូចនេះអង់ទិប៊ីយ៉ូទិកមិនអាចព្យាបាលបានទេ ។ វីរុសមានភាពធន់ខ្លាំង ហើយនៅលើពិភពលោកវីរុសនេះមាន៧ប្រភេទ តែនៅប្រទេសកម្ពុជាយើងគោកឃើញមានវីរុស ៣ ប្រភេទ គឺប្រភេទ O , A និង Asia 1 ។

*រូបភាពទី ១៦៨: គេមានការលំបាកក្នុងការទប់ស្កាត់ការឆ្លងរាលដាលជំងឺនេះណាស់ ពីព្រោះវាបង្កដោយវីរុសដែលមានភាពធន់ខ្លាំង និងអាចឆ្លងតាមខ្យល់*



ការចម្លង៖ វីរុសអាចសាយភាយតាមរយៈខ្យល់ដកដង្ហើម ( តំណក់ចេញមកក្រៅតាមការដកដង្ហើម)៖

- ការប៉ះពាល់ដោយផ្ទាល់ជាមួយសត្វដែលឈឺ ។
- ការប៉ះពាល់មិនផ្ទាល់ តាមរយៈស្បែកជើង ដៃ ឬសំលៀកបំពាក់របស់កសិករ ឬភ្នាក់ងារសុខភាពសត្វភូមិពេលប៉ះពាល់សត្វឈឺ ។

**រោគសញ្ញា៖**

- គ្រុនក្តៅ និងមិនស៊ីចំណី
- ហៀរទឹកមាត់ច្រើន
- មានពងដោរនៅ អណ្តាត ចុងច្រមុះ និងបបូរមាត់ ។
- ពងដោរមាននៅលើគល់ក្រចក ចង្កេះជើង ដោះ និង ចង្កេះជើង ។
- កូនគោអាចងាប់ដោយសារការខូតខាតសាច់ដុំបេះដូង ។



រូបភាពទី ១៦៩: ដំបៅអញ្ចាញ



រូបភាពទី ១៧០: ដំបៅអណ្ដាត



រូបភាពទី ១៧១: ដំបៅដោះ



រូបភាពទី ១៧២: ដំបៅគល់ក្រចក

ការព្យាបាល:

- ជំងឺអុតក្ដាមបង្កឡើងដោយវីរុស ដូចនេះគ្មានថ្នាំដែលមានប្រសិទ្ធភាព ។
- ការចាក់វ៉ាក់សាំងដល់សត្វឈឺគឺមិនមានប្រសិទ្ធភាពឡើយ ។

គោលបំណងនៃការព្យាបាលគឺដើម្បីការពារជំងឺឱកាសនិយមផ្សេងៗ ។ គេត្រូវព្យាបាលដូចខាងក្រោម:

- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ឬ អុកស៊ីតេត្រាស៊ីគ្លីន (OTC) រយៈពេលពី ៥ទៅ៧ ថ្ងៃ
- លាងដំបៅជាមួយនឹងទឹកម្ជូរ ឬសាប៊ូ
- បាញ់ថ្នាំសម្លាប់មេរោគជាមួយថ្នាំពណ៌ខៀវដែលមានអុកស៊ីតេត្រាស៊ីគ្លីន (Violet de gentiane + OTC) សត្វឈឺមិនអាចដើរ មិនអាចស៊ី និងផឹកទឹកបានឡើយ ដូចនេះត្រូវ:
  - ផ្ដល់ស្មៅ និងកន្ទក់
  - ត្រូវចងវាទុកនៅក្រោមម្លប់ដើម្បីការពារភាពបាត់បង់ជាតិទឹក

វិធានការការពារជំងឺអុតក្ដាម

- ការចាក់វ៉ាក់សាំងមានប្រសិទ្ធភាព
- ត្រូវប្រើវ៉ាក់សាំងដែលមានវីរុស ៣ ប្រភេទ (O +A + Asia1)

- ចាក់លើកទី ១ នៅពេលគោមានអាយុ ៤ ខែ លើកទី ២ ធ្វើនៅ ១ ខែ ក្រោយចាក់លើក ទី១ និង ចាក់រំលឹករៀងរាល់ ៦ ខែ ឬ ចាក់វ៉ាក់សាំងឡើងវិញ នៅពេលមានជំងឺផ្ទុះនៅភូមិជិតខាង។
- នៅពេលមានផ្ទុះជំងឺអុតក្តាមនៅភូមិជិតខាងយើងត្រូវចាក់វ៉ាក់សាំងភ្លាម ប្រព័ន្ធភាពស៊ាំកើតឡើងលឿន ដែលអាចការពារសត្វបាន។ យុទ្ធនាការចាក់វ៉ាក់សាំងគួររៀបចំនៅថ្នាក់ភូមិដើម្បីទប់ស្កាត់ការ ការសាយភាយរបស់ជំងឺ។

*រូបភាពទី ១៧៣: សត្វបន្តកន្ទុយគ្នាដើម្បីចាក់វ៉ាក់សាំងអុតក្តាម*



- វិធានការជីវសុវត្ថិភាពពមិនអាចធ្វើបានទេ ព្រោះវីរុសឆ្លងរាលដាលលឿនណាស់ យើងត្រូវរក្សាសត្វនៅ ក្រោមផ្ទះ និងជៀសវាងការប៉ះផ្ទាល់ជាមួយសត្វដទៃទៀត។

## ៣. ជំងឺរាក

ការរាកគឺជាការបញ្ចេញលាមកដែលមានទឹក ច្រើនដងក្នុង១ថ្ងៃ លាមមកមានសភាពជ្រាយ មិនជាប់គ្នា និងមានក្លិនមិនល្អ។ លាមកមានពណ៌ផ្សេងៗគ្នា ពីពណ៌បៃតងចាស់ រហូតដល់ក្រហមក្រម៉ៅ ដោយសារមានលាយឈាមនៅក្នុងលាមក។ ជួនកាលគេមិនអាចឃើញលាមករាកផ្ទាល់ទេ តែគេ អាចឃើញមានស្នាមប្រលាក់លាមករាកនៅជាប់គូទ ឬកន្ទុយ។

*រូបភាពទី ១៧៤: សត្វរាក*



**រាកដោយគ្មានរោគសញ្ញាផ្សេងទៀត**

បង្កឡើងដោយចំណីដូចជា :

- ការប្តូរចំណីលឿនពេក
- ការស៊ីស្មៅខ្ចីច្រើនពេក ជាពិសេសពេលដើមរដូវភ្លៀង
- ចំណីសល់យូរមានសភាពជូរផ្អូម ឬដុះផ្សិត (ពោត កន្ទក់)



រូបភាពទី ១៧៥: លាមករាក

ការការពារ

- ផ្តល់នូវស្មៅថ្មីឱ្យសត្វស៊ីបន្តិចម្តងៗ
- យកចំណីដែលប្រឡាក់លាមកឬផ្ទួមជូរចេញ

រាកស្គមរីងរៃ :

ជាទូទៅបង្កដោយពពួកព្រូន ។

ព្រូនក្នុងពោះវៀន ឆ្លងចូលពេលសត្វលេបកូនដង្កូវនៅពេលស៊ីស្មៅ ។

រោគសញ្ញា :

- លាមករាកបាញ់ពណ៌បៃតង
- ស្រកទំងន់
- មិនសូវស៊ីចំណី តែមិនគ្រុនក្តៅ
- រោមបះ



រូបភាពទី ១៧៦: សត្វប្រឹងរាក

ព្យាបាល :

- ប្រើថ្នាំដូចជាឡីវ៉ាមីសូល (Levamisole) ឬអាល់បង់ដាសូល (Albendazole)ជាដើម ។
- ចាក់អ៊ីវែមិចទិន ១ % (Ivermectine 1%) កំរិតប្រើ ១ សេសេ សំរាប់គោ ៥0 គីឡូក្រាម ចាក់ក្រោមស្បែក ។

រាកស្គមរ៉ាំរៃលើកូនគោ :

ជារឿយបង្កឡើងដោយកុកស៊ីដ្យូស៊ីស ។

រោគសញ្ញាៈ

- លាមករាក
- មិនសូវស៊ីចំណី និងស្រកទំងន់ ហើយជាទូទៅស្គម
- កន្ទុយ និងជើងក្រោយប្រលាក់លាមកពណ៌ខ្មៅស្អិតជាប់គូទ
- ក្នុងករណីធ្ងន់ធ្ងរលាមកមានលាយឈាម និងសំបោរ
- ពេលជុះកូនគោខំប្រឹងខ្លាំង

ការព្យាបាលៈ

- ស៊ុលហ្វា ៣៣ (Sulfa 33)



*រូបភាពទី ១៧៧: លាមករាកជាប់នឹងគូទ*

ភាគស្គមរាំរៃ និងស្លេកស្លាំងៈ

មូលហេតុចម្បងគឺដង្កូវថ្លើម។

រោគសញ្ញាៈ នៅពេលព្លូនចូលទៅដល់បំពង់ទឹកប្រមាត់ វាធ្វើឱ្យស្ទះបំពង់ទឹកប្រមាត់ និងខូចថ្លើម។

រោគសញ្ញាមានៈ

- រាករាំរៃ
- ស្រកទំងន់ និងស្គមកំព្រឹង
- ស្លេកស្លាំង
- ហើមថ្គាម



*រូបភាពទី ១៧៨: លាមករាកខ្មៅមានលាយសំបោរ*

ការព្យាបាលៈ

ប្រើថ្នាំ ដូវេនិច (Dovenix) ឬអាល់បង់ដាសូល (Albendazole)។

ភាគលើកូនគោកំពុងបៅដោះ

ជារឿយៗវាបង្កឡើងដោយបាក់តេរីអ៊ីកូលី (E. Coli) កូនគោឆ្លងបាក់តេរីតាមទងផ្ចិត ឬ នៅពេលវាបៅ។

រោគសញ្ញា:

- លាមករាកមានពណ៌ស-លឿង



រូបភាពទី ១៧៩: រាកពណ៌លឿង

- កូនគោចាប់ផ្ដើមចុះខ្សោយខ្លាំង និងលែងបៅ
- មេរោគបង្កជំងឺនៅទងផ្ចិត និងសន្លាក់ និងអាចឆ្លងចូលក្នុងឈាម

ការព្យាបាល:

- ប្រើអង់ទីប៊ីយូទិកដូចជា កូលីស្ទីន (Colistin) ឬ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) ឬអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin)
- កុំឱ្យកូនបៅ
- ឱ្យផឹកទឹកដែលមាន ស្ករ ៦ ស្លាបព្រាកាហ្វេ និង អំបិលកន្លះ ស្លាបព្រាកាហ្វេ លាយជាមួយទឹកស្អាតក្ដៅ ឧណ្ហ ១ លីត្រ ។

ការការពារ:

- ត្រូវឱ្យកូនគោបៅទឹកដោះដំបូងឱ្យបានគ្រប់គ្រាន់ ជាពិសេសចន្លោះពីកើតរហូតដល់ ៦ ម៉ោង ។

រាក និងមានរោគសញ្ញាធ្ងន់ធ្ងរផ្សេងទៀត

នៅពេលមានរោគសញ្ញាធ្ងន់ធ្ងរផ្សេងទៀតកើតមានជាមួយរាកយើងគួរសង្ស័យលើរាកបង្កដោយសាល់ម៉ូណេឡា ។



រូបភាពទី ១៨០: ត្រូវឱ្យកូនគោបៅទឹកដោះដំបូង

រោគសញ្ញា:

- គ្រុនក្ដៅ ( កំដៅពី ៤០ -៤១ អង្សាសេ)
- សត្វខ្សោយខ្លាំង និងមិនស៊ីចំណី
- រាកធ្ងន់ធ្ងរ និងមានក្លិនស្អុយអាសោច រាវ និងមានលាយឈាម ឬសំបោរ



*រូបភាពទី ១៨១: រាកមានលាយឈាម និងក្លិនស្អុយ*

- ចំពោះកូនគោរោគសញ្ញាមានភាពធ្ងន់ធ្ងរ ហើយអាចងាប់នៅចន្លោះពេលពី ២ទៅ៣ ថ្ងៃ

ការព្យាបាលៈ

- មានការលំបាកខ្លាំងព្រោះបាក់តេរីសាល់ម៉ូណេឡាមានភាពធន់ នឹងអង់ទីប៊ីយ៉ូទិកផ្សេងៗ (កុំប្រើថ្នាំអុកស៊ិតេត្រាស៊ីគ្លីន) ។
- ត្រូវប្រើថ្នាំ ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) ឬ អង់រ៉ូហ្លុកសាក់ស៊ីនឈ (Enrofloxacin) ។
- ប្រើយ៉ាងតិច ៦ ថ្ងៃ។

## ៤. ហើមពោះ

បញ្ហាហើមពោះគឺជាការប៉ោងនៅផ្នែកពោះ ហើយគេអាចសំគាល់ឃើញមានការហើមនៅពោះខាងឆ្វេង ។ គោមិនអាចភើ បញ្ចេញខ្យល់ដែលមាននៅក្នុងពោះធំ ។

រោគសញ្ញាៈ

- បើគោះពោះគោ នោះគេដឹងថាវាមានឧស្ម័ននៅខាងក្នុង
- គោលែងទំពាអៀង
- ពោះធំរីកសង្កត់ទៅលើសន្ទះទ្រូង ជាហេតុធ្វើឱ្យគោពិបាកដកដង្ហើម
- កំដៅខ្លួនមានសភាពធម្មតា

ការស្ទះវត្ថុផ្សេងៗ

- វត្ថុផ្សេងៗតែងតែបង្កឱ្យមានការស្ទះនៅបំពង់អាហារ ដូចជាស្នូលពោត និង ផ្លែឈើ ជាដើម
- បសុពេទ្យត្រូវធ្វើការស្ទាបនៅដើមក និងបំពង់អាហារ

ការព្យាបាលៈ

- ពេទ្យសត្វត្រូវព្យាយាមលូកយកដុំ ឬចំណីដែលស្ទះចេញ

- ករណីហើមធ្ងន់ធ្ង ត្រូវប្រើត្រូការ (Trocar) ចាក់ទំលុះ ពោះធំ ដើម្បីបន្ទូរខ្យល់
- ត្រូវចាក់អង់ទីប៊ីយូទិក ដើម្បីការពារកុំឱ្យរលាកភ្នាសស្តើងពោះ



រូបភាពទី ១៨២: ទីកន្លែងដែលត្រូវចាក់ត្រូការ



រូបភាពទី ១៨៣: ការចាក់ត្រូការ

## ស្មៅខ្ចីសើម



- បញ្ហាហើមពោះនេះអាចកើតមានឡើងភ្លាមៗ ជាពិសេសពេលសត្វស៊ីនៅលើវាលស្មៅសើម នាពេលព្រលឹម ។
- សត្វស៊ីស្មៅខ្ចីច្រើនពេកនាដើមរដូវភ្លៀង

រូបភាពទី ១៨៤: ទុកបំពង់ត្រូការដើម្បីឱ្យឱ្យឧស្ម័នចេញ

- អាចបណ្តាលឱ្យសត្វងាប់ភ្លាមៗ

រូបភាពទី ១៨៥: ដើមរដូវវស្សា គោឃ្លានខ្លាំង និងប្រឹងស៊ីស្មៅខ្ចី



ការការពារ :

- កុំឱ្យសត្វដែលឃ្លានចំណីខ្លាំង ស៊ីតាមចំណង់នៅវាលស្មៅខ្ចី

ការព្យាបាល :

- បញ្ចូកប្រេងឆាពី ៣០០ ទៅ ៥០០ ម.ល

## ពុលអ៊ុយរ៉េ

- ការហើមពោះកើតឡើងដោយសារគោវាលិតនូវអ៊ុយរ៉េដែលមានសល់ក្នុងបាវ

- កសិករខ្លះប្រើវិធីសាស្ត្រស្រោចទឹកអ៊ុយរ៉េលើចំបើងផ្ទាល់ដើម្បីកែលំអចំណី ។ វិធីសាស្ត្រនេះគួរធ្វើដោយប្រុងប្រយ័ត្ន ។

រូបភាពទី ១៨៦: ការប្រើចំបើងផ្អាប់ជាមួយអ៊ុយរ៉េ មិនមានគ្រោះថ្នាក់ទេ ពីព្រោះ អ៊ុយរ៉េបានបំលែង ទៅជាអាម៉ូញាក់ បន្ទាប់ពី ផ្អាប់ ២ ទៅ ៣ សប្តាហ៍



រោគសញ្ញា :

- ហើមពោះខ្លាំង
- ញាក់ញ័រសាច់ដុំ ដែលនាំឱ្យសត្វមិនអាចបញ្ឈរខ្លួនបាន
- អាចងាប់ក្នុងអំឡុង ២ ម៉ោង

ការព្យាបាល :

- ប្រើទឹកខ្មេះ ២ ទៅ៥ លីត្រ លាយជាមួយទឹក

## ៥. ការក្ទៀន

ការក្ទៀនគឺមានន័យថាសត្វមិនអាចជុះ ឬជុះអាចមិដុំចេញមកក្រៅបានដោយលំបាក ។

រូបភាពទី ១៨៧: លាមកក្ទៀន



- ក្ទៀនគឺច្រើនតែជារោគសញ្ញាមួយក្នុងចំណោមរោគសញ្ញាផ្សេងៗនៃជំងឺ ។ វាកើតឡើងទូទៅជាមួយគ្រុន ក្តៅ ព្រោះសត្វបាត់បង់ការស៊ីចំណី និងការបញ្ចេញលាមកឃើត ។
- ក្ទៀនរ៉ាំរ៉ៃជាទូទៅកើតមានដោយជំងឺអាណាប្លាស្មា (Anaplasma)
- ការពុលសំណរ៉ាំរ៉ៃអាចធ្វើឱ្យមានបញ្ហាក្ទៀនធ្ងន់ធ្ងរដែរ

ការព្យាបាល :

- ត្រូវឱ្យគោផឹកទឹកឱ្យបានគ្រប់គ្រាន់
- ត្រូវព្យាបាលជំងឺដែលបណ្តាលឱ្យក្តៅខ្លួន ដើម្បីចាប់ផ្តើមឱ្យសត្វស៊ីចំណីឡើងវិញ ។

## ៦. ការខូចថ្លើម

ថ្លើមមានតួនាទីសំខាន់ធ្វើឱ្យសត្វមានសុខភាពល្អ និងចាំបាច់ជួយក្នុងការរំលាយអាហារ ។

ថ្លើមអាចត្រូវបំផ្លាញដោយ:

- ដង្កូវថ្លើម



*រូបភាពទី ១៨៨: ថ្លើមខូចដោយសារដង្កូវថ្លើម*

- ការពុល ដោយសារប្រើអ៊ីវ៉ែមិចទិន (Ivermectin) លើសកំរិត
- ជំងឺបង្កដោយបរាសិតក្នុងឈាមដូចជា ទ្រីប៉ាណូសូម៉ា (Trypanosoma) និងបាបេស្យា (Babesia)
- ជំងឺឆ្លងរ៉ាំរ៉ៃដូចជា លាសដោះ និងរលាកស្បូនជាដើម

រោគសញ្ញាលើការរំលាយអាហារដែលបង្កដោយដង្កូវថ្លើមមាន:

- មិនស៊ីចំណី
- ខាន់ល្មឿង
- ជួនកាលក្តៅខ្លួន-ជួនកាលរាក

### ការងាយទទួលរងដោយពន្លឺព្រះអាទិត្យ

បញ្ហានេះគេតែងតែជួបប្រទះនៅប្រទេសកម្ពុជា វាបង្កឡើងដោយសារថ្លើមមិនអាចបំបែកក្លរ៉ូហ្វីល ដែលមាននៅក្នុងរុក្ខជាតិ ជាហេតុធ្វើឱ្យកើនឡើងនូវសារធាតុគីមី ដែលធ្វើឱ្យសត្វងាយទទួលរងប៉ះពាល់ដោយពន្លឺថ្ងៃព្រះអាទិត្យ ។

រោគសញ្ញា:

នៅពេលគោក្របី ត្រូវពន្លឺព្រះអាទិត្យធ្វើឱ្យលេចចេញនូវរោគសញ្ញាដូចជា :

- ដំបៅស្បែក
- ស្នាមបែកប្រេះ និងហូរឈាម



*រូបភាពទី ១៨៩: ដំបៅនៅលើស្បែក*

ការព្យាបាល:

- ចងគោទុកនៅក្រោមម្លប់
- ទប់ស្កាត់សត្វល្អិត ដែលបង្កឱ្យរមាស់ ឬរលាកស្បែក
- ដើម្បីការពារកុំឱ្យដំបៅរីក ត្រូវចាក់អង់ទីប៊ីយ៉ូទិក ដូចជា អាម៉ុកស៊ីលីន ឬអុកស៊ីតេត្រាស៊ីគ្លីន (Amoxillin or OTC)
- ព្យាបាលបញ្ហាថ្លើម

គោលការណ៍នៃការព្យាបាលថ្លើម:

- ប្រើថ្នាំដែលមានសកម្មភាពជួយជំរុញការបញ្ចេញទឹកប្រមាត់ ដូចជា អេប៉ាតុល Hepatol (Coophavet)
- វីតាមីនបេកំប្លេ (B-complex) ជួយគាំទ្រដល់មុខងាររបស់ថ្លើម
- ឱសថដែលមានសមាសធាតុ ឌីអិល-មេត្យូនីន អ៊ីណូស៊ីតុល និង វីតាមីនអ៊ី (DL.Methionine + Inositol + Vit E)
- ផ្ដល់ចំណីឱ្យបានត្រឹមត្រូវ ដើម្បីឱ្យពោះធំដំណើរការសមស្រប ដោយផ្ដល់នូវថាមពល និង ប្រូតេអ៊ីន គ្រប់គ្រាន់
- សត្វមានជំងឺថ្លើមត្រូវការចំណាយពេលយូរក្នុងការព្យាបាលឱ្យជាសះស្បើយ

## ជ. បញ្ហា និងជំងឺលើការបន្តពូជ

ចំណូលរបស់កសិករវាផ្សាភ្ជាប់ទៅនឹងការលក់សត្វក្មេងៗ។ ជីវភាពឬប្រាក់ចំណូលរបស់កសិករនឹងថយចុះ ប្រសិនកូនគោមានសុខភាពមិនល្អ និង ចន្លោះពេលពីកើតកូនមួយ ទៅកូនមួយទៀតមានរយៈពេលយូរ។ យើងគួរចងចាំថាបញ្ហាការបន្តពូជវាទាក់ទងជាសំខាន់ទៅនឹងគុណភាពរបស់ចំណី។

## ១. បញ្ហាមិនរកឈ្មោល

ការមិនរកឈ្មោលមានន័យថាមេគោ (មិនផើម) មិនត្រូវការបា។ ការមិនរកឈ្មោលនៅដំណាក់កាលដំបូងនៃការ បំបៅដោះជាការធម្មតា។

### មូលហេតុ

ភាពមិនប្រក្រតីមួយចំនួនធ្វើឱ្យសត្វមិនរកឈ្មោលយូរ ក្នុងករណីនេះយើងអាចនិយាយបានថា **សត្វអា** (មិនមានការបង្កកំណើត) ដូចជា:

- បញ្ហារលាកស្បូន
- បញ្ហាមានគីសនៅលើអូវែ

ប៉ុន្តែ នៅកម្ពុជាយើង ៩០ % នៃការក្ររកឈ្មោលក្នុងរយៈពេលយូរ បណ្ដាលមកពីស្ថានភាពដងខ្លួនមិនល្អ (ស្គមស្គាំង)។



*រូបភាពទី ១៩០: គោនេះត្រូវសង្គ្រោះជាមុនសិន វាមិនអាចបង្កើតកូនបានទេ*

### ការព្យាបាល:

- បើមេគោមានសភាពធម្មតា យើងត្រូវព្យាបាលគីសនៃអង្គលឿង (Luteal Cysts) ដោយចាក់ប្រូស្តាគ្លង់ឌីន ដូចជាលុយតាលីស (Lutalyse) ៥ ម.ល ដើម្បីជំរុញការរកឈ្មោល ពី ៣ ទៅ ៥ ថ្ងៃ ក្រោយ។
- បើមានការចម្លងជំងឺ សូមអានជំពូកស្ដីពីការហូរខ្ទុះតាមទ្វារបន្តពូជ
- ក្រផ្ដាច់ដោះកូនគោ (លើសពី ៦ខែ) កើតមានច្រើននៅកម្ពុជា ហើយវាបណ្ដាលឱ្យគោស្គមខ្លាំង ព្រោះគោបានប្រើចំណីបម្រុងក្នុងរាង្គកាយដើម្បីផលិតទឹកដោះ។



*រូបភាពទី ១៩១: កូនគោមានអាយុច្រើនហើយមិនគួរឱ្យវាបៅទៀតទេ*

- ខ្វះសារធាតុចិញ្ចឹមគ្រប់មុខៈ ក្នុងករណីនេះ ជាដំបូងយើងត្រូវផ្តល់ចំណីឱ្យបានគ្រប់គ្រាន់
  - ✓ ផ្តល់ចំបើងផ្អាប់ជាមួយអ៊ុយរ៉េ ដើម្បីជួយង្កើនប្រូតេអ៊ីន
  - ✓ ផ្តល់បន្ថែមនូវស្លឹកដំឡូងមីស្ងួតរួមជាមួយស្មៅដែលមាន គុណភាពល្អ ( ស្តេចស្មៅ នេពៀ ជាដើម)
  - ✓ ផ្តល់បន្ថែមនូវចំណីសំរេចផ្សំដោយខ្លួនឯង ឬពីទីផ្សារ
  - ✓ ចាក់វីតាមីនចំរុះ ADE ជាប្រចាំ

## ២. ការរកឈ្មោលឡើងវិញ

មេគោរកឈ្មោលធម្មតានៅ ( រៀងរាល់ ៣អាទិត្យ) តែបង្កាត់រួចមិនជាប់ ឬមិនផើម ។

**មូលហេតុសំខាន់ៗ:**

- រលាកស្បូនៈ គឺជាការឆ្លងរោគមិនជាក់លាក់មួយ បង្កឡើងដោយការជ្រាតចូលរបស់បាក់តេរី ទៅក្នុងស្បូន ក្រោយពេលកើតកូនភ្លាម ដែលបណ្តាលឱ្យអំប្រីយ៉ុងបង្កកំណើតមិនអាចលូតលាស់បានល្អក្នុងស្បូនបាន ។



*រូបភាពទី ១៩២: មេគោទើបកូនហើយត្រូវចងនៅកន្លែងស្អាតជៀសវាងការជ្រាតចូលរបស់មេរោគ*

- គោបានមិនអាចបន្តពូជបាន ឬ អា

**ការព្យាបាលៈ**

- **រលាកស្បូន** (Endometritis) :
  - ✓ ចាក់ប្រូស្តាគ្លង់ឌីន ដូចជាលុយតាលីស (Lutalyse) ៥ ម.ល ដោយចាក់ ២ ដង ហើយការចាក់លើកទី ២ ធ្វើនៅ ១១-១៤ ថ្ងៃក្រោយលើកទី ១
  - ✓ ចាក់អង់ទីប៊ីយូទិក ដូចជា តេត្រាស៊ីគ្លីន (Tetracycline) ឬទីឡូស៊ីន (Tylosin) ៥ ថ្ងៃជាប់គ្នា
- **បាមានបញ្ហាៈ** នៅពេលម្ចាស់សត្វប្រឈមមុខនឹងបញ្ហាដាក់មិនជាប់នេះជាញឹកញាប់ ហើយអាចកំណត់ថា គោបានេះអា និងមិនត្រូវប្រើបានេះទៀតឡើយ ។



*រូបភាពទី ១៩៣: ទោះបីគោបានេះមើលទៅល្អ ក៏អាចធ្វើឱ្យមេគោរកឈ្មោលឡើងវិញបានដែរ ប្រសិនបើទឹកកាមរបស់វាមិនអាចបង្កកំណើត បន្ទាប់ពីមានជំងឺពី ២ទៅ ៣ អាទិត្យ*

## ៣. ការហូរខ្ទុះតាមប្រដាប់បន្តពូជ

វាជាការហូរចេញមក ក្រៅតាមយោនីនូវខ្ទុះ ឬសំបោរ។ ការហូរទឹកពណ៌សថ្លា នៅពេលរកឈ្មោលឬ បន្ទាប់ពីកើតកូនរួច ជាលក្ខណៈធម្មតារបស់មេគោ។



*រូបភាពទី ១៩៤: ហូរទឹកថ្លាចេញតាមយោនីពេលរកឈ្មោល និងបន្ទាប់កើតកូនជាការធម្មតា*

ប៉ុន្តែពេលខ្លះយើងអាចសង្កេតឃើញខ្ទុះហូរចេញមកក្រៅ ដែលជាទូទៅគឺបណ្តាលមកពីការជ្រាតចូលរបស់មេរោគ ទៅក្នុងស្បូន ហើយបង្កជាជំងឺរលាកស្បូនៈ

- ស្បូនល្អធម្មតា គឺស្អាត និងគ្មានមេរោគ
- ក្រោយពេលកើត ស្បូនឆ្លងមេរោគជាច្រើនចូលតាមផ្លូវបន្តពូជ ប៉ុន្តែជាធម្មតា ពី២ ទៅ៣ ថ្ងៃក្រោយ ស្បូនអាចកំចាត់មេរោគ និងធ្វើការការពារការឆ្លងរោគផ្សេងៗ។
- ប៉ុន្តែពេលខ្លះ ការឆ្លងនៅតែមាន ហើយបាក់តេរីធ្វើការលូតលាស់ ព្រោះស្បូនមិនអាចសម្លាប់បាក់តេរីបាន ដោយសារបញ្ហាផ្សេងៗដូចជា សុកមិនធ្លាក់ អ័រម៉ូនដំណើរការខុសប្រក្រតី ជាដើម។ មូលហេតុនេះ បណ្តាលឱ្យមានខ្ទុះហូរចេញមកក្រៅតាមយោនី។



រូបភាពទី ១៩៥: ការបន្តហូរខ្ទុះតាមយោនី ដោយសាររមេរោគជ្រាតចូល

ការព្យាបាលៈ

- ចាក់ប្រូស្តាគ្លង់ឌីន ដូចជាលុយតា លីស (Lutalyse) ៥ សេសេ ដោយចាក់ ២ ដង ហើយការចាក់លើកទី ២ ធ្វើនៅ ១១-១៤ ថ្ងៃ ក្រោយលើកទី ១
- ចាក់អង់ទីប៊ីយូទិក ដូចជា តេត្រាស៊ីគ្លីន ១ទតេរាចយចលិនចេ ឬទីឡូស៊ីន (Tylosin) ៥ ថ្ងៃជាប់គ្នា
- មិនគួរលាងស្បូនជាមួយសូលុយស្យុងអ៊ីយ៉ូឌីន ឬពែម៉ងកាណាត ព្រោះវាធ្វើឱ្យក្រហាយឬរលាក និងបរិមាណទឹកច្រើនធ្វើឱ្យស្បូនមិនរួញមករកភាពដើមវិញ ។

ការការពារៈ

សត្វប្រឈមមុខនឹងបញ្ហារលាកស្បូននេះ ជាពិសេសនៅពេលមានបញ្ហាមួយចំនួនក្នុងពេលកើតកូន ដូចជា ជួយទាញយកកូនចេញពេលកើតកូន សុកមិនធ្លាក់ និង លាសដោះបន្ទាប់ពីកើតកូន។ ដើម្បីជៀសវាងបញ្ហានេះ យើងត្រូវចាក់ ប្រូស្តាគ្លង់ឌីន (Prostaglandin) មួយដង ក្រោយពេលកើតកូនបាន ២៤ ម៉ោង ហើយត្រូវចាក់ ម្តងទៀត នៅ ២ សប្តាហ៍ក្រោយ ។

## ៤. ការរលូត

ការរលូតគឺមេគោបញ្ចេញកូនចេញមកក្រៅមុនដល់ពេលត្រូវកើត ។ កូនគោមិនអាចរស់បានទេ។

ការរលូតអាចកើតដោយគ្រោះថ្នាក់ផ្សេងៗដូចជា ជល់គ្នា ឬដួល ប៉ុន្តែជាធម្មតាការរលូតបណ្តាលមកពីជំងឺឆ្លង ។

ជំងឺបង្កដោយប្រ៊ុសេឡូស (Brucellosis)

ជំងឺនេះបង្ហាញរោគសញ្ញាតែមួយគត់គឺសត្វរលូត ។



រូបភាពទី ១៩៦: យកកូនដែលងាប់ចេញពីមេ

- សត្វឆ្លងជំងឺនេះដោយសារការលេបចូលនូវបាក់តេរី ដោយគេឃើញមានវត្តមាននៃបាក់តេរីលើសលុបនៅក្នុងកូនរលូត ភ្នាសស្ដើង ឬទឹករំអិលដែលខ្ទុះហូរចេញពីស្បូន។
- ពេលបាក់តេរីចេញមកមជ្ឈដ្ឋានខាងក្រៅវាអាចធ្វើការ ចំលងទៅមនុស្ស ហើយបង្កជាបញ្ហាធ្ងន់ធ្ងរ ដែលគេឱ្យឈ្មោះថាគ្រុនក្ដៅញាកញ័រ។

ការធ្វើរោគវិនិច្ឆ័យត្រូវធ្វើដោយយកសំណាកឈាមមកវិភាគនូវ វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល។ ជំងឺនេះមិនកើតមានជាទូទៅនៅកម្ពុជាទេ។

*រូបភាពទី ១៩៧: ការប្រមូលសំណាកឈាមពីមេគោដែលរលូតមានសារៈសំខាន់ ដើម្បីស្វែងរកការឆ្លងរាលដាល ជំងឺប្រ៊ុសេឡូស៊ីសនៅក្នុងប្រទេសកម្ពុជា*



**ការព្យាបាលៈ** ប្រើអុកស៊ីតេត្រាស៊ីគ្លីន (OTC) ឬយកល្អចាក់ក្លរតេត្រាស៊ីគ្លីន (Chlortetracycline) រយៈពេល ២ សប្ដាហ៍។

**ជំងឺបង្កដោយឡិបតូស្ពីរ៉ូស** (Leptospirosis)

សត្វកកេរ (កណ្ដុរ) គឺជាអ្នកផ្ទុកមេរោគឡិបតូស្ពីរ៉ុស ហើយធ្វើការចម្លងមកសត្វតាមរយៈទឹកនោមរបស់វា។ គោក្របីអាចឆ្លងជំងឺនេះតាមរយៈការផឹកទឹកដែលមានមេរោគ។

*រូបភាពទី ១៩៨: គោផឹកទឹកដែលមានមេរោគ*



រោគសញ្ញា ៖

- រលូតកូន ជាពិសេសលើមេគោក្មេង
- កូនងាប់ក្នុងពោះ ឬកូនកើតមិនគ្រប់ខែ ឬកូនកើតមកខ្សោយ
- ចំពោះកូនគោ ៖ មានរោគសញ្ញាគ្រុនក្ដៅ មិនស៊ីចំណី ពិបាកដកដង្ហើម រោគលឿង នោមឈាម និង ស្លេកស្លាំង

*រូបភាពទី ១៩៩: យកកូនដែលងាប់ចេញពីមេ*

ការព្យាបាល :

- ប្រើតេត្រាស៊ីគ្លីន (Tetracycline)
- ប៉ង់ស្រ្ទីប ឬប៉េនី ឌីអេចអេស (PENI DHS)

**ជំងឺបង្កដោយសាល់ម៉ូនែឡូស** (Salmonellosis)

**រោគសញ្ញា:**

- រលូតកូន
- បន្ទាប់ពីរលូតសុកមានសភាពហើម និងមានពណ៌លឿង

*រូបភាពទី ១៩៩: កូនគោរលូតដោយសារសាល់ម៉ូនែឡូស*



- រោគសញ្ញាធម្មតាផ្សេងទៀតរួមមាន មេរោគក្នុងឈាម គ្រុនក្ដៅខ្លាំង និងរាកមួល

ការព្យាបាល:

- ប្រើទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa)
- ប្រើ អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ប្រសិនបើមានមេរោគក្នុងឈាម

## ៥. បញ្ហាលំបាកកើតកូន

នៅប្រទេសកម្ពុជា គេកំរឃើញកូនគោកើតមកធំពេកណាស់ តែពេលខ្លះគេត្រូវជួយបង្កើតព្រោះកូនអាចកើត មកស្ថិតនៅទីតាំងខុសប្រក្រតី។ ប៉ុន្តែគម្រោង ចិញ្ចឹមសត្វកម្ពុជាសហគន៍អឺរ៉ុបមានកម្មវិធីកែលំអពូជគោតាមរយៈការបង្កាត់សិប្បនិម្មិត ដោយនាំយកទឹកកាមគោបរទេសដែលមានមាឌធំ មកបង្កាត់ ជាមួយពូជគោក្នុងស្រុកដែល មានមាឌតូច ដូច្នេះកូនដែលកើតមកនឹងមានមាឌធំដែរ ដែលយើងចាំបាច់ត្រូវការជំនួយពេលកើតកូន។

*រូបភាពទី ២០០: កូនគោទើបនឹងកើតមានទម្ងន់លើស ២០គក្រ: កូនគោបង្កាត់សិប្បនិម្មិតដោយប្រើទឹកកាមពូជគោសាន់តាហ្គីទ្រូឌីស*



ជាធម្មតាគោកើតកូនរួចរាល់ចំណាយរយៈពេល ២ ម៉ោង ក្រោយពេលបែកទឹកភ្លោះ។ ប្រសិនបើរយៈពេលលើសពីនេះ យើងត្រូវតាមដាន និងកំណត់បញ្ហាឱ្យបានច្បាស់លាស់។

ដំណាក់កាលកើតកូនធម្មតា:



*រូបភាពទី ២០១: ថង់ទឹកភ្លោះចេញមកក្រៅ ហើយបែក*



*រូបភាពទី ២០២: ក្បាលចេញមកមុន*



*រូបភាពទី ២០៣: ការកន្ត្រាក់ចុងក្រោយ*



*រូបភាពទី ២០៤: មេគោលិតកូនភ្លាមៗបន្ទាប់ពីកើត*

បញ្ហាច្រើនជួបប្រទះ

កូនក្នុងស្បូនដែលមានទីតាំងធម្មតាគឺជើងមុខហុចទៅមុខ ទាំង ២ ហើយផ្ទៃកខាងស្តាំលើកឡើងរួមជាមួយចង្កា ផ្ដេក លើជើងមុខ។ តែជួនកាលកូនគោបង្វិលចូលមកផ្លូវបង្កើតក្នុងទីតាំងខុសប្រក្រតី ដូចជា:

- បញ្ច្រាស់ ឬគូទមកមុន (រូបភាពទី ២២១)
- ជើងមុខ ១ ឬ ២ បត់ (រូបភាពទី ២២២)
- ក្បាលបត់ទៅក្រោយ (រូបភាពទី ២២៣)



*រូបភាពទី ២០៥*



*រូបភាពទី ២០៦*



*រូបភាពទី ២០៧*

## ការតាមដានរកបញ្ហា

យើងត្រូវសំអាតដៃ (កាត់ ក្រចកដៃ) ហើយត្រូវលូកដៃថ្នមៗតាមរន្ធគូថ ដើម្បីឱ្យដឹងច្បាស់ពី :

- សភាពរបស់កូនគោ ងាប់ ឬរស់ ដោយចុចអណ្តាត កូនគោ ហើយប្រសិនបើនៅរស់ កូនគោនឹងប្រឹង ទាញអណ្តាតចូលវិញ
- សភាពក្បាល ឬគូទចេញមកមុន
- ទីតាំងរបស់ជើង

## ការជួយនៅពេលកើតកូន

- ទាញជើងដាក់ឱ្យត្រូវទីតាំង
- ប្រើខ្សែចងជើងមុខលើក្រចក
- ទាញខ្សែដើម្បីយកកូនចេញ



*រូបភាពទី ២០៨: ប្រើខ្សែដើម្បីទាញកូនគោចេញមកក្រៅ*

## ការជួយបន្ទាប់ពីកើតកូនលំបាក

- ជូតសំអាតទឹករំអិល នៅមាត់ និងបំពង់ក
- ជួយសំរួលឱ្យកូនគោដកដង្ហើម ដោយជូតវាឱ្យស្ងួត យកចំបើងចាក់ត្បាលក្នុងរន្ធច្រមុះ ឬដាក់វាផ្អៀងសំយ៉ុងក្បាលចុះក្រោម ហើយទះវាថ្នមៗ



*រូបភាពទី ២០៩: សំអាតកូនគោដែលទើបនឹងកើត*

- សំអាត និងសម្លាប់មេរោគនៅទងផ្ចិត ដោយប្រើទឹកអ៊ីយ៉ូឌីន
- ប្រសិនបើមេមិនព្រមលិត ត្រូវយកអំបិលមកជូតលើខ្លួនកូនវា

• ពិនិត្យមើលលើការបៅទឹកដោះដំបូង ។



រូបភាពទី ២១០: ឱ្យកូនគោបៅទឹកដោះដំបូង

## ៦. បញ្ហាសុកធ្លាក់មិនអស់

ប្រសិនបើសុកមិនធ្លាក់ក្នុងរយៈពេល ២៤ ម៉ោងក្រោយពេលកើត នោះនឹងអាចបណ្តាលឱ្យមានបញ្ហាដូចជា ស្បូនមិនរួញទៅរកសភាពដើម និងការឆ្លងមេរោគលើស្បូន។ ប្រសិនបើក្នុងរយៈពេល២៤ ម៉ោង ក្រោយពេលកើត យើងគួរទាញយកផ្នែកធំនៃសុកចេញ ដែលអាចធ្វើទៅបាន តែយើងមិនគួរលូកដៃ ទាញយកសុកខាងក្នុងទាំងអស់ ចេញនោះទេ។



រូបភាពទី ២១១: បាយកសុកចេញ បើវាមិនធ្លាក់បន្ទាប់ ពីកូនកើតបាន ២៤ម៉ោងហើយ

ការព្យាបាល :

• ចាក់អង់ទីប៊ីយ៉ូទិក តេត្រាស៊ីគ្លីន (Tetracycline)

• ចាក់ប្រូស្តាគ្លង់ឌីន ដូចជាលុយតាលីស (Lutalyse) ៥ ម.ល និង ត្រូវចាក់លើកទី ២ នៅ ១៥ ថ្ងៃ ក្រោយទៀត ។

## ៧. ស្បូនស្រុត

ស្បូនស្រុត គឺមានន័យថាស្បូនលៀនចេញមកក្រៅ ។

**វិធានការបន្ទាន់ត្រូវធ្វើ:**

• យកសុកនៅសល់ចេញ ហើយលាងសំអាតស្បូន



*រូបភាពទី ២១២: ស្បូនស្រុត*

- ពេលរុញស្បូនចូលខាងក្នុងត្រូវទីតាំងល្អហើយ ត្រូវចាក់ អុកស៊ីតុកស៊ីន ៤០ អុយអ៊ី (៤ ម.ល)
- ដេរទ្វារបន្តពូជដោយអំបោះមាំ ហើយទុករយៈពេល ៣ ថ្ងៃ



*រូបភាពទី ២១៣: ដេរទ្វារដើម្បីកុំឱ្យស្បូនចេញមកក្រៅទៀតបន្ទាប់ពីការរុញបញ្ចូល*

- ចាក់អង់ទីប៊ីយ៉ូទិក តេត្រាស៊ីគ្លីន (Tetracycline) រយៈពេល ៣ ថ្ងៃ

## ឈ. ជំងឺលាសដោះ

ជំងឺលាសដោះ គឺជាការឆ្លងជំងឺលើកន្សោមដោះ ដែលបង្កឡើងដោយបាក់តេរី ។

- មេរោគចូលតាមរយៈមុខរបួស ឬរន្ធដោះ



*រូបភាពទី ២១៤: កន្លែងដែលមេរោគជ្រាតចូលតាមមុខរបួស ឬរន្ធដោះ*

ក្នុងករណីកើតជំងឺលាសដោះធ្វើឱ្យ:

• ផលិតផលទឹកដោះថយចុះយ៉ាងខ្លាំង ។ ទឹកដោះមានគុណភាពអន់ និង មានមេរោគ ធ្វើឱ្យកូនគោរាកធ្ងន់ធ្ងរ

*រូបភាពទី ២១៥: ពេលកន្សោមដោះមិនផលិតទឹកដោះ កូនគោឃ្លាន និងចុះខ្សោយយ៉ាងលឿន*



**រោគសញ្ញា:**

បរិមាណទឹកដោះថយចុះ ធ្វើឱ្យកូនគោព្យាយាមបៅដោយសារឃ្លាន

*រូបភាពទី ២១៦: ចាំបាច់ត្រូវស្ទាបកន្សោមដោះដើម្បីដឹងថាមេគោកើតជំងឺលាសដោះឬអត់*



ទឹកដោះមិនល្អមានពណ៌ខុសពីធម្មតា (ពណ៌លឿង)

*រូបភាពទី ២១៧: ការប្រៀបធៀបរវាងទឹកដោះល្អ និងទឹកដោះខូចដោយបាក់តេរី អ៊ីកូលី*



មេគោព្យាយាមមិនឱ្យកូនបៅដោយសារកន្សោមដោះមានការឈឺចាប់ ។ មេគោឈប់ស៊ីចំណី និងមានគ្រុនក្តៅ ។

**ការព្យាបាល:**

ការព្យាបាលជោគជ័យទៅបានលុះត្រាតែ គេធ្វើការព្យាបាលឱ្យបានឆាប់ត្រូវ:

- ចាក់អុកស៊ីតុកស៊ីន (Ocytocin) ដើម្បីសំរួលឱ្យកន្សោមដោះកន្រ្តាក់បញ្ចេញទឹកដោះ
- ច្របាច់ទឹកដោះកខ្វក់ចេញពីកន្សោមដោះ ដោយច្របាច់ ២ ដងក្នុងមួយថ្ងៃ (ចាំបាច់ត្រូវដាក់គោក្នុង សាឡុងដើម្បីងាយស្រួលអនុវត្ត ពីព្រោះសត្វមានការឈឺចាប់) ។



រូបភាពទី ២១៨: ព្យាយាមច្របាច់ទឹកដោះកខ្វក់ចេញ

- ចាក់អង់ទីប៊ីយូទិក ដូចជាទ្រីមមេតូព្រីមជាមួយស៊ុលហ្វា (TMP + Sulfa) ហើយអាចចាក់បន្ថែមនូវតេត្រាស៊ីគ្លីន (Tetracycline) ផងដែរ ក្នុងរយៈពេល ៣ ថ្ងៃ ។ ការចាក់អង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពជាក់លាក់នៅលើក្បាលដោះ ផ្តល់នូវភាពជោគជ័យក្នុងការព្យាបាល ។



រូបភាពទី ២១៩: ចាក់អង់ទីប៊ីយ៉ូទិកចូលតាមក្បាលដោះ

- ប្រសិនបើកន្សោមដោះឡើងរឹង ត្រូវចាក់ដិចសាមេតាសូន (Dexamethason) ឬតុលហ្វេឌីន (Tolfedine) មួយដង ដើម្បីបន្ថយការរលាក ។

## ៣. បញ្ហា និងជំងឺលើជើង

កាធ្វើរោគវិនិច្ឆ័យ និងព្យាបាលបញ្ហាជើងចំពោះគោវាមានសារៈសំខាន់ណាស់សម្រាប់គោដែលជាកំលាំងអូសទាញ ព្រោះវាជះឥទ្ធិពលលើជីវភាពរបស់កសិករ ។

### ១. ពិការ

**ដំបៅជើង**

គឺជាដំបៅរលួយនៃស្បែករវាងក្រចកជើង ។ ការធ្វើការងារភ្ជួររាស់អាចជាមូលហេតុចំបងបង្កដោយមានដំបៅនេះ ។

រោគសញ្ញា:

- ពិការជើងភ្លាមៗ ជាទូទៅច្រើនកើតមានតែលើជើងម្ខាង
- ហើមជើង
- រហែកស្បែកនៅចង្កេះជើង ហើយឃើញមានខ្ទុះតិចៗផង



*រូបភាពទី ២២០: រហែកចង្កេះជើង*

ការព្យាបាល:

- ចាក់ស៊ុលហ្វា ៣៣ (Sulfa 33) តាមសរសៃវ៉ែនគឺមាន ប្រសិទ្ធភាពបំផុត
- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+ Sulfa) រយៈពេល ៣ ថ្ងៃ

បញ្ហារលាកស្បែកក្រចកជើង

ជាបញ្ហាសិកដាច់ស្បែកនៅចន្លោះក្រចកជើង និងខ្នែងជើង ហើយធ្វើឱ្យគោមាន សភាពមិនស្រួល និងថយថាមពលពេលធ្វើការភ្ជួររាស់។ បញ្ហានេះច្រើនកើតមានឡើងនៅពេលគោធ្វើការនៅក្នុងភក់។ បញ្ហារលាក ស្បែកនៅគល់ក្រចកជើងនេះងាយស្រួលក្លាយ ទៅជាដំបៅរលួយជើង។

រោគសញ្ញា:



*រូបភាពទី ២២១: រលាកស្បែកក្រចកជើង*

ការព្យាបាល:

ការត្រាំជើង: មានការឈឺចាប់ ត្រូវត្រាំ ពី១ ទៅ ២ នាទីនៅក្នុងធុង ដែលមានសារធាតុដូចខាងក្រោម:

- ហ្វ័រមាលីន ៣០ មីលីលីត្រ លាយជាមួយទឹក១លីត្រ ប្រើ ២ដងក្នុងមួយថ្ងៃ រយៈពេល ៣ថ្ងៃ។

- ទង់ដែងស៊ុលហ្វាត ៥០ ក្រាម លាយជាមួយទឹក១លីត្រ ប្រើ ២ដងក្នុងមួយថ្ងៃ រយៈពេល ៣ថ្ងៃ ។

**ជំងឺអុតក្ដាម**

ចំពោះគោរោគសញ្ញាដំបូងដែលឃើញគឺ ដំបៅនៅលើមាត់ ធ្វើឱ្យហូរទឹកមាត់មិនឈប់ និងរោគសញ្ញាបន្ទាប់ គឺ ដំបៅនៅលើជើងដែលធ្វើឱ្យពិការ ។

**រោគសញ្ញាដំបូងរួមមានៈ**

- គ្រុនក្ដៅ និងមិនស៊ីចំណី
- ហូរទឹកមាត់
- ពងដោរនៅអណ្ដាត អញ្ចាញធ្មេញ និងបន្ទាប់មកទៀតមានពងដោរនៅលើឆ្អឹងខ្នីជើង និងចង្អៃកយើង



*រូបភាពទី ២២២: ៣ថ្ងៃក្រោយមកទៀត*



*រូបភាពទី ២២៣: ១អាទិត្យក្រោយមកទៀត*

**ការព្យាបាលៈ**

ជំងឺអុតក្ដាមបង្កឡើងដោយវីរុស ដូចនេះការព្យាបាលធ្វើឡើងសម្រាប់តែបង្ការការជ្រាតចូលរបស់ជំងឺឱកាសនិយម និងបង្កើនការជាសះស្បើយតែប៉ុណ្ណោះ ។

- ចាក់ទ្រីមេតូព្រីមជាមួយស៊ុលហ្វា (TMP+Sulfa) ឬ អុកស៊ីតេត្រាស៊ីគ្លីន (OTC) រយៈពេល ៥-៧ ថ្ងៃ
- លាងដំបៅជាមួយទឹកម្ជូរ ឬសាប៊ូ
- បាញ់ថ្នាំវីយ៉ូលេឌីហ្សង់ត្យានដែលមានអុកស៊ីតេត្រាស៊ីគ្លីន (Violet de Gentiane + OTC) ។

**រលាកសន្លាក់** (Arthritis)

គឺជាបញ្ហាបង្កឱ្យមានរលាកសន្លាក់ដែលបង្កឡើងដោយៈ

- របួសនៅសន្លាក់

រូបភាពទី ២២៤: សត្វឈឺសន្លាក់



• ជំងឺឆ្លង ( ប្រ៊ូសេឡូស៊ីស ឬ មីកូប្លាស្មា) ដែលរាលដាលដល់សន្លាក់
• គោបំបៅកូន ដែលមានបញ្ហាកង្វះខាតនូវកាល់ស្យូម ផូស្វ័រ និងសារធាតុរ៉ែប្រភេទមីក្រូផ្សេងៗទៀត

រោគសញ្ញា :

• ពិការ

រូបភាពទី ២២៥: ពិនិត្យមើលសន្លាក់



• ពេលស្ទាបនៅសន្លាក់គោមានការឈឺចាប់ខ្លាំង
• មិនសូវស៊ីចំណី

ការព្យាបាល :

• ប្រើអង់ទីប៊ីយ៉ូទិកៈ អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacine) ឬ ទីឡូស៊ីន (Tylosin) ដោយប្រើរយៈពេល ពី៥ ទៅ៧ ថ្ងៃ
• ប្រើថ្នាំ បន្ថយការឈឺចាប់ និងការរលាក ដូចជា
    ✓ ហ្វេនីប៊ុយតាសូន (Phenylbutazone)
    ✓ ឌីពីរ៉ូន ១ឌុយធិរ្យនចេ ដូចជា អាណាហ្សាំង (Analgine) ឬកាល់ម៉ាហ្សាំង (Calmalgine) ឬ
    ✓ តុលហ្វេឌីន (Tolfedine) ។

## ក្រចកជើងដុះវែងខុសធម្មតា

ក្រចកជើងដុះជាប្រចាំ និងជួនកាលក្រចកដុះលឿន ហើយវែងជ្រុលធ្វើឱ្យគោនៅមិនសុខ និងបង្កឱ្យពិបាកដើរ ។

រូបភាពទី ២២៦: ក្រចកដុះលយខុសប្រក្រតី



ការព្យាបាលៈ

- កាត់ក្រចកដែលដុះវែងនេះចេញ ដោយកាត់ បន្តិចម្តងៗ ហើយរហូតស្មើសាច់

រូបភាពទី ២២៧: ក្រចកដុះលយខុសប្រក្រតី



- ឈប់កាត់នៅពេលចេញឈាម
- បន្ទាប់ពីកាត់រួចត្រូវយកដែកឆាបមកកូសគែម ក្រច្រកឱ្យស្មើ

**មុតវត្ថុផ្សេងៗនៅជើង**

វត្ថុផ្សេងៗកប់ក្នុងដីដូចជាដុំថ្ម អំបែងដប ឬកែវ ឬដែកគោលដែលបោះចោលអាចធ្វើឱ្យគោមាន របួសចេញឈាម និង អាចឈានទៅដល់ដំបៅ។



រូបភាពទី ២២៨: មុតដោយវត្ថុរឹង



រូបភាពទី ២២៩: ត្រូវពិនិត្យមើលជើងជាប្រចាំ ប្រសិនបើគោមានបញ្ហាជើង ឬពិការ

**រោគសញ្ញា ៖**

- ដំបូងគោឈឺជើងតិចតួច និងក្រោយមកទៅជាពិការធ្ងន់ធ្ងរ
- សភាពរបស់វាអាស្រ័យលើទីតាំងដែលវត្ថុនោះមុតចូល
- អាស្រ័យសភាពរបួស ធំ ឬតូច

**ការព្យាបាល ៖**

- ដកវត្ថុធាតុដែលមុតនោះចេញ
- លាងក្រចកជើងទាំងមូលជាមួយអ៊ីដ្រូសែន ពែរ៉ុកស៊ីត (Hydrogen Peroxyde) ការពារជំងឺតេតាណូស
- ចាក់អាម៉ុកស៊ីស៊ីលីនដែលមានសកម្មភាពយូរ (Amoxillin LA) ។

## ២. ខ្វិន

### ខ្វិនសរសៃប្រសាទខ្នង ឬជើងក្រោយ

វាបណ្តាលឱ្យទន់ និងទ្រេតទ្រោតជើងក្រោយរបស់គោ ។ មូលហេតុចំបងរបស់ការខ្វិនប្រភេទនេះ ដោយសារការចាក់ថ្នាំខុសទីតាំង ជាពិសេសនៅពេលប្រើថ្នាំ អង់ទីប៊ីយ៉ូទិកដែលមានសកម្មភាពយូរ ដែលបណ្តាលឱ្យមានប្រតិកម្មនៅនឹងកន្លែងចាក់ធ្ងន់ធ្ងរ ។



*រូបភាពទី ២៣០: ចាក់ថ្នាំខុសទីតាំងអាចបណ្តាលឱ្យសត្វខ្វិន*

**ការព្យាបាល៖**

ចាក់ដិចសាមេតាសូន (Dexamethason) រៀងរាល់ ២ ថ្ងៃម្តង ក្នុងអំឡុងពេល ២ សប្តាហ៍ ។

### ដេកងើបមិនរួច

គោខ្វិនសរសៃជើងមុខ (ទន់ឬស្ពឹកស្រពន់ជើងមុខ) ដោយសារគោស្គម និងខ្សោយ មិនអាចក្រោកឈរយូរថ្ងៃ ។ សាច់ដុំមិនអាចការពារប្រព័ន្ធប្រសាទបាន ហើយប្រព័ន្ធប្រសាទរងការខូចខាតនៅពេលគោ ដេកតែមួយចំហៀងខ្លួន ដោយមិនអាចប្រែខ្លួនបាននោះ ។



*រូបភាពទី ២៣១: បាក់កំលាំងមិនអាចដើបរួច*

ការព្យាបាល :

- ជួយគោដែលទន់ខ្សោយនេះឱ្យក្រោកឈរ ២ ដង ក្នុងមួយថ្ងៃ
- ចាក់ថ្នាំជួយលើកកំលាំងដូចជា ការាស៊ីល (Carasil) អេម៉ាតូប៉ង់បេ ១២ (Hematopan B12)
- យកចំបើងមកដុសជូតនៅស្មា និងភ្លៅ

បូទុយលីស (Botulism)

ជំងឺនេះបង្កឡើងដោយជាតិពុលខ្លាំងរបស់បាក់តេរីដែលមាននៅក្នុងផ្ទាំងសាច់ស្អុយរលួយ ហើយវាអាចរស់នៅក្នុងដីបានយូរឆ្នាំ។ គោអាចឆ្លងនៅពេលស៊ីស្មៅនៅតំបន់មានសំរាម។

រោគសញ្ញា:

- ជាតិពុលធ្វើឱ្យសាច់ដុំទាំងអស់ខ្វិន មិនអាចធ្វើចលនាកើត
- គោដេកស្ដាបក្រាបដី ហើយងាកក្បាលទៅម្ខាង
- កន្ទុយក៏ខ្វិនលែងកំរើក
- អណ្ដាតអាចលានចេញក្រៅ។

*រូបភាពទី ២៣២: កូនគោនេះមានសភាពខ្វិន និងខ្សោយអស់កំលាំងខ្លាំង បន្ទាប់បាន ដើរស៊ីស្មៅនៅកន្លែងសម្រាម វាអាចជាជំងឺបូទុយលីស*





រូបភាពទី ២៣១: បាក់កំលាំងមិនអាចងើបរួច

ការព្យាបាល :

- ជួយគោដែលទន់ខ្សោយនេះឱ្យក្រោកឈរ ២ ដង ក្នុងមួយថ្ងៃ
- ចាក់ថ្នាំជួយលើកកំលាំងដូចជា ការាស៊ីល (Carasil) អេម៉ាតូប៉ង់បេ ១២ (Hematopan B12)
- យកចំបើងមកដុសជូតនៅស្មា និងភ្លៅ

បូទុយលីស (Botulism)

ជំងឺនេះបង្កឡើងដោយជាតិពុលខ្លាំងរបស់បាក់តេរីដែលមាននៅក្នុងផ្ទាំងសាច់ស្អុយរលួយ ហើយវាអាចរស់នៅក្នុងដីបានយូរឆ្នាំ ។ គោអាចឆ្លងនៅពេលស៊ីស្មៅនៅតំបន់មានសំរាម ។

រោគសញ្ញា:

- ជាតិពុលធ្វើឱ្យសាច់ដុំទាំងអស់ខ្វិន មិនអាចធ្វើចលនាកើត
- គោដេកស្តាបក្រាបដី ហើយងាកក្បាលទៅម្ខាង
- កន្ទុយក៏ខ្វិនលែងកំរើក
- អណ្តាតអាចលានចេញក្រៅ ។



រូបភាពទី ២៣២: កូនគោនេះមានសភាពខ្វិន និងខ្សោយអស់កំលាំងខ្លាំង បន្ទាប់បាន ដើរស៊ីស្មៅនៅកន្លែងសម្រាម វាអាចជាជំងឺបូទុយលីស

**ជំងឺឆ្កែឆ្កួត** (Rabies)

រោគសញ្ញាលេចឡើងក្រោយពេលឆ្កែខាំ។



*រូបភាពទី ២៣៣: ឆ្កែមានជំងឺឆ្កួត*

រោគសញ្ញានឹងចេញលឿនប្រសិនឆ្កែខាំនៅជិតក្បាល ប៉ុន្តែរោគសញ្ញានឹងលេចចេញយូរប្រសិនបើការខាំនៅឆ្ងាយពីក្បាលដូចជានៅជើងក្រោយជាដើម ក្នុងករណីនេះស្នាមរបួសខាំនឹងបាត់ មុននឹងលេចចេញនូវរោគសញ្ញាឆ្កែឆ្កួត។

**រោគសញ្ញា:**

- សត្វនៅមិនស្ងៀម និងផ្អើល
- សំរាប់គោសញ្ញាសំគាល់សំខាន់នោះគឺស្រែករោទិ៍ញឹកញាប់ដោយសំលេងចម្លែក
- គោនឹងខ្ជិន ហើយងាប់

# ជំពូក ៣ ការគ្រប់គ្រង និងចាក់ថ្នាំឱ្យបានត្រឹមត្រូវ

## ១. សាឡុង

សាឡុងគឺជាមធ្យោបាយដែលមានសុវត្ថិភាពបំផុតដើម្បីរៀបចំចាក់ថ្នាំគោក្របីឱ្យបានត្រឹមត្រូវ។ សាឡុងធ្វើពីឈើ រឹងមាំ ដែលមានសសរជាប់ផ្ទាល់នឹងដីដែលមានៈ



រូបភាពទី ២៣៤: សំភារៈសម្រាប់សង់សាឡុង



រូបភាពទី ២៣៥: សាឡុងរឹងមាំសម្រាប់ពិនិត្យ និងព្យាបាលគោ

- បណ្តោយ ៣ ម៉ែត្រ
- កំពស់ ១,៥០ ម៉ែត្រ
- ទទឹង ០,៦៥ម៉ែត្រ

ជាធម្មតាគោតែងតែខ្លាចក្នុងការចូលទៅក្នុង សាឡុង ប្រសិនបើច្រកត្រូវបានបង្ខាំង វាមានសារៈសំខាន់ណាស់សម្រាប់រៀបចំប្រព័ន្ធយ៉ាងសាម័ញ្ញនិង លឿនមួយដើម្បីបិទផ្លូវខាងមុខ និងខាងក្រោយគោ នៅពេលដែល វាចូលទៅក្នុង សាឡុង។



រូបទី ២៣៦: សាឡុង



រូបភាពទី ២៣៧: សាឡុង និងភ្នាក់ងារសុខភាពសត្វភូមិ

## ២. ការប្រើខ្សែគោ

ការប្រើប្រាស់ខ្សែមានការលំបាកក្នុងការចាប់សត្វជំទង់ដែលមានសុខភាពល្អ ។



រូបទី ២៣៨: សត្វឃើគីខ្សោយនិងងាយស្រួលកាន់ជាមួយនិងខ្សែ



រូបភាពទី ២៣៩: ប្រសិនបើគោពិបាកឈរនោះ-មិនចាំ បាច់ប្រើសាឡុងទេ ពីព្រោះប្រសិនបើ-សត្វដេកដើប មិនរួច អាចបង្កើតជាបញ្ហាធំ

## ៣. ការចាប់កាន់ក្បាល

ដាក់ម្រាមដៃចាប់ច្រមុះធ្វើឱ្យក្បាលសត្វមិនកំរើក និងបញ្ឈប់ចលនាបានមួយរំពេច ខណៈពេលនេះធ្វើឱ្យយើងអាចធ្វើអន្តរាគមន៍សកម្មភាពភ្លាមៗបាន ដូចជាការចាក់ថ្នាំជាដើម ។

រូបភាពទី ២៤០: ចាប់កាន់ក្បាល



## ៤. ការការពារការជុល

បច្ចេកទេសនេះគឺមានសារៈសំខាន់ណាស់នៅពេលយើងចង់ពិនិត្យដោះ ។

រូបភាពទី ២៤១: ចាប់គោដើម្បីពិនិត្យដោះ



## ៥. ការចាក់ថ្នាំ

### ការចាក់ក្រោមស្បែក (SC)



រូបភាពទី ២៤២: កន្លែងដែលងាយចាក់



រូបភាពទី ២៤៣: កន្លែងដែលល្អសម្រាប់ចាក់ថ្នាំដែលចុកខ្លាំង

### ការចាក់សាច់ដុំ (IM)



រូបភាពទី ២៤៤: កាន់ម្ជុល



រូបភាពទី ២៤៥: ចាក់ម្ជុលចូល



រូបភាពទី ២៤៦: ចាក់ថ្នាំ

### ការចាក់តាមសរសៃ



រូបភាពទី ២៤៧: ការសង្កត់បញ្ចេញសរសៃវ៉ែន



រូបភាពទី ២៤៨: ការចាក់តាមសរសៃវ៉ែន

### ការចាក់តាមពោះ

រូបភាពទី ២៤៩: ការចាក់តាមពោះ



## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ការណែនាំអំពីការប្រើប្រាស់វ៉ាក់សាំង សំរាប់ភ្នាក់ងារសុខភាពសត្វភូមិ

ឧបត្ថម្ភដោយៈ

គម្រោងចិញ្ចឹមសត្វកម្ពុជា
សហគមន៍អឺរ៉ុប

សហគមន៍អឺរ៉ុប

អង្គការស្បៀង និងកសិកម្ម
នៃអង្គការសហប្រជាជាតិ

# មាតិកា

ទំព័រ

| | | |
|---|---|---|
| ជំពូក ១: | ការចាក់វ៉ាក់សាំង | ២ |
| ជំពូក ២: | តួនាទីនៃការចាក់វ៉ាក់សាំង | ៤ |
| ជំពូក ៣: | ការរក្សាទុកវ៉ាក់សាំង | ៧ |
| ជំពូក ៤: | ការរៀបចំវ៉ាក់សាំង | ៨ |
| ជំពូក ៥: | របៀបលាយវ៉ាក់សាំង | ៩ |
| ជំពូក ៦: | ការណែនាំអំពីវ៉ាក់សាំង | ១០ |
| ជំពូក ៧: | ផលប៉ះពាល់របស់វ៉ាក់សាំង | ១៣ |
| តារាង: | តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត | ១៤ |

# ជំពូក ១ ការចាក់វ៉ាក់សាំង

- វ៉ាក់សាំង គឺជាថ្នាំការពារជំងឺ វាផ្សំឡើងដោយវីរុស ឬបាក់តេរីដែលគេសម្លាប់ ឬធ្វើឱ្យខ្សោយសកម្មភាពបង្ករោគដើម្បីការពារជំងឺ ។
- ការចាក់វ៉ាក់សាំងគឺជាការ*ចាក់បញ្ចូលមេរោគ* (វីរុស ឬបាក់តេរី) ក្នុងទំរង់ខាងលើ ។ មេរោគទាំងនោះត្រូវបានសំលាប់ ឬបង្អាក់សកម្មភាពដោយសារសារធាតុគីមី ។
- មេរោគទាំងនេះ ***មិនអាចបង្កជំងឺបានទេ*** ប៉ុន្តែវាអាចបង្កើតអោយមានប្រព័ន្ធភាពស៊ាំ ឬ ហៅថាអង់ទីគ័រនៅក្នុងខ្លួនសត្វ ក្រោយពីគេចាក់វាចូលទៅក្នុងខ្លួនសត្វបានពី ៣ ទៅ ២១ថ្ងៃ។ ប្រព័ន្ធភាពស៊ាំ ឬអង់ទីគ័រមានតួនាទីប្រឆាំងនឹងជំងឺមកពីខាងក្រៅ ។
- អង់ទីគ័រ អាចស្ថិតនៅក្នុងខ្លួនសត្វបានរយៈពេលវែង ឬខ្លីអាស្រ័យលើប្រភេទវ៉ាក់សាំងដែលបានចាក់បញ្ចូល ហើយវាប្រឆាំងនឹងមេរោគ ដែលជ្រៀតចូលពីខាងក្រៅ ។

*បន្ទាប់ពីចាក់វ៉ាក់សាំងអង់ទីគ័រត្រូវបានកើតឡើង (រូបភាពពណ៌លឿង) ស្ថិតក្នុងឈាមត្រៀមប្រឆាំងការមកដល់របស់មេរោគ។*



*នៅពេលដែលមានវត្តមានវីរុសចូលពីខាងក្រៅ (រូបភាពពណ៌ខៀវ) ពេលនោះអង់ទីគ័រដែលមាននៅក្នុងខ្លួនសត្វធ្វើការប្រឆាំងយ៉ាងលឿន ដោយការចាប់ និងបង្អាក់សកម្មភាពបង្កជំងឺរបស់វីរុស។*



# ការចាក់វ៉ាក់សាំង

## កសិករចាំបាច់ត្រូវចាក់វ៉ាក់សាំងប្រឆាំងជំងឺសំខាន់ៗមួយចំនួនដូចជា៖

**១. ជ្រូក**

ប៉េស្ត



អុតក្តាម



**២. គោ**

អុតក្តាម



សារទឹក



**៣. មាន់**

ញ៉ីវកាស



អុត



## វ៉ាក់សាំងមួយចំនួនដែលមាននៅប្រទេសកម្ពុជា














# តួនាទីនៃការចាក់វ៉ាក់សាំង

- វ៉ាក់សាំងគឺគ្រាន់ជា *ថ្នាំសំរាប់ចាក់ការពារ*។ សូមកុំចាក់វាលើសត្វដែលគ្មានសុខភាពល្អ។
- អង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពក្នុងការសំលាប់ពពួក*វីរុស*ទេ ដូច្នេះការចាក់វ៉ាក់សាំងការពារនឹងជំងឺបង្កដោយវីរុសមានសារៈសំខាន់ណាស់។ ជំងឺបង្កដោយ វីរុសរួមមានៈ ប៉េស្តជ្រូក ញ៉ូវកាសអុតក្តាមជាដើម។
- វ៉ាក់សាំងមួយមុខអាចការពារជំងឺបានតែមួយមុខដែរ។ វ៉ាក់សាំង ប្រឆាំងជំងឺប៉េស្តមិនអាចចាក់សំរាប់ការពារជំងឺអុតក្តាមទេ។
- ពេលខ្លះជំងឺតែ១ប្រភេទ អាចបង្កដោយវីរុសដែលស្ថិតក្នុងអនុប្រភេទ ផ្សេងៗគ្នា។ ឧទាហរណ៍ៈ ជំងឺអុតក្តាមបង្កដោយវីរុសអនុប្រភេទ O, A, Asia1 ។ ក្នុងករណីនេះ ដើម្បីការពារសត្វឱ្យមានប្រសិទ្ធភាពខ្ពស់ យើងត្រូវចាក់វ៉ាក់សាំងការពារជំងឺអុតក្តាមដោយប្រើប្រាស់វ៉ាក់សាំងដែលមានអនុប្រភេទវីរុសទាំង ៣ នេះបញ្ចូលគ្នា។
- អង់ទីគ័រនៅក្នុងខ្លួនសត្វត្រូវស្ថិតនៅក្នុងកំរិតមួយអប្បបរិមាដែលអាចការពារសត្វទល់នឹងជំងឺ ដូច្នេះជាការល្អយើងត្រូវចាក់វ៉ាក់សាំងទៅតាមកម្មវិធីនៃការចាក់វ៉ាក់សាំងដែលបានណែនាំ។ ជារឿយៗ វ៉ាក់សាំងត្រូវបានគេចាក់ ២ដង ក្នុងមួយខែ ហើយយើងត្រូវចាក់រំលឹកអោយបានទៀងទាត់។

# តួនាទីនៃការចាក់វ៉ាក់សាំង

- ប្រសិនបើមេរោគជាប្រភេទបាក់តេរី ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកនឹងមានប្រសិទ្ធិភាព ហើយអាចសំលាប់មេរោគនោះបានយ៉ាងលឿន។



*ចាក់អង់ទីប៊ីយ៉ូទិកអាចព្យាបាលជំងឺដែលបង្កដោយបាក់តេរី*

- ប៉ុន្តែប្រសិនបើមេរោគជាប្រភេទវីរុស ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពទេ មានតែអង់ទីគ័រនៅក្នុងខ្លួនសត្វទេ ដែលអាចប្រឆាំងនឹងវីរុសបាន។ អង់ទីគ័រអាចបង្កើតបានដោយចំណាយពេលវេលាពី ១ ទៅ ២ អាទិត្យ ចំណែកឯវីរុសកាចសាហាវ អាចរីកលូតលាស់យ៉ាងលឿន និងបង្ករោគក្នុងខ្លួនសត្វ។



ក្រោយពីការឆ្លងមេរោគបានប៉ុន្មានថ្ងៃ អង់ទីគ័រត្រូវបានបង្កើតឡើងដើម្បីប្រឆាំងនឹងមេរោគ

- ប៉ុន្តែក្នុងករណីជំងឺស្រួចស្រាល់ សារពាង្គកាយសត្វ ពុំមានពេលវេលាគ្រប់គ្រាន់ ដើម្បីបង្កើតអង់ទីគ័រប្រឆាំងនឹងមេរោគទេ ក្នុងករណីនេះធ្វើឱ្យសត្វឈឺធ្ងន់ធ្ងរ អាចជាមកវិញបានក្នុងរយៈពេលវែង ឬជួនកាលបណ្តាលឱ្យស្លាប់តែម្តង។



*ជ្រូកមិនបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺប៉េស្ត មិនអាចជាសះស្បើយទាំងស្រុងបានទេ។ វាតែងស្ថិតនៅក្នុងស្ថានភាពខ្សោយជានិច្ច ហើយជារឿយៗស្លាប់ពី ១ ទៅ ២ អាទិត្យ បន្ទាប់ពីការឆ្លង។*

# តួនាទីនៃការចាក់វ៉ាក់សាំង

- វ៉ាក់សាំងគឺគ្រាន់ជា *ថ្នាំសំរាប់ចាក់ការពារ* ។ សូមកុំចាក់វាលើសត្វដែលគ្មានសុខភាពល្អ ។
- អង់ទីប៊ីយ៉ូទិកគ្មានប្រសិទ្ធភាពក្នុងការសំលាប់ពពួក*វីរុស*ទេ ដូច្នេះការចាក់វ៉ាក់សាំងការពារនឹងជំងឺបង្កដោយវីរុសមានសារៈសំខាន់ណាស់ ។ ជំងឺបង្កដោយ វីរុសរួមមានៈ ប៉េស្តជ្រូក ញ៉ូវកាសអុតក្តាមជាដើម ។
- វ៉ាក់សាំងមួយមុខអាចការពារជំងឺបានតែមួយមុខដែរ ។ វ៉ាក់សាំង ប្រឆាំងជំងឺប៉េស្តមិនអាចចាក់សំរាប់ការពារជំងឺអុតក្តាមទេ ។
- ពេលខ្លះជំងឺតែ១ប្រភេទ អាចបង្កដោយវីរុសដែលស្ថិតក្នុងអនុប្រភេទ ផ្សេងៗគ្នា ។ ឧទាហរណ៏: ជំងឺអុតក្តាមបង្កដោយវីរុសអនុប្រភេទ O, A, Asia1 ។ ក្នុងករណីនេះ ដើម្បីការពារសត្វឱ្យមានប្រសិទ្ធភាពខ្ពស់ យើងត្រូវចាក់វ៉ាក់សាំងការពារជំងឺអុតក្តាមដោយប្រើប្រាស់វ៉ាក់សាំងដែលមានអនុប្រភេទវីរុសទាំង ៣ នេះបញ្ចូលគ្នា ។
- អង់ទីគ័រនៅក្នុងខ្លួនសត្វត្រូវស្ថិតនៅក្នុងកំរិតមួយអប្បបរិមាដែលអាចការពារសត្វទល់នឹងជំងឺ ដូច្នេះជាការល្អយើងត្រូវចាក់វ៉ាក់សាំងទៅតាមកម្មវិធីនៃការចាក់វ៉ាក់សាំងដែលបានណែនាំ ។ ជារឿយៗ វ៉ាក់សាំងត្រូវបានគេចាក់ ២ដង ក្នុងមួយខែ ហើយយើងត្រូវចាក់រំលឹកអោយបានទៀងទាត់ ។

# ជំពូក ៣ ការរក្សាទុកវ៉ាក់សាំង

- ការរក្សាទុកវ៉ាក់សាំងបានល្អ គឺអាស្រយ័លើ *"ប្រពន្ធ័ត្រជាក់"*។ មានន័យថា ត្រូវរក្សាទុកក្នុងសីតុណ្ហភាពពី ២-៨ អង្សាសេ ចាប់តាំងពីពេលផលិតរហូតដល់ចាក់អោយសត្វ។

- វ៉ាក់សាំងត្រូវរក្សាទុកក្នុងកន្លែងត្រជាក់ ទូទឹកកក ឬធុងទឹកកកនៅកន្លែងលក់។



- ត្រូវរក្សាទុកវ៉ាក់សាំងក្នុងធុងទឹកកក ដើម្បីដឹកជញ្ជូនពីកន្លែងលក់ទៅផ្ទះភ្នាក់ងារសុខភាពសត្វភូមិ ឬ កសិដ្ឋាន



- វ៉ាក់សាំង ត្រូវរក្សាទុកនៅកន្លែងត្រជាក់នៅផ្ទះភ្នាក់ងារសុខភាពសត្វភូមិ មុននឹងប្រើប្រាស់



- បើទោះបីជានៅពេលកំពុងចាក់វ៉ាក់សាំងក្នុងភូមិក៏ ដោយ វ៉ាក់សាំងដាច់ខាតត្រូវរក្សានៅក្នុងធុងទឹកកក។



# ជំពូក ៤ ការរៀបចំវ៉ាក់សាំង

- **វ៉ាក់សាំងដែលបង្អាក់សកម្មភាព ឬងាប់:** ជាទូទៅវាមានទំរង់ខាប់ (ប្រេង) និងរាវ (សារធាតុអាលុយមីន)។ វ៉ាក់សាំងនេះអាចប្រើដោយយើងគ្រាន់តែអនុវត្តតាមការណែនាំពីបរិមាណ និង ការចាក់ជាការស្រេច។ វ៉ាក់សាំងទាំងនេះត្រូវប្រើក្នុងរយៈពេលកំណត់ណាមួយ ប៉ុន្តែគេអាចរក្សាបរិមាណដែលនៅសល់ទុកក្នុងកន្លែងត្រជាក់ (ទូទឹកកក ឬ ធុងទឹកកក)ដើម្បីប្រើនៅពេលក្រោយទៀត។




- **វ៉ាក់សាំងរស់: វាមានលក្ខណៈជាម្សៅ** យើងដាច់ខាត ត្រូវលាយជាមួយទឹកសំរាប់លាយដែលមានភ្ជាប់ជាមួយវ៉ាក់សាំង។ នៅពេលលាយបញ្ចូលគ្នាម្សៅវ៉ាក់សាំង និង ទឹកសម្រាប់លាយត្រូវមានសីតុណ្ហភាពដូចគ្នា។ វ៉ាក់សាំងដែលលាយហើយ*ត្រូវប្រើភ្លាមៗ* មិនអោយលើសពីរយៈពេល១ម៉ោងឡើយ។ វ៉ាក់សាំងដែលសល់ពីការប្រើប្រាស់ មិនអាចរក្សាទុកសម្រាប់ប្រើប្រាស់នៅថ្ងៃបន្ទាប់ឡើយ ពីព្រោះវាគ្មានប្រសិទ្ធភាព និងជួនកាលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ទៀតផងដូច្នេះយើងត្រូវកំទេចចោល។



# ជំពូក ៥ របៀបលាយវ៉ាក់សាំង

១. បូមទឹកសម្រាប់លាយវ៉ាក់សាំងបន្តិចដោយម្ជុល និងស៊ីរ៉ាំងដែលស្អាតល្អ

២. បាញ់បញ្ចូលទឹកលាយទៅក្នុងដបម្សៅវ៉ាក់សាំង

៣. ក្រឡុកល្បាយនោះថ្នមៗ ប្រហែលជា១០ វិនាទី រួចបូមល្បាយនោះចេញ

៤. បាញ់បញ្ចូលល្បាយនោះទៅក្នុងដបទឹកសំរាប់លាយ។

ត្រូវអនុវត្តតាមរូបភាពដែលបានបង្ហាញនេះស្រាប់



រូបភាពទី១



រូបភាពទី២



រូបភាពទី៣



រូបភាពទី៤

# ជំពូក ៦ ការណែនាំអំពីវ៉ាក់សាំង

**១ ‑ រាល់ការណែនាំពីរបៀបប្រើ** ត្រូវបានសរសេរនៅលើក្រដាសណែនាំ ឬស្លាករបស់វ៉ាក់សាំង ប៉ុន្តែ:

- ពេលខ្លះជាភាសា អង់គ្លេស ថៃ វៀតណាម
- ពេលខ្លះអ្នកផលិតប្រើអក្សរតូចៗពេក
- ពេលខ្លះមានការណែនាំច្រើនពេកលើស្លាករបស់វ៉ាក់សាំង

ដូច្នេះយើងមានការលំបាកបន្តិចក្នុងការអានក្រដាសណែនាំ ឬ ស្លាករបស់វ៉ាក់សាំង។

**ក្រដាសណែនាំ និងស្លាកសញ្ញាទាំងនេះផ្តល់នូវព័ត៌មានដូចខាងក្រោម:**


intervet
DECIVAC FMD DOE
MONOVALENT
Intervet [Intervet Phils, Inc] Rx
COMPOSITION: Per dose At least 6 $PD_{50}$ of the antigen type O1 Manisa.
PRESENTATION: Inj 100 mL (50 doses), 250 mL (125 doses).
DESCRIPTION: FMD virus propagated on BHK cells, inactivated by binary ethylene imine and subsequently purified and concentrated by precipitation with polyethylene glycol in a double oil emulsion.
INDICATIONS: Active immunization of cattle, buffalo, pigs, sheep and goats against foot-and-mouth disease.
DOSAGE & ADMINISTRATION: Cattle, Buffalo: 2 mL SC or IM. Sheep, Goats: 1 mL SC or IM. Pigs: 2 mL IM. Piglets: 1 mL IM.
Vaccination Program: Young animals without maternal antibodies: Primary vaccination from 2 weeks of age onwards, followed by re-vaccination 4-6 weeks later. Young animals with, or suspected of having maternal antibodies: Primary vaccination from 2 months of age onwards, followed by re-vaccination 4-6 weeks later. Adult animals: Every 4-6 months.
WITHDRAWAL PERIODS: None.
PRECAUTIONS: A transient local swelling may occur. Shake before use.
STORAGE: Store between +2°C and +8°C. Protect from light. Do not freeze.

*ក្រដាសណែនាំ ជាភាសាអង់គ្លេស*



*ស្លាកបិទជាប់នឹងដបជាភាសាថៃ*

**សមាសធាតុផ្សំ:** ប្រភេទវីរុសនៅក្នុងដប

**ការរៀបចំរបស់វ៉ាក់សាំង:** ចំនួន មីលីលីត្រ នៅក្នុងដប និងកំរិត (សំរាប់ចាក់សត្វប៉ុន្មានក្បាលក្នុង១ដប)

**ការប្រើប្រាស់:** បង្ហាញពីឈ្មោះជំងឺដែលអាចការពារបានដោយវ៉ាក់សាំងនេះ (ឧ អុតក្តាម)

## ២ ‑ កំរិត និង ការចាក់

- បរិមាណជា មីលីលីត្រ សំរាប់ចាក់អោយសត្វ
- ផ្លូវចាក់បញ្ចូល: ចាក់សាច់ដុំ ក្រោមស្បែក បន្ទក់ភ្នែកជាដើម
- អនុសាសន៍សំរាប់រៀបចំកម្មវិធីវ៉ាក់សាំង

**ផលប៉ះពាល់:** ឧទាហរណ៍ពុំមានផលប៉ះពាល់ជាអវិជ្ជមានទេបន្ទាប់ពីការចាក់វ៉ាក់សាំង

**ការរក្សាទុក:** ជាធម្មតាត្រូវទុកក្នុងសីតុណ្ហភាព ២-៨ អង្សាសេ

**សុពលភាពនៃការប្រើប្រាស់:** មិនត្រូវប្រើវ៉ាក់សាំងដែលហួសកាលកំណត់ដែល មានសរសេរនៅលើស្លាកនោះទេ។

## ៣ ~ សំរាប់មាន់

- បន្តក់ភ្នែក: វាមានលក្ខណៈងាយស្រួលក្នុងការចាប់កូនមាន់ និងមេមាន់។ ជាការប្រសើរត្រូវប្រើទឹកលាយដែលមានពណ៌ ដើម្បីប្រាកដថាតំណក់វ៉ាក់សាំងបានចូលក្នុងភ្នែកមាន់។
- ចាក់ក្រោមស្បែក: ចាក់ក្រោមស្បែកផ្នែកកខាងក្រោម។
- ចាក់ទំលុះផ្នែកស្តើងនៃស្លាប សំរាប់ជួសអុតមាន់។





## ៤ ~ សំរាប់ជ្រូក



- ចាក់សាច់ដុំ
- សំរាប់កូនជ្រូក: ចាក់នៅត្រង់ក ផ្នែកខាងមុខស្មា។
- សំរាប់ជ្រូកសាច់ ឬមេជ្រូក: ចាក់នៅត្រង់កផ្នែកលើ
- ខាងក្រោយស្លឹកត្រចៀក ព្រោះវាមានកំរាស់ខ្លាញ់ស្តើង។
- ប្រើអន្ទាក់ចាប់ជ្រូកដើម្បីងាយស្រួលក្នុងការចាក់បញ្ចូលវ៉ាក់សាំង។
- ប្រើម្ជុល និងស៊ីរ៉ាំងដែលស្អាតសំរាប់ចាក់។



## ៥ ‿ សំរាប់គោ

- ចាក់ក្រោមស្បែក ឬចាក់សាច់ដុំ
- នៅផ្នែកកខាងមុខស្មា ឬ បួរ
- ជាការល្អត្រូវដាក់គោក្នុងសាឡុង ដើម្បីងាយស្រួលក្នុងការចាក់វ៉ាក់សាំង ។
- ប្រើម្ជុល និង ស៊ីរាំងដែលស្អាតសំរាប់ចាក់ ។







# ជំពូក ៧ ផលប៉ះពាល់របស់វ៉ាក់សាំង



- ជាទូទៅបន្ទាប់ពីចាក់វ៉ាក់សាំង *សត្វអន់ចំណីមួយថ្ងៃ ហើយសត្វអាចឡើងកំដៅ*។
- *ហើម* (ឈឺចាប់) ដុំពករឹងអាចកើតមានរយៈពេល ៤-៥ថ្ងៃ (សំរាប់អុតក្តាម) មុននឹងបាត់ទៅវិញ។
- ការថប់ដង្ហើម (Shock): (ក្នុងករណីចាក់វ៉ាក់សាំង ការពារជំងឺអូជេស្គី) ធ្វើអោយស្បែកមេជ្រូកឡើងក្រហម និងពិបាកដកដង្ហើម។ គ្មានស្រ្តេសមុន និងក្រោយការធ្វើវ៉ាក់សាំងជាការល្អ។ ចាក់វ៉ាក់សាំងនៅពេលត្រជាក់ (ព្រលឹម ឬ ល្ងាច)។ ក្នុងករណីមានការថប់ដង្ហើមក្រោយចាក់វ៉ាក់សាំងត្រូវចាក់ដិចសាមេតាសូន។



- *ការឈឺ ឬ ស្លាប់* (ក្នុងករណីចាក់វ៉ាក់សាំងប្រឆាំងនឹង ជំងឺប៉េស្តជ្រូក): *ជំងឺប៉េស្តជ្រូក ជាជំងឺច្រើនកើតមាននៅក្នុងតំបន់ ដូច្នេះពេលខ្លះ យើងអាចចាក់វ៉ាក់សាំងប៉េស្តជ្រូក ទៅលើជ្រូកដែលកំពុងផ្ទុកជំងឺប៉េស្តប៉ុន្តែវាមិនបង្ហាញរោគសញ្ញាឱ្យឃើញ។ ក្នុងករណីនេះ ជ្រូកអាចក្តៅខ្លួន បាត់ការឃ្លាន និងជួនកាលបណ្តាលឱ្យស្លាប់។*



- បូស (អាប់សែ): ជាទូទៅកើតឡើងដោយសារការចាក់ខុសកន្លែង ឬដោយម្ជុល ឬស៊ីរាំងមិនស្អាត។
- បង្កជាជំងឺ (ក្នុងករណីចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺអុតមាន់): វ៉ាក់សាំង ជំងឺអុតមាន់ ជាប្រភេទវ៉ាក់សាំងរស់ដែលអាចបង្កើតជាដុំពកនៅកន្លែងចាក់។



# តារាងកម្មវិធីវ៉ាក់សាំងដែលត្រូវអនុវត្ត

| ឈ្មោះជំងឺ | ប្រភេទសត្វ | ចាក់លើកទី ១ | ចាក់លើកទី ២ | ចាក់លើកក្រោយដើម្បីបន្តភាពស៊ាំ ឬអង់ទីគ័រ |
|---|---|---|---|---|
| ប៉េស្តជ្រូក | កូនជ្រូក | អាយុ ៣អាទិត្យ | អាយុ ៧អាទិត្យ | អាយុ ១១អាទិត្យ |
| | មេក្រមុំ មេជ្រូក | អាយុ ៦ខែ | រាល់១ខែមុនកើតកូន | |
| ប៉ារ៉ូ | មេក្រមុំ | អាយុ ៦.៥-៧.៥ខែ | ២អាទិត្យមុនដាក់បា | |
| | មេជ្រូក | រាល់១០ថ្ងៃមុនផ្ដាច់ដោះ | | |
| អូជេស្គី | មេក្រមុំ | អាយុ ៦-៧ខែ | | |
| | មេជ្រូក | រាល់១.៥ខែ មុនកើតកូន | | |
| អុតក្ដាមជ្រូក | ជ្រូកទុកសំរាប់ធ្វើពូជ | អាយុ ២-៣ខែ | នៅ១ខែក្រោយមក | រំលឹករាល់២-៣ខែម្ដង |
| អុតក្ដាមគោ | គោ | អាយុ ៤ខែ | នៅ១ខែក្រោយមក | រំលឹករាល់ ៦ខែម្ដង |
| បូសខ្យល់ | គោ | អាយុ ២ខែបន្ទាប់កើត | នៅ១ខែក្រោយមក | បន្ទាប់មក១ឆ្នាំនិង៥ឆ្នាំក្រោយ |
| សារទឹក | គោ | អាយុ ៦ខែ (ចាក់មុនរដូវភ្លៀង) | នៅ ៦ខែក្រោយមក | |
| ញូវកាស I2 | មាន់ | អាយុ ៣អាទិត្យ | ២អាទិត្យក្រោយមក | |
| អាសន្នរោគ | មាន់ | អាយុ ៦អាទិត្យ | ៤អាទិត្យក្រោយមក | បន្ទាប់មក ២អាទិត្យមុនពង |
| អុត | មាន់ | កូនមាន់អាយុ ១០ថ្ងៃ-១០អាទិត្យ | នៅអាយុ ១២-១៦អាទិត្យ | |

ត្រូវកត់ត្រាថ្ងៃខែចាក់វ៉ាក់សាំងឱ្យច្បាស់លាស់ ដើម្បីប្រាកដថាសត្វទាំងអស់បានធ្វើវ៉ាក់សាំងទៀងទាត់។ ប្រសិនបើចាក់វ៉ាក់សាំងមិនទៀងទាត់ តាមកម្មវិធីច្បាស់លាស់ទេ នោះសត្វរបស់អ្នកនឹងមិនអាចការពារទប់ទល់នឹងជំងឺបានល្អទេ។